**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de droit et des sciences Economoiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខណ្ឌចំការមន និង ការងារសម្រេចបានពីឆ្នាំ ២០១៨ ~ ២០១៩

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ថាន ម៉ារតី**
កញ្ញា **យិន ស្រីពេញ**

សាស្ត្រាចារ្យណែនាំ
លោក **យូ តូនី**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ**
ជំនាន់ទី១៣

ឆ្នាំចូលសិក្សា ២០១៦
ឆ្នាំសរសេរសារណា ២០២០

# សេចក្តីថ្លែងអំណរគុណ

៚❃៛

នាងខ្ញុំទាំងពីរឈ្មោះ **ថាន ម៉ារ៉ាតី** និង **យិន ស្រីពេញ** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ជំនាញរដ្ឋបាលសាធារណៈឆ្នាំទី ៤ ជំនាន់ទី ១៣ ក្រុម P4A2 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ**

**លោកឪពុក អ្នកម្តាយ** ដែលជាអ្នកមានគុណមិនអាចកាត់ថ្លៃបាន លោកបានផ្តល់កំណើត ចិញ្ចឹមបីបាច់ថែរក្សា កូនប្រកបទៅដោយព្រហ្មវិហារធម៌ និងទំនុកបម្រុងកូនគ្រប់យ៉ាង រហូតដល់កូនអាចមានឱកាសបន្តការសិក្សាដល់ចប់ថ្នាក់បរិញ្ញាបត្រ និងក្លាយជាធនធានមនុស្សដែលសង្គមត្រូវការ។

ឯកឧត្តម **លុយ ចណ្ណា** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានអនុញ្ញាតឱ្យយើងខ្ញុំបានចូលសិក្សាថ្នាក់បរិញ្ញាបត្រ រដ្ឋបាលសាធារណៈនៅសាកលវិទ្យាល័យនេះ ដែលជួយឱ្យការសិក្សារបស់យើងខ្ញុំប្រកបទៅដោយគុណភាព និងទទួលបានចំណេះដឹងយ៉ាងល្អប្រសើរ។

លោកគ្រូ **យូ តូនី** ជាសាស្ត្រាចារ្យណែនាំ ដែលបានឆ្លៀតពេលវេលាដ៏មានតម្លៃ និងមមាញឹករបស់លោកគ្រូពីការបង្រៀន ដើម្បីដឹកនាំយើងខ្ញុំសរសេរសារណាបញ្ចប់ការសិក្សា លោកបានលះបង់ទាំងកំលាំងកាយ និងកំលាំងចិត្ត ខិតខំប្រឹងប្រែងណែនាំ កែសម្រួល និងផ្តល់ជាមតិយោបល់ល្អៗ ដែលធ្វើឱ្យសារណានេះបានល្អប្រសើរ។

**លោក លោកស្រីសាស្ត្រាចារ្យ និងបុគ្គលិក** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចទាំងអស់ដែលបានខិតខំប្រឹងប្រែងបណ្តុះបណ្តាលយើងខ្ញុំទាំងពីរឱ្យទទួលបានចំណេះដឹងប្រកបដោយប្រសិទ្ធភាព។

**លោក ថេង សុផុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន ដែលបានអនុញ្ញាតឱ្យយើងខ្ញុំទាំងពីរបានធ្វើការចុះស្រាវជ្រាវឯកសារនៅសាលាខណ្ឌចំការមន។ លោក **គង់ ថារិទ្ធ** ប្រធានការិយាល័យរដ្ឋបាលខណ្ឌចំការមន ព្រមទាំងមន្ត្រីរាជការទាំងអស់នៅសាលាខណ្ឌចំការមនដែលបានជួយជ្រោមជ្រែង និងបង្កលក្ខណៈងាយស្រួលដល់ការស្រាវជ្រាវ ក៏ដូចជាផ្តល់នូវឯកសារសំខាន់ៗជាច្រើន ដែលនាំឱ្យសារណាបញ្ចប់ការសិក្សាយើងខ្ញុំបញ្ចប់ទៅប្រកបដោយភាពជោគជ័យ។

ជាចុងក្រោយនៃកថានេះយើងខ្ញុំទាំងពីរអ្នកសូមគោរពប្រសិទ្ធពរជ័យ សិរីសួរស្តី ជ័យមង្គល កើតមានដល់លោកអ្នកមានគុណទាំងអស់ សូមឱ្យលោកជួបប្រទះនូវពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ និង ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ៜ✵ៜ

សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជាគ្រឹះស្ថានសាធារណៈមួយដែលជួយបណ្តុះបណ្តាលធនធានមនុស្សឱ្យក្លាយជាកម្លាំងចលករយ៉ាងសំខាន់នៅក្នុងការអភិវឌ្ឍន៍សង្គមជាតិ ប្រកបទៅដោយ វិន័យ គុណភាព ប្រសិទ្ធភាព សីលធម៌ រាជរដ្ឋាភិបាល ក៏ដូចជាប្រទេសជាតិទាំងមូល។ ក្រោយពីបានសិក្សារយៈពេល ៤ ឆ្នាំ យើងខ្ញុំបានទទួលនូវចំណេះដឹងជាច្រើន និងបានសរសេរសារណាបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈប្រកបដោយភាពជោគជ័យ។

វត្ថុបំណងដែលយើងខ្ញុំជ្រើសរើសយកនូវ ប្រធានបទស្តីអំពី“ **ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខណ្ឌចំការមន និងការងារសម្រេចបានពីឆ្នាំ ២០១៨ ~ ២០១៩** ” មកសរសេរជាសារណាបញ្ចប់ការសិក្សា គឺដោយសារតែមើលឃើញពីកាលានុវត្តភាពរបស់សាលាខណ្ឌចំការមន និងចង់បង្ហាញពី ស្ថានភាពទូទៅរបស់ខណ្ឌ ដំណើរការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ រចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខណ្ឌ និងការងារដែលសម្រេចបានប្រចាំឆ្នាំ ២០១៩ របស់សាលាខណ្ឌចំការមន។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណានេះអាចនឹងរួមចំណែកក្នុងការជួយជម្រុញការអនុវត្តការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការគ្រប់គ្រងបុគ្គលិករដ្ឋបាលខណ្ឌឱ្យមានប្រសិទ្ធភាពស្របទៅតាមគោការណ៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងអាចចូលរួមបង្កើនចំណេះដឹងបន្ថែមនៅក្នុងការសិក្សាស្រាវជ្រាវរបស់សិស្ស និស្សិត។

យ៉ាងណាមិញយើងខ្ញុំក៏សូមអភ័យទោសនូវរាល់កំហុសឆ្គងទាំងឡាយ និងភាពខ្វះចន្លោះនានាព្រមទាំងការបកស្រាយនៅក្នុងសារណានេះ ដែលកើតមានឡើងដោយអចេតនា។

យើងខ្ញុំរីករាយ និងទទួលយករាល់ការរិះគន់ កែលម្អ ពីសំណាក់មិត្តអ្នកអាន និងអ្នកសិក្សាស្រាវជ្រាវទាំងឡាយ ដើម្បីស្ថាបនាបន្ថែមឱ្យស្នាដៃសារណាបញ្ចប់ការសិក្សានេះកាន់តែមានភាពល្អប្រសើរ។

យើងខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជ័យមង្គលសូមឱ្យកើតមានដល់អស់លោក -លោកស្រីសាស្ត្រាចារ្យ សិស្សនិស្សិតនិងមិត្តអ្នកអានគ្រប់ៗគ្នា។

# មាតិកា


ទំព័រ

**សេចក្តីផ្តើម** ........................................ ១

**ជំពូកទី១**

**ស្ថានភាពទូទៅ និង រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាខណ្ឌចំការមន**

**ផ្នែកទី១៖ ស្ថានភាពទូទៅ** ........................................ ២

ក. ប្រវត្តិរបស់សាលាខណ្ឌចំការមន ........................................ ២

ខ. ស្ថានភាពប្រជាជន ........................................ ៤

គ. ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច ........................................ ៤

**ផ្នែកទី២៖ រចនាសម្ព័ន្ធគ្រប់គ្រង** ........................................ ៤

ក. ក្រុមប្រឹក្សាខណ្ឌ និង គណៈកម្មាធិការនានា ........................................ ៥

ខ. គណៈអភិបាលខណ្ឌ និងនាយករដ្ឋបាល ........................................ ៥

គ. ការិយាល័យចំណុះរដ្ឋបាលខណ្ឌ និងអង្គភាពលទ្ធកម្ម ........................................ ៦

**ជំពូកទី២**

**ការគ្រប់គ្រងបុគ្គលិក**

**ផ្នែកទី១៖ ការជ្រើសរើសបុគ្គលិក** ........................................ ៧

ក. លក្ខខណ្ឌនៃការជ្រើសរើស ........................................ ៧

ខ. ការធ្វើកម្មសិក្សា ការតាំងស៊ប់ ........................................ ៨

គ. ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់តំណែង ........................................ ១០

**ផ្នែកទី២៖ ការគ្រប់គ្រងរដ្ឋបាល** ........................................ ១៥

ក. ការគ្រប់គ្រងបុគ្គលិក ........................................ ១៥

ខ. ការងារលិខិតរដ្ឋបាល ........................................ ១៧

គ. ការងារអន្តរវិស័យ ............................................................................ ១៨

ឃ. ការងារហិរញ្ញវត្ថុ ............................................................................ ១៩

## ជំពូកទី៣

## សមិទ្ធផលការងារសម្រេចបានពីឆ្នាំ ២០១៨-២០១៩

**ផ្នែកទី១៖ សេវាសាធារណៈដែលផ្តល់ដោយសាលាខណ្ឌ** ............................................................ ២២

ក.ការងារអត្រានុកូលដ្ឋាន ............................................................................ ២២

ខ. ការិយាល័យច្រកចេញចូលតែមួយ ............................................................................ ២២

**ផ្នែកទី២៖ វិស័យសេដ្ឋកិច្ច** ............................................................................ ២៣

ក.ការងារគមនាគមន៍ ភូមិបាល និងសំណង់ ............................................................................ ២១

ខ.ការងារសិប្បកម្ម ឧស្សាហកម្ម និងការងារពាណិជ្ជកម្ម ............................................................................ ២៥

គ. ការងារទេសចរណ៍ ............................................................................ ២៦

**ផ្នែកទី៣៖ វិស័យសង្គមកិច្ច** ............................................................................ ២៧

ក.ការងារសុខាភិបាល និងការងារវប្បធម៌ និងវិចិត្រសិល្បៈ ............................................................................ ២៨

ខ. ការងារកិច្ចការនារី និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ ............................................................................ ២៩

គ. ការងារពត៌មាន និងការងារធម្មការ និងសាសនា ............................................................................ ៣១

**ផ្នែកទី៤៖ ការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ** ............................................................................ ៣៤

ក. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ............................................................................ ៣៤

ខ. គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ ............................................................................ ៤០

**សេចក្តីសន្និដ្ឋាន** ............................................................................ ៤១

**អនុសាសន៍** ............................................................................ ៤២

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

បន្ទាប់ពីឆ្លងកាត់ស្បែអន្តការយ៉ាងខ្មៅងងឹតជាច្រើនឆ្នាំកន្លងមកប្រទេសកម្ពុជា ក៏បានប្រែមុខមាត់ថ្មីដោយមានការរីកចម្រើន និងអភិវឌ្ឍជាលំដាប់គួរឱ្យកត់សម្គាល់នៅរយៈប៉ុន្មានឆ្នាំចុងក្រោយនេះ។ ចាប់ផ្តើមពីចំនុចសូន្យ រហូតដល់មានការអភិវឌ្ឍដូចសព្វថ្ងៃក៏ព្រោះតែការខិតខំប្រឹងប្រែងពីសំណាក់រាជរដ្ឋាភិបាល និងការរួមចំណែកយ៉ាងសកម្មពីប្រជាជនទូទាំងប្រទេស ដូច្នេះហើយរាជរដ្ឋាភិបាលកម្ពុជាតែងតែផ្តោតការលើកទឹកចិត្តយ៉ាងខ្លាំងដល់ប្រជាពលរដ្ឋឱ្យ ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យស្របពេលដែលនយោបាយមាន ស្ថេរភាព និងរចនាសម្ព័ន្ធតាមបែបប្រជាធិបតេយ្យត្រូវបានពង្រីកទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីធានាដល់ការអភិវឌ្ឍប្រទេសជាតិប្រកបដោយដោយចីរភាព ក្នុងនោះផងដែររដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

យ៉ាងណាមិញយើងសង្កេតឃើញថាខណ្ឌគឺជា កម្លាំងរដ្ឋបាលសាធារណៈមួយយ៉ាងសំខាន់នៅក្នុងការគាំទ្រឱ្យការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យទទួលបានជោគជ័យ។ បច្ចុប្បន្ន នៅទូទាំងប្រទេសរួមមាន រាជធានីចំនួន១ ខេត្តចំនួន២៤ ក្រុងចំនួន២៧ ស្រុកចំនួន១៦២ ខណ្ឌចំនួន១៤ ឃុំ សង្កាត់ចំនួន១.៦៤៦ និងភូមិចំនួន១៤.៣៨៣ ដែលថ្នាក់ដឹកនាំភូមិត្រូវបានបោះឆ្នោតជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សាឃុំ សង្កាត់។ នៅក្នុងចំណោមខណ្ឌទាំង១៤នៅក្នុងរាជធានីភ្នំពេញ ខណ្ឌចំការមន ជាខណ្ឌដែលមានសក្តានុពលមួយដែលមានការរីកចម្រើនទាំងលើគ្រប់ផ្នែក និងគ្រប់វិស័យ។ ដោយសារតែមើលឃើញពីកាលានុវត្តភាពរបស់ខណ្ឌបែបនេះហើយ ទើបក្រុមយើងខ្ញុំបានលើកយកប្រធានបទដែលស្តីអំពីការនៃការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខណ្ឌក៏ដូចជាការងារដែលសាលាខណ្ឌសម្រេចបាននៅឆ្នាំ ២០១៨~២០១៩ ក្នុងគោលបំណងដើម្បីស្វែងយល់បន្ថែមទាក់ទងនិងរចនាសម្ព័ន្ធគ្រប់គ្រងរបស់រដ្ឋបាលខណ្ឌ។ ដើម្បីជាស្ពានឈានដល់ ការបកស្រាយលើប្រធានបទឱ្យកាន់តែស៊ីជម្រៅ យើងគប្បីសិក្សានូវចំណោទបញ្ហាមួយចំនួនដូចខាងក្រោមសិន ៖

- តើសាលាខណ្ឌចំការមនមានរចនាសម្ព័ន្ធគ្រប់គ្រងដូចម្តេចខ្លះ ?
- តើនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខណ្ឌចំការមនមានអ្វីខ្លះ ?
- នៅក្នុងអំឡុងឆ្នាំ ២០១៨ ~ ២០១៩នេះ តើការងារអ្វីខ្លះដែលសាលាខណ្ឌសម្រេចបាន ?

ដើម្បីឆ្លើយតបទៅនឹងសំណួរខាងលើ ប្រធានបទ “ **ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខណ្ឌចំការមន និងការងារសម្រេចបានពីឆ្នាំ ២០១៨~២០១៩** ”នេះនឹងត្រូវធ្វើការបកស្រាយដោយ បែកចែកជា៣ជំពូកធំៗគឺ៖

- ជំពូកទី១៖ ស្ថានភាពទូទៅ និងរចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាខណ្ឌចំការមន
- ជំពូកទី២៖ ការគ្រប់គ្រងបុគ្គលិក
- ជំពូកទី៣៖ សមិទ្ធផលសម្រេចបានពីឆ្នាំ ២០១៨ ~ ២០១៩

# ជំពូកទី១

# ស្ថានភាពទូទៅ និង រចនាសម្ព័ន្ធគ្រប់គ្រងរបស់សាលាខណ្ឌចំការមន

## ផ្នែកទី១៖ ស្ថានភាពទូទៅ

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់, ខាងលិចទល់នឹងខណ្ឌបឹងកេងកង, ខាងត្បូងទល់នឹងខណ្ឌមានជ័យ, ខាងជើងទល់នឹងខណ្ឌដូនពេញ (ផ្ទៃដីសរុបមានទំហំ ៧,១៥១,៤២៤.៥៧ម៉ែត្រការ៉េ ស្មើនឹង ៧១៥ហិកតា ១៤អា និង២៤សង់ទីអា )។

ខណ្ឌចំការមនត្រូវបានបំបែកជា២ យោងតាមអនុក្រឹត្យ លេខ :០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៩ ដោយបង្កើតខណ្ឌបឹងកេងកងថ្មី សាលាខណ្ឌចំការមន ជាសាលា**ខណ្ឌបឹងកេងកង**ថ្មី និង ទីតាំងសាលាខណ្ឌចំការមនថ្មី ត្រូវស្ថិតនៅសង្កាត់ទន្លេបាសាក់។ ការបំបែកខណ្ឌនេះបានបន្សល់ទុកអោយខណ្ឌចំការមន មានតែ ៥ សង្កាត់ ដូចតទៅ ទន្លេបាសាក់ ទួលទំពូងទី១ ទួលទំពូងទី២ បឹងត្របែក និង ផ្សារដើមថ្កូវ។

### ក. ប្រវត្តិរបស់សាលាខណ្ឌចំការមន

ខណ្ឌនេះត្រូវបានបែងចែកទៅជា ១២សង្កាត់ និង ៩៥ភូមិ។ ខណ្ឌនេះមានផ្ទៃក្រឡា ១០,៧៨ គម។ តាមរយៈជំរឿនឆ្នាំ១៩៩៨របស់កម្ពុជា ខណ្ឌនេះមានប្រជាជន១៨៧ ០០៤នាក់។ ឈ្មោះខណ្ឌត្រូវបានគេសរសេរជាឡាតាំងថា Chamkamorn តាមរយៈប្រព័ន្ធឡាតាំងយានកម្មដែលបានប្រើនៅកម្ពុជាកំឡុងទសវត្សឆ្នាំ១៩៥០ និង ១៩៦០។ [1] អាសយដ្ឋានទំនាក់ទំនង សាលាខណ្ឌចំការមនចាស់នៅ ផ្ទះលេខ ១៦៩-១៧១-១៧៣-១៧៥ មហាវិថីម៉ៅសេទុង សង្កាត់បឹងកេងកងទី៣ ខណ្ឌចំការមន រាជធានីភ្នំពេញ ក្បែរស្តុបទួលទំពូង។

| ល.រ | សង្កាត់ | ឡាតាំង | ភូមិក្រម |
|---|---|---|---|
| ១ | ទន្លេបាសាក់ | Tonle Basak | ១២០១០១ |
| ២ | បឹងកេងកងទី១ | Boeng Keng Kang Ti Muoy | ១២០១០២ |
| ៣ | បឹងកេងកងទី២ | Boeng Keng Kang Ti Pir | ១២០១០៣ |

[1]- Lua error in Module:Citation/CS1/Date_validation at line 145: attempt to compare nil with number. សូមមើលទំព័រ ១៧៣។

| | | | |
|---|---|---|---|
| ៤ | បឹងកេងកងទី៣ | Boeng Keng Kang Ti Bei | ១២០១០៤ |
| ៥ | អូឡាំពិក | Olympic | ១២០១០៥ |
| ៦ | ទូលស្វាយព្រៃទី១ | Tuol Svay Prey Ti Muoy | ១២០១០៦ |
| ៧ | ទូលស្វាយព្រៃទី២ | Tuol Svay Prey Ti Pir | ១២០១០៧ |
| ៨ | ទំនប់ទឹក | Tumnob Tuek | ១២០១០៨ |
| ៩ | ទួលទំពូងទី១ | Tuol Tompoung Ti Muoy | ១២០១០៩ |
| ១០ | ទួលទំពូងទី២ | Tuol Tompoung Ti Pir | ១២០១១០ |
| ១១ | បឹងត្របែក | Boeng Trobaek | ១២០១១១ |
| ១២ | ផ្សារដើមថ្កូវ | Phsar Daem Thkov | ១២០១១២ |

[2]យោងតាមអនុក្រឹត្យ លេខៈ ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩។ ដោយបង្កើតខណ្ឌបឹងកេងកងថ្មី សាលាខណ្ឌចំការមន ជាសាលាខណ្ឌបឹងកេងកងថ្មី និង សាលាសង្កាត់ទន្លេបាសាក់ ក្លាយជាសាលាខណ្ឌចំការមនថ្មី។ ដែលបន្សល់ទុកអោយខណ្ឌចំការមន មានតែ ៥ សង្កាត់ ដូចតទៅ ទន្លេបាសាក់ ទួលទំពូងទី១ ទួលទំពូងទី២ បឹងត្របែក និង ផ្សារដើមថ្កូវ។

| ល.រ. | សង្កាត់ | ឡាតាំង | ភូមិក្រម |
|---|---|---|---|
| ១ | ទន្លេបាសាក់ | Tonle Basak | ១២០១០១ |
| ២ | ទួលទំពូងទី១ | Tuol Tompoung Ti Muoy | ១២០១០២ |
| ៣ | ទួលទំពូងទី២ | Tuol Tompoung Ti Pir | ១២០១០៣ |
| ៤ | បឹងត្របែក | Boeng Trobaek | ១២០១០៤ |
| ៥ | ផ្សារដើមថ្កូវ | Phsar Daem Thkov | ១២០១០៥ |

[2]- អនុក្រឹត្យ លេខៈ ០៣ អនុក្រ.បក ស្តីពី ការបង្កើតខណ្ឌបឹងកេងកងនៃរាជធានីភ្នំពេញ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩

**ខ. ស្ថានភាពប្រជាជន**

ស្ថិតិប្រជាពលរដ្ឋមានចំនួន ៩,៤៤២គ្រួសារ , មនុស្សចំនួន ៤៧,០៥៣នាក់ ស្រីចំនួន ២២,៦១២នាក់ ប្រជា-ពលរដ្ឋខ្មែរ អាយុ ១៨ឆ្នាំឡើង ចំនួន ៣០,៣៦៩នាក់។

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៩,៤៤២ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៧,៣៣៨ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១,៩៦៥ |
| ៤ | ប្រជាពលរដ្ឋសរុប | ៤៧,០៥៣ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ២២,៦១២ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៣០,៣៦៩ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | 0 |

**គ. ស្ថានភាពសេដ្ឋកិច្ច និងសង្គមកិច្ច**

❖ **ស្ថានភាពសេដ្ឋកិច្ច**

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤របស់រាជធានីភ្នំពេញដែលមានទីតាំងស្ថិតនៅចំកណ្តាលផងនោះ ព្រមទាំងមានប្រជាពលរដ្ឋរស់នៅនិងប្រកបរបរច្រើនប្រភេទ។ ជាងនេះទៅទៀតសម្បូរទៅដោយសំណង់អាគារទំនើបៗខ្ពស់ៗ និងអាគារលំនៅដ្ឋាន សណ្ឋាគារ ផ្ទះសំណាក់ សួនច្បារ មណ្ឌលពាណិជ្ជ-កម្ម ផ្សារទំនើបសង់អមសងខាងដងវិថីតូចធំខ្វាត់ខ្វែងអាចទាក់ទាញភ្ញៀវទេសចរណ៍ជាតិ និងអន្តរជាតិឱ្យចូលទស្សនា និងទិញទំនិញគ្រប់ប្រភេទ។

❖ **ស្ថានភាពសង្គមកិច្ច**

ផ្អែកតាមស្ថានភាពនៃភូមិសាស្ត្រខណ្ឌចំកាមន មានប្រជាពលរដ្ឋរស់នៅច្រើន និងគ្រប់និន្នាការចម្រុះគ្នាដូចជា៖ អាជីវករ ផលិតករ សិប្បករ ពាណិជ្ជករ សេវាករ មន្ត្រីរាជការ បុគ្គលិក និយោជិក និយោជក អ្នកមានជីវភាពធូរធា អ្នកក្រីក្រ ព្រះសង្ឃ អ្នកកាន់សាសនាផ្សេងៗ និងអ្នកនយោបាយផងនោះ ត្រូវបានរដ្ឋបាលខណ្ឌយកចិត្តទុកដាក់ខ្ពស់លើការងារសង្គមដោយមិនប្រកាន់និន្នាការការងារ និងប្រកាន់ពូជសាសន៍ គឺពលរដ្ឋទាំងនោះទទួលបាននូវការថែរក្សាការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈបានស្មើៗភាពគ្នា។

**ផ្នែកទី២៖ រចនាសម្ព័ន្ធគ្រប់គ្រង**

រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌចំការមនគឺត្រូវបានគ្រប់គ្រងដោយក្រុមប្រឹក្សា គណៈអភិបាល គណៈនាយករដ្ឋបាល ការិយាល័យជំនាញចំនួន៤ និងអង្គភាពចំនួន១ជាជំនួយការ។

### ក. ក្រុមប្រឹក្សាខណ្ឌ និង គណៈកម្មាធិការនានា

ក្រុមប្រឹក្សាខណ្ឌបង្កើតឡើង ដោយការបោះឆ្នោតអសកលស្របតាមនីតិវិធីដែលកំណត់ដោយ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ក្រុមប្រឹក្សាខណ្ឌចំការមន មានសមាជិកចំនួន១៩រូប ដោយមានប្រធាន១រូប( លោក ថេង សុថុល ) និង ១៨រូបជាសមាជិក ក្នុងនោះស្រីចំនួន៤រូប មានអាណត្តិ៥ឆ្នាំ ហើយធ្វើការប្រជុំសាមញ្ញ១២លើកក្នុង១ឆ្នាំ ដើម្បីត្រួតពិនិត្យ វាយតម្លៃតាមដាន រៀបចំផែនការអភិវឌ្ឍ និងអនុម័តកិច្ចការស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួនដែលការប្រជុំត្រូវបានបែងចែកជាពីរ គឺប្រជុំសាមញ្ញ និងប្រជុំវិសាមញ្ញ។ យោងតាមមាត្រា ៥០. ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ

- ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ
- សកម្មភាពនានាដែលបានអនុវត្ត
- របាយការណ៍ហិរញ្ញវត្ថុ
- ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា
- លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា៤០ នៃច្បាប់នេះ។[3]

វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ។

ក្រុមប្រឹក្សាខណ្ឌ មានគណៈកម្មាធិការចំពោះកិច្ចចំនួន៣ ដូចជា៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម។

### ខ. គណៈអភិបាលខណ្ឌ និងនាយករដ្ឋបាល

- **គណៈអភិបាលខណ្ឌ**

គណៈអភិបាលខណ្ឌចំការមនមានសមាជិកចំនួន៥រូប ដែលកើតឡើងពីការតែងតាំងដោយស្របតាមលក្ខខណ្ឌនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមានអាណត្តិមិនលើសពី៥ឆ្នាំ។ គណៈអភិបាលខណ្ឌចំការមនដឹកនាំដោយលោក **ថេង សុថុល** ជាអភិបាលខណ្ឌ និងអភិបាលរងចំនួន ៤រូប ក្នុងនោះមាន១រូបជាស្ត្រី។

[3]-សូមមើលមាត្រា៤០ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ( ២០០៨ )

❖ **នាយករដ្ឋបាលខណ្ឌ**

រដ្ឋបាលខណ្ឌចំការមនមាន នាយករដ្ឋបាល ១រូប គឺលោក **ស៊ុន សិទ្ធី** និងនាយករងរដ្ឋបាលចំនួន២រូបជាជំនួយការ។

## គ. ការិយាល័យចំណុះរដ្ឋបាលខណ្ឌ និងអង្គភាពលទ្ធកម្ម

❖ **ការិយាល័យចំណុះរដ្ឋបាលខណ្ឌ**

ផ្អែកតាមគោលការណ៍ដូចមានចែងក្នុងមាត្រា១៧៣ នៃអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលរាជធានីភ្នំពេញ គ-ណៈអភិបាលខណ្ឌរាជធានីភ្នំពេញ ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធាន១រូប និងមានអនុប្រធាន១រូបជាជំនួយការ។

សាលាខណ្ឌចំការមនមានការិយាល័យចាំបាច់ដូចជា៖ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ, ការិយាល័យផែនការ និងអភិវឌ្ឍន៍, ការិយាល័យអន្តរវិស័យ និងការិយាល័យច្រកចេញចូលតែមួយ។

❖ **អង្គភាពលទ្ធកម្ម**

អង្គភាពលទ្ធកម្មមានរចនាសម្ព័ន្ធស្ថិតក្រោមនាយករដ្ឋបាលខណ្ឌ និងជាលេខាធិការដ្ឋានរបស់គណៈក-ម្មាធិការលទ្ធកម្ម។ ចំពោះសមាសភាពរបស់អង្គភាពលទ្ធកម្មខណ្ឌចំការមន ត្រូវដឹកនាំដោយប្រធាន១រូប និងអមដោយអនុប្រធាន ១រូប ជាជំនួយការ។ អង្គភាពលទ្ធកម្មរបស់រដ្ឋបាលខណ្ឌមានភារកិច្ចចាត់ចែងលើការងារដូចជា ៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើរដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើរដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើរដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើរដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយពីលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលខណ្ឌ ។

# ជំពូកទី២

# ការគ្រប់គ្រងបុគ្គលិក

## ផ្នែកទី១៖ ការជ្រើសរើសបុគ្គលិក

ការជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតាមរយៈការប្រលងប្រជែងផ្អែកលើគោលការណ៍តម្លាភាព យុត្តិធម៌ សមធម៌ និងគុណសម្បត្តិស័ក្តិសម។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រលងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ សម្រាប់រដ្ឋបាលរាជធានីគណៈកម្មការត្រូវមានសមាសភាពដូចជា[4] ៖

- តំណាងគណៈអភិបាល ប្រធាន
- នាយករដ្ឋបាល សមាជិក
- ប្រធានទទួលបន្ទុកអង្គភាពបុគ្គលិក សមាជិក
- ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក សមាជិក
- អភិបាលខណ្ឌនិង/ឬចៅសង្កាត់ដែលមានតម្រូវការបុគ្គលិក សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ សមាជិក។

### ក. លក្ខខណ្ឌនៃការជ្រើសរើស

[5] បេក្ខជនទាំងពីភេទអាចទទួលឱ្យចូលធ្វើការក្នុងក្របខណ្ឌរាជការបានលុះត្រាតែ បេក្ខជននោះបានបំពេញនូវលក្ខខណ្ឌដូចខាងក្រោម ៖

+ មានសញ្ជាតិខ្មែរ ( សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា)។[6]
+ មានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយមិនលើសពី ២៥ឆ្នាំ ប៉ុន្តែមានករណីលើកលែងដូចមានចែងខាងក្រោម ៖
    - ចំពោះបេក្ខជនដែលមានសញ្ញាបត្រឧត្តមសិក្សា ការកំរិតអាយុត្រូវបានរំកិលពី ២៥ឆ្នាំ ដល់ ៣០ឆ្នាំ យ៉ាងច្រើនបំផុត។
    - ចំពោះបេក្ខជន ដែលបានរៀននៅគ្រឹះស្ថានឧត្តមសិក្សា មួយឆ្នាំ ឬ ច្រើនឆ្នាំ ហើយមិនបាននូវ

[4]-មាត្រា ១៣នៃព្រះរាជក្រឹត្យលេខ៣៧៣ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

[5]-មាត្រា ១១នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

[6]-មាត្រា ៣ នៃច្បាប់ស្តីពីសញ្ជាតិ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨

សញ្ញាបត្រនោះ ការកំរិតអាយុ ២៥ ឆ្នាំ ត្រូវបានរំកិលតាមចំនួនដែលបានរៀនក្នុងគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ តែមិនឱ្យលើសពី ៣០ឆ្នាំ។

- ចំពោះបេក្ខជនដែលបានបំពេញកាតព្វកិច្ចយោធា ការកំរិតអាយុត្រូវបានរំកិលតាមចំនួន ឆ្នាំដែលបានបំពេញកាតព្វកិច្ចយោធានេះ។
- ក្នុងពេលចាំបាច់ រាជរដ្ឋាភិបាលអាចចេញអនុក្រឹត្យលើកលែងការកំណត់អាយុនៃបេក្ខជនដើម្បីបំពេញសេចក្តីត្រូវការជាអាទិភាព និងដើម្បីផលប្រយោជន៍ជាតិ

\+ មិនបានប្រាសចាកសិទ្ធខាងរដ្ឋប្បវេណី សិទ្ធជាពលរដ្ឋ សិទ្ធខាងនយោបាយ[7]

\+ មិនដែលមានទោសឧក្រិដ្ឋ ឬមជ្ឈឹមពីរឿងល្មើសប៉ះពាល់ដល់ទំនៀមទម្លាប់ កិត្តិយស និងភាពសុចរិត

\+ ត្រូវមានកាយសម្បទាគ្រប់គ្រាន់ក្នុងការបំពេញការងារដែលលក្ខណៈសម្បត្តិមានចែងទុកជាមុននៅក្នុងសេចក្តីណែនាំ និងបទបញ្ជាជាធរមាន

\+ បងប្អូនជនជាតិភាគតិច បងប្អូននៅតំបន់ដាច់ស្រយាល និងបងប្អូននារីភេទ អាចត្រូវបានផ្តល់អាទិ-ភាព និងភាពងាយស្រួល

\+ ត្រូវបំពេញលក្ខខណ្ឌខាងសមត្ថភាពគ្រប់គ្រាន់ ដូចមានចែងក្នុងបទបញ្ជាដោយឡែកនៃអង្គដែលខ្លួនមានបំណងសុំចូលបំរើការងារ

\+ លក្ខខណ្ឌស្តីពីសញ្ជាតិ និងអាយុត្រូវបញ្ជាក់តាមសំបុត្រអត្រានុកូលដ្ឋាន ឬតាមសាលក្រមជំនួសអត្រានុកូលដ្ឋាននោះ

\+ សេចក្តីបញ្ជាក់ថាគ្មានទោសត្រូវកំណត់ក្នុងលិខិតថ្កោលទោសមួយមានសុពលភាព ៣ខែ ដែលចេញដោយក្រសួងយុត្តិធម៌។

ជាគោលការណ៍ រាល់ការប្រលងជ្រើសរើសបេក្ខជនឱ្យចូលក្របខណ្ឌ ត្រូវធ្វើឡើងតាមការប្រលងប្រជែងលើកលែងតែមានការកណត់ផ្សេងពីនេះដោយរាជរដ្ឋាភិបាល។

**ខ. ការធ្វើកម្មសិក្សា ការតាំងស៊ប់**

❖ **ការធ្វើកម្មសិក្សា**

បន្ទាប់ពីទទួលដីការបញ្ចូលក្របខណ្ឌថ្មី កម្មសិក្សាការីត្រូវធ្វើកម្មសិក្សាដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

\+ រយៈពេលកម្មសិក្សា ១២ ( ដប់ពីរ )ខែ ចំពោះកម្មសិក្សាការីដែលត្រូវបានជ្រើសចេញពីសិស្ស និស្សិត

7- មាត្រា ៣២ នៃរដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣

+ រយៈពេលកម្មសិក្សា៦ ( ប្រាំមួយ )ខែ ចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌណាមួយរួចហើយ ហើយបានប្រលងជាប់ចូលក្របខណ្ឌណាមួយនៃអង្គភាពថ្មីមួយទៀតដោយរក្សាអតីតភាពដែលមានពីមុនមក លើកលែងតែមានការកំណត់មិនឱ្យធ្វើកម្មសិក្សាដោយអង្គភាពណាមួយ
+ ការធ្វើកម្មសិក្សាត្រូវបានលើកលែងចំពោះ មន្ត្រីរាជការក្របខណ្ឌទាំងឡាយដែលបានប្រលងជាប់ទៅកាន់ប្រភេទក្របខណ្ឌខ្ពស់ជាងមុនក្នុងអង្គតែមួយដែលបានតាំងស៊ប់រួចហើយ លើកលែងតែមានការកំណត់ឱ្យធ្វើកម្មសិក្សាដោយអង្គណាមួយ
+ កម្មសិក្សាមិនត្រូវយកជាការបានឡើយ ប្រសិនបើសាមីជនអាក់ខានមកធ្វើកម្មសិក្សាដែលមានរយៈពេលសរុបលើសពីសាមសិប ( ៣០ )ថ្ងៃ។ ក្នុងករណីសាមីជនត្រូវបន្តកម្មសិក្សានៅលើកទី២ទៀត។ ក្នុងករណីកម្មសិក្សាលើកទី២មិនបានជោគជ័យទៀត អភិបាលនៃគណៈអភិបាលរដ្ឋខណ្ឌមានសមត្ថកិច្ចត្រូវចេញដីការលុបឈ្មោះចេញពី ក្របខណ្ឌចំពោះ កម្មសិក្សាការីជ្រើសរើសចេញពី សិស្ស និស្សិត ឬ

បញ្ជូនទៅក្របខណ្ឌដើមវិញចំពោះកម្មសិក្សាការីជ្រើសរើសចេញពីមន្ត្រីរាជការ។

+ កម្មសិក្សាការីណាដែលមិនបានបង្ហាញឱ្យឃើញថា ខ្លួនមានកាយសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬពិនិត្យឃើញថាធ្វើការងារមានការខ្ជីខ្ជា ឬក៏គ្មានកំលាំងពលំនឹងកាន់មុខតំណែងបានតាមលក្ខខណ្ឌដែលបានកំណត់តាមសេចក្តីណែនាំជាធរមាន អាចត្រូវបានបញ្ឈប់មិនឱ្យធ្វើការងារនេះនៅពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា។

❖ **ការតាំងស៊ប់**

ការតាំងស៊ប់ក្នុងក្របខណ្ឌ ត្រូវបានអនុញ្ញាតជូនកម្មសិក្សាការីទាំងឡាយណាដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។ ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គណាមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានមានការចូលរួមយោបល់ពីគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃដែលមានសមាសភាពដូចជា ៖

- ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ១ ( មួយ )រូប
- អនុប្រធានអង្គភាពសាមី ១ ( មួយ )រូប
- មន្ត្រីរាជការដែលមានឋានន្តរស័ក្តិខ្ពស់ជាងគេក្នុងអង្គភាពដែលសាមីខ្លួនធ្វើការជាមួយ១( មួយ ) រូប។

ក្នុងករណីពុំមានមន្ត្រីរាជការសមស្របតាមការកំណត់ខាងលើនេះទេ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ជាអ្នកវាយតម្លៃ។ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ត្រូវលើកសំណើរតាមឋានានុក្រមដាក់ជូន អភិបាលនៃគណៈ-អភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីពិនិត្យសម្រេច។

ចំពោះមន្ត្រីរាជការស៊ីវិលដែលបានប្រលងជាប់ទៅកាន់ប្រភេទក្របខណ្ឌខ្ពស់ជាងមុនក្នុងអង្គតែមួយ និងមន្ត្រីរាជការស៊ីវិលដែលប្រឡងប្តូរប្រភេទក្របខណ្ឌក្នុងអង្គភាពផ្សេងគ្នា ត្រូវអនុញ្ញាតឱ្យតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គដែលខ្លួនបានប្រលងជាប់បន្ទាប់ពីការចេញដីការប្រកាសលទ្ធផល។

ក្នុងរយៈពេល ៣០ ( សាមសិប )ថ្ងៃយ៉ាងយូរក្រោយផុតកំណត់រយៈពេលកម្មសិក្សា ដោយផ្អែកលើការវាយតម្លៃរបស់គណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃកម្មសិក្សារដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចអំពី ៖

- ការតាំងស៊ប់កម្មសិក្សាការីក្នុងក្របខណ្ឌ ឬ
- ការឱ្យកម្មសិក្សាការីធ្វើកម្មសិក្សាជាលើកទី ២ ឬ
- ការបញ្ឈប់មិនឱ្យកម្មសិក្សាការីធ្វើការ។

ការតាំងស៊ប់ចាប់ផ្តើមមានប្រសិទ្ធភាពចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សា។ រយៈពេលកម្មសិក្សាត្រូវគិតបញ្ចូលក្នុងអតីតភាពការងារសម្រាប់ពេលចូលនិវត្តន៍។

ការតាំងស៊ប់ក្នុងក្របខណ្ឌនីមួយៗ ត្រូវអនុវត្តតាមការកំណត់ដូចខាងក្រោម ៖

- ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលបេក្ខជនបានប្រលងជាប់ ចំពោះបេក្ខជនដែលបានជ្រើសរើសចេញពី សិស្ស និស្សិត ឬត្រូវបានបន្ថែម ១ ( មួយ )ថ្នាក់ ឬច្រើនថ្នាក់ទៅតាមការកំណត់នៃក្របខណ្ឌនីមួយៗនៃអង្គភាព ឬតាមការកំណត់របស់រាជរដ្ឋាភិបាល។
- ត្រូវចាត់បញ្ចូលទៅថ្នាក់ ដែលមានសន្ទស្សន៍បៀវត្សខ្ពស់បន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន
- ចំពោះបេក្ខជនដែលបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជកាស៊ីវិល។

បែបបទ និងនីតិវិធីនៃការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់មិនឱ្យកម្មសិក្សាការី ត្រូវរៀបចំឡើងដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួងស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។[8] ការតាំងស៊ប់ត្រូវធ្វើឡើងដោយលិខិតបទដ្ឋានរួមមាន ៖

- ចំពោះក្របខណ្ឌ **ក** ត្រូវតាំងស៊ប់ដោយព្រះរាជក្រឹត្យ
- ចំពោះក្របខណ្ឌ **ខ** ត្រូវតាំងស៊ប់ដោយអនុក្រឹត្យ
- ចំពោះក្របខណ្ឌ **គ** ត្រូវតាំងស៊ប់ដោយប្រកាស។

## គ. ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់តំណែង

រាល់ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់តំណែង របស់មន្ត្រីរាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើ

[8]-សូមមើលជំពូកទី៥ នៃព្រះរាជក្រឹត្យលេខ ៣៧៣ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

ឡើងដោយផ្អែកលើគោលការណ៍ប្រសិទ្ធភាពការងារ ពិគ្រោះយោបល់ តម្លាភាព គណនេយ្យភាព សមធម៌ យុត្តិធម៌ អព្យាក្រឹត្យភាពមន្ត្រីរាជការ ស្របតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ [9] ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់តំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ក្នុងខណ្ឌត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលរាជធានីតាមគោលការណ៍ និងនីតិវិធីជាធរមាន។[10]

### ❖ ការតែងតាំង

ក្រោយពេលត្រូវបានតាំងស៊ប់នៅក្នុងក្របខណ្ឌរួចហើយ មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលបានការតែងតាំងក្នុងមុខតំណែងវិជ្ជាជីវៈ ស្របតាមសេចក្តីត្រូវការ នៃការជ្រើសរើសបានកំណត់។ ការតែងតាំងមន្ត្រី រាជការស៊ីវិលនៅថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងឱ្យបានសមស្របទៅតាមចំនួនមុខតំណែងទំនេរ បេសកកម្ម ទំហំការងារ សំណូមពរ និងភារកិច្ចជាក់ស្តែង ដោយមិនត្រូវតែងតាំងឱ្យលើសចំនួនមុខតំណែងដែលបានកំណត់ក្នុងរចនាសម្ព័ន្ធឡើយ។

ការតែងតាំងក្នុងមុខតំណែងវិជ្ជាជីវៈ ត្រូវផ្អែកលើគុណសម្បត្តិស័ក្តិសមនៃមុខតំណែងវិជ្ជាជីវៈនីមួយៗដែលត្រូវកំណត់ដោយអនុក្រឹត្យ និងលិខិតបទដ្ឋានជាធរមាន។

ការតែងតាំងក្នុងមុខតំណែងគ្រប់គ្រងត្រូវផ្អែកលើឧបនិស្ស័យ និងគុណសម្បត្តិស័ក្តិសមរបស់បេក្ខជនសម្រាប់មុខតំណែងអនុលោមតាមបទបញ្ញត្តិជាធរមាន។

ជាគោលការណ៍មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចទទួលបាននូវការតែងតាំងមុខតំណែងណាមួយសមស្របតាមក្របខណ្ឌឋានន្តរស័ក្តិរបស់ខ្លួន។

### ❖ ការផ្លាស់ប្តូរ

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិអាចនិងត្រូវបានអនុញ្ញាតឱ្យផ្ទេរទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ និងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀត។ ចំពោះបែបបទ និងនីតិវិធីនៃការផ្ទេរ និងការផ្លាស់ប្តូរកន្លែងធ្វើការរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។[11]

9-សេចក្តីណែនាំលេខ ២២០២ ស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

10-មាត្រា ២៧ នៃព្រះរាជក្រឹត្យលេខ ៣៧៣ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

11- មាត្រា ៤២ នៃព្រះរាជក្រឹត្យលេខ ៣៧៣ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

[12]ការផ្ទេរនេះអាចធ្វើឡើងបានក្នុងអង្គតែមួយនៃមន្ត្រីរាជការនោះ និងត្រូវផ្អែកលើមុខតំណែងទំនេរនៅក្នុងអង្គភាពដែលទទួលបុគ្គលិកនោះ ព្រមទាំងគុណសម្បត្តិស័ក្តិសមរបស់បុគ្គលិកចំពោះមុខតំណែង។ ការផ្ទេរបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ និងមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវធ្វើតាមគោល-ការណ៍ដូចខាងក្រោម ៖

- **ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយផ្សេងទៀត**
  - ការស្នើសុំរបស់សាមីខ្លួន
  - ការយល់ព្រមពីអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងសងខាង
  - ការផ្ទេរនេះត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងសងខាង
  - រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនដីការសម្រេចផ្ទេរបុគ្គលិកទៅមន្ទីមុខងារសាធារណៈរាជធានីខេត្តដែលសាមីខ្លួននោះផ្ទេរទៅ។ ក្នុងករណីពិនិត្យឃើញដីកា និងសេចក្តីសម្រេចធ្វើឡើងមិនសមស្របតាមបទបញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ មន្ទីមុខងារសា-ធារណៈរាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ។
- **ការផ្ទេររវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ**
  - ការស្នើសុំរបស់សាមីខ្លួន
  - ការយល់ព្រមពីអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិសាមី
  - ការយល់ព្រមពីក្រសួង ស្ថាប័នសាមី
  - ការផ្ទេរនេះធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសរបស់ ក្រសួងស្ថាប័នសាមី។
  - រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនដីកា ឬប្រកាសសម្រេចផ្ទេរបុគ្គលិក ទៅកាន់ក្រសួងមុខងារសាធារណៈ

ក្នុងករណីពិនិត្យឃើញដីការ និងប្រកាសធ្វើឡើងមិនសមស្របតាមបទបញ្ញត្តិជាធរមានពាក់ព័ន្ធនឹង ការគ្រប់គ្រងមុខងារសាធារណៈ មន្ទីមុខងារសាធារណៈ រាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាព របស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ។

❖ **ការចូលនិវត្តន៍**

គឺជាដំណាក់កាលចុងក្រោយនៃជីវិតការងារ របស់មន្ត្រីរាជការនៅក្នុងអាជីពការងាររបស់ខ្លួន។ ការចូល

[12]-សូមមើលជំពូកទី៦ នៃព្រះរាជក្រឹត្យលេខ ៣៧៣ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

និវត្តន៍ចែកចេញជា ៖

+ ការចូលនិវត្តន៍ដោយការដល់អាយុកំណត់ឱ្យចូលនិវត្តន៍
+ ការចូលនិវត្តន៍មុនអាយុតាមការស្ម័គ្រចិត្ត
+ ការដាក់ឱ្យចូលនិវត្តន៍ដោយបញ្ញត្តិ
+ ការដាក់ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ។

➢ **ការចូលនិវត្តន៍ដោយការដល់អាយុកំណត់ឱ្យចូលនិវត្តន៍**

យោងតាមច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងលក្ខន្តិកៈដោយឡែកនៃក្របខណ្ឌនីមួយៗ ចំពោះមន្ត្រីរាជការទាំងពីរភេទត្រូវដាក់ឱ្យចូលនិវត្តន៍នៅពេលដល់អាយុចូលនិវត្តន៍ ( ៥០ , ៥៨ , ៦០ )អាស្រ័យទៅតាមប្រភេទក្របខណ្ឌ ប៉ុន្តែមន្ត្រីរាជការជាស្ត្រីប្រភេទក្របខណ្ឌ ( ខ,គ )អាចប្តូរការងារដល់អាយុ ៦០ ( ហុកសិប )ឆ្នាំ បើមិនចង់ចូលនិវត្តន៍តាមការកំណត់ខាងលើនេះទេនោះ ។

- មន្ត្រីរាជការស្ថិតក្នុងឋានន្តរស័ក្តិទី១នៃក្របខណ្ឌប្រភេទ ក.១ ត្រូវសម្រេចឱ្យចូលនិវត្តន៍ដោយព្រះរាជក្រឹត្យ
- មន្ត្រីរាជការស្ថិតក្នុងឋានន្តរស័ក្តិទី១នៃក្របខណ្ឌប្រភេទ ក.២ ត្រូវសម្រេចឱ្យចូលនិវត្តន៍ដោយអនុក្រឹត្យ
- មន្ត្រីរាជការស្ថិតក្នុងឋានន្តរស័ក្តិទី១នៃក្របខណ្ឌប្រភេទ ក.៣ ត្រូវសម្រេចឱ្យចូលនិវត្តន៍ដោយប្រកាស។

➢ **ការចូលនិវត្តន៍មុនអាយុតាមការស្ម័គ្រចិត្ត**

មន្ត្រីរាជការដែលមានអតីតភាពការងារ ៣០ ( សាមសិប )ឆ្នាំឡើងទៅ ហើយមានអាយុមិនទាន់ដល់អាយុដែលច្បាប់កំណត់ឱ្យចូលនិវត្តន៍អាចស្នើសុំចូលនិវត្តន៍បាន។ នៅពេលដែលមន្ត្រីរាជការនៅក្របខណ្ឌណាមួយ បានបម្រើការងារមានអតីតភាពគ្រប់ ៣០ ( សាមសិប )ឆ្នាំហើយតែមិនទាន់ដល់អាយុត្រូវចូលនិវត្តន៍នោះ ក្រសួង ស្ថាប័នមិនអាចចាប់បង្ខំគេឱ្យចូលនិវត្តន៍បានទេ។

➢ **ការដាក់ឱ្យចូលនិវត្តន៍ដោយបញ្ញត្តិ**

គឺជាលិខិតបទដ្ឋានឯកត្តជនសម្រាប់ដាក់មន្ត្រីរាជការណាម្នាក់ឱ្យចូលនិវត្តន៍ ដោយវិធានការវិន័យអនុវត្តក្នុងជំពូកទី៥ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល និងអនុក្រឹត្យស្តីពីនីតិវិធីអនុវត្តន៍វិន័យចំពោះមន្ត្រីរាជការស៊ីវិល។ ការដាក់ឱ្យចូលនិវត្តន៍ដោយបញ្ញត្តិនៅពេលដែលមន្ត្រីរាជការប្រព្រឹត្តកំហុសធ្ងន់ក្នុងវិជ្ជាជីវៈ ដែលត្រូវទណ្ឌកម្មខាងវិន័យថ្នាក់ទី២ចំណុច ឃ។[13]

[13] -មាត្រា ៤០ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

➢ **ការដាក់ឱ្យចូលនិវត្តន៍ដោយបាត់បង់សម្បទាវិជ្ជាជីវៈ**

ការដាក់ឱ្យចូលនិវត្តន៍នេះ ចំពោះមន្ត្រីរាជការទាំងពីរភេទ ដែលបាត់បង់សម្បទាវិជ្ជាជីវៈហើយមានអតីតភាពការងារចាប់ពី២០ ( ម្ភៃ )ឆ្នាំទៅដល់ក្រោម៣០(សាមសិប )ឆ្នាំហើយពុំគ្រប់អាយុចូលនិវត្តន៍។ ការកំណត់ថាមន្ត្រីរាជការណាម្នាក់បាត់បង់សម្បទាវិជ្ជាជីវៈ ត្រូវសម្រេចដោយគណៈកម្មការ តាមការកំណត់ក្នុងមាត្រា ១៩នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល។[14] ការបាត់បង់សម្បទាវិជ្ជាជីវៈបែងចែកតាមមូលហេតុដូចជា ៖

- **បាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារ**

ត្រូវចាត់ទុកជាគ្រោះថ្នាក់ការងារ គឺគ្រោះថ្នាក់ដែលកើតឡើងដោយធ្វើការ ឬក្នុងពេលធ្វើការជូនក្រសួង ស្ថាប័ន ទោះមានហេតុផលយ៉ាងណាក៏ដោយ ឬមានកំហុសមកពីអ្នករាជការ ឬគ្មានក៏ដោយ ហើយបណ្តាលឱ្យបាត់បង់សម្បទាវិជ្ជាជីវៈទាំងស្រុង និងអចិន្ត្រៃយ៍។ ឧ.ទាៈ

- គ្រោះថ្នាក់កើតឡើងក្នុងពេលម៉ោងធ្វើការទាំងក្នុង និងក្រៅក្រសួង ស្ថាប័នដែលអ្នករាជការបានបំពេញភារកិច្ចរបស់ខ្លួន។
- គ្រោះថ្នាក់ក្នុងរយៈពេលធ្វើការ និងរយៈពេលធ្វើការ និងនៅពេលមុន ឬក្រោយពេលធ្វើការ ដែលអ្នករាជការរៀបចំសម្ភារៈពលកម្ម ឬម៉ាស៊ីន។
- គ្រោះថ្នាក់ក្នុងការបំពេញសេចក្តីត្រូវការផ្ទាល់ខ្លួនក្នុងរយៈពេលធ្វើការ ដូចជា ពេលសម្រាកហូបចុក និងពេលបំបៅកូនកណ្តាលវេន ពេលសំអាតខ្លួននៅពេលក្រោយធ្វើការ។
- គ្រោះថ្នាក់ដែលបណ្តាលមកពីកត្តាដែលមានគ្រោះថ្នាក់មានជាតិពុលដោយមិនដឹងខ្លួនជាមុនក្នុងក្រសួង ស្ថាប័ន និងក្នុងផលិតកម្ម ហើយបណ្តាលឱ្យមានរបួសពុលសន្លប់ដល់អ្នករាជការហើយធ្វើឱ្យបាត់បងសម្បទាវិជ្ជាជីវៈជាស្ថាពរនូវសមត្ថភាពការងារ។
- គ្រោះថ្នាក់ដែលធ្លាក់លើអ្នករាជការ ក្នុងពេលដែលអ្នកទាំងនោះធ្វើដំណើរពីលំនៅដ្ឋានរបស់ខ្លួនឆ្ពោះត្រង់ទៅកន្លែងធ្វើការ ឬវិលមកវិញដោយគ្មានឈប់ ឬដោយគ្មានវៀងទៅទីណាជាប្រយោជន៍ផ្ទាល់ខ្លួន។

- **បាត់បង់សម្បទាវិជ្ជាជីវៈដោយគ្រោះថ្នាក់ការងារក្នុងពេលបំពេញបេសកកម្ម**

- គ្រោះថ្នាក់នៅពេលអ្នករាជការបញ្ចេញនូវវីរៈភាពក្នុងការបំពេញបេសកកម្មដែលក្រសួង ស្ថាប័នអង្គភាពប្រគល់ឱ្យ ហើយបានលះបង់ជីវិតរបស់ខ្លួន។
- គ្រោះថ្នាក់ដែល កើតមានឡើងក្នុងពេល អ្នករាជការការពារទ្រព្យសម្បត្តិរដ្ឋសាធារណៈ ដូចជា

[14] - សូមមើលមាត្រា ១៩ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល

ភ្លើងឆេះផ្ទះទឹកជំនន់។ល។

- **បាត់បង់សម្បទាវិជ្ជាជីវៈដោយសារជម្ងឺ ឬគ្រោះថ្នាក់ផ្សេងៗ**

ការដាក់ឱ្យចូលនិវត្តន៍ដោយសារការបាត់បង់សម្បទាវិជ្ជាជីវៈដោយសារមន្ត្រីរាជការមានជម្ងឺ ឬដោយសារគ្រោះថ្នាក់ផ្សេងៗក្រៅពីករណីគ្រោះថ្នាក់ខាងលើ។

## ផ្នែកទី២៖ ការគ្រប់គ្រងរដ្ឋបាល

### ក. ការគ្រប់គ្រងបុគ្គលិក

រចនាសម្ព័ន្ធខណ្ឌរួមមាន ៖ សមាជិកក្រុមប្រឹក្សាខណ្ឌ ចំនួន១៩ រូប, ស្រី ៤ រូប ប្រធានក្រុមប្រឹក្សាខណ្ឌ ១ រូប( ប្រុស ), សមាជិកក្រុមប្រឹក្សាខណ្ឌដែលបានផ្លាស់ប្តូរ( គ្មាន ), គណៈអភិបាលខណ្ឌមាន៥ រូបស្រី១ រូប ក្នុងនោះអភិបាលខណ្ឌ ១ រូប និងអភិបាលរងខណ្ឌ ៤ រូប ស្រី១ រូប, នាយក នាយករងរដ្ឋបាល ៣ រូប,ប្រធានការិយាល័យ និងអង្គភាពលទ្ធកម្ម ៥រូប ស្រី ១រូប, អនុប្រធានការិយាល័យនិងអង្គភាពលទ្ធកម្ម ៤ រូប, មន្ត្រីការិយាល័យ និងស្មៀនសង្កាត់ចំនួន ៤២ រូប ស្រី ១៧ រូប, បុគ្គលិកជាប់កិច្ចសន្យា ១៧៧រូប ស្រី ២៨រូប។

**តារាងស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ១៩ | ៤ |
| ២ | ប្រធានក្រុមប្រឹក្សា | ១ | 0 |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | 0 | 0 |
| ៤ | អភិបាល | ១ | 0 |
| ៥ | អភិបាលរង | ៤ | ១ |
| ៦ | នាយករដ្ឋបាល | ១ | 0 |
| ៧ | នាយករងរដ្ឋបាល | ២ | 0 |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ៥ | ១ |

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ៤ | 0 |
| ១០ | មន្ត្រីការិយាល័យ(រាប់ទាំងស្មៀនសង្កាត់) | ៤២ | ១៧ |
| ១១ | បុគ្គលិកកិច្ចសន្យា | ១៧៧ | ២៨ |

❖ **ការគ្រប់គ្រងវត្តមាន**

➢ **មន្ត្រីរាជការស៊ីវិល**

ជាគោលការណ៍មន្ត្រីរាជការស៊ីវិលត្រូវអនុវត្តកាតព្វកិច្ចការងាររយៈពេល៨ ( ប្រាំបី )ម៉ោងក្នុងមួយថ្ងៃ និង ៥ ( ប្រាំ )ថ្ងៃក្នុងមួយសប្តាហ៍ ឬរយៈពេល៤០ ( សែសិប )ម៉ោងក្នុងមួយសប្តាហ៍ផ្អែកលើការបែងចែកម៉ោងធ្វើការទៅតាមការកំណត់របស់ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ដោយមានការឯកភាពពីក្រសួង ស្ថាប័នសាមី ដើម្បីធានាឱ្យបាននូវនិរន្តរភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ត្រូវអនុញ្ញាតឱ្យ មន្ត្រីរាជការចាប់ផ្តើមនិងចេញពីធ្វើការ មុននិង/ឬ ក្រោយម៉ោងកំណត់នៃការងារក្នុង១ ( មួយ )ថ្ងៃមិនឱ្យលើសពី១ ( មួយ )ម៉ោងចំពោះមន្ត្រីរាជការស៊ីវិលដែលមានស្ថានភាព ដូចខាងក្រោម ៖

- មន្ត្រីរាជការដែលមានជនចាស់ជរា ឬជនដែលមានស្មារតីវិបល្លាស ឬជនពិការអចិន្ត្រៃយ៍ក្នុងបន្ទុក
- មន្ត្រីរាជការដែលមានផ្ទៃពោះ
- មន្ត្រីរាជការដែលជនពិការ
- មន្ត្រីរាជការដែលមានអាយុក្រោម១ ( មួយ )ឆ្នាំ
- មន្ត្រីរាជការដែលមានជម្ងឺរ៉ាំរ៉ៃមានការបញ្ជាក់ពីគ្រូពេទ្យមានសមត្ថកិច្ចនិងមានអាយុចាប់ពី៥០ឆ្នាំឡើងទៅ
- មន្ត្រីរាជការដែលទទួលការបណ្តុះបណ្តាលបន្ថែមក្រៅម៉ោងធ្វើការ។[15]

ចំពោះការគ្រប់គ្រងវត្តមានសម្រាប់មន្ត្រីរាជការស៊ីវិល មានសិទ្ធសុំច្បាប់ឈប់សម្រាកតាមនីតិវិធីដូចមានចែងក្នុងបទបញ្ញត្តិជាធរមាន ដែលការឈប់សម្រាកនោះមិនអនុញ្ញាតឱ្យលើសពីរយៈពេលកំណត់របស់រាជរដ្ឋាភិបាលបានឡើយ។ រាល់អវត្តមានមានច្បាប់អនុញ្ញាត និងគ្មានច្បាប់អនុញ្ញាតត្រូវតែចុះក្នុងព្រឹត្តិបត្រការងារប្រចាំ

[15]- មាត្រា៧នៃអនុក្រឹត្យលេខ៥៦ ចុះថ្ងៃ០១ មេសា ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា

ឆ្នាំរបស់មន្ត្រីរាជការស៊ីវិលសាមី។

អវត្តមានគ្មានច្បាប់អនុញ្ញាតចំនួន៤ ( បួន )ម៉ោងជាប់គ្នា ត្រូវចាត់ទុកថា អវត្តមានគ្មានច្បាប់អនុញ្ញាតកន្លះថ្ងៃ។ ក្នុងករណីអវត្តមានគ្មានច្បាប់ចំនួន៨ ( ប្រាំបី )ម៉ោងជាប់គ្នាត្រូវចាត់ទុកថាអវត្តមានគ្មានច្បាប់អនុញ្ញាតចំនួន១ ( មួយ )ថ្ងៃ។ ក្នុងករណីមិនបានបំពេញទាំងស្រុងនូវកាតព្វកិច្ចរបស់ខ្លួនផ្អែកលើលទ្ធផលការងារដែលបានកំណត់ដោយប្រធានអង្គភាពឱ្យទៅធ្វើការនៅក្រៅអង្គភាពត្រូវចាត់ទុកថា អវត្តមានគ្មានច្បាប់អនុញ្ញាតតាមចំនួនថ្ងៃដែលបានកំណត់ ។[16]

❖ **ការអភិវឌ្ឍសមត្ថភាព**

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ៩ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៤២៣ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៨៤ |

### ខ. ការងាររលិខិតរដ្ឋបាល

បានដាក់ចេញនូវសេចក្តីសម្រេចសំខាន់ៗចំនួន១៤ គឺ ៖

- សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការព័ត៌មាន និងប្រតិកម្មរហ័សខណ្ឌ។
- សេចក្តីសម្រេច ស្តីពីការបែងចែកតួនាទីភារកិច្ចរបៀបរបបធ្វើការងារជូនអភិបាលខណ្ឌ។
- សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមប្រតិបត្តិការចម្រុះខណ្ឌចំការមន ដើម្បី ចូលរួមសហការអនុវត្តដីកាសម្រេច បង្គាប់ប្រគល់អចលវត្ថុ លេខ ៨២៣គ.រ ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៩ របស់ សាលាដំបូងរាជធានីភ្នំពេញ។
- សេចក្តីសម្រេច ស្តីពីការបង្កើតរង្វាន់ទេយ្យបុរប្រទានសម្រាប់ឆ្នាំ២០១៩។
- សេចក្តីសម្រេច ស្តីពីបិទបញ្ជីថវិកាចំណូល-ចំណាយ ឆ្នាំ២០១៨ របស់រដ្ឋបាល ខណ្ឌ។
- សេចក្តីសម្រេច ស្តីពីបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងរបស់រដ្ឋបាល ខណ្ឌ។

[16]-មាត្រា៧នៃអនុក្រឹត្យលេខ៥៦ ចុះថ្ងៃ០១ មេសា ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា

- សេចក្ដីសម្រេច ស្ដីពីការបែងចែកភារកិច្ច និងរបៀបរៀបរយធ្វើការងារជូនគណៈអភិបាលខណ្ឌចំការមននៃរាជធានីភ្នំពេញ។
- សេចក្ដីសម្រេច ស្ដីពីបង្កើតគណៈកម្មការគ្រប់គ្រងគម្រោងរបស់រដ្ឋបាលខណ្ឌ។
- សេចក្ដីសម្រេច ស្ដីពីការបង្កើតគណៈកម្មាធិការលទ្ធកម្ម (គ.ល) រដ្ឋបាលខណ្ឌ។
- សេចក្ដីសម្រេច ស្ដីពីការបង្កើតគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស របស់ក្រុមប្រឹក្សាខណ្ឌ។
- សេចក្ដីសម្រេច ស្ដីពីការបង្កើតគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សា។
- សេចក្ដីសម្រេច ស្ដីពីការបង្កើតគណៈកម្មាធិការគ្រប់គ្រងគម្រោងរបស់រដ្ឋបាលខណ្ឌ។
- សេចក្ដីសម្រេច ស្ដីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មខណ្ឌចំការមន។
- សេចក្ដីសម្រេច ស្ដីពីការបង្កើតក្រុមការងារកសាងផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខណ្ឌ។

❖ **លិខិតរដ្ឋបាល**

- លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ២,៨៤៥លិខិត និងទទួលបានចំនួន ២,៤៤៣លិខិត។

**តារាងសង្ខេបការងារលិខិតស្នាម**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ១ |
| ២ | សេចក្ដីសម្រេចដែលបានដាក់ចេញ | ១៤ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ២,៨៤៥ |
| ៤ | លិខិតដែលបានទទួល | ២,៤៤៣ |
| ៥ | សៀវភៅស្នាក់នៅ | ២៧១ |

## គ. ការិយាល័យអន្តរវិស័យ

ការិយាល័យអន្តរវិស័យដែលមានលោក **ឌី សុផល** ជាប្រធាន និងលោក **ម៉ៅ ណូលីន** ជាអនុប្រធាន ព្រមទាំងមន្ត្រីមួយចំនួន ដែលធានារ៉ាប់រងការងារដូចជា ៖

- ការងារដីធ្លី និងសំណង់
- ការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា បរិស្ថាន កាកសំណល់ អនាម័យ សួនច្បារ តាមការធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានី
- អនុវត្តមុខងារភារកិច្ចផ្សេងៗទៀតដែលបានធ្វើប្រតិភូកម្មពីរដ្ឋបាលរាជធានីការងាសណ្ដាប់ធ្នាប់

សាធារណៈ កិច្ចការច្បាប់ និងសិទ្ធមនុស្ស

- ការរំលោភអំណាច និងការដោះស្រាយវិវាទនៅមូលដ្ឋាន។

## ឃ. ការងារហិរញ្ញវត្ថុ

❖ **ការអនុវត្តចំណូល និងចំណាយ**

[17] រដ្ឋបាលខណ្ឌចំការមន បានទទួលសេចក្ដីសម្រេចលេខ០៦០/១៨សសរ.ហចុះថ្ងៃទី៨ខែកុម្ភៈឆ្នាំ ២០១៨ របស់រាជធានីភ្នំពេញ ស្ដីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរឥណទានថវិកា, អភិបាល នៃគ-ណៈអភិបាលខណ្ឌចំការមន ត្រូវទទួលបន្ទុកជាអាណាប័កផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងឥណទានថវិកា របស់រដ្ឋបាលខណ្ឌចំការមន។ ឥណទានថវិការបស់រដ្ឋបាលខណ្ឌចំការមន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩រួមមាន៖

- សរុបចំណូលៈ ៥,២៥៣,០០០,០០០រៀល (ក្នុងនោះចំណូលឧបត្ថម្ភពីថវិការាជធានី
- ៥,០០០,០០០,០០០រៀល និងចំណូលលើសេវា រដ្ឋបាល ២៥៣,០០០,០០០រៀល។
- សរុបចំណាយៈ ៥,២៥៣,០០០,០០០ រៀល។

**តារាង ការអនុវត្តចំណូល និងចំណាយ**

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ផ្នែកចំណូល | | | | |
| ៧០ | ចំណូលសារពើពន្ធ | | | |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | | | |
| ៧៣ | ផលទុនលើការលក់-ជួល ទ្រព្យសម្បត្តិ និងសេវា | ២៥៣,០០០,០០០រ | ២៤០,៩០៣,៦២០រ | ៩៥.២២% |
| ៧៤ | ផលពីការពិន័យ និងការ ដាក់ទណ្ឌកម្ម | | | |
| ៧៥ | ការឧបត្ថម្ភកធន | ៥,០០០,០០០,០០០រ | ៥,០០០,០០០,០០០ រ | ១០០% |
| ៧៦ | ផលហិរញ្ញវត្ថុ | | ៥,១០០,១០០រ | ០០.០% |
| ៧៧ | ផលផ្សេងៗ និងផល ពិសេស | | | |

[17]-របាយការណ៍បូកសរុបលទ្ធផលការងាររដ្ឋបាលខណ្ឌចំការមនប្រចាំឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ៧៨ | ការងារនៃរដ្ឋទេយ្យ | | | |
| ០៨ | ចំណូលមូលនិធិបម្រុង | | | |
| ១៣ | ឧបត្ថម្ភកធន-វិនិយោគ | | | |
| សរុបចំណូល | | ៥,២៥៣,000,000៛ | ៥,២៤៦,00៣,៦២0៛ | ៩៩.៨៧% |
| ផ្នែកចំណាយ | | | | |
| ៦0 | ការទិញ | ២0១,000,000៛ | ១៧១,២0៤,២៦0៛ | ៨៥.១៨% |
| ៦១ | សេវាខាងក្រៅ | ២,0៣៧,៦00,000៛ | ២,២៩១,0៧២,៣00៛ | ១១២.៤៤% |
| ៦២ | សេវាខាងក្រៅផ្សេងៗ | ១១0,000,000៛ | ១0៩,១៨៧,000៛ | ៩៩.២៦% |
| ៦៣ | ពន្ធ និងអាករ | | | |
| ៦៤ | បន្ទុកបុគ្គលិក | ២,៦៤២,៤00,000៛ | ២,៥៥៥,៣៨0,៦២0៛ | ៩៦.៧១% |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | | | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | | | |
| ៦៧ | បន្ទុកពិសេស | | | |
| ៦៨ | ទាយជ្ជទានឱ្យដល់រម្លស់អចលកម្មរូបី | | | |
| 0៩ | ចំណាយមិនបានគ្រោងទុក | ២៦២,000,000៛ | - | |
| ២0 | អចលកម្មអរូបី | | | |
| ២១ | អចលកម្មរូបី | | | |
| សរុបចំណាយ | | ៥,២៥៣,000,000៛ | ៥,១២៦,៨៤៤,១៨0៛ | ៩៧.៦0% |

### ❖ ការគ្រប់គ្រងទ្រព្យសម្បត្តិ

ឆ្នាំ២០១៩ រដ្ឋបាលខណ្ឌចំការមន បានទិញសំភារៈមួយចំនួនសម្រាប់ប្រើប្រាស់ ដូចជា៖ កៅអីជ័រ១៤៤ កៅអី(៣៦x៤=១៤៤) និងម៉ាស៊ីនព្រីន ៣គ្រឿង។

**តារាង ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | ១៤៧ |
| ២ | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | 0 |
| ៣ | ទ្រព្យសម្បត្តិ សរុប | 0 |

# ជំពូកទី៣

# សមិទ្ធផលការងារសម្រេចបានពីឆ្នាំ ២០១៨-២០១៩

## ផ្នែកទី១ ៖ សេវាសាធារណៈដែលផ្ដល់ដោយសាលាខណ្ឌ

### ក.ការងារអត្រានុកូលដ្ឋាន

សាលាខណ្ឌចំការមនបានរៀបចំក្នុងការត្រួតពិនិត្យ និងអនុវត្តការងារស្ថិតិ និងអត្រានុកូលដ្ឋាននៅខណ្ឌរបស់ខ្លួនដោយមានការិយាល័យរដ្ឋបាលជាអ្នកទទួលខុសត្រូវ និងមានផ្នែកហិរញ្ញវត្ថុសេនាធិកាដែលមានភារៈកិច្ចខាងក្រោម៖

- ត្រួតពិនិត្យ និងបូកសរុបស្ថិតិប្រជាពលរដ្ឋ ដែលស្ថិតនៅក្រោមការគ្រប់គ្រង់របស់សាលាខណ្ឌ និងត្រូវធ្វើរបាយការណ៍ទៅសាលារាជធានីតាមពេលវេលាកំណត់។
- បូកសរុបស្ថិតិប្រជាពលរដ្ឋដែលបានចុះសៀវភៅអត្រានុកូលដ្ឋានគ្រប់ប្រភេទដែលមានប្រចាំខែនីមួយៗ ដើម្បីផ្ញើរជូនទៅការិយាល័យរដ្ឋបាលខណ្ឌ និងមន្ត្រីអត្រានុកូលដ្ឋាននៃទីចាត់ការរបស់សាលាខណ្ឌ រៀងរាល់១០ ថ្ងៃក្នុងខែបន្តបន្ទាប់។

**ការចម្លងសបុត្រអត្រានុកូលដ្ឋានឆ្លងឆ្នាំអនុវត្តបាន**

| លរ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្ដីចម្លងសបុត្រកំណើត | ៤៩៣ |
| ២ | សេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត | ២៥៥៨ |
| ៣ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៣៣៦ |
| ៤ | សេចក្ដីចម្លងសំបុត្រមរណភាព | ៤១ |

### ខ. ការិយាល័យច្រកចេញចូលតែមួយ

ការិយាល័យច្រកចេញចូលតែមួយខណ្ឌចំការមន បានផ្ដល់សេវាជូនប្រជាពលរដ្ឋ ពីខែមករា ដល់ខែធ្នូ ឆ្នាំ ២០១៩ បានចំនួន ៣៣,៧៧៦ ប្រជាពលរដ្ឋមកទទួលសេវាបានចំនួន ៣៥,៦៥១នាក់ ស្រី ៤,៤៧២នាក់, ចំណូលសរុបចំនួន ២០៤,៩២៧,២០០រៀល។

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេវាសរុបដែលបានផ្ដល់ចប់សព្វគ្រប់ | ៣៣,៧៧៦ |
| ២ | ប្រជាពលរដ្ឋសរុបដែលបានទទួលសេវា | ៣៥,៦៥១ |

| | | |
|---|---|---|
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានទទួលសេវា | ៤,៤៧២ |
| ៤ | ចំណូលដែលទទួលបានពីការផ្តល់សេវា | ២០៤,៩២៧,២០០ |
| ៥ | ករណីបណ្តឹងដែលទទួលបានសរុប | ០០ |
| ៦ | ករណីបណ្តឹងដែលបានដោះស្រាយរួចជាស្ថាពរ | ០០ |

## ផ្នែកទី២៖ វិស័យសេដ្ឋកិច្ច

**សេដ្ឋកិច្ច** គឺជាកំម្លាំងចលករដ៏សំខាន់សំរាប់ការទទួលបាននូវភាពរីកចម្រើន។ ដើម្បីអភិវឌ្ឍន៍ និងគ្រប់គ្រង់ទឹកដីរបស់ខណ្ឌប្រកបដោយភាពរីកចម្រើនទៅបានសាលាខណ្ឌបានធ្វើនូវសកម្មភាពនានាជាច្រើនលើគ្រប់វិស័យ។ គ្រប់សកម្មភាពទាំងនោះ ត្រូវបានក្លាយទៅជាកត្តាយកចិត្តទុកដាក់ដោយមិនអាចខ្វះបានរបស់ សាលាខណ្ឌដែលត្រូវបំពេញកាតព្វកិច្ច និងភារកិច្ចក្នុងការបំពេញការងារទាំងនោះ ដើម្បីអោយមានដំណើរការល្អទៅមុខជានិរន្ត។

### ក.ការងារគមនាគមន៍ ភូមិបាល និងសំណង់

❖ **ការងារគមនាគមន៍**

បានជួសជុលផ្លូវ និងដាក់ប្រព័ន្ធលូ ក្នុងសង្កាត់ទាំង៥ ដែលជាគម្រោងរបស់មូលនិធិសង្កាត់រួមមាន៖

- សង្កាត់ទន្លេបាសាក់
  - ច្រកផ្លូវភូមិ៧ ចាក់បេតុង ៤៥,៥ម x ២,៥ម លទ្ធផលសម្រេចបាន ១០០%
  - ច្រកផ្លូវភូមិ១២ ចាក់បេតុង ២១៩ម x ៤ម លទ្ធផលសម្រេចបាន ១០០%
  - ច្រកផ្លូវភូមិ១៦ ចាក់បេតុង ៣៣៦ម x ២,២៣១ម លទ្ធផលសម្រេចបាន ១០០%
  - បានដាក់លូច្រកផ្លូវភូមិ៧ ទំហំ ៦០០មម ប្រវែង ៤៤ម លទ្ធផលសម្រេចបាន ១០០%
  - បានដាក់លូច្រកផ្លូវភូមិ១២ ទំហំ ៦០០មម ប្រវែង ១៤៨ម លទ្ធផលសម្រេចបាន ១០០%
  - បានដាក់លូច្រកផ្លូវភូមិ១៦ ទំហំ ៥០០មម ប្រវែង ៣៣៧ម លទ្ធផលសម្រេចបាន ១០០% ។
- សង្កាត់ទួលទំពូងទី២
  - ច្រកផ្លូវ៤៦០ ទីតាំងផ្លូវលេខ១៦៣ ដល់ផ្លូវលេខ ១៦៧ ដាក់លូទំហំ ៦០០មម ប្រវែង ៤៧៤ម លទ្ធផលសម្រេចបាន ១០០% ។
- សង្កាត់ទួលទំពូងទី១
  - ច្រកផ្លូវ១២៣ ទីតាំងផ្លូវលេខ៤៦៨ ដល់ផ្លូវលេខ ៤៧៨ ចាក់បេតុង១៩១ម x ៧ម លទ្ធផលសម្រេចបាន ១០០% ។

- សង្កាត់បឹងត្របែក
  - ច្រកផ្លូវ៤៤០ ទីតាំងផ្លូវលេខ១០១ ដល់ផ្លូវទាល់ អ៊ុតកៅស៊ូ ១៣៨មx ៧,២ម លទ្ធផលសម្រេចបាន ១០០%
  - ច្រកផ្លូវ៤២៨ ទីតាំងផ្លូវលេខ១០៥ ដល់ផ្លូវលេខ ៩៥ អ៊ុតកៅស៊ូ ១៥៣មx ៦,២ម លទ្ធផលសម្រេចបាន ១០០%
- សង្កាត់ផ្សារដើមថ្កូវ
  - ច្រកផ្លូវ៤៣០ និង ១០៣ ភូមិ១ ភូមិ២ និងភូមិ៤ ដាក់លូទំហំ ៥០០មម ប្រវែង៩៤៧ លទ្ធផលសម្រេចបាន១០០%

❖ **ការងារសុរិយោដីនិងភូមិបាល:**

- ចេញប័ណ្ណកម្មសិទ្ធិផ្ទះ ចំនួន ៤ប័ណ្ណ
- លក់ផ្តាច់កម្មសិទ្ធិចំនួន ចំនួន ៤ច្បាប់
- ចេញប័ណ្ណដី ចំនួន ៦៦ប័ណ្ណ
- លក់ផ្តាច់ប័ណ្ណដីចំនួន ចំនួន ៣២៣ច្បាប់
- ចេញប័ណ្ណសហកម្មសិទ្ធិ ចំនួន ០ប័ណ្ណ
- លក់ផ្តាច់សហកម្មសិទ្ធ ចំនួន ១,៩៥៧ច្បាប់
- អំណោយផ្តាច់កម្មសិទ្ធផ្ទះ ចំនួន ៤ច្បាប់
- កាន់កាប់និងសាងសង់ ចំនួន ៣៩ច្បាប់
- អំណោយផ្តាច់ប័ណ្ណដី ចំនួន ៧៥ច្បាប់
- ទុត្តិយាតាដី-ផ្ទះ ចំនួន ៣ច្បាប់
- អំណោយផ្តាច់សហកម្មសិទ្ធ ចំនួន ០ច្បាប់
- ទំនាស់ដី-ផ្ទះ ចំនួន ០ច្បាប់
- ការងារសាងសង់តាមការិយាល័យច្រក១នៅរដ្ឋបាលខណ្ឌ ចំនួន ៤៨ច្បាប់
- ការងារជួសជុលតាមការិយាល័យច្រក១នៅរដ្ឋបាលខណ្ឌ ចំនួន ២២ច្បាប់ ។

❖ **ការងារសំណង់**

- សំណង់ថ្មីមានច្បាប់ ចំនួន ៣៩ច្បាប់
- សំណង់ជួសជុលមានច្បាប់ ចំនួន ០ច្បាប់
- សំណង់ថ្មីគ្មានច្បាប់ ចំនួន ០ច្បាប់

- សំណង់ជួសជុលគ្មានច្បាប់ ចំនួន ០ច្បាប់
- សំណង់ថ្មីខុសប្លង់ ចំនួន ០ច្បាប់
- សំណង់ជួសជុលខុសច្បាប់ ចំនួន ០ច្បាប់
- ស្នើសុំជួសជុលទៅមន្ទីរ ចំនួន ០ច្បាប់

**ខ.ការងារសិប្បកម្ម ឧស្សាហកម្ម និងការងារពាណិជ្ជកម្ម**

❖ **ការងារសិប្បកម្ម ឧស្សាហកម្ម**

- រោងចក្រសរុបចំនួន ៣មូលដ្ឋាន ពលករសរុបៈ ២៤៥នាក់។
- សិប្បកម្មសរុបចំនួន ៣៨០មូលដ្ឋាន ពលករសរុបៈ ២២៩១នាក់។
- ចុះបញ្ជីនៅការិយាល័យច្រកចេញ-ចូលតែមួយសរុបៈ ២មូលដ្ឋាន។
- ចុះបញ្ជីនៅមន្ទីរសរុបៈ ៥មូលដ្ឋាន ថ្មីៈ ១មូលដ្ឋាន បន្តៈ ៤មូលដ្ឋាន។
- ចុះបញ្ជីនៅក្រសួងសរុបៈ ១មូលដ្ឋាន ថ្មីៈ ០មូលដ្ឋាន បន្តៈ ១មូលដ្ឋាន។
- យកផលិតផលពិនិត្យគុណភាពៈ ៩មូលដ្ឋាន ស្មើៈ ១១មុខផលិតផល។
- ស្រង់ស្ថិតិសិប្បកម្មចំនួនៈ ៤១មូលដ្ឋាន គ្មានច្បាប់អនុញ្ញាត។
- ចែកលិខិតជូនដំណឹងដល់ម្ចាស់សិប្បកម្មចំនួន ២ទីតាំង ( ធ្វើអធិការកិច្ចថ្នាក់មន្ទីរ )។
- ចុះណែនាំម្ចាស់សិប្បកម្មផលិតផលទឹកពិសារដបបោះពុម្ពខុសអក្ខរាវិរុទ្ធ ចំនួន ១មូលដ្ឋា
- ចុះណែនាំម្ចាស់សិប្បកម្មផលិតស្រាបៀរស្រស់អោយមកសុំចុះបញ្ជីចំនួន ១ មូលដ្ឋាន។
- សហការជាមួយមន្ទីរឧស្សាហកម្ម និងសិប្បកម្មចុះធ្វើអធិការកិច្ចសិប្បកម្មផលិតទឹកសុទ្ធ១លើក។
- សហកាជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះធ្វើអធិការកិច្ចរោងចក្រ ១លើក។
- ចុះយកផលិតផលទំនិញវេចខ្ចប់ ចំនួន ៨ទីតាំង ស្មើ ១៣មុខផលិតផល។
- ចុះពិនិត្យ និងផ្ទៀងផ្ទាត់រង្វាស់រង្វាល់ ទីតាំងស្ថានីយ៍ប្រេងឥន្ធៈ ចំនួន ១ស្ថានីយ៍ ស្មើ ២ទូ ស្មើ ៤ដៃបាញ់ប្រេង។

❖ **ការងារពាណិជ្ជកម្ម**

- .បានចុះជម្រុញទីតាំងអាជីវកម្ម-សេវាកម្មបើកថ្មី និងបន្តសុពលភាពនៅមន្ទីរពាណិជ្ជកម្មក្នុងឆ្នាំ ២០១៩ សរុបបានចំនួន ៣១៤ទីតាំង ក្នុងនោះមាន ៖
  - ថ្មីបានចំនួន ៧៥ទីតាំង
  - បន្តចំនួន ២៣៩ទីតាំង

- ការផ្តល់សេវាប្រកបអាជីវកម្មសេវាកម្មក្នុងការិយាល័យច្រកចេញចូលតែមួយ តាមផ្សារ ចំនួន ៦០២តូប
- បានសហការជាមួយមន្ត្រីកាំកុងត្រូលចុះត្រួតពិនិត្យសុវត្ថិភាពចំណីអាហារជាប្រចាំ។
- ចេញលិខិតអនុញ្ញាតតូបផ្សារចំនួន ៦០២តូប។

**គ. ការងារទេសចរណ៍**

➢ **រដ្ឋបាលខណ្ឌបានពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តិនានា៖**

- បានប្រជុំផ្សព្វផ្សាយបញ្ហាគ្រឿងញៀនបានសរុប ១លើក នៅសាលាខណ្ឌចំការមន មានអ្នកចូលរួមសរុបចំនួន ៧៨នាក់ ស្រី ១១នាក់។
- បានសហការដោះស្រាយបញ្ហាបង្កសម្លេងរំខាន ពីសំណាក់ទីតាំងអាជីវកម្ម ភោជនីយដ្ឋាន ខារ៉ាអូខេ និងក្លឹបឌីស្កូតែក ជាប្រចាំ។
- បានសហការផ្សព្វផ្សាយ និងចលនាម្ចាស់ភោជនីយដ្ឋាន អាហាដ្ឋាន ចូលរួមប្រឡងប្រណាំងភោជនីយដ្ឋានស្អាត។
- បានសហការជាមួយសង្កាត់ទាំង៥ ក្នុងការចុះស្រង់ស្ថិតិធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ២០១៩។

➢ **ការងារគ្រប់គ្រងមូលដ្ឋានអាជីវកម្ម៖**

- ការចេញអាជ្ញាប័ណ្ណដោយរដ្ឋបាលខណ្ឌចំការមន (ការិយាល័យច្រកចេញចូលតែមួយ) បានសរុបចំនួន ៨៧ទីតាំង ក្នុងនោះរួមមាន ៖
  - ស្នើសុំអាជ្ញាប័ណ្ណថ្មី ចំនួន ៣៣ទីតាំង
  - ស្នើសុំបន្តអាជ្ញាប័ណ្ណ ចំនួន ៥២ទីតាំង
  - ស្នើសុំបិទអាជីវកម្ម ចំនួន ២ទីតាំង

➢ **ការងារពង្រឹងការកត់ត្រាភ្ញៀវស្នាក់នៅ តាមសណ្ឋាគារ ផ្ទះសំណាក់៖**

- ចុះត្រួតពិនិត្យការកត់ត្រា អត្តសញ្ញាណភ្ញៀវស្នាក់នៅតាម សណ្ឋាគារ ផ្ទះសំណាក់។
- ចូលរួមវេទិកាសាធារណៈតាមសង្កាត់ទាំង៥អំពីភូមិ-សង្កាត់មានសុវត្ថិភាពបានចំនួន១២លើក។

➢ **ការងារទីក្រុងស្អាត រមណីយដ្ឋានសោភា៖**

- ចូលរួមប្រជុំផ្សព្វផ្សាយ និងជូនដំណឹងបបមដល់សង្កាត់ទាំង៥ អំពីគោលការណ៍ថ្មីរបស់សាលារាជធានីភ្នំពេញ អំពីការប្រឡងប្រណាំងខណ្ឌស្អាត សង្កាត់ស្អាត កិច្ចការនេះសាលារាជធានីភ្នំពេញ បានកំពុងបង្កើតយន្តការដើម្បីប្រឡងប្រណាំង។

- សហការផ្សព្វផ្សាយ និងចូលរួមយុទ្ធនាការ បរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ទីក្រុង សរុប ១២ លើក។
- សហការជាមួយសង្កាត់ទាំង៥ ចុះណែនាំ និងយុទ្ធនាការដល់ម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន អំពីគ្មានសំរាមក្រដាស។
- ចុះជម្រុញមូលដ្ឋានអាជីវកម្ម សណ្ឋាគារ ឱ្យចូលរួមប្រឡងប្រណាំងធុរកិច្ចបៃតងចំនួន ៦ទីតាំង។
- សហការជាមួយមន្ទីរ ចុះត្រួតពិនិត្យ និងណែនាំម្ចាស់គ្រប់គ្រងអាជីវកម្ម អំពីការដាក់តាំងស្លាកយីហោអាជីវកម្មឲ្យបានត្រឹមត្រូវអនុលោមតាមសារាចរណ៍ណែនាំលេខ ០០៤ របស់ក្រសួងទេសចរណ៍បានចំនួន ២កន្លែង។
- ចូលរួមកម្មវិធីរើសសំរាមតាមកន្លែងសាធារណៈនានាចំនួន ៦គោលដៅ ក្រោយថ្ងៃព្រះរាជពីធីបុណ្យអុំទូក រៀបចំដោយរដ្ឋបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាព ឯកឧត្តម ហួត ហៃ អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ តំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម ឃួង ស្រេង អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។

**ផ្នែកទី៣៖ វិស័យសង្គមកិច្ច**

- ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយមន្ទីរសអយ និងអជ្ញាធរមូលដ្ឋានប្រមូលជនអនាថាតាមដងផ្លូវសាធារណៈ និងស្តុបនៅក្នុងខណ្ឌចំការមន សរុបទាំងអស់បានចំនួន ៣៤នាក់ ស្រី ១៤នាក់ បញ្ជូនទៅមន្ទីរអប់រំណែនាំ។
- នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានអញ្ជើញសមាគមអតីត ចូលរួមអបអរសាទរខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ចំនួន ១៣នាក់ នៅសាលារាជធានីភ្នំពេញ ក្នុងមួយនាក់ទទួលបានថវិកា ចំនួន ៥០,០០០រៀល (ប្រាំម៉ឺនរៀលគត់)។
- នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌចំការមនបានអញ្ជើញមនុស្សចាស់តាមសង្កាត់នីមួយៗក្នុងមួយសង្កាត់ ៣នាក់ សរុប ១៥នាក់ អោយចូលរួមអបអរសាទរទិវាមនុស្សចាស់អន្តរជាតិលើកទី២១ ក្រោមប្រធានបទ "គាំទ្រសុខុមាលភាពមនុស្សចាស់ គឺជាកត្តាសំខាន់ក្នុងការអនុវត្តប្រព័ន្ធគាំពារសុខុមាលភាពមនុស្សវ័យ ចាស់ គ្រប់វិស័យក្នុងសង្គមជាតិនៅកម្ពុជា" ក្រោមគណៈអធិបតីភាពឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ក្នុងនោះមនុស្សចាស់ចូលរួមទទួលបានថវិកាក្នុងមួយនាក់ ៥០,០០០រៀល (ប្រាំម៉ឺនរៀលគត់)។
- នៅថ្ងៃទី៣-៦ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យ ស អ យ ខណ្ឌបានសហការណ៍ជាមួយ លោកស្រី

គ្រួច ស៊ីថូ អធិការរងខណ្ឌចំការមន បានចូលរួមសកម្មភាព ដឹកជញ្ជូនសមាជិកសមាគមអតីតយុទ្ធជនកម្ពុជារាជធានីភ្នំពេញ ទៅទទួលយក ផ្ទះ-ដី សប្បទានសង្គមកិច្ចនៅភូមិបាក់វែក ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ចំនួន ៨៩នាក់ ក្នុងនោះខណ្ឌចំការមនចំនួន ៥នាក់ សរុបគ្រួសារទាំងអស់គ្នាដែលត្រូវទៅនោះចំនួន ២៦៥គ្រួសារ។

នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរងខណ្ឌចំការមន បានអញ្ជើញគ្រួសារអតីតយុទ្ធជនចំនួន ៨នាក់ចូលរួមសំណេះសំណាលជាមួយ ឯកឧត្តមនាយឧត្តមសេនីយ៍ គង់ គីម ទេសរដ្ឋមន្ត្រី និងជាអនុប្រធានសមាគមអតីតយុទ្ធជនកម្ពុជា នៅវិមានឈ្នះឈ្នះ គ្រួសារអតីតយុទ្ធជនអាស៊ាន ក្នុងមួយនាក់ទទួលបានអង្ករ ២០គីឡូក្រាម, ទឹកត្រី ១យួរ, ទឹកស៊ីអ៊ីវ ១យួរ, ប៊ីចេង ១កញ្ចប់, ស្ករស១កញ្ចប់, ត្រីខ ១០កំប៉ុង, មុង ១, ភួយ ១ និងថវិកា ២០ ម៉ឺនរៀល (ម្ភៃម៉ឺនរៀលគត់)។ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរងខណ្ឌចំការមន និងលោក សុខ ច័ន្ទវណ្ណៈ ប្រធានភូមិភាគពិសេសខណ្ឌចំការមន បានចូលរួមបើកប្រាក់ធានារ៉ាប់រងសង្គម១២ខែ ដល់គ្រួសារសពអតីតយុទ្ធជនចំនួន ៥គ្រួសារ រួមមាន៖

១.សំ គុន

២-ធីម សាវីន

៣-អ៊ុក ណែត

៤-ស្រី សំអេង

៥-អ៊ូច ស៊ន

- នៅផ្ទះលេខ១២៩ ផ្លូវសុធារស ភូមិ៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។
- នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរងខណ្ឌ យោធាខណ្ឌ កងរាជអាវុធហត្ថខណ្ឌចំការមន ក្រុមប្រឹក្សាសង្កាត់ទួលទំពូងទី២ នាយរងប៉ុស្តិ៍ និងប្រធានភូមិ បាននាំយកថវិកាមរណៈសង្គ្រោះចំនួន ៤,000,000រៀល (បួនលានរៀលគត់) ទៅប្រគល់ជូនគ្រួសារសពលោកស្រី អ៊ូច ស៊ន នៅផ្ទះលេខ ១អា ផ្លូវលេខ ១៦៧ ភូមិ៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

### ក.ការងារសុខាភិបាល និងការងារវប្បធម៌ និងវិចិត្រសិល្បៈ

- **ការងារសុខាភិបាល**

| | |
|---|---|
| – ការពិនិត្យផ្ទៃពោះសរុប | ចំនួន ៥,៧៥៣នាក់ |
| – ការសំរាលកូនសរុប | ចំនួន ១០៣នាក់ |

- ការផ្តល់ជាតិដែក៩០គ្រាប់មុនសំរាល ចំនួន ២,៤៤៩នាក់
- ចំនួនកុមារចាក់ថ្នាំបង្ការគ្រប់មុខ ចំនួន ២,២៨៦នាក់
- ស្ត្រីមានផ្ទៃពោះចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង ចំនួន ១,០៣៤នាក់
- ស្រីអាយុ១៥-៤៤ឆ្នាំចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង ចំនួន ២,២៩១នាក់
- តាមដានជាប្រចាំករណីមាតាស្លាប់និងទារកស្លាប់ក្រោម២៨ថ្ងៃ ចំនួន ០លើក
- តាមកដានជាប្រចាំករណីជម្ងឺផ្សេងៗ ចំនួន ០លើក
- ប្រជុំពង្រឹងការងារគាំពារមាតានិងទារក-កុមារ ចំនួន ២៤ដង
- ផ្តល់ថ្នាំមេបង់ដាហ្សុលដល់សិស្សានុសិស្ស ចំនួន ៣៨,៩៦៦គ្រាប់

❖ **ការងារវប្បធម៌ និងវិចិត្រសិល្បៈ**

- សហការរួមជាមួយមន្ត្រីបេតិកភ័ណ្ឌ និងមន្ត្រីសង្កាត់ ចុះស្រង់ទិន្នន័យ និងជំរុញទីតាំងចម្លាក់ឈើជាក្បាច់រចនាបទខ្មែរឱ្យមកធ្វើច្បាប់អាជីវកម្ម។
- រួមសហការជាមួយមន្ត្រីសង្កាត់ចុះស្រង់ទិន្នន័យតាមសង្កាត់។
- បានចេញលិខិតអនុញ្ញតដោយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈបានចំនួនៈ
  - ថ្មីចំនួន ៤ទីតាំង
  - បន្តចំនួន ១៤ ទីតាំង
- បានចេញលិខិតអនុញ្ញាតដោយការិយាល័យច្រកចេញចូលតែមួយបានចំនួនៈ
  - ថ្មីចំនួន ៤ទីតាំង
  - បន្តចំនួន ៦ទីតាំង

## ខ. ការងារកិច្ចការនារី និងការងារបណ្តុះបណ្តាលវិជ្ជាជីវៈ

❖ **ការងារកិច្ចការនារី**

- ចុះស្រង់ទិន្នន័យការងារសេវាសង្គមតាមសង្កាត់ទាំង៥ ក្នុងខណ្ឌចំការមនបានចំនួន ១២លើក
- ចូលរួមប្រជុំរបស់ គ.ក.ន.ក តាមសង្កាត់ទាំង៥ បានចំនួន ១២លើក
- រៀបចំការប្រជុំរបស់ គ.ក.ស.ក បានចំនួន ១២លើក
- ឧបសម្ព័ន្ធ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣ ១២លើក
- នារីខណ្ឌចូលរួមផ្សព្វផ្សាយ និងសហការណ៍ជាមួយ គ.ក.ន.ក និងអង្គការជួយស្ត្រី-កុមារក្រីក្រគ្មានគោលដៅនៅតាមសង្កាត់ ឬ សហគមន៍ នានាដូចជាៈ

- ស្រង់ការធ្វើបច្ចុប្បន្នភាពស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិក្នុងខណ្ឌ សង្កាត់ ក្រុមប្រឹក្សា ប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ជូនទៅមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ។
- កិច្ចការនារី ខណ្ឌចំការមនចូលរួមកម្មវិធីសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់សង្កាត់-ខណ្ឌ ឆ្នាំ២០១៩ នៅវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានីផ្សារដើមថ្កូវ
- គ.ក.ន.ក សង្កាត់ ធ្វើសំបុត្រកំណើតឱ្យគ្រួសារក្រីក្រចំនួន ៣គ្រួសារ
- គ.ក.ន.កសង្កាត់ និងអង្គការរ៉ាក់ចុះស្រាវជ្រាវរកជម្ងឺរបេង ក្នុងសហគមន៍បានចំនួន ៩នាក់ ស្រី ៣នាក់
- គ.ក.ន.កសង្កាត់ និងអង្គការមិត្តសំឡាញ់ ការប្រើប្រាស់គ្រឿងញៀន អំពើហិង្សាទាក់ទង និងយេនឌ័រ នៅសហគមន៍ផ្សារដើមថ្កូវ បានចំនួន ១៤៧នាក់ ស្រី ៧៣នាក់។
- ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះ ឱ្យទៅពិនិត្យពោះយ៉ាងតិចអោយបាន ២ដង មុនសម្រាលចំនួន ២៤នាក់
- អង្គការ S.H.C.C ផ្សព្វផ្សាយដល់គ្រួសារក្រីក្រស្លាប់ ក្នុងសពមួយស្មើ ៤0ដុល្លាស្មើចំនួន ៣នាក់ លេខទំនាក់ទំនងរបស់អង្គការ S.H.C.C : ០១២ ២៧០ ១៧១ ។
- កិច្ចការនារីខណ្ឌ ស្រង់ទិន្នន័យការធ្វើបច្ចុប្បន្នភាព ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិ មានក្រុមប្រឹក្សាខណ្ឌ មន្ត្រីថ្នាក់ខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិជូនទៅមន្ទីរកិច្ចការនាទីរាជធានីភ្នំពេញ។
- កិច្ចការនារីខណ្ឌ សហការណ៍ជាមួយ គ.ក.ន.ក សង្កាត់ទាំង៥ ស្រង់ទិន្នន័យអំពើហិង្សា ការរំលោភសេពសន្ថវ នៅក្នុងខណ្ឌចំការមនបានចំនួន ៥ករណីជូនមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ។
- គ.ក.ន.ក សង្កាត់ទន្លេបាសាក់ សហការណ៍ជាមួយអ្នកស្ម័គ្រចិត្តភូមិ ចូលរួមជាមួយគ្នានឹងមន្ទីរសុខាភិបាលផ្សព្វផ្សាយ ស្តីពីការដាក់កងក្នុងស្បូនដោយឥតគិតថ្លៃ។
- គ.ក.ន.ក សង្កាត់ចូលរួមសិក្ខាសាលាជាមួយ អង្គការអាក់សិនអេកកម្ពុជា នៅសណ្ឋាគារភ្នំពេញ រយៈពេល ២ថ្ងៃ។

❖ **ការងារបណ្តុះបណ្តាលវិជ្ជាជីវៈ**

មន្ទីរការងារចុះធ្វើអធិការកិច្ចការងារនៅតាមសហគ្រាសគ្រឹះស្ថានក្នុងខណ្ឌចំការមនបានចំនួន៥៨ទីតាំង

- បានចូលរួមប្រជុំប្រចាំខែនៅមន្ទីរការងារបានចំនួន ១២លើក
- បានចូលរួមសិក្ខាសាលាស្តីពីសន្តិសុខ និងហានិភ័យការងារនៅមន្ទីរការងារបានចំនួន ២ថ្ងៃ
- បានចូលរួមសិក្ខាសាលាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មករ នៅមន្ទីរការងារបានចំនួន ២ថ្ងៃ

- បានចូលរួមរៀនវគ្គបំប៉ន ច្បាប់ស្តីពីការងារបានចំនួន ៧ថ្ងៃ នៅក្រសួងការងារ
- បានចូលរួមប្រជុំក្រុមប្រឹក្សាខណ្ឌបានចំនួន ១២លើក
- បានចូលរួប្រជុំគណៈបញ្ជាការឯកភាពខណ្ឌ ១២លើក
- បានចូលរួមប្រជុំ គ.ក.ស.ក បានចំនួន ១២លើក
- បានចូលរួមវេទិការសាធារណៈរបស់ក្រុមប្រឹក្សាខណ្ឌ ១លើក។

**គ. ការងារពត៌មាន និងការងារធម្មការ និងសាសនា**

❖ **ការងារពត៌មាន**

- ជម្រុញម្ចាស់អាជីវកម្មរោងពុម្ពអោយធ្វើច្បាប់បន្តអាជីវកម្ម ដែលហួសសុពលភាពបានចំនួន ៧ មូលដ្ឋាន, បោះពុម្ពដៃនិងហ្វូតូកូពីបានចំនួន ៥០ទីតាំង។
- ជម្រុញម្ចាស់តូបកាសែតអោយបន្តច្បាប់អាជីវកម្មដែលហួសសុពលភាពបានចំនួន ៤១តូប។
- បិទរូបថតសកម្មភាពការងារថ្នាក់ដឹកនាំនៅបញ្ជោរព័ត៌មានសាលាខណ្ឌចំការមនបានចំនួន ៧២ សន្លឹក។
- ចុះណែនាំជាប្រចាំចំពោះម្ចាស់តូបលក់កាសែត អោយដាក់តាំងលក់សៀវភៅកាសែតសមស្រប តាមគោលការណ៍ច្បាប់ និងតាំងលក់ដូរមានសណ្តាប់ធ្នាប់តាម ការណែនាំរបស់អាជ្ញាធរ និងអោយបន្ត សុពលភាពច្បាប់ប្រចាំឆ្នាំបានចំនួន ៤៣តូប។
- ចុះជម្រុញដល់ម្ចាស់រោងពុម្ពអោយសុំបន្តច្បាប់អាជីវកម្មដែលហួសសុពលភាពបន្តទៀតបាន ចំនួន៤មូលដ្ឋាន។

❖ **ការងារធម្មការ និងសាសនា**

- បានសហការជាមួយសាលាអនុគណខណ្ឌ បានធ្វើស្ថិតិព្រះសង្ឃអាចារ្យ គណៈកម្មការ សិស្ស និស្សិត នៅតាមបណ្តាលវត្តដូចខាងក្រោមៈ
- វត្តមណិរតនារាមទួលទំពូង ព្រះសង្ឃសរុប ៩៤អង្គ អាចារ្យ គណៈកម្មការ ៨នាក់ តាជីយាយជី ៤ នាក់ សិស្សនិស្សិត ៧៥នាក់
- វត្តនួនមណីរាម ថាន់ ព្រះសង្ឃសរុប ៣៨០អង្គ អាចារ្យ គណៈកម្មការ ៨នាក់ តាជីយាយជី ១៩ នាក់ សិស្សនិស្សិត ១៣២នាក់
- វត្តប្រយុវង្ស ព្រះសង្ឃសរុប ១៤អង្គ អាចារ្យ គណៈកម្មការ ៦នាក់ តាជីយាយជី ៥នាក់ សិស្ស និស្សិត ៤នាក់
- វត្តស្វាយពពៃ ព្រះសង្ឃសរុប ៣៤អង្គ អាចារ្យ គណៈកម្មការ ១០នាក់ តាជីយាយជី ១០នាក់ សិស្ស

និស្សិត ៥៣នាក់

- ក្នុងនោះមានគោរម្យងារជាសម្តេច ៤ព្រះអង្គ ព្រះរាជគណៈចំនួន ៥អង្គ ព្រះគ្រូ ១អង្គ ចៅអធិការវត្តចំនួន ៨អង្គ
- បានសហការជាមួយសាលាអនុគណខណ្ឌចំការមន ព្រះចៅអធិការ អាចារ្យ គណៈកម្មការវត្តទួលទំពូងត្រៀម
- រៀបចំការប្រឡងធម្មវិន័យមណ្ឌលរាជធានីភ្នំពេញនៅសាលាបឋមសិក្សាវត្តទួលទំពូង នាថ្ងៃទី ៦ ខែមករា ឆ្នាំ២០១៩
- បេក្ខសមណសិស្សដែលបានដាក់ពាក្យប្រឡងសរុបចំនួន ១,២២៦អង្គ/នាក់ ចែកចេញជា ៣០បន្ទប់ក្នុងនោះមាន៖
  - ថ្នាក់ត្រី មានចំនួនសរុប ៦៤៣ អង្គ/នាក់
  - ថ្នាក់ទោ មានចំនួន សរុប ៣៥៦ អង្គ/នាក់
  - ថ្នាក់ឯក មានចំនួន សរុប ២២៧ អង្គ/នាក់
  - គណៈកម្មការប្រឡងចំនួន ៨៨អង្គ/នាក់
  - កម្លាំងសន្តិសុខការពារមណ្ឌលប្រឡងចំនួន ១១នាក់។
- ចូលរួមពិធីអបអរសាទរខួបលើកទី៤០ ទិវាជ័យជំនះ ៧មករា ១៩៧៩-២០១៩ នៅពហុកីឡា-ដ្ឋានជាតិអូឡាំពិក រាជធានីភ្នំពេញ ។
- ចូលរួមប្រជុំនៅសាលាគណៈនៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពសម្តេច ព្រះពុទ្ធជ័យមុនី ឃឹម-សន ព្រះមេគណៈរាជធានីភ្នំពេញ និងប្រធានមន្ទីរធម្មការ និងសាសនា។
- ចូលរួមពិធីប្រកាសប្រធានមន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ។
- ចូលរួមពិធីរៀបចំវេរទៀនវស្សាដល់វត្តទាំងបួន ក្នុងខណ្ឌចំការមន ដឹកនាំដោយលោក ថេង សុថុល អភិបាលខណ្ឌចំការមន និងក្រុមគ្រួសារ ព្រមទាំងមន្ត្រីរាជការសាលាខណ្ឌចំការមន សង្កាត់ទាំង ៥ និងផ្សារទាំង២។ ក្នុងនោះវត្តនីមួយៗទទួលបានទេយ្យទានមាន៖ សាដក២, ទៀន ១គូ, ស្ករស ២៥គីឡូក្រាម, អង្ករ ២បាវ, មី ១កេសធំ, ទឹកសុទ្ធ ១០កេស, ត្រីខ ១កេសធំ, បច្ច័យ ៦០ម៉ឺនរៀល ដោយឡែកវត្តទួលទំពូង បច្ច័យសរុប ៧៥៥,000៛ និង១០០ ដុល្លា
- សាសនាគ្រឹស្ទមានវិហារចំនួន៨ ប្រធាន និងគណៈកម្មការគ្រប់គ្រងវិហារចំនួន ៤០ នាក់បរិស័ទចំនួន ១,៥00នាក់។
- ព្រះវិន័យវង្សា ស៊ា ប៊ុនណាត ព្រះចៅអធិការវត្តមណរតនារាម (ទួលទំពូង)ព្រះសង្ឃ អាចារ្យ គណៈ-

កម្មការ សហការជាមួយការិយាល័យធម្មការ សាសនាខណ្ឌបានរៀបចំទេយ្យទានជូនដល់កាកបាទក្រហមកម្ពុជា និងអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមន ក្នុងនោះបានជួយថវិកាចំនួន៦,០០០,០០០រៀល និងគ្រឿងឧបភោគបរិភោគសរុបគិតជាថវិកាចំនួន១៩,៤៩៥,០០០ រៀល (សម្រាប់ទីស្នាក់ការកណ្តាល) និងថវិកា៣,០០០,០០០រៀល និងគ្រឿងឧបភោគបរិភោគសរុបគិតជាថវិកា ១០,០០០,០០០រៀល (សម្រាប់អនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌ)។

- ចូលរួមប្រជុំជាមួយ សាលាអនុគណៈខណ្ឌចំការមន ផ្នែកគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចមង្គលទេពាចារ្យព្រះចៅអធិការអចិន្ត្រៃយ៍វត្តស្វាយពពែ ត្រៀមរៀបចំពិធីសម្ពោធអន្តេវាសិកដ្ឋាន(កុដិ)។
- ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១៩ ពីធីសម្ពោធអន្តេវាសិកដ្ឋាន(កុដិ)វត្តស្វាយពពែ ក្រោមព្រះរាជាអធិបតីភាពសម្តេចព្រះកិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជណាចក្រកម្ពុជា និងលោកជំទាវ ញ៉េប រ៉ានី អ៊ិត សំហេង បានចូលរួមបច្ច័យក្នុងកម្មវិធីបុណ្យចំនួន១,៥០០ដុល្លារ និងលោក ចេង សុចុល អភិបាល នៃគណៈអភិបាលខណ្ឌចំការមន បានប្រគេនបច្ច័យចំនួន ១,០០០,០០០រៀល។
- បានសហការជាមួយសាលាអនុគណខណ្ឌចំការមន នាំទេយ្យទានគ្រឿងឧបភោគបរិភោគ និងថវិកា ប្រគេនដល់សាលាគណរាជធានីភ្នំពេញ មានដូចជា អង្ករ ៥បាវ, មី១០កេស,ទឹកក្រូច៥កេស, ទឹកសុទ្ធ ៥កេស, តែ ស្ករស ទឹកដោះគោមួយចំនួន និងថវិកាចំនួន ៧០០,០០០ រៀល។
- បានសហការជាមួយសាលាអនុគណខណ្ឌចំការមន នាំទេយ្យទានគ្រឿងឧបភោគបរិភោគ និងថវិកាយកទៅឧបត្ថម្ភដល់កងទ័ពនៅបញ្ជាការដ្ឋានបញ្ជូនសារកំបូល ដូចជា អង្ករ៥បាវ, មី១០កេស, ទឹកសុទ្ធ៥កេស,ទឹកក្រូច ៥កេស, ត្រីខ តែ ស្ករស ទឹកដោះគោ មួយចំនួន និងថវិកាចំនួន៥០០,០០០ រៀល។
- ចូលរួមប្រជុំត្រៀមបដិសណ្ឋារកិច្ច ឯកឧត្តម ប្រធានាធិបតី និងសម្តេចព្រះសង្ឃរាជប្រទេសស្រីលង្កា នៅសាលាអនុគណខណ្ឌចំការមន។
- ចូលរួមពិធីប្រកាសតែងតាំងមន្ត្រីសង្ឃសាលាគណរាជធានីភ្នំពេញនៅសាលសន្និសិទ្ធិចតុមុខ។
- ការិយាលយ័ធម្មការ និងសាសនាខណ្ឌបានចូលរួមប្រជុំប្រចាំខែរបស់ក្រុមការងារពង្រឹងសាសនារាជធានីភ្នំពេញ ក្រោមអធិបតិយភាព លោកជំទាវ ទូច សារ៉ុម ប្រធានក្រុមការងារ។
- ការិយាល័យធម្មការ និងសាសនាខណ្ឌបានចូលរួមផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគ្រឹស្ទសាសនាទូទាំងរាជធានីភ្នំពេញ ក្រោមអធិបតិយភាព ឯកឧត្តម សៀ សុភក្រ្ត រដ្ឋលេខាធិការ-

ក្រសួងធម្មការ និងសាសនានៅវិហារគ្រឹស្ត សែនសុខ។

- ការិយាល័យធម្មការ និងសាសនាសហការជាមួយសាលាអនុគណខណ្ឌចំការមន និងសាលាអនុគណខណ្ឌបឹងកេងកង បានទទួលរៀបចំធ្វើអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងរាជធានីភ្នំពេញ ក្រោមព្រះអធិបតីភាព សម្តេចព្រះពុទ្ធជ័យមុន្នី យឹម សន ព្រះមេគណរាជធានីភ្នំពេញ សម្តេចព្រះមហាអរិយវង្ស បណ្ឌិត សៅរ៍ ចន្ទថុល្ល សម្តេចព្រះឧត្តមចរិយា បណ្ឌិត ឃឹង ប៊ុនឈា សម្តេចព្រះសក្យមុន្នី វត្ន័ សារឿន និងលោកជំទាវ ទូច សារ៉ុម លោកប្រធានមន្ទីរធម្មការ និងសាសនា ក្នុងនោះ លោក ថេង សុថុល អភិបាល នៃគណៈអភិបាល ខណ្ឌចំការមន ក៏បានអញ្ជើញចូលរួមជាកិត្តិយសបានប្រគេនបច្ច័យចំនួនមួយលានរៀល នៅវត្តលង្កា។
- ការិយាល័យធម្មការនិងសាសនាសហការជាមួយសាលាអនុគណខណ្ឌចំការមនព្រះចៅអធិការអាចារ្យគណៈកម្មការ ប្រារព្ធពិធីបង្សុកូលថ្វាយព្រះវិញ្ញាណខន្ធព្រះសពសម្តេចព្រះធម្មលិខិត លាស់ ឡាយ នៅវត្តសន្សំកុសល។

## ផ្នែកទី៤ .ការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

### ក. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- **ការងារបង្ក្រាបសកម្មភាព លួច-ឆក់-ប្លន់គ្រប់ប្រភេទ ៖**

កើតឡើង ៤លើក, បង្ក្រាបបាន ៣លើក, ឃាត់ខ្លួន ១១នាក់ប្រុស, ស្លាប់ជនរងគ្រោះប្រុស ២នាក់ចិន, របួសស្រី ២នាក់ខ្មែរ (សង្កាត់ទន្លេបាសាក់ ៣លើក, បឹងត្របែក ១លើក)។

**បទល្មើសឧក្រិដ្ឋៈ**

កើតឡើង ៤លើក, បង្ក្រាបបាន ៣លើក, ឃាត់ខ្លួន ១១នាក់ប្រុស, ស្លាប់ជនរងគ្រោះប្រុស ២នាក់ចិន, របួសស្រី ២នាក់ខ្មែរ (សង្កាត់ទន្លេបាសាក់ ៣លើក, បឹងត្របែក ១លើក)។

- **ផ្ទុះគ្រាប់បែកៈ** ១លើក, សង្កាត់ទន្លេបាសាក់។
- **ឃាតកម្ម (ចាក់សម្លាប់-វាយសម្លាប់-ទម្លាក់ពីលើអាគារ)៖** ២លើក, សង្កាត់ទន្លេបាសាក់ ១លើកបង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ៥នាក់ ចិន, ស្លាប់ជនរងគ្រោះប្រុស ១នាក់ ជនជាតិ ចិន, បឹងត្របែក ១លើក បង្រាបបាន ១លើក ឃាត់ខ្លួនប្រុស ១នាក់ ខ្មែរ, ស្លាប់ប្រុស ១នាក់ ចិន និងរបួសស្រី ២នាក់ ខ្មែរ (អង្កេតស្រាវជ្រាវ)។
- **បង្ខាំងជំរិតទារប្រាក់ ៖** ១លើក សង្កាត់ទន្លេបាសាក់ ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ៥នាក់ (ជនសង្ស័យជនជាតិ ចិនតៃវ៉ាន់ ៤នាក់, ខ្មែរ ១នាក់)(ជនរងគ្រោះប្រុសចិនតៃវ៉ាន់១នាក់,ម៉ាឡេស៊ី៣នាក់)

+<u>សម្ភារៈខូចខាត</u>៖ បែកកញ្ចក់រថយន្ត ២ផ្ទាំង, កញ្ចក់បង្អួចខុនដូរ១ផ្ទាំង។

+<u>សម្ភារៈបាត់បង់</u>៖ ម៉ូតូ១គ្រឿង (របស់ជនរងគ្រោះ)។

+<u>វត្ថុតាងបន្សល់ទុកនៅកន្លែងកើតហេតុ</u>៖ស្លាបព្រាគ្រាប់បែក ១ លេខ 85Y3PIM-2 អំបែងគ្រាប់បែកមួយចំនួន។

+<u>វត្ថុតាងដកហូត</u>៖ រថយន្ត ១គ្រឿង, អាវុធខ្លី ១ដើម ម៉ាកប៉េអាកុល ៣បង់ មាន២០គ្រាប់ ( របស់ជនល្មើស )

**បទល្មើសមជ្ឈឹម៖** កើតឡើង ៦៤លើក បង្ក្រាបបាន ៦០លើក ឃាត់ខ្លួន ៨៥នាក់ ស្រី ២នាក់, របួសជនរងគ្រោះ ៧នាក់ ស្រី ១នាក់ (សង្កាត់ទន្លេបាសាក់ ៣៧លើក, ទួលទំពូង១. ១០លើក, ទួលទំពូង២. ៥លើក, បឹងត្របែក ៦លើក, ផ្សារដើមថ្កូវ ៦លើក)។

- **ឆក់កាបូប-ទូរស័ព្ទ៖** ២៦លើក, សង្កាត់ទន្លេបាសាក់ ១៨លើក បង្ក្រាប់បាន ១៦លើក ឃាត់ខ្លួនប្រុស ២៧នាក់,ទួលទំពូង១. ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៤នាក់, ទួលទំពូង២. ២លើក ប-ង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៤នាក់ (ព្រហ្មទណ្ឌកម្រិតស្រាលក្រុងបង្រាប ១ករណី), បឹងត្របែក ៣លើក បង្ក្រាបបាន ៣លើក ឃាត់ខ្លួនប្រុស ៤នាក់ (ស្លាប់ជនសង្ស័យម្នាក់នៅកន្លែងកើតហេតុ), ផ្សារដើមថ្កូវ ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ១នាក់ ។
- **លួចម៉ូតូ-ទូរស័ព្ទ-រថយន្ត-ខ្សែក-លុយ៖** ២៦លើក, សង្កាត់ទន្លេបាសាក់ ១៣លើក បង្ក្រាប់បាន ១២លើក ឃាត់ខ្លួន១៣នាក់ ស្រី ១នាក់ ,ទួលទំពូង១. ៦លើក បង្ក្រាបបាន៦លើក ឃាត់ខ្លួនប្រុស ៧នាក់, ទួលទំពូង២. ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនស្រី ១នាក់, បឹងត្របែក ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៣នាក់, ផ្សារដើមថ្កូវ ៤លើក បង្ក្រាបបាន ៤លើក ឃាត់ខ្លួនប្រុស ៥នាក់ ។
- **រំលោភទំនុកចិត្ត៖** ៦លើក, សង្កាត់ទន្លេបាសាក់ ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ២នាក់ , ទួលទំពូង១. ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ២នាក់, ទួលទំពូង២.១លើក បង្ក្រាបបាន

១លើក។

- ឃាត់ខ្លួនប្រុស ១នាក់, ផ្សារដើមថ្កូវ ១លើក បង្ក្រាបបាន១លើកឃាត់ខ្លួនប្រុស១នាក់ ។
- **ហិង្សាដោយចេតនា៖** ៦លើក, សង្កាត់ទន្លេបាសាក់ ៤លើក បង្ក្រាប់បាន ៣លើក ឃាត់ខ្លួនប្រុស ៩នាក់ (ចិន ១នាក់, ខ្មែរ ៨នាក់), ទួលទំពូង២. ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ២នាក់ (របួសជនរងគ្រោះប្រុស ១នាក់ចិន), បឹងត្របែក ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ១នាក់ (របួសជនរងគ្រោះ ២នាក់) ។

  + សម្ភារៈបាត់បង់៖ ទឹកប្រាក់ជាកញ្ចក់ទិញសំបុត្រយន្តហោះទៅដំណើរកំសាន្តទៅប្រទេសចិន សរុប ៤៦,៣១០ ដុល្លាអាមេរិក (ជនរងគ្រោះសរុប ១៣៣នាក់) និងលុយសុទ្ធសរុប ២,៨១០,៩១៥.៩

ដុល្លាអាមេរិក, រថយន្ត ១គ្រឿង, ម៉ូតូ ៤គ្រឿង, ទូរស័ព្ទ ៦គ្រឿង, លិខិតឆ្លងដែន ១ក្បាល (របស់ជនរងគ្រោះ)។

+ វត្ថុតាងដកហូត៖ រថយន្ត ១គ្រឿង, ម៉ូតូ ៣០គ្រឿង, កង់ ១គ្រឿង, ទូរស័ព្ទ ២៥គ្រឿង, លុយ ១,០០០ ដុល្លា អាមេរិក (របស់ជនរងគ្រោះ ប្រគល់ជូនម្ចាស់វិញ), ម្សៅក្រាមសថ្លា ១កញ្ចប់តូច, អាវុធខ្លី ២ដើម ,ម៉ូតូ ៤៦គ្រឿង, ទូរស័ព្ទ ១៤គ្រឿង, ដែកសំប៉ែត ២, ដំបង ១, សោរខ្សែ ១, កាំបិតប៉ុងតោ ១, រថយន្ត ២គ្រឿង គិតជាទឹកប្រាក់ ៩៥,២០០ ដុល្លាអាមេរិក និងលុយសុទ្ធសរុប ១,៦១២,០០០ ដុល្លាអាមេរិក (ដកហូតពីជនសង្ស័យ)។

➢ **ការទារបទ្រ្កាបគ្រឿងញៀន ៖**

កើតឡើង ៧៥លើក បង្ក្រាបបាន ៧៥លើក ឃាត់ខ្លួន ១២៤នាក់ ស្រី ១២នាក់(សង្កាត់ទន្លេបាសាក់ ៣៩ លើក, ទួលទំពូង១. ១០លើក, ទួលទំពូង២. ៣លើក, បឹងត្របែក ៥លើក និង ផ្សារដើមថ្កូវ ១៨លើក)។

- **ប្រើប្រាស់គ្រឿងញៀន៖** ៣២លើក សង្កាត់ទន្លេបាសាក់ ២១លើក បង្ក្រាបបាន ២១ ឃាត់ខ្លួន ៣៣នាក់ ស្រី ១នាក់, ទួលទំពូង១. ៥លើក បង្ក្រាបបាន ៥លើក ឃាត់ខ្លួនប្រុស ៨នាក់, បឹងត្របែក ២លើក ប-ង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ២នាក់ (ផ្នែកគ្រឿងញៀន-ព្រហ្មទណ្ឌខណ្ឌ ១ករណី), ផ្សារដើមថ្កូវ ៤លើក បង្ក្រាបបាន ៤លើក ឃាត់ខ្លួនប្រុស ៤នាក់ (ផ្នែកគ្រឿងញៀន បង្ក្រាប ១ករណី)។
- **រក្សាទុកគ្រឿងញៀន៖** ២៩លើក សង្កាត់ទន្លេបាសាក់ ១៣លើក បង្ក្រាបបាន ១៣លើក ឃាត់ខ្លួន ២៤ នាក់ ស្រី ៤នាក់ (កម្លាំងចម្រុះរឹតបន្តឹងច្បាប់ចរាចរណ៍ បង្ក្រាបបាន ១ករណី), ទួលទំពូង១. ៣លើក បង្ក្រាបបាន ៣លើក ឃាត់ខ្លួនប្រុស ៤នាក់, ទួលទំពូង២. ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៣នាក់, បឹងត្របែក ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៣នាក់, ផ្សារដើមថ្កូវ ៩លើក បង្ក្រាបបាន ៩លើក ឃាត់ខ្លួន ១៩នាក់ ស្រី ២នាក់ (ផ្នែកគ្រឿងញៀនបង្ក្រាប ១ករណី)។
- **ជួញដូរគ្រឿងញៀន៖** ១៤លើក សង្កាត់ទន្លេបាសាក់ ៥លើក បង្ក្រាបបាន ៥លើក ឃាត់ខ្លួន ១១នាក់ ស្រី១នាក់ (ផ្នែកគ្រឿងញៀនបង្ក្រាបបាន ១ករណី), ទួលទំពូង១. ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ០២នាក់ (ផ្នែកគ្រឿងញៀន-ព្រហ្មទណ្ឌ បង្ក្រាបបាន ១ករណី), ទួលទំពូង២. ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ១នាក់, បឹងត្របែក ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួន ៣នាក់ ស្រី ១ នាក់, ផ្សារដើមថ្កូវ ៥លើក បង្ក្រាបបាន ៥លើក ឃាត់ខ្លួន ៧នាក់ ស្រី ៣នាក់ (ផ្នែកគ្រឿងញៀនបង្ក្រាប ២ករណី)។

+ វត្ថុតាងដកហូត ៖ ម្សៅក្រាមសថ្លា ១៦២ កញ្ចប់ ( ៩ ធំ , ១៥៣ តូច ) , ថ្នាំគ្រាប់ ១ គ្រាប់, រថយន្ត

១គ្រឿង, ម៉ូតូ ៦៥ គ្រឿង, ម៉ូតូឡាំបាតា ៣គ្រឿង, កង់ ២គ្រឿង, រទេះអូស ៣គ្រឿង, ទូរស័ព្ទ ៥២ គ្រឿង, នាឡិកា ២គ្រឿង, លិខិតឆ្លងដែន ១ក្បាល, អត្ត ២សន្លឹក, ដែកសោរលេខប្រាំបីដប ២ដើម, កញ្ចក់រថយន្ត ២គូរ, លុយ-ឧបករណ៍ជក់ និងសម្ភារមួយចំនួន (របស់ជនល្មើស)។

បច្ចុប្បន្ន មនុស្ស រួមនិងវត្ថុតាង បញ្ជូនទៅតុលាការ។

➢ **ការងារបង្ក្រាបក្មេងទំនើង៖**

កើតឡើង ១៤លើក បង្ក្រាបបាន ១៤លើក ឃាត់ខ្លួន ២៦នាក់ ស្រី ១នាក់ របួសប្រុស ១នាក់ (សង្កាត់ទន្លេបាសាក់ ៩លើក, ទួលទំពូង១. ៣លើក និង ផ្សារដើមថ្កូវ ២លើក) ។

- **ប៉ុនប៉ងលួច៖** ៧លើក, សង្កាត់ទន្លេបាសាក់ ៣លើក បង្ក្រាបបាន ៣លើក ឃាត់ខ្លួនប្រុស ៥នាក់, ទួលទំពូង១. ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៣នាក់ និង ផ្សារដើមថ្កូវ ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួនប្រុស ៤នាក់។
- **ហិង្សាវាយគ្នាទៅវិញទៅមក៖** ៤លើក, សង្កាត់ទន្លេបាសាក់ ៤លើក បង្ក្រាបបាន ៤លើក ឃាត់ខ្លួនប្រុស ១០នាក់។
- **ទំនាស់ក្នុងគ្រួសារ៖** ១លើក, សង្កាត់ទួលទំពូង១. ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ១នាក់ របួសប្រុស ១នាក់។
- **ពាក់អាវមានសញ្ញា POLIC-ARMY៖** ២លើក, សង្កាត់ទន្លេបាសាក់ ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួន ៣នាក់ ស្រី ១នាក់ (អប់រំ-ធ្វើកិច្ចសន្យា ឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ)។

\+ ***សម្ភារខូចខាត៖*** បែកកញ្ចក់រថយន្ត២គ្រឿង (របស់ជនរងគ្រោះ)។

\+ ***វត្ថុតាងដកហូត៖*** ម៉ូតូ ១៧គ្រឿង, ឡាំប៉ាតា ១គ្រឿង, កង់ ២គ្រឿង, ទូរស័ព្ទ ៨គ្រឿង, កាំបិតប៉ុងតោ ៤, សោខ្សៀ ៣, ដែកសំប៉ែត ៥, ដែកកាប់ ៤, ដំបងឈើ ៣ដើម, កាបូប១, កញ្ចក់ឡាន ៣គូរ, កៅអីឈើ ១ និងសម្ភារមួយចំនួន (របស់ជនល្មើស)។

បច្ចុប្បន្នមនុស្ស រួមនឹងវត្ថុតាង បញ្ជូនទៅតុលារការ ។

❖ **ការងារបង្ក្រាបការលេងល្បែងស៊ីសង៖**

- កើតឡើង ៥លើក បង្ក្រាបបាន ៥លើក ឃាត់ខ្លួន ៦៣នាក់ ស្រី ២៤នាក់ (សង្កាត់ទន្លេបាសាក់ ៣លើក, ផ្សារដើមថ្កូវ ២ លើក)។
- **ហ្គេមបាញ់ត្រី៖** ៣លើក, សង្កាត់ទន្លេបាសាក់ ២លើក បង្ក្រាបបាន ២លើក ឃាត់ខ្លួន ៥០នាក់ ស្រី២១-

នាក់ (ព្រហ្មទណ្ឌកម្រិតស្រាលក្រុង បង្ក្រាប ១ករណី, សាលាខណ្ឌចំការមន បង្ក្រាប ១ករណី), ផ្សារដើមថ្កូវ ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួន ៦នាក់ ស្រី ២នាក់ ។

- **បៀរ៖** ២លើក, សង្កាត់ទន្លេបាសាក់ ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួនប្រុស ៣នាក់, ផ្សារដើមថ្កូវ ១លើក បង្ក្រាបបាន ១លើក ឃាត់ខ្លួន ៤នាក់ ស្រី ១នាក់ (អប់រំ និងធ្វើកិច្ចសន្យា រួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ) ។

វត្ថុតាងដកហូត៖ ទូរហ្គេមបាញ់ត្រី ១២ទូរ, ម៉ូតូ ៣គ្រឿង, ទូរស័ព្ទ ២៣គ្រឿង ,ចំណែកមនុស្ស ៣១នាក់ ប្រុស ១៨នាក់ បានធ្វើការអប់រំ-កិច្ចសន្យា រួចឱ្យត្រឡប់ទៅលំនៅដ្ឋានវិញ និងទូរហ្គេមបាញ់ត្រី ១១ទូរ រក្សាទុកនៅសាលាខណ្ឌចំការមន ។

➢ **ការខារគ្រោះថ្នាក់ចរាចរណ៍៖**

- កើតឡើង ១៦៨លើក, ស្លាប់ប្រុស ៦នាក់, រងរបួសធ្ងន់ ៩៧នាក់ ប្រុស ៧១នាក់ និងស្រាល ៥៤នាក់ ប្រុស ៤២នាក់, ខូចខាតម៉ូតូ ៩៣គ្រឿង,ខូចខាតរថយន្ត ១៥០គ្រឿង, ម៉ូតូកង់បី ៦គ្រឿង, ម៉ូតូឡាំប៉ាតា ៨គ្រឿង, រ៉ឺម៉ក់កង់បី ៤ គ្រឿង, ទ្វារផ្ទះ ២ផ្ទាំង, ក្បាលនាគ ១៩កង់ និងរបាំងថ្មចែកទ្រូងផ្លូវ ២៦កង់ , បង្កាន់ដៃដែកផ្លូវ ១ដើម, បង្កាន់ដៃស្ពាន ១ដើម,បង្គោលរបងស្ពានទូតរុស្ស៊ី ៣ដើម, បង្គោលផ្លាកសញ្ញា ៥ផ្ទាំង, បង្គោលភ្លើងបំភ្លឺផ្លូវ ២ដើម, បង្គោលភ្លើង ៤ដើម, ដើមឈើ ១ដើម។
- ផ្តើមពី៖ ល្បឿនលឿន ៨២ករណី, ខ្វះការប្រុងប្រយ័ត្ន ២០ករណី, បុកពីក្រោយ ៣ករណី, មិនគោរពផ្លាកសញ្ញា ៩ករណី, មិនគោរពសិទ្ធិស្តាំដៃ ៣២ករណី, មិនគោរពសិទ្ធិអាទិភាព ២ករណី, មិនគោរពភ្លើងស្តុប ៣ករណី, ស្រវឹង ៦ករណី, ដាច់ហ្វ្រាំង ១ករណី, វ៉ៃក្រោយខ្វះការប្រុងប្រយ័ត្ន ១ករណី។ ករណី ១២០លើក ខាងលើ បានប្រគល់ ឱ្យការិយាល័យចរាចរណ៍ផ្លូវគោកក្រុង និង ៤៨ករណីចាត់ការបន្ត នៅអធិការដ្ឋាននគរខណ្ឌចំការមន។

➢ **សភាពការណ៍គ្រោះថ្នាក់ដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះនិងវិធានការណ៍ដោះស្រាយ**

➢ នៅខណ្ឌចំការមនប្រជាពលរដ្ឋពុំមានរងគ្រោះដោយសារយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះទេ។

➢ **សភាពការណ៍ទប់ស្កាត់ គ្រប់គ្រងនិងឆ្លើយតបចំពោះគ្រោះមហន្តរាយប្រកបដោយប្រសិទ្ធិភាព**

➢ សាលាខណ្ឌ សង្កាត់ទាំង៥ និងផ្សារទាំង២ បានចេញសេចក្តីជូនដំណឹងប្រជាពលរដ្ឋ អាជីវករ ឱ្យយកចិត្តទុកដាក់ និងប្រុងប្រយ័ត្នគ្រោះថ្នាក់ដោយអគ្គិភ័យ។

➢ **អគ្គិភ័យ៖** ២៤លើក, ស្លាប់ប្រុស ១នាក់, របួសប្រុស ២នាក់, ឆេះផ្ទះ ១០ខ្នង និងឆេះបន្ទប់ជួល ១បន្ទប់, ខោ-អាវជជុះគីប អស់ប្រហែល ៧,០០០ដុំ, ខូចខាតទូរទឹកកក ១គ្រឿង, ឡាន ១គ្រឿង, ម៉ូតូ

៤គ្រឿង, ម៉ាស៊ីនបោកខោអាវ ១គ្រឿង, កង្ហារ ៥គ្រឿង, ពូង ១, ទូរទស្សន៍ ១គ្រឿង, ម៉ាស៊ីនភ្លើង១គ្រឿង, ម៉ាស៊ីនត្រជាក់ ២គ្រឿង, រទេះកាហ្វេ ១គ្រឿង, កុំព្យូទ័រ ៣គ្រឿង និងសម្ភារមួយចំនួន ក្នុងនោះប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ ១៤០គ្រឿង អស់ទឹក១៣៦គ្រឿង បំពង់ពន្លត់អគ្គីភ័យ៤៩បំពង់។

- **សភាពការណ៍ទប់ស្កាត់ ការត្រួតពិនិត្យខុសច្បាប់**
  - ក្នុងភូមិសាស្ត្រខណ្ឌចំការមន ពុំបានដាក់ប៉ុស្តិ៍ត្រួតពិនិត្យខុសច្បាប់ទេ។

❖ **ការងារបរិស្ថាន**

- **ការងារចុះពិនិត្យមើលសំរាម:**
  - បានចុះពិនិត្យមើល ការប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ិន ទ្រី តាមដងផ្លូវសំខាន់ៗ និងផ្លូវក្នុងចំនួន ២៤៩ លើក ឃើញថាគ្មានសំរាមកកស្ទះទេ រថយន្តក្រុមហ៊ុន ស៊ិន ទ្រី បានមកប្រមូលទាន់ពេលវេលា។
  - មានសំរាមកកស្ទះមួយរយៈ ដោយសារស្ទះនៅទីលាន និងកម្មករធ្វើពលកម្ម និងថ្ងៃបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ ដោយកម្មករទៅលេងស្រុកកំណើត។
- **ការងារត្រួតពិនិត្យការបំពុល:**
  - បានចុះសហការណ៍ជាមួយមន្ត្រីជំនាញ របស់មន្ទីរបរិស្ថាន ចុះដោះស្រាយបណ្តឹង របស់ប្រជាពលរដ្ឋដែលប៉ះពាល់សម្លេង និងក្លឹបបាន ១ករណី
  - ភោជនីយដ្ឋានភូមិគ្រឹះ ហ៊ា ផ្លូវលេខ ៤១០ សង្កាត់បឹងត្របែក
  - បានចុះសហការណ៍ជាមួយមន្ត្រីជំនាញរបស់មន្ទីរបរិស្ថាន ចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លិខិតបញ្ជាកែប្រែបាន ១ទីតាំង ៖
  - ទីតាំងក្លឹបភ្នំពេញស្ព័រ ផ្លូវលេខ ២៧១ សង្កាត់ទួលទំពូងទី២ ទីតាំងនេះបានកែប្រែទៅតាម លិខិតរបស់មន្ទីរបរិស្ថាន
  - បានចុះសហការណ៍ជាមួយរដ្ឋបាលរាជធានីភ្នំពេញ ចុះវាស់សម្លេងបាន ១ករណី
  - បានចុះសហការណ៍ជាមួយរដ្ឋបាលខណ្ឌចំការមន ចុះផ្អាកក្លឹប ម៉ែ អាមី ដែលបង្កផលប៉ះពាល់ដល់អ្នកជិតខាង
  - បានចុះសហការណ៍ជាមួយក្រុមការងាររបស់មន្ទីរបរិស្ថានរាជធានីភ្នំពេញចែកលិខិតណាត់ជួបដើម្បីត្រួតពិនិត្យ គុណភាពបរិស្ថាន និងច្បាប់បានចំនួន ១៩២ ទីតាំង
  - ចុះបានចំនួន ១៥៨ទីតាំង ក្នុងនោះ ១៦ទីតាំង បានយលព្រមធ្វើកិច្ចសន្យាការពារបរិស្ថាន។

- **ការងារអប់រំ**
  - បានសហការណ៍ជាមួយមន្ទីរបរិស្ថានរាជធានីភ្នំពេញ ចុះអប់រំ និងដើររើសសំរាមនៅ វិមានឈ្នះ-ឈ្នះ ២ថ្ងៃ
  - បានសហការណ៍ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់បានដាក់ប៉ាន់ណូ ២ផ្ទាក ចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋការទុកដាក់ និងវិចខ្ចប់សំរាមបាន ២លើកបានចំនួន ៣២២ខ្នងផ្ទះ
  - ចុះអប់រំផ្សព្វផ្សាយតាមសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ បានចំនួន ២០លើក មានលោកគ្រូ អ្នកគ្រូ សិស្ស ចូលរួមចំនួន ៦,៦៧២ នាក់
  - ចុះអប់រំតាមប្រលាយបានចំនួន ៦លើក មានអ្នកចូលរួម ២៩៦នាក់
  - ទិវាបរិស្ថាន អន្តរជាតិបានសហការណ៍ជាមួយ សង្កាត់ធ្វើយុទ្ធនាការ សម្អាតតាមផ្លូវក្នុងសង្កាត់ទន្លេបាសាក់ មាន  មន្ត្រីចូលរួមចំនួន ២៦២នាក់។
- **ការងារអតិរក្ស**
  - បានចុះពិនិត្យទីតាំងលក់វត្ថុអនុស្សាវរីយ៍ ដែលធ្វើពីសត្វព្រៃ ចំនួន ១៣ទីតាំង ក្នុងនោះ ៦ទីតាំងនៅក្នុងផ្សារទួលទំពូង មានលក់ ភ្លុក ធ្មេញ ស្នែងសត្វព្រៃ។

## ខ. គ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ

បំរែបំរួលអាកាសធាតុ និងគ្រោះមហន្តរាយ គឺជាបញ្ហាដែលយើងទាំងអស់គ្នាមិនអាចព្យាករណ៍ដឹងមុន ដូចនេះដើម្បីទប់ស្កាត់រាល់បញ្ហា ដែលកើតមានឡើងដោយថាហេតុរដ្ឋបាលខណ្ឌត្រូវមានផែនការដាក់លាក់ក្នុងការត្រៀមដោះស្រាយនូវបញ្ហាដែលបានកើតមាន និងជាពិសេសរដ្ឋបាលខណ្ឌត្រូវមានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយសម្រាប់ជួយដោះស្រាយនៅពេល ដែលជួបឧបទ្ទវហេតុកើតមានឡើងនៅពេលណាមួយជាចាំបាច់។

គ្រោះមហន្តរាយអាចកើតមានឡើងដោយកត្តាពីរគឺកត្តាធម្មជាតិ និងកត្តាមនុស្សដូច្នេះដើម្បីមានវិធានការទប់ស្កាត់លើគ្រោះមហន្តរាយទាំងអស់នោះរដ្ឋបាលខណ្ឌបានរៀបចំនូវវគ្គបណ្តុះបណ្តាលប្រជាពលរដ្ឋដូចជាៈ

- បានបង្កើតឱ្យមានគណៈកម្មការគ្រប់គ្រងគ្រោះមហន្តរាយ
- អប់រំប្រជាពលរដ្ឋអោយយល់ដឹងពីគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ
- ប្រជាពលរដ្ឋចូលរួម និងការពារទប់ស្កាត់គ្រោះអគ្គីភ័យដែលអាចកើតមានដោយយថាហេតុ
- អប់រំ និងណែនាំប្រជាពលរដ្ឋអោយចេះប្រើប្រាស់បំពង់ពន្លត់អគ្គីភ័យ
- ណែនាំប្រជាពលរដ្ឋអោយចេះថែរក្សាការពារបរិស្ថាន។

# សេចក្តីសន្និដ្ឋាន

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវ អំពីការគ្រប់គ្រងបុគ្គលិក និងសមិទ្ធផលសម្រេចបានរបស់រដ្ឋបាលខណ្ឌចំការមនរួចមក ក្រុមយើងខ្ញុំសង្កេតឃើញថា ការគ្រប់គ្រងបុគ្គលិករបស់រដ្ឋបាលខណ្ឌចំការមនមានដំណើរការប្រព្រឹត្តទៅយ៉ាងល្អប្រសើរ ស្របទៅតាមគោលការណ៍ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ រួមទាំងការអនុវត្តច្បាប់ សកម្មភាពការងាររបស់ក្រុមប្រឹក្សា របស់គណៈអភិបាល ក៏ដូចជាសកម្មភាពរបស់មន្ត្រីដែលបម្រើការងារនៅសាលាខណ្ឌ ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពការងារ ពិគ្រោះយោបល់ តម្លាភាព គណនេយ្យភាព សមធម៌ យុត្តិធម៌ អធ្យាក្រឹត្យភាព អ្វីដែលគួរឱ្យកត់សម្គាល់នោះគឺភាពល្អប្រសើរ និងប្រព្រឹត្តយ៉ាងរលូននៅក្នុងការផ្តល់សេវាជូនប្រជាពលរដ្ឋដែលមកទទួលយកសេវាសាធារណៈដែលផ្តល់ដោយខណ្ឌ ។

ជាក់ស្តែងនៅអំឡុងឆ្នាំ២០១៨ ~ ២០១៩កន្លងមកនេះ ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានីភ្នំពេញ ខណ្ឌចំការមនបានបន្តខិតខំជម្នះ ពុះពាររាល់ការលំបាកស្មុគស្មាញ និងអនុវត្តគ្រប់វិធានការការងារចាត់តាំងគោលនយោបាយភូមិ.សង្កាត់ មានសុវត្ថិភាពបានកាន់តែល្អ គ្រប់គ្រងបានសភាពការណ៍ សន្តិសុខនៅក្នុងខណ្ឌ ក្នុងនោះគួរអោយកត់សំគាល់សកម្មភាពបង្កចលាចលនយោបាយ និងអំពើភេរវកម្ម ត្រូវបានទប់ស្កាត់មិនអោយកើតមានអំពើប្លន់ប្រដាប់អាវុធ អំពើអានាចារ្យ អំពើអបាយមុខបង្កដោយក្រុមក្មេងទំនើង ល្បែងស៊ីសង និងគ្រឿងញៀន ត្រូវបានកាត់បន្ថយ ផ្តល់នូវភាពកក់ក្តៅដល់ប្រជាពលរដ្ឋ វិនិយោគិន និងភ្ញៀវបរទេស។ ម្យ៉ាងទៀតការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកជូនប្រជាពលរដ្ឋ និងរួមចំណែកធ្វើអោយករណីគ្រោះថ្នាក់ និងករណីកកស្ទះចរាចរណ៍ ត្រូវបានកាត់បន្ថយ ។ រដ្ឋបាលខណ្ឌបានខិតខំរៀបចំផែនការសកម្មភាពលម្អិត សន្ទស្សន៍ និងប្រតិទិនការងារតាមសង្កាត់នីមួយៗ ដើម្បីជម្រុញការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំផែនការស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០១៩, សភាពការណ៍ខាងលើនេះបានផ្តល់នូវកាលានុវត្តភាពដល់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអោយទទួលបានជោគជ័យ ពិសេសគឺការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សំណង់អគារខ្ពស់ៗ ធ្វើឱ្យខណ្ឌចំការមន កាន់តែមានសោភ័ណភាពស្រស់បំព្រងឡើងថែមទៀត និងបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ។

# អនុសាសន៍

បន្ទាប់ពីបានឆ្លងកាត់ការសិក្សាយ៉ាងច្រើនក្នុងពេលកន្លងមកទៅលើប្រធានបទ ក្រុមយើងខ្ញុំបានសង្កេតឃើញនូវ ចំណុចខ្វះខាតដែលជាគុណវិបត្តិមួយចំនួនទន្ទឹមនឹងលទ្ធផល ដែលសម្រេចបានជាវិជ្ជមានដូចដែលយើងខ្ញុំបានរៀបរាប់នៅក្នុងសេចក្តីសន្និដ្ឋានខាងលើផងដែរ។ ក្រុមយើងខ្ញុំយល់ឃើញថាសាលាខណ្ឌចំការមនគួរតែពិនិត្យទៅលើចំណុចខ្វះខាត និងកែលម្អឡើងវិញនូវចំណុចមួយចំនួនដូចជា ៖

- ដោយសារខណ្ឌទើបបែងចែកថ្មីៗហេតុនេះគួរតែស្នើសុំទៅក្រសួងដើម្បីផ្គត់ផ្គង់សម្ភារៈបច្ចេកទេសសម្រាប់អនុវត្តការងារនៅក្នុងសាលាខណ្ឌ និងការផ្តល់សេវាជូនប្រជាពលរដ្ឋ។
- រៀបចំក្តារព័ត៌មាន ដែលមានប្លង់ ទីតាំងការិយាល័យនានា និងគំនូសបំព្រួញបញ្ជាក់ពីតួនាទីខ្លះៗរបស់ការិយាល័យទាំងនោះ ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋដែលទៅទទួលយកសេវាសាធារណៈពីសាលាខណ្ឌ ។
- ជម្រុញការប្រកាន់ខ្ជាប់វប្បធម៌សេវាសាធារណៈ ឆន្ទៈ ម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីបម្រើការនៅក្នុងខណ្ឌ។
- ការរៀបចំវគ្គបង្កើនសមត្ថភាពមន្ត្រី ការបង្កើនការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសកម្មភាពការងាររបស់សង្កាត់នីមួយៗដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខណ្ឌ ដើម្បីធានាដល់ការអនុវត្តការងារប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។
- បង្កើនការផ្សព្វផ្សាយច្បាប់ ទាក់ទងនឹងចរាចរណ៍ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈឱ្យបានទូលំទូលាយ ធ្វើឱ្យប្រាកដថាប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន ដែលខ្លួនគ្រប់គ្រងបានយល់ដឹងពីច្បាប់ និងសេចក្តីណែនាំទាំងឡាយដែលសាលាខណ្ឌបានដាក់ចេញ។
- ពង្រឹងបន្ថែមឱ្យបានល្អ នូវការការពារតាមគោលដៅនីមួយៗដែលមានស្រាប់ ដើម្បីធានាថាអាជ្ញាធរដែលគ្រប់គ្រងនៅគោលដៅនីមួយៗអាចគ្រប់គ្រងបាននូវស្ថានការណ៍ទាំងអស់នៅតាមគោលដៅ ឬសង្កាត់ដែលខ្លួនប្រចាំការ។
- សាលាខណ្ឌគួរតែស្នើសុំទៅក្រុមហ៊ុន ស៊ិន ទ្រី លើការប្រមូលសំរាមឱ្យបានទៀងទាត់នឹងជាប្រចាំនៅតាមទីសាធារណៈជាពិសេសនៅតំបន់ទីប្រជុំជន ( ផ្សារ...)ជៀសវាងការធ្វើឱ្យទីក្រុងមានក្លិនមិនល្អនៅពេលមានភ្លៀងធ្លាក់ ក៏ដូចជាធ្វើឱ្យពិបាកក្នុងការធ្វើចរាចរណ៍ជាដើម។
- ចុះតាមមូលដ្ឋានដើម្បីផ្សព្វផ្សាយអប់រំដល់ប្រជាពលរដ្ឋទាក់ទងនឹងសន្តិសុខ សុវត្ថិភាព និងបញ្ហាបរិស្ថាន ( ជាពិសេសដល់ជនក្រីក្រ ស្ត្រី និង ជនដែលងាយរងគ្រោះ )។

# ឯកសារយោង

## ឯកសារគតិយុត្ត ៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- ច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឆ្នាំ ១៩៩៤
- ច្បាប់ស្ដីពីសញ្ជាតិ ឆ្នាំ២០១៨
- ច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨
- ព្រះរាជក្រឹត្យ លេខ ៣៧៣នស/រកត/០៤១៦ ចុះថ្ងៃ០៤ ខែមេសា ឆ្នាំ២០១៦ស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ០៣អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្ដីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជ-ធានីភ្នំពេញ
- អនុក្រឹត្យលេខ ៦៣ ចុះថ្ងៃទី០៨ ខែកញ្ញា ឆ្នាំ ២០០៣ ស្ដីពីការគ្រប់គ្រងការអនុវត្តន៍ការផ្លាស់ប្ដូរក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់របស់មន្ត្រីរាជការស៊ីវិល
- អនុក្រឹត្យលេខ ១១៤អនក្រ.បកចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២១០៥ ស្ដីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ។
- អនុក្រឹត្យលេខ ២៤០អនក្រ.បកចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្ដីពីការធ្វើប្រតិភូកម្មសិទ្ធអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ៥៦អនក្រ.បកចុះថ្ងៃ០១ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា
- សេចក្ដីណែនាំរបស់ក្រសួងមុខងារសាធារណៈលេខ ៧៨៩សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្ដីពីគោលការណ៍ និងបែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្ដីណែនាំរបស់ក្រសួងមុខងារសាធារណៈលេខ ២២០២ សណនចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤ ស្ដីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្ដូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ

## ឯកសារផ្សេងៗ និងឯកសារជាសៀវភៅ ៖

- វចនានុក្រមសម្ដេចព្រះសង្ឃរាជ ជួន ណាត
- របាយការណ៍ប្រចាំឆ្នាំ២០១៨ ~២០១៩ស្ដីពីលទ្ធផលការងាររដ្ឋបាលខណ្ឌចំការមន និងលើកទិសដៅ-

បន្តសម្រាប់ឆ្នាំ២០២០

- ការគ្រប់គ្រងរដ្ឋបាលខណ្ឌតាមបែបរិមជ្ឈការរបស់ក្រសួងមហាផ្ទៃ (សម្រាប់ក្រុមប្រឹក្សាខណ្ឌឆ្នាំ២០១៩)
- សៀវភៅណែនាំស្តីពីតួនាទីភារកិច្ច និងរបៀបរបបការងាររបស់រដ្ឋបាលខណ្ឌ ឆ្នាំ២០១០
- ឯកសារមេរៀនស្តីពីនីតិរដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- សៀវភៅណែនាំរបស់ក្រសួងមហាផ្ទៃ ស្តីពីកិច្ចការរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥
- មេរៀននីតិរដ្ឋបាល សាស្រ្តាចារ្យ យូ តូនី ឆ្នាំ២០១៩
- សៀវភៅសង្ខេបអំពីមុខងារសាធារណៈ សាស្រ្តាចារ្យ ឡាញ់ ដា ឆ្នាំ២០០៥~២០០៦ ។

**គេហៈទំព័រសំខាន់ៗ ៖**

- www.owso.gov.kh
- www.mcs.gov.kh
- www.km.m.wikipedia

# បញ្ជីឧបសម្ព័ន្ធ


| ល.រ | បញ្ជីរាយនាម | ទំព័រ |
|---|---|---|
| ១ | ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល ឆ្នាំ១៩៩៤ | ១ |
| ២ | ព្រះរាជក្រឹត្យ លេខ ៣៧៣នស/រកត/០៤១៦ ចុះថ្ងៃ០៤ ខែមេសា ឆ្នាំ២០១៦ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ | ២២ |
| ៣ | អនុក្រឹត្យលេខ ០៣អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ស្តីពីការបង្កើតខណ្ឌបឹងកេងកង នៃរាជធានីភ្នំពេញ | ៤១ |
| ៤ | អនុក្រឹត្យលេខ ៤៣អនក្រ.បកចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៩ស្តីពីការកែប្រែ និងដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល | ៤៣ |
| ៥ | អនុក្រឹត្យលេខ ៥៦អនក្រ.បកចុះថ្ងៃ០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងវត្តមានមន្ត្រីរាជការស៊ីវិល និងមន្ត្រីជាប់កិច្ចសន្យា | ៦០ |
| ៦ | សេចក្តីណែនាំរបស់ក្រសួងមុខងារសាធារណៈលេខ ២២០២ សណនចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីនីតិវិធីនៃការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ | ៧៥ |
| ៧ | របាយការណ៍បូកសរុបលទ្ធផលការងារប្រចាំឆ្នាំរបស់ខណ្ឌចំការមន | ៩៩ |
| ៨ | រចនាសម្ព័ន្ធខណ្ឌចំការមន | ១៥៤ |
| ៩ | ផែនទីខណ្ឌចំការមន | ១៥៥ |
| ១០ | តារាងអនុវត្តសកម្មភាពការងាររបស់រដ្ឋបាលខណ្ឌចាស់ ( ២០១៨ ) និងសមត្ថភាពគ្រប់គ្រងរដ្ឋបាលខណ្ឌថ្មី ( ២០១៩ ) | ១៥៦ |

នស/រកត/០៤១៦/៣៧៣

# ព្រះរាជក្រឹត្យ
## ស្ដីពី
## លក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា**
**សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ**
**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៣/០១២ ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីវិសោធនកម្មមាត្រា២៨នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្ដីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៦

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ក្រសួងព្រះបរមរាជវាំង

# ក្រោសបន្ទាប់
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ព្រះរាជក្រឹត្យនេះមានគោលបំណងដើម្បីផ្តល់សិទ្ធិអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសមត្ថភាព ផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផល សំដៅឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា២.-**

ព្រះរាជក្រឹត្យនេះមានគោលដៅកំណត់៖

- ការរៀបចំនិងគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការរៀបចំនិងគ្រប់គ្រងបុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- សិទ្ធិអំណាចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា៣.-**

ព្រះរាជក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនៃព្រះរាជាណាចក្រកម្ពុជាដែលរួមមាន៖

- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលដែលត្រូវបានជ្រើសរើសនិងតែងតាំងដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃក្រសួង ស្ថាប័នដែលត្រូវបានផ្ទេរតាមដំណើរការនៃការផ្ទេរមុខងារនិងធនធានឱ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- មន្ត្រីរាជការស៊ីវិលរបស់ក្រសួង ស្ថាប័នដែលត្រូវបានតែងតាំងឬចាត់តាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិ ឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិល រួមមាន មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលត្រូវបានជ្រើសរើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

មន្ត្រីរាជការនៃក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាលឬមន្ត្រីដទៃទៀតដែលអនុវត្តការកិច្ចពាក់ព័ន្ធនឹងសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្សដែលបំពេញការងារនៅថ្នាក់ក្រោមជាតិ មិនស្ថិតក្រោមវិសាលភាពនៃព្រះរាជក្រឹត្យនេះទេ។

## ជំពូកទី២
## គោលការណ៍រួម

**មាត្រា៤.-**

ការរៀបចំនិងការគ្រប់គ្រងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តអនុលោមតាមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៥ ..**

ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់ធនធានមនុស្សនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធានានូវគោលការណ៍ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព អព្យាក្រឹត្យភាព និងសមធម៌។

**មាត្រា៦ ..**

ការផ្ទេរនិងការផ្លាស់ប្តូរទៅវិញទៅមករវាងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិ ត្រូវធានាដល់ការការពារផលប្រយោជន៍នានារបស់បុគ្គលិកនិងប្រសិទ្ធភាពការងារ។

**មាត្រា៧ ..**

ការជ្រើសរើស ការដំឡើងថ្នាក់ ឋានន្តរស័ក្តិ ការតែងតាំងមុខតំណែង និងការផ្តល់ការលើកទឹកចិត្តផ្សេងៗ ត្រូវផ្តល់អាទិភាពដល់ស្ត្រី ជនជាតិដើមភាគតិច និងជនពិការ ដោយផ្អែកលើសមត្ថភាពការងារនិងគុណធម៌។

## ជំពូកទី៣
## អង្គ ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់

**មាត្រា៨ ..**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវស្ថិតនៅក្នុងអង្គ ក្របខណ្ឌ ឋានន្តរស័ក្តិ និងថ្នាក់ ដែលត្រូវអនុវត្តទាំងថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ។

**មាត្រា៩ ..**

មុខតំណែងក្នុងអង្គដើម្បីបម្រើការងារនៅតាមរចនាសម្ព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិនិងមុខតំណែងដើម្បីគាំទ្រប្រតិបត្តិការការងារ បេសកកម្ម និងមុខងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បន្ទាប់ពីមានការពិគ្រោះយោបល់ពីក្រសួងមុខងារសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

## ជំពូកទី៤
## ការរៀបចំផែនការនិងការជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិល នៃរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១០ ..**

រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗទទួលខុសត្រូវរៀបចំផែនការបុគ្គលិកគ្រប់ប្រភេទក្របខណ្ឌនៅពេលមានតម្រូវការធនធានមនុស្សដើម្បីបំពេញភារកិច្ចនិងករណីយកិច្ចឆ្លើយតបទៅនឹងតម្រូវការការងារដែលក្រុមប្រឹក្សាត្រូវអនុវត្តក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ចំពោះការរៀបចំផែនការបុគ្គលិករបស់រដ្ឋបាលរាជធានី ត្រូវដាក់បញ្ចូលនូវផែនការបុគ្គលិករបស់រដ្ឋបាលខណ្ឌ និងរដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ចំពោះការរៀបចំផែនការបុគ្គលិករបស់រដ្ឋបាលក្រុង ត្រូវដាក់បញ្ចូលនូវផែនការបុគ្គលិករបស់រដ្ឋបាលសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំនីមួយៗឱ្យបានរួចរាល់ក្នុងត្រីមាសទី១នៃឆ្នាំ ដើម្បីដាក់បញ្ចូលក្នុងគម្រោងថវិកាប្រចាំឆ្នាំបន្ទាប់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមបែបបទនិងនីតិវិធីជាធរមាន ដោយមានការគាំទ្រពីមន្ទីរមុខងារសាធារណៈនិងមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរាជធានី ខេត្ត។

**មាត្រា១១ .-**

ការរៀបចំផែនការបុគ្គលិកប្រចាំឆ្នាំ ត្រូវផ្អែកទៅលើគោលនយោបាយនិងក្របខណ្ឌម៉ាក្រូហិរញ្ញវត្ថុប្រចាំឆ្នាំនីមួយៗ របស់រាជរដ្ឋាភិបាល ចំនួនមុខតំណែងដែលនៅទំនេរ តម្រូវការបុគ្គលិកផ្អែកលើទំហំការងារ ការកែសម្រួលរចនាសម្ព័ន្ធ និងការផ្ទេរមុខងារ។

គោលការណ៍ បែបបទ និងនីតិវិធីនៃការរៀបចំផែនការបុគ្គលិករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

**មាត្រា១២ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវក្នុងការរៀបចំជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងវិជ្ជាជីវៈនីមួយៗ ផ្អែកតាមផែនការបុគ្គលិកប្រចាំឆ្នាំរបស់ខ្លួន លើកលែងតែការជ្រើសរើសបេក្ខជនសម្រាប់មុខតំណែងវិជ្ជាជីវៈអប់រំនិងសុខាភិបាលដែលត្រូវជ្រើសរើសដោយថ្នាក់ជាតិ។

បេក្ខជនដែលត្រូវបានជ្រើសរើសសម្រាប់មុខតំណែងវិជ្ជាជីវៈនីមួយៗក្នុងក្របខណ្ឌមន្ត្រីរាជការស៊ីវិលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ លុះត្រាតែបេក្ខជនទាំងនោះបានបំពេញតាមគ្រប់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា អង្គ ប្រភេទក្របខណ្ឌ មុខតំណែងវិជ្ជាជីវៈនីមួយៗរបស់មន្ត្រីរាជការស៊ីវិល ព្រមទាំងនិយាមជាតិជាធរមាន។

រដ្ឋបាលថ្នាក់ក្រោមជាតិអាចកំណត់លក្ខខណ្ឌបន្ថែមផ្អែកលើភាពចាំបាច់នៃមុខតំណែងវិជ្ជាជីវៈនីមួយៗ ដើម្បីគាំទ្រដំណើរការការងារនិងបេសកកម្មរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៣ .-**

ការជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងតាមរយៈការប្រឡងប្រជែងផ្អែកលើគោលការណ៍តម្លាភាព យុត្តិធម៌ សមធម៌ និងគុណសម្បត្តិស័ក្តិសម។

ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ដោយឡែករដ្ឋបាលរាជធានី ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលសម្រាប់រាជធានី ខណ្ឌ និងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយរដ្ឋបាលក្រុង ត្រូវរៀបចំឱ្យមានគណៈកម្មការរៀបចំការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលសម្រាប់ក្រុងនិងសង្កាត់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

គណៈកម្មការនេះត្រូវមានសមាសភាពដូចខាងក្រោម៖

**ក- សម្រាប់រដ្ឋបាលរាជធានី**

| | |
|---|---|
| - តំណាងគណៈអភិបាល | ប្រធាន |
| - នាយករដ្ឋបាល | សមាជិក |
| - ប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក | សមាជិក |
| - ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក | សមាជិក |
| - អភិបាលខណ្ឌនិង/ឬចៅសង្កាត់ដែលមានតម្រូវការបុគ្គលិក | សមាជិក |
| - តំណាងមន្ទីរមុខងារសាធារណៈ | សមាជិក |

**ខ- សម្រាប់រដ្ឋបាលខេត្ត ស្រុក**

| | |
|---|---|
| - តំណាងគណៈអភិបាល | ប្រធាន |

- នាយករដ្ឋបាល សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក សមាជិក
- ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ សមាជិក

គ- សម្រាប់រដ្ឋបាលក្រុង

- តំណាងគណៈអភិបាល ប្រធាន
- នាយករដ្ឋបាល សមាជិក
- ប្រធានអង្គភាពទទួលបន្ទុកបុគ្គលិក សមាជិក
- ប្រធានអង្គភាពដែលមានតម្រូវការបុគ្គលិក សមាជិក
- ចៅសង្កាត់ដែលមានតម្រូវការបុគ្គលិក សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ សមាជិក

ឃ- សម្រាប់រដ្ឋបាលឃុំ សង្កាត់(ក្រៅខណ្ឌនិងក្រុង)

- មេឃុំឬចៅសង្កាត់ ប្រធាន
- ជំទប់ទី១ឬចៅសង្កាត់រងទី១ អនុប្រធាន
- ស្មៀនឃុំឬសង្កាត់ សមាជិក
- តំណាងមន្ទីរមុខងារសាធារណៈ សមាជិក

ក្រុមប្រឹក្សាត្រូវធានាឱ្យមានបេក្ខភាពជាស្ត្រីយ៉ាងតិច១(មួយ)រូបនៅក្នុងសមាសភាពនៃគណៈកម្មការនេះ។ ក្នុងករណីដែលមិនមានបេក្ខភាពជាស្ត្រីក្នុងចំណោមសមាសភាពដូចបានកំណត់ខាងលើ ក្រុមប្រឹក្សាអាចបន្ថែមសមាសភាពជាស្ត្រី១(មួយ)រូបជាសមាជិកគណៈកម្មការនេះ។

គណៈកម្មការនេះមានសិទ្ធិក្នុងការបង្កើតអនុគណៈកម្មការនិង/ឬក្រុមការងារតាមការចាំបាច់ ដើម្បីរៀបចំការប្រឡងនេះ។

**មាត្រា១៤ .-**

ការប្រឡងជ្រើសរើសត្រូវផ្តល់អាទិភាពជូនបេក្ខជនជានារីភេទ ជនជាតិដើមភាគតិច ជនពិការ និងបេក្ខជនមានលំនៅឋានស្ថិតនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដែលមានតម្រូវការបុគ្គលិក។

**មាត្រា១៥ .-**

កាលបរិច្ឆេទនៃការប្រឡងប្រជែងចូលក្នុងក្របខណ្ឌបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំនិងផ្សព្វផ្សាយរយៈពេល៣(បី)ខែមុនការប្រឡងចាប់ផ្តើមដំណើរការ។ ក្នុងករណីដែលមានការប្រញាប់ រយៈពេលនេះអាចកាត់បន្ថយមកត្រឹម៣០(សាមសិប)ថ្ងៃ។

**មាត្រា១៦ .-**

លទ្ធផលនៃការប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

**មាត្រា១៧ .-**

ដំណើរការនៃការរៀបចំប្រឡងជ្រើសរើសបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួង ស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៥
## ការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា របស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា១៨ ..**

ការធ្វើកម្មសិក្សាត្រូវអនុវត្តចំពោះបេក្ខជនដែលមានឈ្មោះប្រឡងជាប់ស្ថាពរក្នុងដីកាប្រកាសលទ្ធផលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដោយផ្អែកលើគោលការណ៍ដូចខាងក្រោម៖

- រយៈពេលកម្មសិក្សា១២(ដប់ពីរ)ខែ ចំពោះកម្មសិក្សាការីដែលត្រូវបានជ្រើសចេញពីសិស្ស និស្សិត
- រយៈពេលកម្មសិក្សា៦(ប្រាំមួយ)ខែចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតាំងស៊ប់ក្នុងក្របខណ្ឌណាមួយរួចហើយ ហើយបានប្រឡងជាប់ចូលក្របខណ្ឌណាមួយនៃអង្គថ្មីមួយទៀត ដោយរក្សាអតីតភាពដែលមានពីមុនមក លើកលែងតែមានការកំណត់មិនឱ្យធ្វើកម្មសិក្សាដោយអង្គណាមួយ
- ការធ្វើកម្មសិក្សា ត្រូវបានលើកលែងចំពោះមន្ត្រីរាជការក្របខណ្ឌទាំងឡាយដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខណ្ឌខ្ពស់ជាងមុនក្នុងអង្គតែមួយដែលបានតាំងស៊ប់រួចហើយ លើកលែងតែមានការកំណត់ឱ្យធ្វើកម្មសិក្សាដោយអង្គណាមួយ
- កម្មសិក្សាមិនត្រូវយកជាការបានឡើយ ប្រសិនបើសាមីជនអាក់ខានមកធ្វើកម្មសិក្សាដែលមានរយៈពេលសរុបលើសពី៣០ថ្ងៃ។ ក្នុងករណីនេះ សាមីជនត្រូវបន្តកម្មសិក្សានៅលើកទី២ទៀត
- កម្មសិក្សាការីណាដែលមិនបានបង្ហាញឱ្យឃើញថា ខ្លួនមានកាយសម្បទាវិជ្ជាជីវៈគ្រប់គ្រាន់ ឬក៏ពិនិត្យឃើញថាការធ្វើការងារមានការខ្ជីខ្ជា ឬក៏គ្មានកម្លាំងពលំនឹងកាន់មុខតំណែងបានតាមលក្ខខណ្ឌដែលបានកំណត់ក្នុងសេចក្តីណែនាំជាធរមាន អាចត្រូវបានបញ្ឈប់មិនឱ្យធ្វើការងារនេះនៅពេលណាក៏បានក្នុងរយៈពេលកម្មសិក្សា។

**មាត្រា១៩ ..**

ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គណាមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានអនុញ្ញាតជូនកម្មសិក្សាការីទាំងឡាយណាដែលបានបញ្ចប់កម្មសិក្សាដោយជោគជ័យ។

ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គណាមួយនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានការចូលរួមយោបល់ពីគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃដែលមានសមាសភាពដូចជា ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់១(មួយ)រូប អនុប្រធានអង្គភាពសាមី១(មួយ)រូប និងមន្ត្រីរាជការ១(មួយ)រូបដែលមានឋានន្តរស័ក្តិខ្ពស់ជាងគេក្នុងអង្គភាពដែលសាមីខ្លួនធ្វើការជាមួយ។ ក្នុងករណីពុំមានមន្ត្រីរាជការសមស្របតាមការកំណត់ខាងលើនេះទេ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ជាអ្នកវាយតម្លៃ។ ប្រធានអង្គភាពគ្រប់គ្រងផ្ទាល់ ត្រូវលើកសំណើតាមឋានានុក្រមដាក់ជូនអភិបាលនៃគណៈអភិបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីពិនិត្យសម្រេច។

ចំពោះមន្ត្រីរាជការស៊ីវិលដែលបានប្រឡងជាប់ទៅកាន់ប្រភេទក្របខណ្ឌខ្ពស់ជាងមុនក្នុងអង្គតែមួយនិងមន្ត្រីរាជការស៊ីវិលដែលប្រឡងប្តូរប្រភេទក្របខណ្ឌរវាងអង្គផ្សេងគ្នា ត្រូវអនុញ្ញាតឱ្យតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គដែលខ្លួនបានប្រឡងជាប់បន្ទាប់ពីការចេញដីកាប្រកាសលទ្ធផល។

**មាត្រា២០ ..**

ក្នុងរយៈពេល៣០(សាមសិប)ថ្ងៃយ៉ាងយូរក្រោយផុតកំណត់រយៈពេលកម្មសិក្សា ដោយផ្អែកលើការវាយតម្លៃរបស់គណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃកម្មសិក្សា រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវសម្រេចអំពី៖

- ការតាំងស៊ប់កម្មសិក្សាការីក្នុងក្របខណ្ឌ ឬ

- ការឱ្យកម្មសិក្សាការីធ្វើកម្មសិក្សាជាលើកទី២ ឬ
- ការបញ្ឈប់មិនឱ្យកម្មសិក្សាការីធ្វើការ។

ការតាំងស៊ប់ចាប់ផ្ដើមមានប្រសិទ្ធភាពចាប់ពីថ្ងៃផុតកំណត់នៃកម្មសិក្សា។ រយៈពេលកម្មសិក្សាត្រូវគិតបញ្ចូលក្នុងអតីតភាពការងារសម្រាប់ពេលចូលនិវត្តន៍។

**មាត្រា២១ .-**

ការតាំងស៊ប់ក្នុងក្របខណ្ឌនៃអង្គនីមួយៗ ត្រូវអនុវត្តតាមការកំណត់ដូចខាងក្រោម៖

- ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់ទាបបំផុតនៃក្របខណ្ឌដែលបេក្ខជនបានប្រឡងជាប់ ចំពោះបេក្ខជនដែលបានជ្រើសរើសចេញពីសិស្ស និស្សិត ឬត្រូវបានបន្ថែម១(មួយ)ថ្នាក់ឬច្រើនថ្នាក់ទៅតាមការកំណត់នៃក្របខណ្ឌនីមួយៗនៃអង្គឬតាមការកំណត់របស់រាជរដ្ឋាភិបាល
- ត្រូវចាត់បញ្ចូលទៅក្នុងថ្នាក់ដែលមានសន្ទស្សន៍បៀវត្សខ្ពស់លើបន្ទាប់ពីសន្ទស្សន៍ចាស់របស់សាមីខ្លួន ចំពោះបេក្ខជនដែលបានជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិល។

**មាត្រា២២ .-**

ការសម្រេចឱ្យធ្វើកម្មសិក្សា ការតាំងស៊ប់ក្នុងក្របខណ្ឌ ឬការបញ្ឈប់មិនឱ្យកម្មសិក្សាការីធ្វើការ ត្រូវធ្វើឡើងដោយដឹកការរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមនីតិវិធីជាធរមាន។

**មាត្រា២៣ .-**

បែបបទនិងនីតិវិធីនៃការធ្វើកម្មសិក្សា ការតាំងស៊ប់ និងការបញ្ឈប់កម្មសិក្សា ត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៦
## ការតែងតាំងនិងការបញ្ចប់មុខតំណែង

**មាត្រា២៤ .-**

ក្រោយពេលត្រូវបានតាំងស៊ប់នៅក្នុងក្របខណ្ឌរួចហើយ មន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបានការតែងតាំងក្នុងមុខតំណែងវិជ្ជាជីវៈស្របតាមសេចក្តីត្រូវការនៃការជ្រើសរើសបានកំណត់។

ការតែងតាំងក្នុងមុខតំណែងវិជ្ជាជីវៈ ត្រូវផ្អែកលើគុណសម្បត្តិស័ក្តិសមនៃមុខតំណែងវិជ្ជាជីវៈនីមួយៗដែលត្រូវកំណត់ដោយអនុក្រឹត្យនិងលិខិតបទដ្ឋានជាធរមាន។

**មាត្រា២៥ .-**

ការតែងតាំងក្នុងមុខតំណែងគ្រប់គ្រងត្រូវផ្អែកលើឧបនិស្ស័យនិងគុណសម្បត្តិស័ក្តិសមរបស់បេក្ខជនសម្រាប់មុខតំណែងអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា២៦ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិអាចត្រូវបញ្ចប់មុខតំណែងវិជ្ជាជីវៈឬមុខតំណែងគ្រប់គ្រងក្នុងករណីដូចខាងក្រោម៖

- មរណភាព
- ការចូលនិវត្តន៍ឬការដាក់ឱ្យចូលនិវត្តន៍មុនកំណត់
- ការបាត់បង់សម្បទាវិជ្ជាជីវៈ

- ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស
- ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម
- ការបញ្ឈប់ពីការងារដោយបង្ខំឬការបណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ
- ការលាឈប់ពីមុខតំណែង
- ការផ្ទេរឬផ្លាស់ប្តូរកន្លែងធ្វើការ
- ការផ្តន្ទាទោសជាបទឧក្រិដ្ឋឬជាបទមជ្ឈិមដោយឥតព្យួរទោស
- ការលុបនិងការកែសម្រួលរចនាសម្ព័ន្ធនិងមុខតំណែង។

**មាត្រា២៧.-**

ការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលខេត្ត ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលសាមីនីមួយៗតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ក្នុងខណ្ឌ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលរាជធានីតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលក្រុងនិងសង្កាត់ក្នុងក្រុង ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលក្រុងតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការតែងតាំងនិងការបញ្ចប់មុខតំណែងខាងលើនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលច្បាប់តម្រូវឱ្យមានការតែងតាំងឬបញ្ចប់មុខតំណែងដោយរាជរដ្ឋាភិបាលឬដោយក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗអាចលើកសំណើតែងតាំងនិងបញ្ចប់មុខតំណែងមន្ត្រីរាជការស៊ីវិលទាំងនេះមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចនិង/ឬស្នើសុំការសម្រេចពីរាជរដ្ឋាភិបាល។

**មាត្រា២៨.-**

បែបបទនិងនីតិវិធីនៃការតែងតាំងនិងការបញ្ចប់មុខតំណែងបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៧
## ការដំឡើងថ្នាក់និងឋានន្តរស័ក្តិបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ

**មាត្រា២៩.-**

ការដំឡើងថ្នាក់ និង/ឬ ឋានន្តរស័ក្តិបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តផ្អែកលើការវាយតម្លៃគុណផលការងាររបស់បេក្ខជន។

ការវាយតម្លៃគុណផលការងារនេះ ត្រូវធ្វើឡើងដោយគណៈកម្មការវាយតម្លៃគុណផលការងារដែលមានសមាសភាពដូចគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃការតាំងស៊ប់ដែលមានចែងក្នុងមាត្រា១៩នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៣០.-**

ការដំឡើងថ្នាក់របស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវកំណត់ដូចខាងក្រោម៖

- រយៈពេលអប្បបរមានៃការឡើងថ្នាក់ត្រូវកំណត់រយៈពេល២(ពីរ)ឆ្នាំ។ ការដំឡើងថ្នាក់អាចធ្វើបានម្តងតែមួយថ្នាក់។ អតីតភាពការងារមន្ត្រីរាជការដែលធ្វើការនៅតំបន់ឆ្ងាយដាច់ស្រយាល

តំបន់ប៉ះពាល់សុខភាពឬគ្រោះថ្នាក់ត្រូវគិតបន្ថែមពាក់កណ្តាលនៃអតីតភាពនេះទៀតក្នុងការចុះឈ្មោះលើតារាងរាយនាមសម្រាប់ស្នើសុំដំឡើងថ្នាក់។

- អតីតភាពបម្រើការងារគិតចាប់ពីថ្ងៃតាំងស៊ប់ឬថ្ងៃឡើងថ្នាក់ចុងក្រោយដល់ថ្ងៃទី១៣ ខែមេសានៃឆ្នាំនីមួយៗ។

**មាត្រា៣១ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដំឡើងថ្នាក់ជាស្វ័យប្រវត្តិ ក្នុងករណីដូចខាងក្រោម៖

- បានទទួលការបណ្តុះបណ្តាលដោយជោគជ័យវគ្គសុក្រឹត្យការឬក្រឹត្យការនៅសាលាភូមិន្ទរដ្ឋបាល
- បានទទួលការបណ្តុះបណ្តាលជំនាញសមស្របតាមការតម្រូវនៃអង្គរបស់ខ្លួន ដែលមានរយៈពេលយ៉ាងតិច១(មួយ)ឆ្នាំ ដោយមានសញ្ញាបត្រឬវិញ្ញាបនបត្របញ្ជាក់ទទួលស្គាល់
- មានអតីតភាពការងារយ៉ាងតិច២(ពីរ)ឆ្នាំសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានអនុញ្ញាតឱ្យស្ថិតនៅក្រៅក្របខណ្ឌដើម ដើម្បីទៅបំពេញមុខងារនៅតាមស្ថាប័នសាធារណៈផ្សេងទៀត។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលទទួលបានការដំឡើងថ្នាក់តាមការបណ្តុះបណ្តាលមានសិទ្ធិស្នើសុំការដំឡើងថ្នាក់ប្រចាំឆ្នាំផ្អែកលើអតីតភាពការងារដូចមានចែងក្នុងមាត្រា៣០ខាងលើ។

**មាត្រា៣២ .-**

ក្នុងករណីបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិណាម្នាក់ បានបំពេញការងារមានស្នាដៃល្អពិសេស អាចត្រូវបានដំឡើងថ្នាក់ដោយពុំគិតពីលក្ខខណ្ឌអតីតភាពឡើយ។

**មាត្រា៣៣ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលស្ថិតនៅថ្នាក់ខ្ពស់បំផុតឬថ្នាក់លេខ១នៃឋានន្តរស័ក្តិទី២និងទី៣ក្នុងក្របខណ្ឌប្រភេទ"ក"និង"ខ"នៃអង្គនីមួយៗ ត្រូវបានដំឡើងទៅថ្នាក់ទាបបំផុតនៃឋានន្តរស័ក្តិខ្ពស់បន្ទាប់នៃប្រភេទក្របខណ្ឌរបស់មន្ត្រីរាជការស៊ីវិលនោះ លុះត្រាតែបុគ្គលិកជាមន្ត្រីរាជការនោះ បានបំពេញលក្ខខណ្ឌសម្រាប់ការឡើងថ្នាក់ដូចបានកំណត់ក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៣៤ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិជាកិច្ចបច្ឆាមរណៈក្នុងករណីទទួលមរណភាពដោយសារបំពេញបេសកកម្មឬគ្រោះថ្នាក់ការងារ។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិជាកិត្តិយសក្នុងករណីបាត់បង់សម្បទាវិជ្ជាជីវៈដោយមូលហេតុបំពេញការងារឬក្នុងករណីចូលនិវត្តន៍។

**មាត្រា៣៥ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិក្នុងប្រភេទក្របខណ្ឌណាមួយអាចត្រូវដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិដល់ត្រឹមកម្រិតខ្ពស់បំផុតក្នុងប្រភេទក្របខណ្ឌនោះតែប៉ុណ្ណោះ ដោយពុំអាចធ្វើការដំឡើងទៅក្នុងថ្នាក់និង/ឬឋានន្តរស័ក្តិនៃប្រភេទក្របខណ្ឌផ្សេងទៀតបានឡើយ។

**មាត្រា៣៦ .-**

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលខេត្ត ស្រុក និងឃុំ ត្រូវធ្វើឡើងដោយប្រធានរដ្ឋបាលសាមីនីមួយៗតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខណ្ឌ និងសង្កាត់ក្នុងខណ្ឌ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលរាជធានីតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលក្រុងនិងសង្កាត់ក្នុងក្រុង ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលក្រុងតាមគោលការណ៍និងនីតិវិធីជាធរមាន។

ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិខាងលើនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិពិនិត្យ វាយតម្លៃ និងលើកសំណើសម្រាប់ការឡើងថ្នាក់និង/ឬឋានន្តរស័ក្តិមន្ត្រីរាជការស៊ីវិលទាំងនោះមកក្រសួងមហាផ្ទៃ ដើម្បីពិនិត្យសម្រេចតាមនីតិវិធីជាធរមាន។

**មាត្រា៣៧ .-**

បែបបទនិងនីតិវិធីនៃការដំឡើងថ្នាក់និង/ឬឋានន្តរស័ក្តិរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវរៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៨
## ការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការ

**មាត្រា៣៨ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ អាចត្រូវបានអនុញ្ញាតឱ្យផ្ទេរទៅវិញទៅមករវាងរដ្ឋបាលថ្នាក់ក្រោមជាតិនិងថ្នាក់ជាតិនិងរវាងរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៀត។

ការផ្ទេរនេះអាចធ្វើឡើងបានក្នុងអង្គតែមួយនៃមន្ត្រីរាជការនោះនិងត្រូវផ្អែកលើមុខតំណែងទំនេរនៅក្នុងអង្គភាពដែលទទួលបុគ្គលិកនោះ ព្រមទាំងគុណសម្បត្តិស័ក្តិសមរបស់បុគ្គលិកចំពោះមុខតំណែង។

ការផ្ទេរបុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនិងមន្ត្រីរាជការស៊ីវិលថ្នាក់ជាតិ ត្រូវធ្វើឡើងតាមគោលការណ៍ដូចខាងក្រោម៖

**ក- ការផ្ទេរពីរដ្ឋបាលថ្នាក់ក្រោមជាតិមួយទៅរដ្ឋបាលថ្នាក់ក្រោមជាតិមួយផ្សេងទៀត**

- ការស្នើសុំរបស់សាមីខ្លួន
- ការយល់ព្រមពីអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិទាំងសងខាង
- ការផ្ទេរនេះត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិទាំងសងខាង
- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនដីកាសម្រេចផ្ទេរបុគ្គលិកទៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្តដែលសាមីខ្លួននោះផ្ទេរទៅ។ ក្នុងករណីពិនិត្យឃើញដីកានិងសេចក្តីសម្រេចធ្វើឡើងមិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ។

**ខ- ការផ្ទេររវាងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ**

- ការស្នើសុំរបស់សាមីខ្លួន
- ការយល់ព្រមពីអភិបាល មេឃុំ ចៅសង្កាត់នៃរដ្ឋបាលថ្នាក់ក្រោមជាតិសាមី

- ការយល់ព្រមពីក្រសួង ស្ថាប័នសាមី

- ការផ្ទេរនេះធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិនិងប្រកាសរបស់ក្រសួង ស្ថាប័នសាមី។

- រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបញ្ជូនដីកាឬប្រកាសសម្រេចផ្ទេរបុគ្គលិកទៅក្រសួងមុខងារសាធារណៈ។

ក្នុងករណីពិនិត្យឃើញដីកានិងប្រកាសធ្វើឡើងមិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ ក្រសួងមុខងារសាធារណៈមិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ។

**មាត្រា៣៩.-**

ការផ្ទេរបុគ្គលិកជាមន្ត្រីរាជការស៊ីវិលតាមមាត្រា៣៨ខាងលើនេះ មិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិឡើយ។

**មាត្រា៤០.-**

ការផ្លាស់ប្តូរទីកន្លែងធ្វើការរបស់មន្ត្រីរាជការស៊ីវិលពីអង្គភាពមួយទៅអង្គភាពមួយក្នុងរចនាសម្ព័ន្ធរបស់រដ្ឋបាលនីមួយៗនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

**មាត្រា៤១.-**

ការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការដូចមានចែងក្នុងមាត្រា៣៨និងមាត្រា៤០ខាងលើត្រូវរក្សាអត្ថប្រយោជន៍ដែលសាមីជនធ្លាប់បានទទួលកន្លងមកមានដូចជា ក្របខណ្ឌ ឋានន្តរស័ក្តិ ថ្នាក់ និងអតីតភាពការងារជាដើម។

**មាត្រា៤២.-**

បែបបទនិងនីតិវិធីនៃការផ្ទេរនិងការផ្លាស់ប្តូរកន្លែងធ្វើការរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ រៀបចំដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួងស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី៩

## ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬការដាក់ឱ្យនៅក្រៅតំណែង

**មាត្រា៤៣.-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចត្រូវបានដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬដាក់ឱ្យនៅក្រៅតំណែង ដើម្បីទៅបំពេញការងារជាសមាជិកក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ សមាជិករដ្ឋសភា សមាជិកព្រឹទ្ធសភា សមាជិករាជរដ្ឋាភិបាល និងនៅក្នុងស្ថាប័នសាធារណៈផ្សេងទៀត។

**មាត្រា៤៤.-**

ការដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬការដាក់ឱ្យនៅក្រៅតំណែងរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ លើកលែងតែមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សារដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវសម្រេចដោយក្រសួងមហាផ្ទៃឬរាជរដ្ឋាភិបាលផ្អែកលើករណីនីមួយៗ។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវបានដាក់ឱ្យស្ថិតនៅក្រៅក្របខណ្ឌដើមឬដាក់ឱ្យនៅក្រៅតំណែង ត្រូវរក្សាទុកអតីតភាពសម្រាប់ការឡើងថ្នាក់ ការឡើងឋានន្តរស័ក្តិ និងការចូលនិវត្តន៍នៅអង្គភាពដើម។

## ជំពូកទី១០
## ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស

**មាត្រា៤៥ ._**

ភាពទំនេរគ្មានបៀវត្ស គឺជាស្ថានភាពរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលបាត់សិទ្ធិទទួលប្រាក់បៀវត្ស ការឡើងថ្នាក់ ការឡើងឋានន្តរស័ក្តិ និងអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍។

ការដាក់ឱ្យស្ថិតនៅក្នុងភាពទំនេរគ្មានបៀវត្ស អាចធ្វើឡើងតាមការស្នើសុំរបស់មន្ត្រីសាមីជនឬដោយបញ្ញត្តិ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

**មាត្រា៤៦ ._**

ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំឬដោយបញ្ញត្តិ ត្រូវសម្រេចដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិសាមី។

ការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗមានសិទ្ធិលើកសំណើមកក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យសម្រេចតាមនីតិវិធីជាធរមាន។

**មាត្រា៤៧ ._**

លក្ខខណ្ឌនិងនីតិវិធីនៃការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សតាមពាក្យស្នើសុំឬការដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សដោយបញ្ញត្តិ ត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ ដោយមានការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃនិងក្រសួង ស្ថាប័នពាក់ព័ន្ធក្រោមការសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

## ជំពូកទី១១
## ពេលវេលាបំពេញការងារនិងការឈប់សម្រាក

**មាត្រា៤៨ ._**

ការកំណត់ពេលវេលាបំពេញការងាររបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុលោមតាមអនុក្រឹត្យជាធរមាន។

**មាត្រា៤៩ ._**

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិឈប់សម្រាកការងារអនុលោមតាមបទប្បញ្ញត្តិជាធរមាននិងត្រូវមានការអនុញ្ញាតឈប់សម្រាក ផ្អែកលើករណីដូចខាងក្រោម៖

- ចំពោះអភិបាលរាជធានី ខេត្ត ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ចំពោះមុខតំណែងចាប់ពីនាយកទីចាត់ការរហូតដល់អភិបាលរងរាជធានី ខេត្ត និង អភិបាលក្រុង ស្រុក ខណ្ឌ មេឃុំ ចៅសង្កាត់ ត្រូវមានការអនុញ្ញាតពីអភិបាលរាជធានី ខេត្តសាមី
- ចំពោះមុខតំណែងចាប់ពីប្រធានការិយាល័យរហូតដល់អភិបាលរងក្រុង ស្រុក ខណ្ឌ ត្រូវមានការអនុញ្ញាតពីអភិបាលក្រុង ស្រុក ខណ្ឌ
- ចំពោះបុគ្គលិកក្នុងទីចាត់ការ អង្គភាពនីមួយៗនៃសាលារាជធានី ខេត្ត ត្រូវមានការអនុញ្ញាតពីនាយកទីចាត់ការឬប្រធានអង្គភាពសាមី
- ចំពោះបុគ្គលិកក្នុងការិយាល័យ អង្គភាពនីមួយៗនៃសាលាក្រុង ស្រុក ខណ្ឌ ត្រូវមានការអនុញ្ញាតពីនាយករដ្ឋបាលនៃសាលាក្រុង ស្រុក ខណ្ឌសាមី។

## ជំពូកទី១២
## ការចូលនិវត្តន៍និងការបាត់បង់សម្បទាវិជ្ជាជីវៈ

**មាត្រា៥០ .-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ នៅពេលដល់អាយុកំណត់ចូលនិវត្តន៍ ត្រូវដាក់ឱ្យចូលនិវត្តន៍ជាកំហិតនិងមិនអនុញ្ញាតឱ្យនៅបំពេញមុខតំណែងក្នុងក្របខណ្ឌនៃរដ្ឋបាលថ្នាក់ក្រោមជាតិបានឡើយ។

ការកំណត់ថាបាត់បង់សម្បទាវិជ្ជាជីវៈរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវធ្វើឡើងដោយគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃដែលមានសមាសភាពដូចគណៈកម្មការត្រួតពិនិត្យនិងវាយតម្លៃការតាំងស៊ប់ដែលមានចែងក្នុងមាត្រា១៩នៃព្រះរាជក្រឹត្យនេះ ដោយត្រូវបន្ថែមសមាជិក១(មួយ)រូបជាគ្រូពេទ្យដែលបានធ្វើសច្ចាប្រណិធាន។

**មាត្រា៥១ .-**

ការដាក់ឱ្យចូលនិវត្តន៍និងការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈរបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ប្រភេទក្របខណ្ឌទាំងអស់ ត្រូវធ្វើឡើងដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

ការដាក់ឱ្យចូលនិវត្តន៍និងការដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈខាងលើនេះមិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិអាចលើកសំណើសុំដាក់ឱ្យចូលនិវត្តន៍និងដាក់ឱ្យបាត់បង់សម្បទាវិជ្ជាជីវៈរបស់មន្ត្រីរាជការស៊ីវិលទាំងនេះមកក្រសួងមហាផ្ទៃដើម្បីពិនិត្យសម្រេចតាមនីតិវិធីជាធរមាន។

## ជំពូកទី១៣
## បៀវត្ស ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងវិធានការគាំទ្រផ្សេងៗ

**មាត្រា៥២ .-**

បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ព្រមទាំងប្រាក់បំណាច់មុខងាររបស់បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិជាធរមានដែលអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលស្ថិតក្រោមច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា។

បុគ្គលិកដែលបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗទៀតមិនទាបជាងប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗដែលបុគ្គលិកទាំងនោះធ្លាប់បានទទួលមុនពេលផ្ទេរ។

ការបើកផ្តល់បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្សដែលកំណត់ក្នុងវាក្យខណ្ឌខាងលើ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងទៀតដូចមានចែងក្នុងមាត្រា៥៣ខាងក្រោម ដែលមានរយៈពេលជាប់ៗគ្នាចាប់ពី ៣(បី)ខែ ឡើងទៅត្រូវអនុវត្តតាមតារាងទូទាត់បៀវត្សប្រចាំខែគ្រប់គ្រងដោយក្រសួងមុខងារសាធារណៈ។

**មាត្រា៥៣ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិកំណត់វិធានការគាំទ្រផ្សេងទៀតដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ដូចជាប្រាក់ឧបត្ថម្ភមធ្យោបាយធ្វើដំណើរនិងការស្នាក់នៅ ការផ្តល់មធ្យោបាយអនុវត្តការងារ ប្រាក់ឧបត្ថម្ភផ្អែកលើគុណផលប្រាក់រង្វាន់លើកទឹកចិត្ត ប្រាក់ឧបត្ថម្ភលើការបណ្តុះបណ្តាល ប្រាក់ឧបត្ថម្ភសម្រាប់ការបំពេញការងារនៅតំបន់ដាច់ស្រយាល តំបន់គ្រោះថ្នាក់ តំបន់ប៉ះពាល់សុខភាព និងតំបន់ដែលមានកង្វះខាតធនធានមនុស្សជាដើម ជូនដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

វិធានការគាំទ្រខាងលើត្រូវមានការពិនិត្យនិងឯកភាពជាមុនពីក្រសួងមុខងារសាធារណៈនិងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៥៤ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវគ្រោងការចំណាយសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិដែលមានចែងក្នុងមាត្រា៥២និងមាត្រា៥៣ខាងលើ នៅក្នុងគម្រោងថវិកាប្រចាំឆ្នាំរបស់ខ្លួនតាមគោលការណ៍និងនីតិវិធីជាធរមាន។

## ជំពូកទី១៤
## ការអភិវឌ្ឍសមត្ថភាព

**មាត្រា៥៥ .-**

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិត្រូវទទួលការបណ្តុះបណ្តាលបឋមឬការបណ្តុះបណ្តាលបន្តផ្អែកលើលក្ខខណ្ឌតម្រូវនៃអង្គ ប្រភេទក្របខណ្ឌ និងមុខតំណែងនីមួយៗ។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវរៀបចំផែនការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកលើភាពចាំបាច់នៃការងារនៅក្នុងអង្គភាពផ្ទាល់របស់ខ្លួន។

**មាត្រា៥៦ .-**

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវដាក់បញ្ចូលផែនការអភិវឌ្ឍសមត្ថភាពសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិទៅក្នុងថវិកាប្រចាំឆ្នាំរបស់ខ្លួន។

## ជំពូកទី១៥
## ការតាមដាន ការត្រួតពិនិត្យ ការវាយតម្លៃ និងការគាំទ្រ

**មាត្រា៥៧ .-**

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ(គ.ជ.អ.ប.) ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា មានសមត្ថកិច្ចតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងគាំទ្ររដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីធានាថា ការគ្រប់គ្រងនិងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិអនុលោមតាមគោលនយោបាយនិងកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋាន គតិយុត្តជាធរមាន។

**មាត្រា៥៨ .-**

ក្រសួងមហាផ្ទៃ ក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ ផ្អែកលើករណីជាក់ស្តែងនីមួយៗ ត្រូវណែនាំដល់រដ្ឋបាលថ្នាក់ក្រោមជាតិឱ្យធ្វើការពិនិត្យនិងកែតម្រូវនូវរាល់កំហុសឆ្គងពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិ គោលការណ៍ បែបបទ និងនីតិវិធីជាធរមាន។ ក្នុងករណីពុំមានការកែតម្រូវ ក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវស្នើឱ្យក្រសួងមហាផ្ទៃចាត់វិធានការកែតម្រូវឬលុបដីកាដែលធ្វើឡើងមិនបានត្រឹមត្រូវតាមបទប្បញ្ញត្តិ គោលការណ៍ បែបបទ និងនីតិវិធីជាធរមាននោះ។

**មាត្រា៥៩ .-**

គ្រប់ដីកានិងសេចក្តីសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលនាំឱ្យផ្លាស់ប្តូរស្ថានភាពបៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗនិងការបើកផ្តល់ប្រាក់ទាំងនេះដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ផ្អែកលើបទប្បញ្ញត្តិនៃមាត្រា៥២និងមាត្រា៥៣នៃព្រះរាជក្រឹត្យនេះ ត្រូវបញ្ជូនទៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ដើម្បីរៀបចំការផ្លាស់ប្តូរស្ថានភាពបុគ្គលិកដល់សាមីជន។

បន្ទាប់ពីទទួលបានដីកានិងសេចក្តីសម្រេចខាងលើ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត ត្រូវពិនិត្យនិងរៀបចំការផ្លាស់ប្តូរស្ថានភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិនិងរៀបចំការបើកផ្តល់បៀវត្សនិងប្រាក់បន្ទាប់បន្សំនៃបៀវត្ស ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗថ្មីដល់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិឱ្យបានទាន់ក្នុងខែបន្ទាប់។

ក្នុងករណីពិនិត្យឃើញដីកានិងសេចក្តីសម្រេចធ្វើឡើងមិនស្របតាមបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការគ្រប់គ្រងមុខងារសាធារណៈ មន្ទីរមុខងារសាធារណៈរាជធានី ខេត្ត មិនត្រូវរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិក្នុងតារាងទូទាត់បៀវត្សមន្ត្រីរាជការឡើយ ហើយត្រូវជូនដំណឹងដល់រដ្ឋបាលថ្នាក់ក្រោមជាតិនិងអង្គភាពពាក់ព័ន្ធដោយមានបញ្ជាក់អំពីសម្អាងច្បាស់លាស់ក្នុងរយៈពេលយ៉ាងយូរ៧(ប្រាំពីរ)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារ ដើម្បីធ្វើការកែតម្រូវឱ្យសមស្របតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១៦

## ទណ្ឌកម្មខាងវិន័យ

**មាត្រា៦០.-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវមានអព្យាក្រឹត្យភាពក្នុងសកម្មភាពការងារនិងហាមដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួននិងសម្ភារៈរបស់រដ្ឋដើម្បីបម្រើសកម្មភាពនយោបាយ ព្រមទាំងត្រូវគោរពអនុវត្តច្បាប់ ដីកា បទបញ្ជា និងការណែនាំថ្នាក់លើរបស់ខ្លួន។

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលខុសត្រូវចំពោះថ្នាក់លើអំពីកិច្ចការដែលត្រូវបំពេញក្នុងមុខតំណែងរបស់ខ្លួននិងអំពើដែលអាចធ្វើឱ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរ និង កិត្តិយសរបស់ខ្លួន ព្រមទាំងអង្គភាព។

**មាត្រា៦១.-**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិដែលប្រព្រឹត្តផ្ទុយពីមាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាកំហុសនិងការផ្តាំផ្តងក្នុងវិជ្ជាជីវៈ។

កំហុសនិងការផ្តាំផ្តងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត។

**មាត្រា៦២.-**

ការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី១រួមមាន៖

- ការស្តីបន្ទោស
- ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួនរបស់បុគ្គលិក
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- ការលុបឈ្មោះចេញពីបញ្ជីដំឡើងឋានន្តរស័ក្តិឬថ្នាក់។

ការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី១ ត្រូវសម្រេចដោយប្រធានអង្គភាពសាមីដែលគ្រប់គ្រងបុគ្គលិកផ្ទាល់ បន្ទាប់ពីការដោះសាររបស់សាមីជនពាក់ព័ន្ធ។ ដោយឡែកការអនុវត្តការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យត្រូវសម្រេចដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិតាមសំណើរបស់ប្រធានអង្គភាពសាមី បន្ទាប់ពីការដោះសាររបស់សាមីជនពាក់ព័ន្ធ។

**មាត្រា៦៣.-**

ការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២ រួមមាន ការមិនអនុញ្ញាតដំឡើងឋានន្តរស័ក្តិនិង/ឬថ្នាក់ ក្នុងថេរវេលារហូតដល់២(ពីរ)ឆ្នាំ ឬការដាក់ឱ្យនៅទំនេរគ្មានបៀវត្សរហូតដល់រយៈពេល១(មួយ)ឆ្នាំ ឬការបន្ថយឋានន្តរស័ក្តិឬថ្នាក់១(មួយ)ថ្នាក់ឬច្រើនថ្នាក់ ឬការដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬការបញ្ឈប់ពីការងារដោយបង្ខំ ឬការបណ្តេញចេញពីក្របខណ្ឌ។

ការអនុវត្តទណ្ឌកម្មខាងវិន័យថ្នាក់ទី២ ត្រូវសម្រេចដោយដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោយពីមានយោបល់របស់ក្រុមប្រឹក្សាវិន័យ។

**មាត្រា៦៤ .-**

ក្រុមប្រឹក្សាវិន័យមានសមាសភាពដូចខាងក្រោម៖

ក- ថ្នាក់រាជធានី ខេត្ត

- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរាជធានី ខេត្តចំនួន៣(បី)នាក់ ដែលចាត់តាំងដោយអភិបាលនៃគណៈអភិបាល ដោយម្នាក់បំពេញមុខងារជាប្រធាន ម្នាក់បំពេញមុខងារជាអ្នកធ្វើរបាយការណ៍ និងម្នាក់ទៀតជាសមាជិក
- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងក្របខណ្ឌជាមួយគ្នាចំនួន ២(ពីរ)នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ជាងឬមានអតីតភាពការងារច្រើនជាងក្នុងថ្នាក់ស្មើគ្នាជាសមាជិក។

ក្រុមប្រឹក្សាវិន័យរាជធានី មានសមត្ថកិច្ចផ្តល់យោបល់ក្នុងការដាក់វិន័យទណ្ឌកម្មថ្នាក់ទី២ ចំពោះបុគ្គលិកនៃរដ្ឋបាលខណ្ឌនិងសង្កាត់ចំណុះរាជធានី។

ខ- ថ្នាក់ក្រុង ស្រុក

- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលក្រុង ស្រុកចំនួន៣(បី)នាក់ ដែលចាត់តាំងដោយអភិបាលនៃគណៈអភិបាល ដោយម្នាក់បំពេញមុខងារជាប្រធាន ម្នាក់បំពេញមុខងារជាអ្នកធ្វើរបាយការណ៍ និងម្នាក់ទៀតជាសមាជិក
- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងក្របខណ្ឌជាមួយគ្នាចំនួន ២(ពីរ)នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ជាងឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នាជាសមាជិក ។

ក្រុមប្រឹក្សាវិន័យក្រុង ស្រុក មានសមត្ថកិច្ចផ្តល់យោបល់ក្នុងការដាក់វិន័យទណ្ឌកម្មថ្នាក់ទី២ ចំពោះបុគ្គលិកនៃរដ្ឋបាលឃុំ សង្កាត់។

ត្រូវហាមឃាត់ក្នុងការចាត់តាំងឱ្យចូលក្នុងក្រុមប្រឹក្សាវិន័យចំពោះអ្នកដើមចោទឬក្រុមញាតិរហូតដល់ជួរទី៣។

**មាត្រា៦៥ .-**

ការដាក់ទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា៦១ មាត្រា៦២ និងមាត្រា៦៣ខាងលើនេះ មិនអនុវត្តចំពោះមន្ត្រីរាជការស៊ីវិលដែលត្រូវបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ។

ក្នុងករណីនេះ រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិពិនិត្យ វាយតម្លៃ និងលើកសំណើដាក់ទណ្ឌកម្មខាងវិន័យមកក្រសួងមហាផ្ទៃដើម្បីចាត់វិធានការតាមនីតិវិធីជាធរមាន។

**មាត្រា៦៦ .-**

បែបបទនិងនីតិវិធីនៃការអនុវត្តទណ្ឌកម្មខាងវិន័យ ត្រូវអនុវត្តអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី១៧
## អំពីការដោះស្រាយទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ

**មាត្រា៦៧ .-**

ក្រសួងមុខងារសាធារណៈ តាមរយៈគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ ជាស្ថាប័នមានសមត្ថកិច្ចក្នុងការពិនិត្យនិងដោះស្រាយរាល់ទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្រោមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ។

ROYAUME DU CAMBODGE
MINISTRE DU PALAIS ROYAL

**មាត្រា៦៨.-**

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ មានសិទ្ធិប្ដឹងតវ៉ាទៅតុលាការអំពីករណីដែលពាក់ព័ន្ធទៅនឹងមុខងារសាធារណៈថ្នាក់ក្រោមជាតិ។ ប៉ុន្តែជាការចាំបាច់ បុគ្គលិកនោះត្រូវរកវិធីដោះស្រាយតាមផ្លូវរដ្ឋបាលជាមុនសិន។

នៅដំណាក់កាលដំបូង សមត្ថកិច្ចដោះស្រាយទំនាស់ខាងលើនេះ ត្រូវប្រគល់ជូនគណៈកម្មាធិការអចិន្ត្រៃយ៍មួយមានឈ្មោះថា គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ។

**មាត្រា៦៩.-**

គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ មានសមាសភាពដូចខាងក្រោម៖

- អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ឬតំណាង ប្រធាន
- តំណាងក្រុមប្រឹក្សារាជធានី ខេត្ត សមាជិក
- នាយករដ្ឋបាលរាជធានី ខេត្ត សមាជិក
- ប្រធានមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត សមាជិកអចិន្ត្រៃយ៍
- បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្នុងក្របខណ្ឌជាមួយគ្នាចំនួន២(ពីរ)នាក់ដែលមានឋានន្តរស័ក្តិខ្ពស់ជាងឬមានអតីតភាពការងារចាស់ជាងក្នុងថ្នាក់ស្មើគ្នា សមាជិក
- ប្រធានការិយាល័យត្រួតពិនិត្យរដ្ឋបាលនិងបៀវត្សនៃមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត លេខាធិការ

បែបបទនិងនីតិវិធីក្នុងការដោះស្រាយវិវាទមុខងារសាធារណៈនឹងត្រូវកំណត់ដោយក្រសួងមុខងារសាធារណៈ។

**មាត្រា៧០.-**

គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ មានសមត្ថកិច្ចទទួលដោះស្រាយនិងសម្រុះសម្រួលរាល់ទំនាស់ពាក់ព័ន្ធកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិនៅកម្រិតរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និង ឃុំ សង្កាត់។

បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ ត្រូវដាក់ពាក្យបណ្ដឹងនៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្តដែលសាមីជនកំពុងបំពេញការងារ។

គណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈថ្នាក់ក្រោមជាតិ ត្រូវដោះស្រាយពាក្យបណ្ដឹងនេះ ក្នុងរយៈពេលយ៉ាងយូរ៦០(ហុកសិប)ថ្ងៃ ក្រោយពីពាក្យបណ្ដឹងត្រូវបានដាក់នៅមន្ទីរមុខងារសាធារណៈរាជធានី ខេត្ត។

ក្នុងករណីពុំមានដំណោះស្រាយក្នុងរយៈពេលកំណត់ខាងលើឬសាមីជនមិនឯកភាពចំពោះដំណោះស្រាយរបស់គណៈកម្មាធិការ សាមីជនអាចដាក់ពាក្យបណ្ដឹងបន្តទៅគណៈកម្មាធិការសម្រុះសម្រួលទំនាស់ពាក់ព័ន្ធនឹងកិច្ចការមុខងារសាធារណៈ នៅក្រសួងមុខងារសាធារណៈ។

## ជំពូកទី១៨
## បទប្បញ្ញត្តិដោយឡែក
## មន្ត្រីជាប់កិច្ចសន្យានិងបុគ្គលិកផ្សេងៗទៀត

**មាត្រា៧១.-**

រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិជ្រើសរើសបុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិល រួមមាន មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្ដែត និងទីប្រឹក្សាបច្ចេកទេស ដើម្បីបំពេញការងារទៅតាមតម្រូវការជាក់ស្ដែងនិងផ្អែកលើថវិការបស់ខ្លួន។

ផែនការជ្រើសរើសមន្ត្រីកិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេស ត្រូវដាក់បញ្ចូលក្នុងផែនការបុគ្គលិក ប្រចាំឆ្នាំនីមួយៗរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ស្របតាមបែបបទនិងនីតិវិធីដូចបានកំណត់ក្នុងមាត្រា១០នៃព្រះរាជក្រឹត្យនេះ។

**មាត្រា៧២ ._**

បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវអនុវត្តតួនាទីនិងភារកិច្ចរបស់ខ្លួនផ្អែកលើកិច្ចសន្យាការងារនិង/ឬលក្ខខណ្ឌការងារដែលត្រូវបានកំណត់ដោយរដ្ឋបាលថ្នាក់ក្រោមជាតិសម្រាប់រយៈពេលកំណត់មិនលើសពី១(មួយ)ឆ្នាំ។

ការជ្រើសរើសបុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវផ្អែកលើចំនួនដែលទទួលបានការអនុញ្ញាតនៅក្នុងផែនការបុគ្គលិកប្រចាំឆ្នាំនិងត្រូវអនុវត្តដោយគណៈកម្មការជ្រើសរើសដែលរៀបចំដោយរដ្ឋបាលថ្នាក់ក្រោមជាតិសាមី តាមបទប្បញ្ញត្តិមាត្រា១៣នៃព្រះរាជក្រឹត្យនេះ។

ការបញ្ឈប់បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយមូលហេតុដូចជា សាមីជនមិនបំពេញការងារតាមកិច្ចសន្យាការងារឬលក្ខខណ្ឌការងារ ការប្រព្រឹត្តប៉ះពាល់ដល់កិត្តិយសរបស់អង្គភាព ការរំលោភបំពានច្បាប់និងបទប្បញ្ញត្តិជាធរមានជាដើម ត្រូវសម្រេចដោយរដ្ឋបាលថ្នាក់ក្រោមជាតិសាមីនីមួយៗ តាមសំណើរបស់ប្រធានអង្គភាពសាមី។

**មាត្រា៧៣ ._**

ក្រៅពីសិទ្ធិនិងកាតព្វកិច្ចដែលមានកំណត់ក្នុងកិច្ចសន្យាការងារនិង/ឬលក្ខខណ្ឌការងារ បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបំពេញមុខងារអនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។

**មាត្រា៧៤ ._**

បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលប្រាក់កម្រៃការងារផ្អែកលើការសម្រេចរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ អនុលោមតាមបទប្បញ្ញត្តិជាធរមាន។

បុគ្គលិកមិនមែនជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិ អាចទទួលប្រាក់ឧបត្ថម្ភផ្សេងទៀត ដូចមានចែងក្នុងមាត្រា៥៣នៃព្រះរាជក្រឹត្យនេះ។

## ជំពូកទី១៩
## សហាទិចាន

**មាត្រា៧៥ ._**

បុគ្គលិកជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានសិទ្ធិនិងត្រូវអនុវត្តកាតព្វកិច្ចអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជានិងលិខិតបទដ្ឋានគតិយុត្តជាធរមាន ព្រមទាំងទទួលបានសិទ្ធិនិងត្រូវអនុវត្តកាតព្វកិច្ចផ្សេងទៀតដូចមានចែងក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា៧៦ ._**

ក្រោមការដឹកនាំនិងសម្របសម្រួលរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងមុខងារសាធារណៈ ដោយសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវធានាឱ្យការរៀបចំនិងការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិមានប្រសិទ្ធភាព ដោយអាចកំណត់នូវបទប្បញ្ញត្តិបំពេញបន្ថែមមួយចំនួនទៀតតាមការចាំបាច់។

## ជំពូកទី២០
## អន្តរប្បញ្ញត្តិ

**មាត្រា៧៧ ..**

ក្នុងអំឡុងពេលដែលមិនទាន់រៀបចំបាននូវលិខិតបទដ្ឋានគតិយុត្តនានា ដែលតម្រូវដោយព្រះរាជក្រឹត្យនេះ ការគ្រប់គ្រងនិងការអភិវឌ្ឍសមត្ថភាពបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវអនុវត្តអនុលោមតាមច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា៧៨ ..**

ចំនួនដំបូងនៃក្របខណ្ឌបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកសាងចេញពីសមាហរណកម្មមន្ត្រីទាំងឡាយដែលបច្ចុប្បន្នកំពុងបំពេញមុខតំណែងនិងមុខងារពិតប្រាកដក្នុងរចនាសម្ព័ន្ធសាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។

## ជំពូកទី២១
## អវសានប្បញ្ញត្តិ

**មាត្រា៧៩ ..**

ព្រះរាជក្រឹត្យនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៧ តទៅ។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨០ ..**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។/.

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ១៤ ខែ មេសា ឆ្នាំ២០១៦

នស/រកត/០៤១៦/៣៧៤

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ: ៣៧៤ ស.ណ

**សំណៅដែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ២០១៦

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៤៣...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការកែប្រែនិងការដំឡើងប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៨/០១៧ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៩
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



25

# សម្រេច

**មាត្រា១ .-**

ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិលត្រូវបានកែប្រែនិងដំឡើងដូចខាងក្រោម៖

## ១. វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស

### ១.១ ថ្នាក់ជាតិ

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គលេខាធិការនៃក្រសួង ស្ថាប័ន | ១ ០៨០ ០០០ |
| ២ | អគ្គនាយក | ១ ០១០ ០០០ |
| ៣ | អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ | ១ ០១០ ០០០ |
| ៤ | ប្រធានរដ្ឋបាលជលផល | ១ ០១០ ០០០ |
| ៥ | ប្រធានរដ្ឋបាលព្រៃឈើ | ១ ០១០ ០០០ |
| ៦ | ប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | ១ ០១០ ០០០ |
| ៧ | ប្រធានទីភ្នាក់ងារជាតិមុខរបរនិងការងារ | ១ ០១០ ០០០ |
| ៨ | អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា | ១ ០១០ ០០០ |
| ៩ | អគ្គាធិការ | ១ ០១០ ០០០ |
| ១០ | អគ្គលេខាធិការរងនៃក្រសួង ស្ថាប័ន | ៩៦០ ០០០ |
| ១១ | អគ្គនាយករង | ៩៣០ ០០០ |
| ១២ | អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគណនេយ្យ | ៩៣០ ០០០ |
| ១៣ | អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ៩៣០ ០០០ |
| ១៤ | អនុប្រធានរដ្ឋបាលជលផល | ៩៣០ ០០០ |
| ១៥ | អនុប្រធានរដ្ឋបាលព្រៃឈើ | ៩៣០ ០០០ |
| ១៦ | អគ្គនាយករងវិទ្យាស្ថានស្តង់ដារកម្ពុជា | ៩៣០ ០០០ |
| ១៧ | អនុប្រធានមជ្ឈមណ្ឌលមាត្រាសាស្ត្រជាតិ | ៩៣០ ០០០ |
| ១៨ | អនុប្រធានទីភ្នាក់ងារជាតិមុខរបរនិងការងារ | ៩៣០ ០០០ |
| ១៩ | អគ្គាធិការរង | ៩៣០ ០០០ |
| ២០ | ប្រធាននាយកដ្ឋាន | ៩០០ ០០០ |
| ២១ | ប្រធានផ្នែកនៃទីភ្នាក់ងារជាតិមុខរបរនិងការងារ | ៩០០ ០០០ |
| ២២ | ប្រធានផ្នែក ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ៩០០ ០០០ |
| ២៣ | ប្រធានមន្ទីរពិសោធន៍ ក្រសួងបរិស្ថាន | ៩០០ ០០០ |
| ២៤ | ប្រធានមន្ទីរពិសោធន៍ជាតិកសិកម្ម អគ្គនាយកដ្ឋានកសិកម្ម | ៩០០ ០០០ |
| ២៥ | ប្រធានមន្ទីរពិសោធន៍ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៩០០ ០០០ |
| ២៦ | នាយកអាកាសយានដ្ឋានអន្តរជាតិ | ៩០០ ០០០ |
| ២៧ | នាយកពុទ្ធសាសនបណ្ឌិត្យ | ៩០០ ០០០ |
| ២៨ | ប្រធានអង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ | ៩០០ ០០០ |
| ២៩ | នាយកទីចាត់ការពន្ធដាររាជធានីភ្នំពេញ | ៩០០ ០០០ |
| ៣០ | ប្រធានមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម | ៩០០ ០០០ |
| ៣១ | ប្រធានមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា | ៩០០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ៣២ | ប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ | ៩០០ ០០០ |
| ៣៣ | ប្រធានមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម | ៩០០ ០០០ |
| ៣៤ | ប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ | ៩០០ ០០០ |
| ៣៥ | លេខាធិការនៃលេខាធិការដ្ឋានបេបនីយជីវមណ្ឌលបឹងទន្លេសាប ក្រសួងធនធានទឹកនិងឧតុនិយម | ៩០០ ០០០ |
| ៣៦ | អធិការថ្នាក់កណ្តាល | ៩០០ ០០០ |
| ៣៧ | អនុប្រធាននាយកដ្ឋាន | ៨០០ ០០០ |
| ៣៨ | អនុប្រធានមជ្ឈមណ្ឌលសេវាបច្ចេកទេសប្រព័ន្ធធារាសាស្ត្រ ឧតុនិយម | ៨០០ ០០០ |
| ៣៩ | លេខាធិការរងនៃលេខាធិការដ្ឋានបេបនីយជីវមណ្ឌលបឹងទន្លេសាប ក្រសួងធនធានទឹកនិងឧតុនិយម | ៨០០ ០០០ |
| ៤០ | អនុប្រធានមន្ទីរពិសោធន៍ ក្រសួងបរិស្ថាន | ៨០០ ០០០ |
| ៤១ | អនុប្រធានមន្ទីរពិសោធន៍ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៨០០ ០០០ |
| ៤២ | ប្រធានតំណាងក្រសួងពាណិជ្ជកម្ម ប្រចាំនៅរដ្ឋបាលតំបន់សេដ្ឋកិច្ចពិសេស | ៨០០ ០០០ |
| ៤៣ | ប្រធានសាខាកាំកុងត្រូល | ៨០០ ០០០ |
| ៤៤ | អនុប្រធានមជ្ឈមណ្ឌលមន្ទីរពិសោធន៍ឧស្សាហកម្មកម្ពុជា | ៨០០ ០០០ |
| ៤៥ | អនុប្រធានមជ្ឈមណ្ឌលផលិតភាពជាតិ | ៨០០ ០០០ |
| ៤៦ | អនុប្រធានវិទ្យាស្ថានបណ្តុះបណ្តាលពាណិជ្ជកម្មនិងស្រាវជ្រាវ | ៨០០ ០០០ |
| ៤៧ | អនុប្រធានផ្នែកនៃទីភ្នាក់ងារជាតិមុខរបរនិងការងារ | ៨០០ ០០០ |
| ៤៨ | អនុប្រធានផ្នែក ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី | ៨០០ ០០០ |
| ៤៩ | អធិការរងថ្នាក់កណ្តាល | ៨០០ ០០០ |
| ៥០ | នាយអធិការដ្ឋានរដ្ឋបាលជលផល | ៨០០ ០០០ |
| ៥១ | នាយអធិការដ្ឋានរដ្ឋបាលព្រៃឈើ | ៨០០ ០០០ |
| ៥២ | ប្រធានអង្គភាពលទ្ធកម្ម(ថ្នាក់កណ្តាល) | ៨០០ ០០០ |
| ៥៣ | នាយករងអាកាសយានដ្ឋានអន្តរជាតិ | ៨០០ ០០០ |
| ៥៤ | នាយករងពុទ្ធសាសនបណ្ឌិត្យ | ៨០០ ០០០ |
| ៥៥ | អនុប្រធានអង្គភាពស៊ើបអង្កេតគ្រោះថ្នាក់អាកាសចរណ៍ | ៨០០ ០០០ |
| ៥៦ | នាយករងទីចាត់ការពន្ធដាររាជធានីភ្នំពេញ | ៨០០ ០០០ |
| ៥៧ | អនុប្រធានមន្ទីរពិសោធន៍ជាតិកសិកម្ម អគ្គនាយកដ្ឋានកសិកម្ម | ៨០០ ០០០ |
| ៥៨ | អនុប្រធានមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៨០០ ០០០ |
| ៥៩ | ប្រធានមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៦៦០ ០០០ |
| ៦០ | ប្រធានមន្ទីរពិសោធន៍រូប-គីមីសាស្ត្រទឹក ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៦៦០ ០០០ |
| ៦១ | ប្រធានមន្ទីរពិសោធន៍រូប-គីមីសាស្ត្រម្ហូបអាហារ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៦៦០ ០០០ |
| ៦២ | ប្រធានមន្ទីរពិសោធន៍រូប-គីមីសាស្ត្រមិនមែនម្ហូបអាហារ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៦៦០ ០០០ |
| ៦៣ | ប្រធានមន្ទីរពិសោធន៍មេកានិក អគ្គិសនី និងអេឡិចត្រូនិក ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៦៦០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ៦៤ | ប្រធានមជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី | ៦៦០ ០០០ |
| ៦៥ | អនុប្រធានសាខាកាំកុងត្រូល | ៦៦០ ០០០ |
| ៦៦ | ប្រធានប៉ុស្តិ៍កាំកុងត្រូល | ៦៣០ ០០០ |
| ៦៧ | ប្រធានការិយាល័យថ្នាក់កណ្តាល | ៦៣០ ០០០ |
| ៦៨ | ប្រធានក្រុមកិច្ចការ ក្រសួងកិច្ចការនារី | ៦៣០ ០០០ |
| ៦៩ | ប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួង ស្ថាប័ន | ៦៣០ ០០០ |
| ៧០ | ប្រធានមន្ទីរពិសោធន៍សម្ភារបរិក្ខារ ផលិតផលសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៦៣០ ០០០ |
| ៧១ | ប្រធានមន្ទីរពិសោធន៍ភូគព្ភសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៦៣០ ០០០ |
| ៧២ | នាយខណ្ឌរដ្ឋបាលជលផល | ៦៣០ ០០០ |
| ៧៣ | នាយខណ្ឌរដ្ឋបាលព្រៃឈើ | ៦៣០ ០០០ |
| ៧៤ | ប្រធានមន្ទីរពិសោធន៍រដ្ឋបាលជលផល | ៦៣០ ០០០ |
| ៧៥ | ប្រធានមន្ទីរពិសោធន៍រដ្ឋបាលព្រៃឈើ | ៦៣០ ០០០ |
| ៧៦ | ប្រធានមជ្ឈមណ្ឌលរដ្ឋបាលជលផល | ៦៣០ ០០០ |
| ៧៧ | ប្រធានមជ្ឈមណ្ឌលរដ្ឋបាលព្រៃឈើ | ៦៣០ ០០០ |
| ៧៨ | នាយរងអធិការដ្ឋានរដ្ឋបាលជលផល | ៦៣០ ០០០ |
| ៧៩ | នាយរងអធិការដ្ឋានរដ្ឋបាលព្រៃឈើ | ៦៣០ ០០០ |
| ៨០ | អនុប្រធានអង្គភាពលទ្ធកម្ម(ថ្នាក់កណ្តាល) | ៦៣០ ០០០ |
| ៨១ | នាយកអាកាសយានដ្ឋានជាតិ | ៦៣០ ០០០ |
| ៨២ | អនុប្រធានការិយាល័យថ្នាក់កណ្តាល | ៥៥០ ០០០ |
| ៨៣ | អនុប្រធានក្រុមកិច្ចការ ក្រសួងកិច្ចការនារី | ៥៥០ ០០០ |
| ៨៤ | នាយរងខណ្ឌរដ្ឋបាលជលផល | ៥៥០ ០០០ |
| ៨៥ | នាយរងខណ្ឌរដ្ឋបាលព្រៃឈើ | ៥៥០ ០០០ |
| ៨៦ | អនុប្រធានប៉ុស្តិ៍កាំកុងត្រូល | ៥៥០ ០០០ |
| ៨៧ | អនុប្រធានមន្ទីរពិសោធន៍មីក្រូជីវសាស្ត្រ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៥៥០ ០០០ |
| ៨៨ | អនុប្រធានមន្ទីរពិសោធន៍រូប-គីមីសាស្ត្រទឹក ក្រសួងឧស្សាហកម្មនិងសិប្បកម្ម | ៥៥០ ០០០ |
| ៨៩ | អនុប្រធានមន្ទីរពិសោធន៍រូប-គីមីសាស្ត្រម្ហូបអាហារ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៥៥០ ០០០ |
| ៩០ | អនុប្រធានមន្ទីរពិសោធន៍រូប-គីមីសាស្ត្រមិនមែនម្ហូបអាហារ ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៥៥០ ០០០ |
| ៩១ | អនុប្រធានមន្ទីរពិសោធន៍មេកានិក អគ្គិសនី និងអេឡិចត្រូនិក ក្រសួងឧស្សាហកម្ម និងសិប្បកម្ម | ៥៥០ ០០០ |
| ៩២ | អនុប្រធានមន្ទីរពិសោធន៍រដ្ឋបាលជលផល | ៥៥០ ០០០ |
| ៩៣ | អនុប្រធានមន្ទីរពិសោធន៍រដ្ឋបាលព្រៃឈើ | ៥៥០ ០០០ |
| ៩៤ | អនុប្រធានមជ្ឈមណ្ឌលរដ្ឋបាលជលផល | ៥៥០ ០០០ |
| ៩៥ | អនុប្រធានមជ្ឈមណ្ឌលរដ្ឋបាលព្រៃឈើ | ៥៥០ ០០០ |
| ៩៦ | អនុប្រធានមជ្ឈមណ្ឌលជំរុញការច្នៃប្រឌិត និងបង្កើតថ្មី | ៥៥០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ៩៧ | អនុប្រធានមន្ទីរពិសោធន៍សម្ភារបរិក្ខារ ផលិតផលសំណង់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៥៥០ ០០០ |
| ៩៨ | អនុប្រធានមន្ទីរពិសោធន៍ភូគព្ភសាស្ត្រ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៥៥០ ០០០ |
| ៩៩ | អនុប្រធានក្រុមត្រួតពិនិត្យហិរញ្ញវត្ថុ អមក្រសួង ស្ថាប័ន | ៥៥០ ០០០ |
| ១០០ | នាយករងអាកាសយានដ្ឋានជាតិ | ៥៥០ ០០០ |
| ១០១ | អ្នកផលិតឧបករណ៍សិប្បនិម្មិតនិងរណបជាន់ខ្ពស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥៣០ ០០០ |
| ១០២ | ភ្នាក់ងារប្រឹក្សាផ្តល់យោបល់(មន្ត្រីបច្ចេកទេសជាន់ខ្ពស់) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥៣០ ០០០ |
| ១០៣ | ភ្នាក់ងារសង្គមកិច្ច(មន្ត្រីបច្ចេកទេសជាន់ខ្ពស់) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥៣០ ០០០ |
| ១០៤ | ទីប្រឹក្សាផ្នែកច្បាប់ពាក់ព័ន្ធនឹងកុមារ(មន្ត្រីបច្ចេកទេសជាន់ខ្ពស់) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥៣០ ០០០ |
| ១០៥ | មន្ត្រីផ្នែកចិត្តវិទ្យា(មន្ត្រីបច្ចេកទេសជាន់ខ្ពស់) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥៣០ ០០០ |
| ១០៦ | មន្ត្រីអភិវឌ្ឍន៍សហគមន៍(មន្ត្រីបច្ចេកទេសជាន់ខ្ពស់) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥៣០ ០០០ |
| ១០៧ | មន្ត្រីគ្រប់គ្រងរដ្ឋបាល ឬមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឬមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬ មន្ត្រីការទូតជាន់ខ្ពស់ | ៥០០ ០០០ |
| ១០៨ | ភ្នាក់ងារប្រឹក្សាផ្តល់យោបល់(មន្ត្រីបច្ចេកទេសមធ្យម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០០ ០០០ |
| ១០៩ | អ្នកផលិតឧបករណ៍សិប្បនិម្មិតនិងរណបមធ្យម(មន្ត្រីបច្ចេកទេសមធ្យម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៥០០ ០០០ |
| ១១០ | មន្ត្រីក្រមការ ឬមន្ត្រីបច្ចេកទេសមធ្យម ឬមន្ត្រីក្រមការការបរទេស | ៤៩០ ០០០ |
| ១១១ | លេខាធិការរដ្ឋបាល ឬមន្ត្រីបច្ចេកទេសបឋម | ៤៨០ ០០០ |
| ១១២ | ភ្នាក់ងារសង្គមកិច្ច(មន្ត្រីបច្ចេកទេសបឋម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៨០ ០០០ |
| ១១៣ | អ្នកផលិតឧបករណ៍សិប្បនិម្មិតនិងរណបបឋម(មន្ត្រីបច្ចេកទេសបឋម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៨០ ០០០ |
| ១១៤ | មន្ត្រីអភិវឌ្ឍន៍សហគមន៍(មន្ត្រីបច្ចេកទេសបឋម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៨០ ០០០ |
| ១១៥ | អ្នកជំនួយការបច្ចេកទេសផលិត និងដំឡើងរទេះរុញ(មន្ត្រីបច្ចេកទេសបឋម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៨០ ០០០ |
| ១១៦ | អ្នកជំនួយការបច្ចេកទេសផលិត និងដំឡើងគ្រឿងផ្សំឧបករណ៍សិប្បនិម្មិត (មន្ត្រីបច្ចេកទេសបឋម) ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | ៤៨០ ០០០ |

## ១.២ ថ្នាក់ក្រោមជាតិ

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អភិបាលរាជធានី ខេត្ត | ១ ០១០ ០០០ |
| ២ | អភិបាលរងរាជធានី ខេត្ត | ៩០០ ០០០ |
| ៣ | នាយករដ្ឋបាលសាលារាជធានី ខេត្ត | ៨៧០ ០០០ |
| ៤ | អភិបាលក្រុង ស្រុក ខណ្ឌ | ៨៤០ ០០០ |
| ៥ | ប្រធានសាខាពន្ធដារខេត្ត ខណ្ឌ | ៨០០ ០០០ |
| ៦ | ប្រធានសាខាគយ និងរដ្ឋាករាជធានី ខេត្ត | ៨០០ ០០០ |
| ៧ | ប្រធានរតនាគាររាជធានី ខេត្ត | ៨០០ ០០០ |
| ៨ | នាយករងរដ្ឋបាលសាលារាជធានី ខេត្ត | ៨០០ ០០០ |
| ៩ | ប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៨០០ ០០០ |
| ១០ | នាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ ក្រសួងអភិវឌ្ឍន៍ជនបទ | ៨០០ ០០០ |
| ១១ | ប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ | ៨០០ ០០០ |
| ១២ | អភិបាលរងក្រុង ស្រុក ខណ្ឌ | ៦៨០ ០០០ |
| ១៣ | អនុប្រធានសាខាពន្ធដារខេត្ត ខណ្ឌ | ៦៣០ ០០០ |
| ១៤ | អនុប្រធានសាខាគយ និងរដ្ឋាករាជធានី ខេត្ត | ៦៣០ ០០០ |
| ១៥ | អនុប្រធានរតនាគាររាជធានី ខេត្ត | ៦៣០ ០០០ |
| ១៦ | នាយកទីចាត់ការសាលារាជធានី ខេត្ត | ៦៣០ ០០០ |
| ១៧ | ប្រធានផ្នែកនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | ៦៣០ ០០០ |
| ១៨ | អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៦៣០ ០០០ |
| ១៩ | ប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត | ៦៣០ ០០០ |
| ២០ | នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | ៦៣០ ០០០ |
| ២១ | ប្រធានអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត | ៦៣០ ០០០ |
| ២២ | នាយករងមជ្ឈមណ្ឌលអភិវឌ្ឍន៍ជនបទកម្ពុជា-កូរ៉េ ក្រសួងអភិវឌ្ឍន៍ជនបទ | ៦៣០ ០០០ |
| ២៣ | អនុប្រធានឧទ្យានសួនសត្វ និងមជ្ឈមណ្ឌលសង្គ្រោះសត្វព្រៃភ្នំតាម៉ៅ | ៦៣០ ០០០ |
| ២៤ | នាយករងទីចាត់ការសាលារាជធានី ខេត្ត | ៥៥០ ០០០ |
| ២៥ | អនុប្រធានផ្នែកនៃការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត | ៥៥០ ០០០ |
| ២៦ | អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត | ៥៥០ ០០០ |
| ២៧ | នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | ៥៥០ ០០០ |
| ២៨ | ប្រធានការិយាល័យសាលារាជធានី ខេត្ត | ៥៥០ ០០០ |
| ២៩ | ប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ៥៥០ ០០០ |
| ៣០ | ប្រធានអង្គភាពរដ្ឋាករទឹកមន្ទីរជំនាញរាជធានី ខេត្ត | ៥៥០ ០០០ |
| ៣១ | នាយផ្នែករដ្ឋបាលជលផល | ៥៥០ ០០០ |
| ៣២ | នាយផ្នែករដ្ឋបាលព្រៃឈើ | ៥៥០ ០០០ |
| ៣៣ | អនុប្រធានអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត | ៥៥០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ៣៤ | អនុប្រធានការិយាល័យសាលារាជធានី ខេត្ត | ៥៣០ ០០០ |
| ៣៥ | អនុប្រធានអង្គភាពរដ្ឋាករទឹកមន្ទីរជំនាញរាជធានី ខេត្ត | ៥៣០ ០០០ |
| ៣៦ | ប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | ៥៣០ ០០០ |
| ៣៧ | មន្ត្រីនៃការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ | ៥៣០ ០០០ |
| ៣៨ | ប្រធានការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ | ៥៣០ ០០០ |
| ៣៩ | ប្រធានអង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌ | ៥៣០ ០០០ |
| ៤០ | អនុប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ៥៣០ ០០០ |
| ៤១ | ប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ៥៣០ ០០០ |
| ៤២ | នាយរងផ្នែករដ្ឋបាលជលផល | ៥៣០ ០០០ |
| ៤៣ | នាយរងផ្នែករដ្ឋបាលព្រៃឈើ | ៥៣០ ០០០ |
| ៤៤ | អនុប្រធានអង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌ | ៥១០ ០០០ |
| ៤៥ | អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ៥១០ ០០០ |
| ៤៦ | អនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | ៥១០ ០០០ |
| ៤៧ | អនុប្រធានការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ | ៥១០ ០០០ |
| ៤៨ | មន្ត្រីគ្រប់គ្រងរដ្ឋបាល ឬមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឬមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬមន្ត្រីការទូតជាន់ខ្ពស់ | ៥០០ ០០០ |
| ៤៩ | ស្មៀនឃុំ សង្កាត់ | ៤៩០ ០០០ |
| ៥០ | មន្ត្រីក្រមការ ឬមន្ត្រីបច្ចេកទេសមធ្យម ឬមន្ត្រីក្រមការការបរទេស | ៤៩០ ០០០ |
| ៥១ | លេខាធិការរដ្ឋបាល ឬមន្ត្រីបច្ចេកទេសបឋម | ៤៨០ ០០០ |
| ៥២ | ឆ្មាំឆ្នេរសមុទ្រ | ៤៨០ ០០០ |
| ៥៣ | ឧទ្យានុរក្ស | ៤៨០ ០០០ |

## ២. វិស័យអប់រំ

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | នាយកសាលាភូមិន្ទរដ្ឋបាល | ១ ៨៣០ ០០០ |
| ២ | នាយកវិទ្យាស្ថានជាតិអប់រំ | ១ ២៦០ ០០០ |
| ៣ | នាយកវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១ ២៦០ ០០០ |
| ៤ | នាយកវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ១ ២៦០ ០០០ |
| ៥ | ប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ | ១ ២៦០ ០០០ |
| ៦ | នាយកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ១ ១១០ ០០០ |
| ៧ | សាកលវិទ្យាធិការ | ១ ១១០ ០០០ |
| ៨ | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ១ ១១០ ០០០ |
| ៩ | នាយកវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ១ ១១០ ០០០ |
| ១០ | នាយកវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ១ ១១០ ០០០ |
| ១១ | នាយកវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ១ ១១០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១២ | នាយកវិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ | ១ ១១០ ០០០ |
| ១៣ | នាយកវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ១ ១១០ ០០០ |
| ១៤ | នាយកវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | ១ ១១០ ០០០ |
| ១៥ | នាយកវិទ្យាស្ថានគរុកោសល្យបាត់ដំបង | ១ ១១០ ០០០ |
| ១៦ | នាយករងសាលាភូមិន្ទរដ្ឋបាល | ១ ០៨០ ០០០ |
| ១៧ | នាយកវិទ្យាស្ថានជាតិទេសចរណ៍ | ១ ០១០ ០០០ |
| ១៨ | ប្រធានវិទ្យាស្ថាន(ប្រៃសណីយ៍) | ១ ០១០ ០០០ |
| ១៩ | អគ្គនាយកវិទ្យាស្ថានស្តង់ដារកម្ពុជា | ១ ០១០ ០០០ |
| ២០ | នាយកសាលាវិជ្ជាជីវៈទេសចរណ៍ | ១ ០១០ ០០០ |
| ២១ | នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន | ១ ០១០ ០០០ |
| ២២ | អនុប្រធានវិទ្យាស្ថាន(ប្រៃសណីយ៍) | ៩៣០ ០០០ |
| ២៣ | នាយករងវិទ្យាស្ថានជាតិទេសចរណ៍ | ៩៣០ ០០០ |
| ២៤ | អគ្គនាយករងវិទ្យាស្ថានស្តង់ដារកម្ពុជា | ៩៣០ ០០០ |
| ២៥ | នាយករងវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ៩៣០ ០០០ |
| ២៦ | អនុប្រធានវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ | ៩៣០ ០០០ |
| ២៧ | នាយករងវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | ៩០០ ០០០ |
| ២៨ | នាយកមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល | ៩០០ ០០០ |
| ២៩ | នាយកសាលាពន្ធដារ | ៩០០ ០០០ |
| ៣០ | នាយកសាលាជាតិគយ | ៩០០ ០០០ |
| ៣១ | នាយកវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៩០០ ០០០ |
| ៣២ | សាកលវិទ្យាធិការរង | ៩០០ ០០០ |
| ៣៣ | នាយករងវិទ្យាស្ថានជាតិអប់រំ | ៩០០ ០០០ |
| ៣៤ | នាយកវិទ្យាស្ថានជាតិអប់រំពិសេស | ៩០០ ០០០ |
| ៣៥ | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | ៩០០ ០០០ |
| ៣៦ | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ៩០០ ០០០ |
| ៣៧ | នាយកវិទ្យាស្ថានបណ្តុះបណ្តាលបច្ចេកទេសសាធារណការនិងដឹកជញ្ជូន | ៩០០ ០០០ |
| ៣៨ | នាយកវិទ្យាស្ថាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៩០០ ០០០ |
| ៣៩ | នាយករងវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៩០០ ០០០ |
| ៤០ | នាយករងវិទ្យាស្ថានជាតិពហុបច្ចេកទេសកម្ពុជា | ៩០០ ០០០ |
| ៤១ | នាយករងវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៩០០ ០០០ |
| ៤២ | នាយករងវិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍ | ៩០០ ០០០ |
| ៤៣ | នាយករងវិទ្យាស្ថានជាតិពាណិជ្ជសាស្ត្រ | ៩០០ ០០០ |
| ៤៤ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៩០០ ០០០ |
| ៤៥ | នាយករងវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | ៩០០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ៤៦ | នាយករងវិទ្យាស្ថានគរុកោសល្យបាត់ដំបង | ៩០០ ០០០ |
| ៤៧ | ប្រធានមជ្ឈមណ្ឌល(ប្រៃសណីយ៍) | ៩០០ ០០០ |
| ៤៨ | ប្រធានមជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទា | ៩០០ ០០០ |
| ៤៩ | ព្រឹទ្ធបុរសមហាវិទ្យាល័យ(ប្រៃសណីយ៍) | ៩០០ ០០០ |
| ៥០ | នាយកសាលាមធ្យមវិចិត្រសិល្បៈ | ៩០០ ០០០ |
| ៥១ | នាយកសាលាបណ្តុះបណ្តាលគ្រូបខណ្ឌវប្បធម៌ | ៩០០ ០០០ |
| ៥២ | នាយកវិទ្យាស្ថានជាតិអធិការកិច្ច | ៩០០ ០០០ |
| ៥៣ | នាយករងសាលាជាតិរដ្ឋបាលមូលដ្ឋាន | ៩០០ ០០០ |
| ៥៤ | នាយកទីចាត់ការសាលាជាតិរដ្ឋបាលមូលដ្ឋាន | ៩០០ ០០០ |
| ៥៥ | នាយកសាលាជាតិកសិកម្មកំពង់ចាម | ៩០០ ០០០ |
| ៥៦ | នាយកសាលាជាតិកសិកម្មព្រែកលៀប | ៩០០ ០០០ |
| ៥៧ | ព្រឹទ្ធបុរសមហាវិទ្យាល័យ/ប្រធានផ្នែកនៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៩០០ ០០០ |
| ៥៨ | ប្រធានផ្នែក/ប្រធានដេប៉ាតឺម៉ង់នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៩០០ ០០០ |
| ៥៩ | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ | ៩០០ ០០០ |
| ៦០ | នាយកមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអប់រំបច្ចេកទេស | ៩០០ ០០០ |
| ៦១ | នាយកពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ ក្រសួងធម្មការនិងសាសនា | ៩០០ ០០០ |
| ៦២ | ប្រធានមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៩០០ ០០០ |
| ៦៣ | នាយកផ្នែកសិក្សា សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៩០០ ០០០ |
| ៦៤ | នាយកផ្នែកស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៩០០ ០០០ |
| ៦៥ | នាយកផ្នែកឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៩០០ ០០០ |
| ៦៦ | នាយកសាលាក្រោយឧត្តម សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៩០០ ០០០ |
| ៦៧ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៨៧០ ០០០ |
| ៦៨ | នាយកសាលាក្រោយឧត្តម(សាកលវិទ្យាល័យជាតិគ្រប់គ្រង) | ៨៧០ ០០០ |
| ៦៩ | នាយករងសាលាវិជ្ជាជីវៈទេសចរណ៍ | ៨៧០ ០០០ |
| ៧០ | នាយកប្រតិបត្តិសាខា សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ | ៨៧០ ០០០ |
| ៧១ | នាយកវិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍ | ៨៧០ ០០០ |
| ៧២ | ប្រធានមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ | ៨៧០ ០០០ |
| ៧៣ | នាយកវិទ្យាស្ថានភាសាបរទេស | ៨៧០ ០០០ |
| ៧៤ | នាយកមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន | ៨៧០ ០០០ |
| ៧៥ | នាយកមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ | ៨៧០ ០០០ |
| ៧៦ | ប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៨៧០ ០០០ |
| ៧៧ | សាស្ត្រាចារ្យ | ៨៧០ ០០០ |
| ៧៨ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៨៦០ ០០០ |
| ៧៩ | នាយករងសាលាក្រោយឧត្តម(សាកលវិទ្យាល័យជាតិគ្រប់គ្រង) | ៨៦០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ៨០ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ/អនុប្រធានផ្នែកនៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ | ៨៦០ ០០០ |
| ៨១ | អនុប្រធានផ្នែក/អនុប្រធានដេប៉ាតឺម៉ង់នៃវិទ្យាស្ថានជាតិបណ្ដុះបណ្ដាលបច្ចេកទេស | ៨៦០ ០០០ |
| ៨២ | នាយករងប្រតិបត្តិសាខា សាកលវិទ្យាល័យ ជា ស៊ីម កំចាយមារ | ៨៦០ ០០០ |
| ៨៣ | នាយករងវិទ្យាស្ថានអភិវឌ្ឍន៍សហគមន៍ | ៨៦០ ០០០ |
| ៨៤ | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវនិងនវានុវត្តន៍ | ៨៦០ ០០០ |
| ៨៥ | នាយករងវិទ្យាស្ថានភាសាបរទេស | ៨៦០ ០០០ |
| ៨៦ | នាយករងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-ជប៉ុន | ៨៦០ ០០០ |
| ៨៧ | នាយករងមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ | ៨៦០ ០០០ |
| ៨៨ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៨៦០ ០០០ |
| ៨៩ | សាស្ត្រាចារ្យរង | ៨៣០ ០០០ |
| ៩០ | ប្រធានដេប៉ាតឺម៉ង់នៃសាលាវិជ្ជាជីវៈទេសចរណ៍ | ៨០០ ០០០ |
| ៩១ | នាយករងសាលាមធ្យមវិចិត្រសិល្បៈ | ៨០០ ០០០ |
| ៩២ | នាយករងសាលាពន្ធដារ | ៨០០ ០០០ |
| ៩៣ | នាយករងសាលាជាតិគយ | ៨០០ ០០០ |
| ៩៤ | នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | ៨០០ ០០០ |
| ៩៥ | នាយករងវិទ្យាស្ថានជាតិអធិការកិច្ច | ៨០០ ០០០ |
| ៩៦ | នាយករងសាលាបណ្ដុះបណ្ដាលក្របខណ្ឌវប្បធម៌ | ៨០០ ០០០ |
| ៩៧ | អនុប្រធានមជ្ឈមណ្ឌលស្រាវជ្រាវវប្បធម៌វិទ្យាសាស្ត្រ | ៨០០ ០០០ |
| ៩៨ | អនុប្រធានមជ្ឈមណ្ឌល(ប្រៃសណីយ៍) | ៨០០ ០០០ |
| ៩៩ | អនុប្រធានមជ្ឈមណ្ឌលជាតិព្យាបាលនិងស្ដារនីតិសម្បទា | ៨០០ ០០០ |
| ១០០ | អនុប្រធានមជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ | ៨០០ ០០០ |
| ១០១ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ(ប្រៃសណីយ៍) | ៨០០ ០០០ |
| ១០២ | ប្រធានលេខាធិការដ្ឋាន(ប្រៃសណីយ៍) | ៨០០ ០០០ |
| ១០៣ | នាយករងមជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល | ៨០០ ០០០ |
| ១០៤ | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ៨០០ ០០០ |
| ១០៥ | នាយកសាលាគរុកោសល្យនិងវិក្រឹតការរាជធានី ខេត្ត | ៨០០ ០០០ |
| ១០៦ | នាយករងសាលាជាតិកសិកម្មកំពង់ចាម | ៨០០ ០០០ |
| ១០៧ | នាយករងសាលាជាតិកសិកម្មព្រែកលៀប | ៨០០ ០០០ |
| ១០៨ | នាយករងមជ្ឈមណ្ឌលតំបន់អាស៊ីអាគ្នេយ៍សម្រាប់ការអប់រំបច្ចេកទេស | ៨០០ ០០០ |
| ១០៩ | នាយករងពុទ្ធិកមជ្ឈមណ្ឌលគរុកោសល្យ ក្រសួងធម្មការនិងសាសនា | ៨០០ ០០០ |
| ១១០ | នាយករងវិទ្យាស្ថានជាតិអប់រំពិសេស | ៨០០ ០០០ |
| ១១១ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ស្ពឺ | ៨០០ ០០០ |
| ១១២ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាល | ៨០០ ០០០ |
| ១១៣ | នាយករងវិទ្យាស្ថាន ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ៨០០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១១៤ | នាយករងទីចាត់ការសាលាជាតិរដ្ឋបាលមូលដ្ឋាន | ៨០០ ០០០ |
| ១១៥ | នាយកមជ្ឈមណ្ឌល/នាយកសាលាបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៨០០ ០០០ |
| ១១៦ | នាយករងផ្នែកសិក្សា សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៨០០ ០០០ |
| ១១៧ | នាយករងផ្នែកស្រាវជ្រាវ សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៨០០ ០០០ |
| ១១៨ | នាយករងផ្នែកឆ្នាំសិក្សាមូលដ្ឋាន សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៨០០ ០០០ |
| ១១៩ | នាយករងសាលាក្រោយឧត្តម សាកលវិទ្យាល័យភូមិន្ទកសិកម្ម | ៨០០ ០០០ |
| ១២០ | នាយកមជ្ឈមណ្ឌល ក្រសួងអភិវឌ្ឍន៍ជនបទ | ៧៩០ ០០០ |
| ១២១ | អនុប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៧៩០ ០០០ |
| ១២២ | នាយករងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ៧៩០ ០០០ |
| ១២៣ | សាស្ត្រាចារ្យជំនួយ | ៧៩០ ០០០ |
| ១២៤ | គ្រូឧទ្ទេសឧត្តមសិក្សា(ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ៧៥០ ០០០ |
| ១២៥ | គ្រូឧទ្ទេសកម្រិតឧត្តម នៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស | ៧៥០ ០០០ |
| ១២៦ | នាយកវិទ្យាល័យ | ៧៣០ ០០០ |
| ១២៧ | នាយកអនុវិទ្យាល័យ | ៧០០ ០០០ |
| ១២៨ | គ្រូឧទ្ទេសរងឧត្តមសិក្សា(វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ) | ៧០០ ០០០ |
| ១២៩ | គ្រូឧទ្ទេសរងឧត្តមសិក្សា(វិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង) | ៧០០ ០០០ |
| ១៣០ | នាយកសាលាបឋមសិក្សា | ៦៨០ ០០០ |
| ១៣១ | អធិការមធ្យមសិក្សា | ៦៨០ ០០០ |
| ១៣២ | គ្រូឧទ្ទេសមធ្យមសិក្សាទុតិយភូមិ(ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ៦៨០ ០០០ |
| ១៣៣ | គ្រូឧទ្ទេសជំនួយឧត្តមសិក្សា(វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ) | ៦៨០ ០០០ |
| ១៣៤ | គ្រូឧទ្ទេសជំនួយឧត្តមសិក្សា(វិទ្យាស្ថានគរុកោសល្យខេត្តបាត់ដំបង) | ៦៨០ ០០០ |
| ១៣៥ | ប្រធានដេប៉ាតឺម៉ង់ | ៦៨០ ០០០ |
| ១៣៦ | ប្រធានដេប៉ាតឺម៉ង់/ប្រធានការិយាល័យនៃវិទ្យាស្ថាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦៨០ ០០០ |
| ១៣៧ | អនុប្រធានដេប៉ាតឺម៉ង់/អនុប្រធានការិយាល័យនៃវិទ្យាស្ថាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦៧០ ០០០ |
| ១៣៨ | នាយកសាលាមត្តេយ្យសិក្សា | ៦៧០ ០០០ |
| ១៣៩ | អនុប្រធានដេប៉ាតឺម៉ង់នៃសាលាវិជ្ជាជីវៈទេសចរណ៍ | ៦៧០ ០០០ |
| ១៤០ | អនុប្រធានលេខាធិការដ្ឋាន(ប្រៃសណីយ៍) | ៦៧០ ០០០ |
| ១៤១ | ប្រធានដេប៉ាតឺម៉ង់(ប្រៃសណីយ៍) | ៦៧០ ០០០ |
| ១៤២ | គ្រូឧទ្ទេសកម្រិតមូលដ្ឋាន(ក្របខណ្ឌគ្រូបង្រៀនកម្រិតមូលដ្ឋាន) | ៦៧០ ០០០ |
| ១៤៣ | ប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៦៧០ ០០០ |
| ១៤៤ | នាយកសាលាបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | ៦៧០ ០០០ |
| ១៤៥ | គ្រូឧទ្ទេសកម្រិតមូលដ្ឋាននៃវិទ្យាស្ថានជាតិបណ្តុះបណ្តាលបច្ចេកទេស ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦៧០ ០០០ |
| ១៤៦ | អនុប្រធានដេប៉ាតឺម៉ង់ | ៦៧០ ០០០ |

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១៤៧ | គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅឧត្តមសិក្សា) | ៦៦០ ០០០ |
| ១៤៨ | អនុប្រធានមជ្ឈមណ្ឌលបច្ចេកវិទ្យាព័ត៌មាន សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | ៦៦០ ០០០ |
| ១៤៩ | គ្រូបច្ចេកទេសកម្រិតឧត្តម(Technical) បង្រៀននៅវិទ្យាស្ថាន មជ្ឈមណ្ឌល សាលា នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៦៦០ ០០០ |
| ១៥០ | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូអប់រំកាយ និងកីឡា | ៦៦០ ០០០ |
៣- ច្បាប់ឈប់សម្រាកលំហែមាតុភាព មានរយៈពេល៣ខែ
៤- ច្បាប់ឈប់សម្រាកព្យាបាលជំងឺ មានរយៈពេល១២ខែក្នុងអំឡុងពេលបម្រើការងារជាមន្ត្រី
៥- ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន មានរយៈពេល៣ខែក្នុងអំឡុងពេលបម្រើការងារជាមន្ត្រី

ក្រសួង ស្ថាប័ន.............................................
អង្គភាព..................................................

ឧបសម្ព័ន្ធទី៤នៃអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ២០១៦

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# ព្រឹត្តិបត្រការងារប្រចាំឆ្នាំរបស់មន្ត្រីរាជការស៊ីវិល

**ឈ្មោះ**.............................................**ភេទ**..................**ថ្ងៃខែឆ្នាំកំណើត**..........................................................**អត្តលេខ**..........................................................

| ប្រភេទនៃច្បាប់ឈប់គ្រប់ប្រភេទរបស់មន្ត្រីរាជការស៊ីវិល | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១.ច្បាប់ឈប់ប្រចាំឆ្នាំ មានចំនួន ១៥ថ្ងៃនៃថ្ងៃធ្វើការ/១ឆ្នាំ | | | | | | ២.ច្បាប់ឈប់រយៈពេលខ្លីមានចំនួន ១៥ថ្ងៃ នៃថ្ងៃធ្វើការ/១ឆ្នាំ | | ៣.ច្បាប់ឈប់សម្រាកលំហែមាតុភាពមានចំនួន ៣ខែ | ៤.ច្បាប់ឈប់សម្រាកព្យាបាលជំងឺមានចំនួន ១២ខែ (សម្រាប់មួយជីវិតជាមន្ត្រី) | | ៥.ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួនមានចំនួន ៣ខែ (សម្រាប់មួយជីវិតជាមន្ត្រី) | | ទណ្ឌកម្មវិន័យ និងវិធានការ |
| ចំនួនថ្ងៃដែលមិនទាន់បានអនុវត្តក្នុងឆ្នាំចាស់ | ចំនួនថ្ងៃដែលត្រូវទូទាត់សង | | ចំនួនថ្ងៃឈប់សម្រាកប្រចាំឆ្នាំបន្ថែម | ចំនួនថ្ងៃដែលបានអនុវត្តរួច | ចំនួនថ្ងៃដែលមិនទាន់បានអនុវត្ត | ចំនួនថ្ងៃដែលបានអនុវត្តរួច | ចំនួនថ្ងៃដែលមិនទាន់បានអនុវត្ត | | ចំនួនខែដែលបានអនុវត្តរួច | ចំនួនខែដែលមិនទាន់បាន អនុវត្ត | ចំនួនខែដែលបានអនុវត្តរួច | ចំនួនខែដែលមិនទាន់បានអនុវត្ត | |
| | ឆ្នាំចាស់ | ឈប់សម្រាកផ្សេងៗ | | | | | | | | | | | |
| | | | | | | | | | | | | | |
| | | | | | | | | | | | | | |

- អវត្តមានមានច្បាប់អនុញ្ញាតប្រចាំឆ្នាំ : ........................
- អវត្តមានគ្មានច្បាប់អនុញ្ញាតប្រចាំឆ្នាំ : ........................
- ទំនេរគ្មានបៀវត្ស : ..........................................
- ផ្សេងៗ : ..........................................

ធ្វើនៅ ថ្ងៃទី ខែ ឆ្នាំ២០១.....
ប្រធាន..................................

សម្គាល់ : ទណ្ឌកម្មវិន័យអនុវត្តចំពោះអវត្តមានគ្មានច្បាប់អនុញ្ញាតៈ
១- មន្ត្រីរាជការស៊ីវិល
- ការស្តីបន្ទោស
- ការស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ការផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យឬការលុបឈ្មោះចេញពីតារាងដំឡើងឋានន្តរស័ក្តិឬថ្នាក់
- ការលុបឈ្មោះចេញពីក្របខណ្ឌ។

២- មន្ត្រីជាប់កិច្ចសន្យា
- ណែនាំលើកទី១
- ណែនាំចុងក្រោយ
- លុបឈ្មោះពីអង្គភាពសាមី។

ប្រភេទច្បាប់ឈប់សម្រាករបស់មន្ត្រីរាជការស៊ីវិលរួមមានៈ
១- ច្បាប់ឈប់ប្រចាំឆ្នាំ មានរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ/១ឆ្នាំ
២- ច្បាប់ឈប់រយៈពេលខ្លី មានរយៈពេល១៥ថ្ងៃនៃថ្ងៃធ្វើការ/១ឆ្នាំ
៣- ច្បាប់ឈប់សម្រាកលំហែមាតុភាព មានរយៈពេល៣ខែ
៤- ច្បាប់ឈប់សម្រាកព្យាបាលជំងឺ មានរយៈពេល១២ខែក្នុងអំឡុងពេលបម្រើការងារជាមន្ត្រី
៥- ច្បាប់ឈប់សម្រាកដោយមានកិច្ចការផ្ទាល់ខ្លួន មានរយៈពេល៣ខែក្នុងអំឡុងពេលបម្រើការងារជាមន្ត្រី

## លក្ខណសម្បត្តិនិងឧត្តមនិស្ស័យតាមមុខតំណែងនីមួយៗ

<table>
<tr><th>ឧបនិស្ស័យមុខតំណែង</th><th>ក្របខ័ណ្ឌ ឋានន្តរស័ក្តិ</th><th>លក្ខណសម្បត្តិ</th></tr>
<tr><td colspan="3">រាជធានី ខេត្ត</td></tr>
<tr><td>- នាយករងរដ្ឋបាលសាលារាជធានី ខេត្ត<br>- នាយកទីចាត់សាលារាជធានី ខេត្ត</td><td rowspan="2">- នាយក្រមការ</td><td>- មានអតីតភាពការងារយ៉ាងតិច ០៥ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីភាពល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។</td></tr>
<tr><td>- ប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត</td><td>- មានអតីតភាពការងារយ៉ាងតិច ០៥ឆ្នាំ<br>- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្ររងផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុ<br>- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុយ៉ាងតិច ០៣ឆ្នាំ<br>- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- មានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។</td></tr>
</table>

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| | រាជធានី ខេត្ត | |
| - នាយករងទីចាត់ការសាលារាជធានី ខេត្ត<br>- អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត<br>- ប្រធានការិយាល័យសាលារាជធានី ខេត្ត | - ក្រមការដើមខ្សែ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីភាពល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- - មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យសាលារាជធានី ខេត្ត | - ក្រមការ | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការចាត់ចែងការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| | ក្រុង ស្រុក ខណ្ឌ | |
| - នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ- - ប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | - ក្រមការ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - ប្រធានអង្គភាពលទ្ធកម្មក្រុង ស្រុក ខណ្ឌ | | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានកម្រិតវប្បធម៌ចាប់ពីបរិញ្ញាបត្ររងផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុ<br>- មានបទពិសោធន៍ការងារផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុយ៉ាងតិច ០៣ឆ្នាំ<br>- ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលផ្នែកលទ្ធកម្មសាធារណៈ ដោយមានវិញ្ញាបនបត្របញ្ជាក់ពីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ<br>- មានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ<br>- អនុប្រធានអង្គភាពលទ្ធកម្មក្រុងស្រុកខណ្ឌ | - នាយលេខាធិការរដ្ឋបាល | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការអនុវត្តការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| មន្ទីរ អង្គភាពជំនាញរាជធានី ខេត្ត | | |
| - ប្រធានមន្ទីរ អង្គភាព | - ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទក | - មានអតីតភាពការងារយ៉ាងតិច ០៥ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានមន្ទីរ អង្គភាព | - ឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - ប្រធានការិយាល័យ | - ឋានន្តរស័ក្តិទី២នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យ | - ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការអនុវត្តការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

| ឧបនិស្ស័យមុខតំណែង | ក្របខ័ណ្ឌ ឋានន្តរស័ក្តិ | លក្ខណសម្បត្តិ |
|---|---|---|
| ការិយាល័យ អង្គភាពជំនាញក្រុង ស្រុក ខណ្ឌ | | |
| - ប្រធានការិយាល័យ អង្គភាព | - ឋានន្តរស័ក្តិទី៣នៃក្របខ័ណ្ឌប្រភេទ ខ | - មានអតីតភាពការងារយ៉ាងតិច ០៤ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការដឹកនាំនិងគ្រប់គ្រង<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |
| - អនុប្រធានការិយាល័យ អង្គភាព | - ឋានន្តរស័ក្តិទី១នៃក្របខ័ណ្ឌប្រភេទ គ | - មានអតីតភាពការងារយ៉ាងតិច ០៣ឆ្នាំ<br>- មានបទពិសោធន៍និងសមត្ថភាពក្នុងការអនុវត្តការងារ<br>- មានគំនិតផ្តួចផ្តើមក្នុងការអនុវត្តការងារ<br>- មានសីលធម៌ គុណធម៌ និងមនសិការវិជ្ជាជីវៈ<br>- មានសាមគ្គីល្អនិងមានស្មារតីទទួលខុសត្រូវក្នុងការងារ<br>- មានសុខភាពល្អ។ |

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

**រាជធានីភ្នំពេញ**
**រដ្ឋបាលខណ្ឌចំការមន**
លេខ៖......................រ.ប.ក

# របាយការណ៍បូកសរុប
## ស្តីពី
## លទ្ធផលការងាររដ្ឋបាលខណ្ឌចំការមន ប្រចាំឆ្នាំ២០១៩ និងលើកទិសដៅឆ្នាំ២០២០

## I- សេចក្តីផ្តើម

កម្ពុជាជារដ្ឋទោល ដែលក្នុងនោះរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវបានបង្កើតឡើងនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ រដ្ឋបាលថ្នាក់ក្រោមជាតិនេះត្រូវបានបែងចែកជាពីរប្រភេទ គឺរដ្ឋបាលតំបន់ និងរដ្ឋបាលមូលដ្ឋាន។ រដ្ឋបាលតំបន់សំដៅទៅលើរដ្ឋបាលខេត្ត។ រដ្ឋបាលមូលដ្ឋានរួមមាន រដ្ឋបាលដែលមានបីថ្នាក់ គឺរដ្ឋបាលរាជធានី ខណ្ឌ សង្កាត់ និងរដ្ឋបាលដែលមានពីរថ្នាក់ គឺរដ្ឋបាលក្រុង សង្កាត់ និងរដ្ឋបាលស្រុក ឃុំ។ បច្ចុប្បន្ន នៅទូទាំងប្រទេសរួមមាន រាជធានីចំនួន១ ខេត្តចំនួន២៤ ក្រុងចំនួន២៦ ស្រុកចំនួន១៥៩ ខណ្ឌចំនួន១២ ឃុំ សង្កាត់ចំនួន១.៦៣៣ និងភូមិចំនួន១៤.១៤៧ ដែលថ្នាក់ដឹកនាំភូមិត្រូវបានបោះឆ្នោតជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សាឃុំ សង្កាត់។

រដ្ឋបាលថ្នាក់ក្រោមជាតិមានក្រុមប្រឹក្សាកើតចេញពីការបោះឆ្នោតជាតំណាង។ ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់ មានភារកិច្ចអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ហើយក្រុមប្រឹក្សាមានសិទ្ធិត្រួតពិនិត្យមើលពីលើការអនុវត្តនេះ។ ទន្ទឹមនឹងនេះ ច្បាប់រៀបចំអង្គការបានប្រគល់តួនាទីឱ្យអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌជាតំណាងឱ្យក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងការសម្របសម្រួលជាមួយមន្ទីរ អង្គភាពខ្សែបណ្តោយរបស់ក្រសួង ស្ថាប័នទាំងនោះផងដែរ។

យោងមាត្រា ៥០. ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំដែលពាក់ព័ន្ធ :

- ដីកា និងសេចក្តីសម្រេចនានាដែលបានដាក់ចេញ
- សកម្មភាពនានាដែលបានអនុវត្ត
- របាយការណ៍ហិរញ្ញវត្ថុ
- ការវាយតម្លៃការបំពេញការងាររបស់គណៈអភិបាល និងបុគ្គលិកក្រុមប្រឹក្សា
- លទ្ធផលនៃការតាមដាន និងវាយតម្លៃ ដូចមានចែងក្នុងមាត្រា ៤០ នៃច្បាប់នេះ
- វិធានការចាំបាច់ ដើម្បីធ្វើឱ្យប្រសើរឡើងនូវការអនុវត្តការងាររបស់ក្រុមប្រឹក្សា ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តរបាយការណ៍ប្រចាំឆ្នាំខាងលើនេះ មិនឱ្យលើសពីសែសិបប្រាំ (៤៥) ថ្ងៃ បន្ទាប់ពីដំណាច់ឆ្នាំ។

និងយោងតាមមាត្រា ១៦៣ ច្បាប់ស្តីពី ការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គណៈអភិបាល ត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តនូវ :

- កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិលប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ

- ផែនការអភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំនិង ក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដូចមានចែងក្នុងមាត្រា ៥០ នៃច្បាប់នេះដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ដូច្នេះនេះហើយទើបក្រុមប្រឹក្សាខណ្ឌ និងគណៈអភិបាលខណ្ឌ បានរៀបចំរបាយការណ៍ប្រចាំនេះឡើង និងបានសរសេររៀបរាប់អំពីស្ថានភាពទូទៅ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌ ការបង្ហាញពីការងារនានាដែលសម្រេចបានក្នុងរយៈពេលពេញ ១ឆ្នាំ២០១៩ របស់រដ្ឋបាលខណ្ឌចំការមន ការិយាល័យជំនាញ ការងាររដ្ឋបាលសង្កាត់ និងបានលើកយកពីបញ្ហាប្រឈមនានា ដំណោះស្រាយ សេចក្តីសន្និដ្ឋាន និងការលើកទិសដៅអនុវត្តការងារសម្រាប់ឆ្នាំ២០២០ ។

យើងខ្ញុំសង្ឃឹមថា ការធ្វើសន្និបាតនឹងបន្តជួយអោយរដ្ឋបាលខណ្ឌចំការមន បានផ្សព្វផ្សាយអំពីលទ្ធផលការងារកន្លងមកស្វែងរកបញ្ហាប្រឈម ដែលបានកើតមានកន្លងមក និងក៏ដូចជាបញ្ហាដែលអាចនឹងកើតមាននៅពេលខាងមុខ ហើយយើងរួមគ្នាក្នុងការស្វែងរកដំណោះស្រាយជាក់លាក់អាចអនុវត្តបាន និងការលើកទិសដៅអនុវត្តការងារសម្រាប់ឆ្នាំ ២០២០។

## II- ស្ថានភាពទូទៅ និងរចនាសម្ព័ន្ធ

### ១- ស្ថានភាពទូទៅ

ខណ្ឌចំការមនត្រូវបានបំបែកជា២ យោងតាមអនុក្រឹត្យ លេខ: ០៣ អនក្រ.បក ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ ២០១៩ ដោយបង្កើតខណ្ឌបឹងកេងកងថ្មី សាលាខណ្ឌចំការមន ជាសាលាខណ្ឌបឹងកេងកងថ្មី និង ទីតាំងសាលាខណ្ឌចំការមនថ្មី ត្រូវស្ថិតនៅសង្កាត់ទន្លេបាសាក់ ។ ការបំបែកខណ្ឌនេះបានបន្សល់ទុកអោយខណ្ឌចំការមន មានតែ ៥ សង្កាត់ ដូចតទៅ ទន្លេបាសាក់ ទួលទំពូងទី១ ទួលទំពូងទី២ បឹងត្របែក និង ផ្សារដើមថ្កូវ។

ខណ្ឌចំការមន គឺជាខណ្ឌមួយក្នុងចំណោមខណ្ឌទាំង១៤នៃរាជធានីភ្នំពេញ ដែលមានព្រំប្រទល់ ខាងកើតទល់នឹងខណ្ឌច្បារអំពៅ ដោយដងទន្លេបាសាក់, ខាងលិចទល់នឹងខណ្ឌបឹងកេងកង, ខាងត្បូងទល់នឹងខណ្ឌមានជ័យ, ខាងជើងទល់នឹងខណ្ឌដូនពេញ (ផ្ទៃដីសរុបមានទំហំ ៧,១៥១,៤២៤.៥៧ម៉ែត្រការ៉េ ស្មើនឹង ៧១៥ហិកតា ១៤អា និង២៤ទីអា។

ទីតាំងបណ្តោះអាសន្នរបស់សាលាខណ្ឌចំការមន ត្រូវបានផ្លាស់ប្តូរមកទីស្នាក់ការថ្មីជាបណ្តោះអាសន្នដែលស្ថិតនៅអាគារ Sales Center (ជាប់ស្ថានីយពន្លត់អគ្គីភ័យកោះពេជ្រ) ក្នុងទីក្រុងកោះពេជ្រ វិថីកោះពេជ្រ ភូមិ ១៤ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ចាប់ពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០១៩ ។

| ល.រ | ការបរិយាយ | សរុប | ឯកត្តា |
|---|---|---|---|
| ១ | ផ្ទៃដីសរុប | ៧,១៥១,៤២៤.៥៧ | ម៉ែត្រការ៉េ |
| ២ | ចំនួនសង្កាត់ | ០៥ | សង្កាត់ |
| ៣ | ចំនួនភូមិ | ៣៨ | ភូមិ |
| ៤ | ចំនួនគ្រួសារ | ៩,៤៤២ | គ្រួសារ |
| ៥ | ចំនួនប្រជាពលរដ្ឋ | ៤៧,០៥៣ | នាក់ |
| ៦ | ចំនួនស្ត្រីសរុប | ២២,៦១២ | នាក់ |

# ២- រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌចំការមន



III- **លទ្ធផលសម្រេចបាន**

- **ផ្នែកទី១ ការងារគណៈអភិបាល ក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

**១.១- ការងាររបស់គណៈអភិបាល**

១.១.១- កិច្ចប្រជុំគណៈអភិបាល (រួមទាំងការអនុវត្តតួនាទីជាតំណាងក្រសួង ស្ថាប័ន)

ប្រជុំអឌ្ឍមាសរបស់គណៈអភិបាលមានចំនួន ១២លើក ការប្រជុំប្រចាំខែរបស់គណៈអភិបាល មាន១២លើ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | ១២ |
| ២ | កិច្ចប្រជុំប្រចាំខែ(អឌ្ឍមាសទី២)របស់គណៈអភិបាល | ១២ |

**១.១.២- សកម្មភាពការងាររបស់គណៈអភិបាល**

**១. លោក ថេង សុធុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន ៖**

- អញ្ជើញចូលរួមអបអរទិវាជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ធ្នូ ២០១៩ នៅសាលមហោស្រពកោះពេជ្រ។
- អញ្ជើញចុះត្រួតពិនិត្យការដ្ឋានសំណង់ខុនដូរ ធេនហៅស៍ ស្ថិតនៅដីឡូត៍លេខ៨៨៣ ផ្លូវសុធារស ភូមិ៥ សង្កាត់ទន្លេបាសាក់។
- ដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះការពារក្បួនគណៈប្រតិភូ នៅចំណុចមុខទីស្នាក់ការធ្វេរបី ផ្លូវរដ្ឋសភា ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់។
- ដឹកនាំកិច្ចប្រជុំសម្របសម្រួលទីតាំងលក់ដូររបស់អាជីវករក្នុងវិទ្យាល័យ ហ៊ុនសែន ប៊ុនរ៉ានី ផ្សារដើមថ្កូវ នៅសាលាខណ្ឌចំការមន។
- ដឹកនាំកិច្ចប្រជុំគណៈអភិបាលខណ្ឌចំការមន នៅសាលាខណ្ឌចំការមន។
- ដឹកនាំកិច្ចប្រជុំជាមួយក្រុមការងារសម្របសម្រួលជាមួយប្រជាពលរដ្ឋ ក្នុងការបុកសៀផាយប្រឡាយបឹងត្របែក ក្នុងសង្កាត់ផ្សារដើមថ្កូវ។
- អញ្ជើញចូលរួមសិក្ខាសាលាជាតិ ស្តីពីការរៀបចំផែនការសកម្មភាពនិងថវិកា ឆ្នាំ២០២០ នៃគណៈកម្មាធិការជាតិ
- សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ( គ.ជ.អ.ប.) នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកិច្ចប្រជុំលើកទី៤ នៃគណៈកម្មការរៀបចំមហាសន្និបាត របស់សមាគម អន្តរជាតិនៃអភិបាលក្រុងប្រើប្រាស់ភាសាបារាំង(AIMF) លើកទី៣៩ ឆ្នាំ២០១៩ នៅសណ្ឋាគារសុខាភ្នំពេញ។
- អញ្ជើញជាអធិបតីភាពក្នុងវេទិកាសាធារណៈប្រចាំខែរបស់រដ្ឋបាលសង្កាត់ផ្សារដើមថ្កូវ នៅចំណុចផ្លូវ៩៧ ភូមិ៥ (សហគមន៍រុងរឿង) សង្កាត់ផ្សារដើមថ្កូវ។
- អញ្ជើញចូលរួមគោរពវិញ្ញាណក្ខ័ន្ធសព ឧបាសក ភូ មិន ដែលត្រូវជាឪពុករបស់កញ្ញា ភូ ហ៊ិចឃីន ជាមន្ត្រីនៃរដ្ឋបាលខណ្ឌចំការមន នៅផ្ទះលេខ៤៣ ផ្លូវ១៣ ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ។
- អញ្ជើញចូលរួមជាកិត្តិយស ក្នុងពិធីបញ្ចុះបឋមសិលាសាងសង់ផ្សារទំនើប សេនជូរី ផ្លាហ្សា ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកិច្ចប្រជុំ ស្តីការពង្រឹងការអនុវត្តសារាចរលេខ១១ សរ. របស់រាជរដ្ឋាភិបាល ស្តីពីការលុប ការបង់

ថ្លៃ ចំពោះប្រជាពលរដ្ឋលក់ដូរតាមកញ្ច្រែង កញ្ជើ ល្អី ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។

- រៀបចំយុទ្ធនាការសម្អាត អនាម័យបរិស្ថានតាមបណ្តោយផ្លូវលេខ ១០៥ ក្នុងសង្កាត់ទួលទំពូងទី១ សង្កាត់បឹងត្របែក និង សង្កាត់ផ្សារដើមថ្កូវ។
- ចូលរួមទិវាអន្តរជាតិរំលឹក ដល់ជនរងគ្រោះ ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោកលើកទី១៤ ក្រោមអធិបតីភាព**សម្តេចក្រឡាហោម ស ខេង** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិសុវត្ថិភាពចរាចរណ៍ផ្លូវគោក។
- ចូលរួមពិធីបង្សុកូល ដើម្បីឧទ្ទិសកុសល ជូនវិញ្ញាណក្ខន្ធជនរងគ្រោះ ក្នុងឧបទ្ទវហេតុអតីតស្ពានពេជ្រ នៃទីក្រុងកោះពេជ្រ កាលពីថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី** អភិបាលរងរាជធានីភ្នំពេញ។
- អញ្ជើញអមដំណើរ **ឯកឧត្តម មាន ចាន់យ៉ាដា** អភិបាលរងរាជធានីភ្នំពេញ ចុះត្រួតពិនិត្យតាមគោលដៅការពារ តំបន់ការពារA5 និងរៀបចំសណ្តាប់ធ្នាប់ក្នុងឱកាសប្រារព្ធ ពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។
- រៀបចំកម្លាំងសណ្តាប់ធ្នាប់ខណ្ឌចំការមន ឲ្យឈរជើងការពារនៅមុខអគារកូរ៉េ, រង្វង់មូលសម្តេច ជួន ណាត និងសួនច្បារ សម្តេច ហ៊ុន សែន ដើម្បីរក្សាសុខសុវត្ថិភាព ជូនប្រជាពលរដ្ឋ ក្នុងឱកាសប្រារព្ធ ពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក។
- អញ្ជើញចូលរួមកិច្ចប្រជុំ ស្តីពីការត្រៀមរៀបចំសម្អាត ប្រមូល និងដឹកជញ្ជូនសំរាមសម្រាប់ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុកឆ្នាំ២០១៩ ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាលនៃ គណៈអភិបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញជាអធិបតីភាពក្នុងពិធីសំណេះសំណាល ជាមួយកម្លាំងសណ្តាប់ធ្នាប់ និងក្រុមការងារប្រតិកម្មរហ័សខណ្ឌ-សង្កាត់ និងបានបែងចែកម៉ូតូ០៥គ្រឿង ដែលជាអំណោយរបស់សាលារាជធានីភ្នំពេញ ជូនដល់សាលាសង្កាត់ទាំង០៥ សម្រាប់ ប្រើប្រាស់ប្រមូលសំរាមក្នុងមូលដ្ឋានសង្កាត់នីមួយៗ នៅសាលាខណ្ឌចំការមន។
- ចុះជួបសំណេះសំណាលជាមួយប្រជាការពារសង្កាត់ទាំង៥ ដើម្បីពង្រឹងស្មារតី កម្លាំងឲ្យយកចិត្តទុកដាក់អំពីតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការរក្សាសន្តិសុខ សណ្តាប់ធ្នាប់ក្នុងមូលដ្ឋាន។

- ដឹកនាំមន្ត្រីក្រោមឱវាទ ចូលរួមអង្គកឋិនទានរបស់ **ឯកឧត្តមបណ្ឌិត អ៊ិត សំហេង** នៅទីស្តីការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។
- អញ្ជើញជាអធិបតីភាពក្នុងពិធីបើកបវេសនកាលឆ្នាំ២០១៩-២០២០ នៅវិទ្យាល័យទួលទំពូង។
- អញ្ជើញជាអធិបតីភាពក្នុងពិធីផ្សព្វផ្សាយ ទប់ស្កាត់ការរីករាលមេរោគអេដស៍ ជំងឺអេដស៍ នៅទីស្នាក់ការប្រចាំការឆ្នេរ៣ សង្កាត់ទន្លេបាសាក់។
- អញ្ជើញចូលរួមអង្គកឋិនទាន ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានី ភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញចូលរួមថ្វាយកម្រងផ្កា គោរពវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ" គម្រប់ខួប៧ឆ្នាំ ដឹកនាំដោយលោក **ឯកឧត្តម ឃួង ស្រេង** អភិបាលរាជធានីភ្នំពេញ។
- ដឹកនាំមន្ត្រីខណ្ឌ អមដំណើរឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ ចុះត្រួត

ពិនិត្យ ការសង់ពង្រីកស្ពានអាកាសក្បាលថ្នល់ ការពង្រីកផ្លូវ និងការជួសជុលដាក់ប្រព័ន្ធលូថ្មី។

- អញ្ជើញចូលរួមពិធីបុណ្យឆ្លងអន្តេវាសិកដ្ឋាន(កុដិ) នៅវត្តស្វាយពពែ សង្កាត់ទន្លេបាសាក់ ក្រោមព្រះរាជាធិបតីភាព របស់សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតីកិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះមហាសង្ឃ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា។
- អញ្ជើញចុះត្រួតពិនិត្យការដាក់ប្រព័ន្ធលូថ្មី នៅចំណុច ផ្លូវលេខ៩ ភូមិ៣ សង្កាត់ទន្លេបាសាក់។
- ដឹកនាំកិច្ចប្រជុំពិភាក្សាស្តីពីសំណួរ សំណើរ សំណូមពររបស់ប្រជាពលរដ្ឋ ដែលបានលើកឡើងក្នុងវេទិកាសាធារណៈ សង្កាត់បឹងត្របែក។
- អញ្ជើញចូលរួមក្នុងពិធីផ្សព្វផ្សាយ និងដាក់ឲ្យអនុវត្តអនុក្រឹត្យស្តីពីមុខងារនិង រចនាសម្ព័ន្ធរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងអនុក្រឹត្យស្តីពីការប្រគល់មុខងារគ្រប់គ្រង និងផ្តល់សេវាសុខាភិបាលទៅ ឲ្យរដ្ឋបាល រាជធានីភ្នំពេញ ក្រោមអធិបតីភាព **សម្តេចក្រឡាហោម ស ខេង** ឧបនាយករដ្ឋមន្ត្រី មន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប នៅសាលប្រជុំអគារ «ទ» ទីស្តីការក្រសួងមហាផ្ទៃ។

២. **លោកស្រី កែវ សាម៉ុល អភិបាលរងខណ្ឌចំការមន ៖**

- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌ ចំការមន អញ្ជើញចូលរួមពិធីប្រកាសតែងតាំងប្រធាន អនុប្រធានលេខាធិការដ្ឋានរៀបចំការបោះឆ្នោតរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- តំណាងលោក **ថេង សុថុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញជាអធិបតីភាព ក្នុងវេទិកា សាធារណៈរបស់សាលាសង្កាត់បឹងត្របែក។
- តំណាងលោក **ថេង សុថុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកិច្ចប្រជុំប្រចាំខែរបស់ការិយាល័យ ច្រកចេញចូលតែមួយនៅសាលាខណ្ឌចំការមន។
- រដ្ឋបាលខណ្ឌចំការមន បានបើក កិច្ចប្រជុំស្តីពីទិន្នន័យទីតាំងនិង ស្ថានភាព អគាររដ្ឋបាលក្រុង-ស្រុក ឃុំ-សង្កាត់ នៅសាលាខណ្ឌចំការមន ក្រោមអធិបតីភាព លោកស្រី កែវ សាម៉ុល និងលោក អាំង សិរីពិសិដ្ឋ អភិបាលរងខណ្ឌ តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌ ចំការមន។
- អញ្ជើញចូលរួមកិច្ច ប្រជុំស្តីពីទិន្នន័យទីតាំងនិងស្ថានភាពអគាររដ្ឋបាលក្រុង-ស្រុក ឃុំ-សង្កាត់ ក្រោមអធិបតីភាព **ឯកឧត្តម កើត ឆែ** អភិបាលរងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមកិច្ចប្រជុំស្តីពីគម្រោងផែនការថវិកាឆ្នាំ ២០២០ នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញចូលរួមប្រជុំ ស្តីពីគម្រោងសិក្សារៀបចំនិងកែលម្អផ្លូវថ្មើរជើង តាមបណ្តោយមហាវិថីម៉ៅសេទុង នៅសាលារាជធានីភ្នំពេញ។
- បានដឹកនាំមន្ត្រី ក្រោមឱវាទចូលរួមទិវាបរិស្ថាននៅសួនច្បារវត្តបុទុមវត្តី ក្រោមអធិបតីភាព **ឯកឧត្តម ឃួត ហៃ** អភិបាលរងរាជធានីភ្នំពេញ។
- អញ្ជើញចូលរួម ពិធីបិទកីឡាពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន លើកទី១៣ ឆ្នាំ ២០១៩ នៅពហុកីឡដ្ឋានជាតិអូឡាំពិក។
- បានដឹកនាំកម្លាំង គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌចំការមន ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះនៅចំណុចផ្លូវរដ្ឋសភា កែងផ្លូវ៧៨ ក្នុងសង្កាត់ទន្លេបាសាក់។
- បានចូលរួមជាមួយសាខាកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ បាននាំយក អំណោយមនុស្សធម៌ របស់អនុសាខាផ្តល់ជូនលោកតា ឡុង សាម៉ុន អាយុ៧៥ឆ្នាំ ដែលមានជីវភាពខ្វះខាតស្នាក់នៅ ក្នុងវត្តថាន់ សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមពិធីប្រគល់

ទេយ្យទានសាលាគណរាជធានីភ្នំពេញ និងសាលា អនុគណទាំង១៤ខណ្ឌ ជូនចំពោះកាកបាទក្រហមកម្ពុជារាជធានីភ្នំពេញ។

៣. **លោក កែវ សំណាង អភិបាលរងខណ្ឌចំការមន ៖**

- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌ ចំការមន បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះបង្រ្កាបទីតាំងអាជីវកម្មមជ្ឈមណ្ឌលកំសាន្ត សម្រាប់ កុមារហ្គេម វើលដ៍ ដែលស្ថិតនៅក្រោយស្ពានទូតអូស្ត្រាលី ផ្លូវលេខ៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន បានចុះត្រួតពិនិត្យរដ្ឋបាលនៅចំណុចកោះពេជ្រ ផ្លូវបេតុង ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់។
- បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះត្រួតពិនិត្យរដ្ឋបាលរោងស្នាក់នៅកម្មករកោះពេជ្រ ផ្លូវបេតុង ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់។
- សហការជាមួយសង្កាត់ទន្លេបាសាក់ អញ្ជើញចុះណែនាំនិងធ្វើកិច្ចសន្យាជាមួយប្រជាពលរដ្ឋឲ្យរុះរើតូបនៅក្រោមស្ពានព្រះមុនីវង្ស។
- បានដឹកនាំកម្លាំងចម្រុះ ចុះបង្រ្កាបទីតាំងហ្គេមបាញ់ត្រី នៅចំណុចផ្ទះគ្មានលេខ ផ្លូវ១០១ ក្រុម៣១ ភូមិ៥ សង្កាត់ផ្សារដើមថ្កូវ។
- អញ្ជើញចូលរួមកិច្ចប្រជុំ ពិភាក្សាលើសំណើសុំក្នុងការរៀបចំពិធីផ្សេងៗ ក្នុងពិធីបុណ្យឯករាជ្យជាតិ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក នៅសាលារាជធានីភ្នំពេញ។
- បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌចំការមន ចុះត្រួតពិនិត្យអាវុជាតិផ្ទុះនៅចំណុចមុខផ្ទះ៣ ផ្លូវរដ្ឋសភា សង្កាត់ទន្លេបាសាក់។
- បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌចំការមន ចុះត្រួតពិនិត្យរដ្ឋបាលនៅចំណុចតារាងបាល់ទះលេខ១៦៨ ផ្លូវ៤៧៤ ក្រុម២៧ ភូមិ៨ សង្កាត់បឹងត្របែក។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានអញ្ជើញចូលរួមប្រជុំស្តីពិភាក្សា ស្តីពីការត្រៀមលក្ខណៈរៀបចំពិធីទទួលទានអំបុក ដើម្បីការពារជាតិ សាសនា ព្រះមហាក្សត្រ នៅថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០១៩ ក្រោមអធិបតីភាព ឯកឧត្តម មាន ចាន់យ៉ាដា អភិបាលរងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញចូលរួមប្រជុំ ត្រៀម រៀបចំកម្មវិធីបុណ្យឯករាជ្យជាតិ បុណ្យអុំទូកបណ្តែត អកអំបុក និងសំពះព្រះខែ និង បុណ្យសាកល នៅក្រសួង ព្រះបរមរាជវាំង។
- បានកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌចំការមន ចុះត្រួតពិនិត្យរដ្ឋបាលនៅចំណុចតារាងបាល់ទះលេខ១៦៨ ផ្លូវ៤៧៤ ក្រុម២៧ ភូមិ៨ សង្កាត់បឹងត្របែក។
- តំណាង លោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការតុបតែងលម្អអគារ ពាណិជ្ជកម្ម ដើម្បីចូលរួមអបអរសាទរទិវាបុណ្យឯករាជ្យជាតិ និងព្រះរាជពិធីបុណ្យអំទូក បណ្តែតប្រទីប និងសំពះ ព្រះខែ អកអំបុក និងពីធីបុណ្យចូលឆ្នាំសកលខាងមុខ សាលប្រជុំធំ អគារចាស់ ជាន់ទី២ ក្រោមអធិបតីភាព **ឯកឧត្តម មាន ចាន់យ៉ាដា** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ និង **ឯកឧត្តម ហួត ហៃ** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌ ចំការមន បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះនៅចំណុចក្បែរស្ថានទូត រុស្ស៊ី ផ្លូវរដ្ឋសភា សង្កាត់ទន្លេបាសាក់។

- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌ ចំការមន បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះត្រួតពិនិត្យរដ្ឋបាលនៅចំណុចកោះពេជ្រ ផ្លូវបេតុង ក្រុម៧៨ ភូមិ១៤ សង្កាត់ទន្លេបាសាក់។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ នៅចំណុចទីស្នាក់ការឆ្មេរបី ផ្លូវរដ្ឋសភា កែង ផ្លូវ៧៨ សង្កាត់ទន្លេបាសាក់។

៤. **លោក ម៉ុន សុវ័ណ្ណ អភិបាលរងខណ្ឌចំការមន ៖**

- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចុះ ពិនិត្យការដាក់លូនៅផ្លូវលេខ៩ ភូមិ៣ សង្កាត់ទន្លេបាសាក់។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ នៅចំណុចមុខស្នាក់ការឆ្មេរបី ផ្លូវរដ្ឋសភា កែង ផ្លូវ៧៨ សង្កាត់ទន្លេបាសាក់។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកិច្ចប្រជុំ សាមញ្ញ លើកទី៦ របស់ក្រុមប្រឹក្សាខណ្ឌចំការមន អាណត្តិទី៣ នៅសាលាខណ្ឌចំការមន។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមប្រជុំពិភាក្សាស្តីពីករណីល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ។
- បានដឹកនាំកម្លាំងគណៈបញ្ជាការឯកភាពខណ្ឌចំការមន ចុះត្រួតពិនិត្យអាវុធជាតិផ្ទុះ នៅចំណុចផ្លូវរដ្ឋសភា កែង ផ្លូវ៧៨ សង្កាត់ទន្លេបាសាក់។
- បានដឹកនាំយុវជន ខណ្ឌចំនួន៥០នាក់ ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយពីសភាពការណ៍បច្ចុប្បន្ននៅកម្ពុជា នៅទីស្តីការក្រសួងបរិស្ថាន។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីសំណើសុំកិច្ចសហការក្នុងការរៀបចំ ទិវាអន្តរជាតិរំលឹកដល់ជនរងគ្រោះ ដោយគ្រោះថ្នាក់ចរាចរណ៍ផ្លូវគោក លើកទី១៤ នាថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់អគ្គលេខាធិការដ្ឋាននៃគ.ស.ច.គ នៅសាលារាជធានីភ្នំពេញ។
- បានចុះពិនិត្យនិងណែនាំឲ្យ ក្រុមហ៊ុនត្រៀមកម្លាំងចូលអ៊ុតផ្លូវ៣០៦ ក្នុងសង្កាត់បឹងកេងកងទី១។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានអញ្ជើញចូលរួមកិច្ចប្រជុំពិភាក្សាស្តីពីការផ្សព្វផ្សាយការរៀបចំ និង កសាងផែនការអភិវឌ្ឍន៍រាជធានី ឆ្នាំ២០២០-២០២៤ ក្រោមអធិបតីភាព **ឯកឧត្តម ខួង ស្រេង** អភិបាលរងរាជធានីភ្នំពេញ។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមសិក្ខាសាលាបណ្តុះបណ្តាលស្តីពី «នីតិវិធីរៀបចំ និងអនុវត្ត ថវិកាសម្រាប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ» នៅសណ្ឋាគារហ្គោលដិនស៊ីធី។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមជំនួបពិភាក្សាការងារជាមួយក្រុមការងារបរិស្ថាន ទីក្រុង គីតាក្យូស៊ូ ដើម្បីជម្រាបជូនអំពីគ្រោងការនៃខ្លឹមសារ និងកាលបរិច្ឆេទនៃបេសកកម្មទៅលើ «គម្រោងធ្វើឲ្យប្រសើរ ឡើងការគ្រប់គ្រងសំណល់រឹងក្នុងរាជធានីភ្នំពេញ» ក្រោមអធិបតីភាព **ឯកឧត្តម ឃួង ម៉ែង** អភិបាលរងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌ ចំការមន អញ្ជើញចូលរួមកិច្ចប្រជុំស្តីពីការ

អនុញ្ញាតជីក និងខួងលើចិញ្ចើមផ្លូវនិងឆ្លងកាត់តាមបណ្តោយវិថី មហាវិថី ទាំង១៧ ក្រោមអធិបតីភាព **ឯកឧត្តម ស៊ុយ សេរិទ្ធិ** អភិបាលរងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។

៥. **លោក អ៊ាំង សិរីពិសិដ្ឋ អភិបាលខេខណ្ឌចំការមន ៖**

- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌ អញ្ជើញចូលរួម កិច្ចប្រជុំស្តីពីការពិនិត្យវឌ្ឍនភាពការងារលើវិស័យរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ រយៈពេល៥ខែ (ខែមិថុនា ដល់ ខែតុលា ឆ្នាំ២០១៩) ក្រោមអធិបតីភាព **ឯកឧត្តម ឃួត ហៃ** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញចូលរួមកិច្ច ប្រជុំពិភាក្សាបច្ចេកទេសសម្រាប់គម្រោងលំនៅដ្ឋានមានចីរភាព សម្រាប់ប្រជាជនបង្កើតគុណភាពរស់នៅក្នុងទីក្រុងនៃប្រទេសកម្ពុជា (Build People) ក្រោមអធិបតីភាព **ឯកឧត្តម នួន ផារ័ត្ន** អភិបាលរង រាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- អញ្ជើញចូលរួមពីធី ដង្ហែនិងបូជាព្រះសព សម្តេចព្រះរាជបុត្រីព្រះរៀម នរោត្តម បុប្ផាទេវី ឧត្តមក្រុមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និងជាសមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ នៅវត្តបុទុមវតី។
- តំណាងលោក **ថេង សុថុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញជាអធតិបតីភាព ក្នុងវេទិកាសាធារណៈ នៅចំណុចផ្លូវលំ ច្រកផ្លូវព្រះនរោត្តម មុខផ្ទះលេខ ២០០ ក្រុម១២០ ភូមិ១៦ សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញជាអធតិបតីភាពក្នុង វេទិកាសាធារណៈនៅដីឡូត៍លេខ១៤ ផ្លូវ៤៥៦ ក្រុម២២ ភូមិ៤ សង្កាត់ទួលទំពូងទី១។
- តំណាងលោក **ថេង សុថុល** អភិបាល នៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញជាអធតិបតីភាព ក្នុងវេទិកាសាធារណៈ(ប្រជុំភូមិ សង្កាត់មានសុវត្ថិភាព) របស់សាលាសង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកិច្ចប្រជុំដោះស្រាយទំនាស់រវាងដើមបណ្តឹងឈ្មោះ មុំ សំអែល និងឈ្មោះ ឡៅ អានី ទាក់ទងនឹងការសង់ជាប់ព្រំខុសគម្លាតដែលច្បាប់អនុញ្ញាត នៅសាលាខណ្ឌចំការមន។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានកោះអញ្ជើញដើមបណ្តឹងលោកស្រី ចាន់ មុន្នីរ័ត្ន ដែលបានប្តឹងក្រុមហ៊ុន ឆាយណាខន់ស្ត្រាក់សិនគ្រឹះស្ថានទី១ មកសាលាខណ្ឌចំការមន។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានចុះដោះស្រាយទំនាស់ នៅចំណុចផ្ទះលេខ២៥អឺ១ ផ្លូវសុជាវស ភូមិ៣ សង្កាត់ទន្លេបាសាក់។
- តំណាងលោក ថេង សុថុល អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមវេទិកាសាធារណៈ នៅភូមិ៤ សង្កាត់ទួលទំពូងទី១។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចុះត្រួតពិនិត្យ អាវុធជាតិផ្ទុះ នៅចំណុចផ្លូវវង្វេសភា កែងផ្លូវ៧៨ សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចុះត្រួតពិនិត្យ អាវុធជាតិផ្ទុះ នៅចំណុចជាប់របងស្ថានទូតរុស្ស៊ី ផ្លូវ វង្វេសភា សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុថុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានជួបប្រជាពលរដ្ឋ ប្រមាណ១០គ្រួសារ ដែលបានប្តឹងក្រុមហ៊ុនឆាយណាខន់ស្ត្រាក់សិនគ្រឹះស្ថានទី១ ដែលបានបង្កឲ្យមានផលប៉ះពាល់ ដល់ការរស់នៅរបស់ពួកគាត់ប្រចាំថ្ងៃ។

- តំណាងលោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានចុះត្រួតពិនិត្យ ការដ្ឋានសំណង់ស្នាក់ស្ថិតនៅផ្លូវ៤២០ ភូមិ៤ សង្កាត់បឹងត្របែក និងនៅដីឡូត៍លេខ៣៥ ផ្លូវ៤២០ ភូមិ៤ សង្កាត់បឹងត្របែក។
- តំណាងលោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានចុះដោះស្រាយ ទំនាស់ដល់ទីកន្លែងនៅចំណុចផ្ទះលេខ៧០អា ផ្លូវ១០៥ ភូមិ៤ សង្កាត់បឹងត្របែក។
- អញ្ជើញចូលរួមប្រជុំ ពិភាក្សាស្តីពីក្រុមហ៊ុនសាងសង់Cambodia First Unite Construction Group Co. Ltd បានចាក់បេតុងលើគម្រប Joint Pit No.1 នៃខ្សែបណ្តាញអគ្គិសនី 115KV ប្រភេទកាប្លិ៍កប់ដីនៅជិត Aoen Mall Cambodia No.1សម្រាប់ គម្រោងសាងសង់ខ្សែបណ្តាញបញ្ជូនអគ្គិសនី115KV ប្រភេទកាប្លិ៍កប់ដីនិងអនុស្ថានីយ៍អគ្គិសនីGS9 សួនច្បារសម្តេច ហ៊ុន សែន នៅនាយកដ្ឋានផែនការយុទ្ធសាស្ត្រ និងគម្រោងការនៃអគ្គិសនីកម្ពុជា។
- អញ្ជើញចូលរួមកិច្ចប្រជុំ ផែនការការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងឱកាសប្រារព្ធពិធីបុណ្យបុណ្យឯករាជ្យ និងព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ក្រោមអធិបតីភាព នាយឧត្តមសេនីយ៍ ទូច ណារ៉ុថ អគ្គស្នងការរងរាជធានីភ្នំពេញ។
- អញ្ជើញចូលរួមប្រជុំស្តីពី ការពង្រឹងការគ្រប់គ្រងដីចំណីផ្លូវនៃគម្រោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្តសាធារណៈការទាំងអស់ដែលបានសាងសង់ ស្តារ ថែទាំ ឬពង្រីករួចនាពេលកន្លងមក។
- តំណាង លោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចូលរួមកិច្ចប្រជុំស្តីលេខាធិការដ្ឋាននៃគណៈ កម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានីភ្នំពេញ (គ.រ.ប.ជ) សាលប្រជុំធំអគារថ្មីជាន់ទី១ ក្រោមអធិបតីភាព **លោកជំទាវ កែវ សុខពិសី** អភិបាលរង នៃគណៈអភិបាលរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ។
- តំណាងលោក **ថេង សុផុល** អភិបាល នៃគណៈអភិបាលខណ្ឌ ចំការមន អញ្ជើញបានដឹកនាំកិច្ចប្រជុំជាមួយចៅសង្កាត់ទាំង៥ ពាក់ព័ន្ធនិងការពង្រឹងការគ្រប់គ្រងច្បាប់សំណង់, ការគ្រប់គ្រងចំណីផ្លូវសាធារណៈ, ការស្រង់ឈ្មោះស្ថានីយ៍ប្រេងឥន្ធនៈ, ការធ្វើបច្ចុប្បន្នភាពកន្លែងលក់និងជួសជុល រថយន្ត, ការត្រួតពិនិត្យដើមឈើ និងការសាងសង់ស្លាកយីហោនិងការដាក់ទូរអេជីអឹម ដែលរំលោភចំណីផ្លូវ សាធារណៈនៅសាលាខណ្ឌចំការមន។
- តំណាងលោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន បានដឹកនាំកិច្ចប្រជុំសម្របសម្រួលទីតាំងលក់ដូររបស់អាជីវករ ក្នុងវិទ្យាល័យ ហ៊ុនសែន ប៊ុនរ៉ានី ផ្សារដើមថ្កូវ នៅសាលាខណ្ឌចំការមន។
- តំណាងលោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចុះត្រួតពិនិត្យការដ្ឋានសំណង់នៅក្បាលដីលេខ២៣៦ ផ្លូវសុធារស សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុផុល** អភិបាល នៃគណៈអភិបាលខណ្ឌ ចំការមន អញ្ជើញចុះត្រួតពិនិត្យនិងសិក្សាស្តីពីការពង្រីកផ្លូវ៨៣០ សង្កាត់ទន្លេបាសាក់។
- តំណាងលោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញចុះត្រួតពិនិត្យទីតាំងដាក់ប្រព័ន្ធលូ នៅផ្សារកាប់គោ និងបានពិភាក្សាគម្រោងមិនឲ្យមានការផ្ញើកង់ម៉ូតូ លើផ្លូវសាធារណៈ។
- តំណាងលោក **ថេង សុផុល** អភិបាលនៃគណៈអភិបាលខណ្ឌចំការមន អញ្ជើញកិច្ចប្រជុំស្តីពីការ ត្រួតពិនិត្យពង្រឹងការអនុវត្តច្បាប់ និងដោះស្រាយបញ្ហាប្រឈមនានា នៅសាលាដំបូងរាជធានីភ្នំពេញ។

## ១.២- ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌ ចំនួន ១២លើក, កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា ០១លើក, កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សាចំនួន ០១លើក, កិច្ចប្រជុំគណៈ កម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារចំនួន ១២លើក។

តារាងកិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ០៧ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ០១ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០១ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០០ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ១២ |

តារាងការរៀបចំវេទិកា

| ល.រ | ឈ្មោះវេទិកា | អ្នកចូលរួម | |
|---|---|---|---|
| | | សរុប | ស្រី |
| ១ | បានរៀបចំវេទិកាសាធារណៈអនុវត្តគោលនយោបាយភូមិ.សង្កាត់មានសុវត្ថិភាព ៦០លើក | ១,២៥៥ | ៦៤០ |
| ២ | បានរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌចំការមន ទាំង៥សង្កាត់ | ៣៩០ | ១២០ |
| ៣ | បានរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ | | |

ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក

| ល.រ | សូចនាករ | ផែនការប្រចាំឆ្នាំ | លទ្ធផលសម្រេច | |
|---|---|---|---|---|
| | | | ជាក់ស្តែង | ភាគរយ |
| ១ | ចំនួនកិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក នៅថ្នាក់ខណ្ឌ | ១២ | ១២ | ១០០% |
| ២ | ចំនួនថវិកាប្រចាំឆ្នាំសម្រាប់ចំណាយលើផ្នែកសេវាសង្គម (រៀល) | ០០ | ០០ | ០០ |
| ៣ | ខណ្ឌបានចងក្រងទិន្នន័យអគ្រានុកូលដ្ឋានដែលទទួលបានពីសង្កាត់ | ១៨០០ | ១,១៩១ | ៦៦% |
| ៤ | ចំនួនបេសកកម្មដែល គ.ក.ស.ក ខណ្ឌបានចុះគាំទ្រ និងផ្តល់សេវាសង្គម | ៣៦ | ៣៦ | ១០០% |
| ៥ | ចំនួនសង្កាត់ដែល គ.ក.ស.ក ខណ្ឌ បានចុះគាំទ្រ | ០៥ | ០៥ | ១០០% |
| ៦ | ចំនួនវគ្គបណ្តុះបណ្តាលដែល គ.ក.ស.ក ខណ្ឌបានទទួល | ០០ | ០០ | ០០ |

## ❖ ផ្នែកទី២ ការគ្រប់គ្រងរដ្ឋបាលខណ្ឌ

### ➢ ការិយាល័យរដ្ឋបាល

**១.ការងារលិខិតរដ្ឋបាល**

១.១- ដីកា

១.២- សេចក្តីសម្រេច ដែលបានដាក់ចេញចំនួន១៤ គឺ ៖

- សេចក្តីសម្រេចលេខ ០១/១៩ សសរ ចុះថ្ងៃទី១៧ ខែ មករា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការព័ត៌មាន និងប្រតិកម្មរហ័សខណ្ឌ ចំការមន។
- សេចក្តីសម្រេចលេខ ០២/១៩ សសរ ចុះថ្ងៃទី១១ ខែ កុម្ភៈ ឆ្នាំ២០១៩ ស្តីពីការបែងចែកតួនាទីភារកិច្ច របៀបរបបធ្វើការងារជូនអភិបាលខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ០៣/១៩ សសរ ចុះថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមប្រតិបត្តិការចម្រុះ ខណ្ឌចំការមន ដើម្បី ចូលរួមសហការអនុវត្តដីកាសម្រេច បង្គាប់ប្រគល់អចលវត្ថុ លេខ ៨២៣គ.រ ចុះថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០១៩ របស់ សាលាដំបូងរាជធានីភ្នំពេញ។
- សេចក្តីសម្រេចលេខ ០៤/១៩សសរ ចុះថ្ងៃទី២៥ ខែ កុម្ភៈ ឆ្នាំ២០១៩ ស្តីពីការបង្កើតរង្វាន់ទេយ្យបុរប្រទាន សម្រាប់ឆ្នាំ២០១៩។
- សេចក្តីសម្រេចលេខ ០៥/១៩ សសរ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៩ ស្តីពីបិទបញ្ជីថវិកាចំណូល-ចំណាយ ឆ្នាំ ២០១៨ របស់រដ្ឋបាល ខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ០៧/១៩ សសរ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ស្តីពីបង្កើតគណៈកម្មការគ្រប់គ្រង គម្រោងរបស់រដ្ឋបាល ខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ៦/១៩ សសរ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ស្តីពីការបែងចែកភារកិច្ច និងរបៀប រៀបរយធ្វើការងារជូនគណៈអភិបាលខណ្ឌចំការមននៃរាជធានីភ្នំពេញ។
- សេចក្តីសម្រេចលេខ ០៧/១៩ សសរ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០១៩ ស្តីពីបង្កើតគណៈកម្មការគ្រប់គ្រង គម្រោងរបស់រដ្ឋបាលខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ០២/១៩ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការលទ្ធ កម្ម (គ.ល) រដ្ឋបាលខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ០៣/១៩ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការ សម្របសម្រួលបច្ចេកទេស របស់ក្រុមប្រឹក្សាខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ០៤/១៩ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការ ពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមាររបស់ក្រុមប្រឹក្សាខណ្ឌចំកាមន។
- សេចក្តីសម្រេចលេខ ០៥/១៩ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការ គ្រប់គ្រងគម្រោងរបស់រដ្ឋបាលខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ០៦/១៩ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតគណៈកម្មាធិការ រៀបចំដែនដី និងនគរូបនីយកម្មខណ្ឌចំការមន។
- សេចក្តីសម្រេចលេខ ១៤/១៩ សសរ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៩ ស្តីពីការបង្កើតក្រុមការងារកសាង ផែនការអភិវឌ្ឍន៍ និង កម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលខណ្ឌចំការមន។

១.៣- លិខិតរដ្ឋបាល

- លិខិតរដ្ឋបាលដែលបានដាក់ចេញចំនួន ២,៤៤៥លិខិត និងទទួលបានចំនួន ២,៤៤៣លិខិត។

**តារាងសង្ខេបការងារលិខិតស្នាម**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ដីកាដែលបានដាក់ចេញ | ០១ |

| | | |
|---|---|---|
| ២ | សេចក្តីសម្រេចដែលបានដាក់ចេញ | ១៤ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ២,៤៤៥ |
| ៤ | លិខិតដែលបានទទួល | ២,៤៤៣ |
| ៥ | សៀវភៅស្នាក់នៅ | ២៧១ |

## ២. ការគ្រប់គ្រងប្រជាពលរដ្ឋ

ស្ថិតិប្រជាពលរដ្ឋមានចំនួន ៩,៤៤២គ្រួសារ , មនុស្សចំនួន ៤៧,០៥៣នាក់ ស្រីចំនួន ២២,៦១២នាក់ ប្រជាពលរដ្ឋខ្មែរ អាយុ ១៨ឆ្នាំឡើង ចំនួន ៣០,៣៦៩នាក់ ។

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៩,៤៤២ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៧,៣៣៨ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ១,៩៦៥ |
| ៤ | ប្រជាពលរដ្ឋសរុប | ៤៧,០៥៣ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ២២,៦១២ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៣០,៣៦៩ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ០០ |

## ៣. ការងារអត្រានុកូលដ្ឋាន

ការចម្លងសំបុត្រអត្រានុកូលដ្ឋានឆ្លងឆ្នាំអនុវត្តបាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ៤៩៣ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ២,៥៥៨ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៣៣៦ |
| ៤ | សេចក្តីចម្លងសំបុត្រមរណភាព | ៤១ |

## ៤. ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ

(រួមទាំងការងារសមាគម អង្គការមិនមែនរដ្ឋាភិបាល និងការងារចងសម្ព័ន្ធមេត្រីភាព )

ការងារផ្សព្វផ្សាយតាមទូរទស្សន៍បានចំនួន ១៩ លើក បិទផ្សាយព័ត៌មានសាធារណៈចំនួន ៥៧ ,សាធារណៈជនមកទំនាក់ទំនងនៅសាលាខណ្ឌចំនួន ១,៥៩៥ ,គណៈប្រតិភូភ្ញៀវជាតិ-អន្តរជាតិ ចំនួន ១៩៥នាក់។

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ក). ការផ្សព្វផ្សាយព័ត៌មាន | | |
| ១ | វិទ្យុ | ០០ |
| ២ | ទូរទស្សន៍ | ១៩ |
| ៣ | បិទផ្សាយលើក្តារព័ត៌មានសាធារណៈ | ៥៧ |
| ៤ | ព្រឹត្តិបត្រព័ត៌មានទស្សនាវដ្តី សារព័ត៌មាន | ០៦ |
| ៥ | ផ្សេងៗ | ០០ |

| ខ). ទំនាក់ទំនងសាធារណៈ | | |
|---|---|---|
| ១ | សាធារណជនមកទំនាក់ទំនងសាលាខណ្ឌ | ១,៩៩៥ |
| ២ | គណៈប្រតិភូភ្ញៀវជាតិ អន្តរជាតិ | ១៩៥ |

## ៥. ការគ្រប់គ្រងធនធានមនុស្ស

### ៥.១. ការគ្រប់គ្រងបុគ្គលិក

រចនាសម្ព័ន្ធខណ្ឌរួមមាន ៖ សមាជិកក្រុមប្រឹក្សាខណ្ឌ ចំនួន ១៩រូប ស្រី ០៤ រូប, ប្រធានក្រុមប្រឹក្សាខណ្ឌ ០១ រូប(ប្រុស), សមាជិកក្រុមប្រឹក្សាខណ្ឌដែលបានផ្លាស់ប្តូរ(គ្មាន), គណៈអភិបាលខណ្ឌមាន០៥ រូបស្រី០១ រូប ក្នុងនោះអភិបាលខណ្ឌ ០១ រូប និងអភិបាលរងខណ្ឌ ០៤ រូប ស្រី០១ រូប, នាយក នាយករងរដ្ឋបាល ០៣ រូប,ប្រធាន ការិយាល័យ និងអង្គភាពលទ្ធកម្ម ០៥រូប ស្រី ០១រូប, អនុប្រធានការិយាល័យនិងអង្គភាពលទ្ធកម្ម ០៤ រូប, មន្ត្រីការិយាល័យ និងស្មៀនសង្កាត់ចំនួន ៤២ រូប ស្រី ១៧ រូប, បុគ្គលិកជាប់កិច្ចសន្យា ១៧៧រូប ស្រី ២៨រូប។

តារាងស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

| ល.រ | ការបរិយាយ | សរុប | ស្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សា | ១៩ | ០៤ |
| ២ | ប្រធានក្រុមប្រឹក្សា | ០១ | ០០ |
| ៣ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរ | ០០ | ០០ |
| ៤ | អភិបាល | ០១ | ០០ |
| ៥ | អភិបាលរង | ០៤ | ០១ |
| ៦ | នាយករដ្ឋបាល | ០១ | ០០ |
| ៧ | នាយករងរដ្ឋបាល | ០២ | ០០ |
| ៨ | ប្រធានការិយាល័យ និងអង្គភាព | ០៥ | ០១ |
| ៩ | អនុប្រធានការិយាល័យ និងអង្គភាព | ០៤ | ០០ |
| ១០ | មន្ត្រីការិយាល័យ(រាប់ទាំងស្មៀនសង្កាត់) | ៤២ | ១៧ |
| ១១ | បុគ្គលិកកិច្ចសន្យា | ១៧៧ | ២៨ |

### ៥.២. ការអភិវឌ្ឍសមត្ថភាព

តារាងការអភិវឌ្ឍសមត្ថភាព

| ល.រ | ឈ្មោះវគ្គសិក្សា | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ០៩ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៤២៣ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៨៤ |

## ៦- ការងារហិរញ្ញវត្ថុ

### ៦.១.ការអនុវត្តចំណូល និងចំណាយ

- រដ្ឋបាលខណ្ឌចំការមន បានទទួលសេចក្តីសម្រេចលេខ០៦០/១៨ សសរ.ហចុះថ្ងៃទី០៨ខែកុម្ភៈឆ្នាំ ២០១៨ របស់

រាជធានីភ្នំពេញ ស្តីពីការតែងតាំងអាណាប័កផ្ទេរសិទ្ធិនិងការផ្ទេរឥណទានថវិកា, អភិបាល នៃគណៈអភិបាលខណ្ឌចំការមន ត្រូវទទួលបន្ទុកជាអាណាប័កផ្ទេរសិទ្ធិក្នុងការគ្រប់គ្រងឥណទានថវិកា របស់រដ្ឋបាលខណ្ឌចំការមន។ ឥណទានថវិការបស់រដ្ឋបាលខណ្ឌចំការមន សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៩រួមមាន៖

- សរុបចំណូលៈ ៥,២៥៣,០០០,០០០រៀល (ក្នុងនោះចំណូលឧបត្ថម្ភពីថវិការាជធានី ៥,០០០,០០០,០០០ រៀល និងចំណូលលើសេវា រដ្ឋបាល ២៥៣,០០០,០០០រៀល។
- សរុបចំណាយៈ ៥,២៥៣,០០០,០០០ រៀល។

**តារាង ការអនុវត្តចំណូល និងចំណាយ**

| ជំពូក | ចំណាត់ថ្នាក់ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ផ្នែកចំណូល | | | | |
| ៧០ | ចំណូលសារពើពន្ធ | | | |
| ៧២ | ផលទុននៃទ្រព្យសម្បត្តិរដ្ឋ | | | |
| ៧៣ | ផលទុនលើការលក់-ជួលទ្រព្យសម្បត្តិ និងសេវា | ២៥៣,០០០,០០០៛ | ២៤០,៩០៣,៦២០៛ | ៩៥.២២% |
| ៧៤ | ផលពីការពិន័យ និងការដាក់ទណ្ឌកម្ម | | | |
| ៧៥ | ការឧបត្ថម្ភកធន | ៥,០០០,០០០,០០០៛ | ៥,០០០,០០០,០០០៛ | ១០០% |
| ៧៦ | ផលហិរញ្ញវត្ថុ | | ៥,១០០,១០០៛ | ០០.០% |
| ៧៧ | ផលផ្សេងៗ និងផលពិសេស | | | |
| ៧៨ | ការងារនៃរដ្ឋទេយ្យ | | | |
| ០៨ | ចំណូលមូលនិធិបម្រុង | | | |
| ១៣ | ឧបត្ថម្ភកធន-វិនិយោគ | | | |
| សរុបចំណូល | | ៥,២៥៣,០០០,០០០៛ | ៥,២៤៦,០០៣,៦២០៛ | ៩៩.៨៧% |
| ផ្នែកចំណាយ | | | | |
| ៦០ | ការទិញ | ២០១,០០០,០០០៛ | ១៧១,២០៤,២៦០៛ | ៨៥.១៨% |
| ៦១ | សេវាខាងក្រៅ | ២,០៣៧,៦០០,០០០៛ | ២,២៩១,០៧២,៣០០៛ | ១១២.៤៤% |
| ៦២ | សេវាខាងក្រៅផ្សេងៗ | ១១០,០០០,០០០៛ | ១០៩,១៨៧,០០០៛ | ៩៩.២៦% |
| ៦៣ | ពន្ធ និងអាករ | | | |
| ៦៤ | បន្ទុកបុគ្គលិក | ២,៦៤២,៤០០,០០០៛ | ២,៥៥៥,៣៨០,៦២០៛ | ៩៦.៧១% |
| ៦៥ | ឧបត្ថម្ភកធននិងជំនួយសង្គម | | | |
| ៦៦ | បន្ទុកហិរញ្ញវត្ថុ | | | |
| ៦៧ | បន្ទុកពិសេស | | | |
| ៦៨ | ទាយជ្ជទានឱ្យដល់រម្លស់អចលកម្មរូបី | | | |
| ០៩ | ចំណាយមិនបានគ្រោងទុក | ២៦២,០០០,០០០៛ | - | |
| ២០ | អចលកម្មអរូបី | | | |
| ២១ | អចលកម្មរូបី | | | |
| សរុបចំណាយ | | ៥,២៥៣,០០០,០០០៛ | ៥,១២៦,៨៤៤,១៨០៛ | ៩៧.៦០% |

៦.២.ការគ្រប់គ្រងទ្រព្យសម្បត្តិ

ឆ្នាំ២០១៩ រដ្ឋបាលខណ្ឌចំការមន បានទិញសំភារៈមួយចំនួនសម្រាប់ប្រើប្រាស់ដូចជា៖ កៅអីជ័រ១៤៤កៅអី(៣៦ x៤=១៤៤) និងម៉ាស៊ីនព្រីន ០៣គ្រឿង។

តារាង ការគ្រប់គ្រងទ្រព្យសម្បត្តិ

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិ ដែលបានទិញ ឬទទួល (ថ្មី) | ១៤៧ |
| ២ | ទ្រព្យសម្បត្តិ ដែលបានកាត់ចេញ | ០០ |
| ៣ | ទ្រព្យសម្បត្តិ សរុប | ០០ |

## ➢ ការិយាល័យអន្តរវិស័យ

### ១- ការសម្របសម្រួលតាមវិស័យ

- អធិការនគរបាលខណ្ឌបានបើកស្ថានីយ៍តាមសង្កាត់ទាំង៥ បានបំពេញបែបបទធ្វើអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ" គំរូថ្មី" ជូនប្រជាពលរដ្ឋបានចំនួន ១,៣៦០នាក់ ប្រុស ៦៦៦នាក់។ ក្នុងនោះហួសសុពលភាព ៣៣៣នាក់ ប្រុស ១៥៦នាក់, ផ្តល់លេខថ្មី ១,០២៧នាក់ ប្រុស ៥១០នាក់ និងផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសរុប ៩៨៥នាក់ ប្រុស ៥១១នាក់។
- គណៈបញ្ជាការឯកភាពរដ្ឋបាលខណ្ឌចំការមន បានចុះត្រួតពិនិត្យជាតិអាល់កុលនិងអាវុធជាតិផ្ទុះក្នុងមូលដ្ឋានបាន ៩៧លើក លើ៩៧គោលដៅ ជាលទ្ធផលកម្លាំងចម្រុះ បានត្រួតពិនិត្យរកឃើញមធ្យោបាយឆ្លងកាត់ ១១,២៨៦គ្រឿង (រថយន្ត ៣,៣៥២គ្រឿង, ម៉ូតូ ៧,៩៣៤គ្រឿង), ត្រួតពិនិត្យជាតិស្រវឹង ៨៧៨គ្រឿង (រថយន្ត ០១គ្រឿង, ម៉ូតូ ៨៧៧គ្រឿង), អប់រំ ៣៩៩នាក់ (ម៉ូតូ), ឃាត់អ្នកបើករថយន្ត-ម៉ូតូមានជាតិអាកុលលើសកំរិត ០,៤០ មីលីក្រាម ក្នុងមួយលីត្រខ្យល់ សរុប៤៧៩នាក់ (រថយន្ត០១គ្រឿង, ម៉ូតូ៤៧៨គ្រឿង)ទៅការិយាល័យចរាចរណ៍ផ្លូវគោកក្រុង និងធ្វើការផាកពិន័យអ្នកបើកម៉ូតូមានជាតិអាកុល ៩២,៦០០,០០០រៀល (កៅសិបពីរលានប្រាំមួយរយពាន់រៀលគត់) និងត្រួតពិនិត្យជាតិផ្ទុះ ៤៩លើក លើ ៤៩គោលដៅ ជាលទ្ធផលមានអាវុធឆ្លងកាត់ ២៨ដើមខ្លី សមាសភាពនគរបាល ០៨នាក់, យោធា ១៨នាក់, កងរាជអាវុធហត្ថ ០១នាក់, ស៊ីវិល ០១នាក់ មានលិខិតប្រើប្រាស់ត្រឹមត្រូវ និងត្រួតពិនិត្យម៉ូតូកង់បី ដកហូតសម្ភារៈរួមមាន៖ វិទ្យុទាក់ទង ០៧គ្រឿង, ទង់ជាតិខ្មែរ ០៦ទង់, កាំបិត ០៣, ពូថៅ ០២, ញញួរ ០៧, ដែកជ្រុង ០១, ដែកទីប ០៥, ដំបងឈើ ០៦, ដែកវាយកូនហ្គោល ០១, ដែកសរសៃ ០១ រក្សាទុកនៅអធិការដ្ឋាន។
- <u>ថ្ងៃទី០១-៣១ ខែមករា ឆ្នាំ២០១៩</u>
  - លោក ប្រធាន និងអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមសម្ពោធវិមានឈ្នះៗ នៅក្នុងខណ្ឌជ្រោយចង្វារ ដឹកនាំដោយលោកអភិបាលខណ្ឌ ។
  - លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
  - លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
  - លោកប្រធានការិយាល័យ ចូលរួមប្រជុំដោះស្រាយបណ្តឹងសាងសង់ប៉ះពាល់ដីមុខផ្ទះ នៅមន្ទីរដែនដី ។
  - លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមប្រជុំពិភាក្សាស្តីពីការស្នើសុំលិខិតអនុញ្ញាត ប្រកបអាជីវកម្ម នៃវិស័យ ព័ត៌មាន នៅសាលារាជធានីភ្នំពេញ ។

- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកប្រធានការិយាល័យ ចូលរួមប្រជុំដោះស្រាយបណ្តឹងរំខានអ្នកជិតខាង នៅមន្ទីរដែនដី ។
- -មន្ត្រីការិយាល័យ ចូលរួមអបអរសោទរជ័យជម្នះ ៧មករាគម្រប់ខួបលើកទី៤០ នៅពហុកីឡដ្ឋានជាតិអូឡាំពិក ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកប្រធាន និងអនុប្រធាន ចូលរួមសម្ពោធផ្លូវក្រវ៉ាត់ក្រុងទី៣ នៅខេត្តកណ្តាល ។

• ថ្ងៃទី០១-២៨ ខែកុម្ភៈ ឆ្នាំ២០១៩

- លោកប្រធានការិយាល័យ ដឹកនាំប្រជុំពង្រឹងការងារក្នុងការិយាល័យ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។

• ថ្ងៃទី០១-៣១ ខែមីនា ឆ្នាំ២០១៩

- លោកប្រធានការិ.ចូលរួមប្រជុំបែងចែកកម្លាំងតាមការិយាល័យដើម្បីចូលរួមបើកការដ្ឋានសាងសង់ កម្រោងការពារទឹកជំនន់នៅខណ្ឌចំការមន ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកប្រធាន អនុប្រធាន មន្ត្រីការិយាល័យ ចូលរួមពិធីបើកការដ្ឋានសាងសង់គម្រោងកម្រោងការពារទឹកជំនន់ និងកែលំអប្រព័ន្ធប្រឡាយលូនៅក្នុងរាជធានីភ្នំពេញ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធានការិ. ចុះរៀបចំសណ្តាប់ធ្នាប់ នៅផ្លូវ១៦៣ សង្កាត់ទួលស្វាយព្រៃទី១
- លោកអនុប្រធានការិ. ចូលរួមកម្មវិធីសមាហរណកម្មជនរងគ្រោះដោយសារគ្រឿងញៀន ដែលបានជាសះ

ស្មើយនៅមណ្ឌលឱកាសខ្ញុំ
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកប្រធាន អនុប្រធាន និងមន្ត្រីការិ.ចូលពិធីកម្ទេចផលិតផលក្លែងក្លាយខុសច្បាប់នៅផ្លូវ៦០ ម៉ែត្រ ។
- លោកអនុប្រធាន ចុះប្រមូលសម្រាម និងលាងសម្អាតផ្លូវនៅមុខពេទ្យរុស្ស៊ី ។
- លោកប្រធាន ការិ.ចូលរួមប្រជុំត្រួតពិនិត្យរបាយការណ៍លទ្ធផលការងារ ធ្វើនៅសវនកម្មឆ្នាំ២០១៧ នៅខណ្ឌចំការមន ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកប្រធាន ការិ.ចូលរួមបិទក្លឹបកំសាន្ត Duplex and Banana Pub នៅផ្លូវ២៧៨ សង្កាត់បឹងកេងកងទី១ ។
- លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
- លោកប្រធាន ការិ.ចូលរួមបិទក្លឹបកំសាន្ត Maimi នៅផ្លូវ៣៦០ សង្កាត់បឹងកេងកងទី១ ។
- លោកប្រធាន អនុប្រធាន មន្ត្រីការិយាល័យ ចូលរួមផ្សព្វផ្សាយ បញ្ហាទុកដាក់សម្រាម ដល់ប្រជាពលរដ្ឋតាមបណ្តោយប្រឡាយ ១០៥

- <u>ថ្ងៃទី០១-៣០ ខែមេសា ឆ្នាំ២០១៩</u>
  - លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
  - លោកអនុប្រធាន ការិយល័យអន្តរវិស័យ ចូលរួមរៀបចំសណ្តាប់ធ្នាប់ កន្លែងលក់បន្លែនៅផ្លូវមុនីរ៉េត សង្កាត់ទួលស្វាយព្រៃទី២ ដឹកនាំដោយលោក អភិបាលខណ្ឌ ។
  - លោកប្រធាន អនុប្រធាន មន្ត្រីការិយាល័យ ចូលរួមផ្សព្វផ្សាយ បញ្ហាទុកដាក់សម្រាម ដល់ប្រជាពលរដ្ឋតាមបណ្តោយប្រឡាយ ១០៥
  - លោកប្រធាន អនុប្រធាន មន្ត្រីការិយាល័យ ចូលរួមពិធីសម្ពោធជាផ្លូវការ សារមន្ទីរសេដ្ឋកិច្ច និងរូបិយវត្ថុ ព្រះឥសានវរ្ម័ន ។
  - លោកអនុប្រធាន ការិ.ចូលរួមត្រួតពិនិត្យសំណង់ ផ្សារសហគមន៍ទំនើប និងមានបណ្តឹងពីស្ថានទូតចិន នៅតាមផ្លូវម៉ៅសេទុង ។
  - លោកអនុប្រធានការិ.ចូលរួមកម្មវិធីសិក្ខាសាលាបច្ចេកទេសស្តីពីប្លង់អភិវឌ្ឍន៍តំបន់ប៉ែកខាងត្បូងរាជធានីភ្នំពេញ នៅសាលារាជធានីភ្នំពេញ ។
  - ក្រុមការងារការិ.ចុះបិទអាជីវកម្មអ៊ីនធើណេតនៅផ្ទះលេខ ២៤ ផ្លូវ១១៣ សង្កាត់បឹងកេងកងទី២ ។
- <u>ថ្ងៃទី០១-៣១ ខែឧសភា ឆ្នាំ២០១៩</u>
| ៣ | ធនធានធម្មជាតិ និងបរិស្ថាន | ១៦ | ០០ | ០១ | ១៥ |
| ៤ | សេវាកម្មរដ្ឋបាល និងសន្តិសុខ | ៥៣ | ០០ | ០០ | ៥៣ |
| ៥ | យេនឌ័រ | ២៤ | ០០ | ០០ | ២១ |
| សរុប | | ១៤៧ | ០០ | ០១ | ១៤០ |

## ២.៦.ការអនុវត្តថវិកាសង្កាត់

| ល.រ | ការបរិយាយ | អនុម័ត | ជាក់ស្តែង | ភាគរយ |
|---|---|---|---|---|
| ១ | ចំណូលសរុប | ២,៥៤៨,៦៥០,៧១២៛ | ១,៥៥៤,៣៩៤,១៦២៛ | ៦០.៩៩% |
| ២ | ចំណាយសរុប | ២,៥៤៨,៦៥០,៧១២៛ | ១,៤១៤,៧៨៧,៥០២៛ | ៥៥.៥១% |

## ២.៧.ការគ្រប់គ្រងទ្រព្យសម្បត្តិសង្កាត់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ទ្រព្យសម្បត្តិសង្កាត់ ដែលបានទិញ ឬទទួល (ថ្មី) | ៣២ |
| ២ | ទ្រព្យសម្បត្តិសង្កាត់ដែលបានកាត់ចេញ | ០០ |
| ៣ | ទ្រព្យសម្បត្តិសង្កាត់សរុប | ២៥១ |

## ២.៨.ការអភិវឌ្ឍសមត្ថភាព

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | វគ្គសិក្សា | ៥៣ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៣០៣ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ៥៩ |

## ២.៩.សកម្មភាពសេវាសង្គម

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីសង្កាត់ | ០០ |

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់សម្រាប់កែលម្អអនាម័យ(ការលាងដៃ នឹងសាប៊ូ) | ០០ |
| ៣ | គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ០០ |
| ៤ | គ្រួសារងាយរងគ្រោះគាំទ្រពីសង្កាត់ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០០ |
| ៥ | គ្រួសារងាយរងគ្រោះដែលសង្កាត់ចុះកំណត់អត្តសញ្ញាណ | ១៧ |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីសង្កាត់ | ០៣ |

២.១០.ការសម្រុះសម្រួលទំនាស់

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ករណីដែលបានសម្រុះសម្រួលបញ្ចប់ដោយសង្កាត់ | ៦២ |
| ២ | ករណីដែលបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ១៣ |

២.១១. ការងារអត្រានុកូលដ្ឋាន

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សំបុត្រកំណើត | ៦៥០ |
| ២ | សំបុត្របញ្ជាក់កំណើត | ៦១៣ |
| ៣ | សេចក្តីចម្លងសំបុត្រកំណើត | ១,៤៦៤ |
| ៤ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១,៤៣៣ |
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ៣៧២ |
| ៦ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៩០៧ |
| ៧ | សំបុត្រមរណភាព | ១៤៩ |
| ៨ | សេចក្តីចម្លងសំបុត្រមរណភាព | ៤៣៨ |

២.១២.ការចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | ប្រជាពលរដ្ឋដែលបានចុះឈ្មោះថ្មី | ៥១ |
| ២ | ប្រជាពលរដ្ឋដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះអ្នកបោះឆ្នោត | ៦៦ |
| ៣ | ប្រជាពលរដ្ឋសរុបដែលមានឈ្មោះបោះឆ្នោត (ចាស់ និងថ្មី) | ៣២,៩៣៩ |

## ៣- បញ្ហាប្រឈមដែលរដ្ឋបាលសង្កាត់បានជួបប្រទះ

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១ | ប្រជាពលរដ្ឋទុកសំរាមគ្មានរបៀបរៀបរយ។ | ផ្សព្វផ្សាយ ណែនាំដល់ប្រជាពលរដ្ឋទុកដាក់សំរាមឲ្យមាន របៀបរៀបរយ និងចំគោលដៅ។ |

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| | (សង្កាត់ទន្លេបាសាក់) | |
| ២ | តាមច្រកផ្លូវតូចៗមួយចំនួនក្នុងមូលដ្ឋាន មានការលក់ដូរដាក់តាំងលើធ្វើឲ្យពិបាកក្នុងការធ្វើដំណើរចូល-ចេញ (សង្កាត់ទន្លេបាសាក់) | ណែនាំដល់អាជីវករ ដែលមានដាក់លក់តាំងគ្មានរបៀបរៀបរយ ។ |
| ៣ | ករណីកកស្ទះចរាចរនៅក្នុងមូលដ្ឋានសង្កាត់ (សង្កាត់ទន្លេបាសាក់) | ចុះសម្រួលបញ្ហាចរាចរជាប្រចាំ នៅគោលដៅដែលមានការកកស្ទះ ។ |
| ៤ | មានករណីលួចប្រើប្រាស់គ្រឿងម្តងម្កាលនៅក្នុងមូលដ្ឋានសង្កាត់។ (សង្កាត់ទន្លេបាសាក់) | សហការចុះបង្ក្របជាប្រចាំ ។ |
| ៥ | ល្បែងស៊ីសងគ្រប់ប្រភេទ ក្នុងមូលដ្ឋានសង្កាត់។ (សង្កាត់ទន្លេបាសាក់) | |
| ៦ | ប្រជាពលរដ្ឋនៅតែមានការធ្វេសប្រហែសចំពោះបញ្ហាភ្លើងទាន ធ្យូង ចង្រ្កាន្ត ហ្គាស និងចរន្តអគ្គិសនី។ (សង្កាត់ទន្លេបាសាក់) | ផ្សព្វផ្សាយតាមរយៈប្រជុំវេទិកាសាធារណៈ និងធ្វើលិខិតជូនដំណឹងជាសាធារណៈ ។ |
| ៧ | សង្កាត់ខ្វះថវិកាសម្រាប់ស្តារប្រព័ន្ធលូនានា។(សង្កាត់ទួលទំពូងទី១) | សុំរដ្ឋបាលខណ្ឌចំការមនជួយស្តារលូគ្រប់ខ្សែក្នុងសង្កាត់។ |
| ៨ | លទ្ធផលបើកកំណាត់ផ្លូវលេខ ១៦៧ ស្ថិតក្នុងភាពអវិជ្ជមាន (សង្កាត់ទួលទំពូងទី២) | រដ្ឋបាលរាជធានីភ្នំពេញបានឯកភាពបើកផ្លូវលេខ ១៦៧ ទទឹង ៧ម ។ |
| ៩ | កំណាត់ផ្លូវលេខ ៤៥៤ ភ្ជាប់ទៅផ្លូវលេខ ៤៣០ ពុំទាន់បានបើក។ (សង្កាត់ទួលទំពូងទី២) | សុំឱ្យរដ្ឋបាលខណ្ឌចំការមនបើកកំណាត់ផ្លូវលេខ ៤៥៤ ភ្ជាប់ទៅផ្លូវលេខ ៤៣០ ឱ្យបានឆាប់រហ័ស ។ |
| ១០ | បញ្ហាមូសច្រើន (សង្កាត់ផ្សារដើមថ្កូវ) | សូមអោយក្រសួងសុខាភិបាលបាញ់ថ្នាំមូស ។ |
| ១១ | បញ្ហាគ្រឿងញៀន និងក្មេងទំនើង (សង្កាត់ផ្សារដើមថ្កូវ) | -សូមអោយអាជ្ញាធរចុះល្បាតពេលយប់នៅភូមិ៤ និងភូមិ៥។ |
| ១២ | នៅផ្លូវលេខ ១០១,១០៣ និង ៤៧៤ អត់មានភ្លើងបំភ្លឺផ្លូវ (សង្កាត់បឹងត្របែក) | បានរាយការណ៍ជូនទៅលោកអភិបាលខណ្ឌក្នុងអង្គប្រជុំភូមិ-សង្កាត់មានសុវត្ថិភាព។ |
| ១៣ | ផ្លូវលេខ ៤៦៦ មានប្រវែង ២២៥ម មានការលិចទឹករាល់ថ្ងៃ ដោយសារអត់មានប្រព័ន្ធលូ។ (សង្កាត់បឹងត្របែក) | សុំឱ្យរដ្ឋបាលខណ្ឌចំការមនជួយដោះស្រាយផ្លូវលេខ ៤៦៦ មានប្រវែង ២២៥ម មានការលិចទឹករាល់ថ្ងៃ ដោយសារអត់មានប្រព័ន្ធលូ ។ |

## ❖ ផ្នែកទី៤: ការងាររបស់ការិយាល័យ អង្គភាពជំនាញ

### ៤.១. ការងារផែនការ ស្ថិតិ

- ចូលរួមធ្វើជំរឿនទូទៅប្រជាជននៅរាជធានីភ្នំពេញ ឆ្នាំ២០១៩
- ចុះសិក្សាគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៩
- សម្របសម្រួលការដេញថ្លៃគម្រោងមូលនិធិសង្កាត់ឆ្នាំ២០១៩

- សម្របសម្រួលសង្កាត់រៀបចំផែនការកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០១៩
- រៀបចំផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់រដ្ឋបាលខណ្ឌចំការមន
- សម្របសម្រួលសិក្ខាសាលាសមាហរណកម្មវិនិយោគ សង្កាត់ ខណ្ឌ ឆ្នាំ (២០២០-២០២២) នៅថ្នាក់ខណ្ឌ
- រៀបចំសៀវភៅកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលខណ្ឌ (២០២០-២០២២)
- រៀបចំសៀវភៅផែនការអភិវឌ្ឍ៥ឆ្នាំ (២០២០-២០២៤) របស់រដ្ឋបាលខណ្ឌចំការមន
- សម្របសម្រួលសង្កាត់រៀបចំសៀវភៅកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០២០
- សម្របសម្រួលវគ្គបណ្តុះបណ្តាលការស្រង់ព័ត៌មានទិន្នន័យភូមិ សង្កាត់ ខណ្ឌ ឆ្នាំ២០១៩ ។

៤.២.-**ការងារសាធារណៈការ**

បានជួសជុលផ្លូវ និងដាក់ប្រព័ន្ធលូ ក្នុងសង្កាត់ទាំង៥ ដែលជាគម្រោងរបស់មូលនិធិសង្កាត់រួមមាន៖

១-សង្កាត់ទន្លេបាសាក់

+ច្រកផ្លូវភូមិ៧ ចាក់បេតុង ៤៥,៥ម x ២,៥ម លទ្ធផលសម្រេចបាន ១00%

+ច្រកផ្លូវភូមិ១២ ចាក់បេតុង ២១៩ម x ៤ម លទ្ធផលសម្រេចបាន ១00%

+ច្រកផ្លូវភូមិ១៦ ចាក់បេតុង ៣៣៦ម x ២,២៣១ម លទ្ធផលសម្រេចបាន ១00%

+បានដាក់លូច្រកផ្លូវភូមិ៧ ទំហំ ៦00មម ប្រវែង ៤៤ម លទ្ធផលសម្រេចបាន ១00%

+បានដាក់លូច្រកផ្លូវភូមិ១២ ទំហំ ៦00មម ប្រវែង ១៤៨ម លទ្ធផលសម្រេចបាន ១00%

+បានដាក់លូច្រកផ្លូវភូមិ១៦ ទំហំ ៥00មម ប្រវែង ៣៣៧ម លទ្ធផលសម្រេចបាន ១00% ។

២-សង្កាត់ទួលទំពូងទី២

+ច្រកផ្លូវ៤៦0 ទីតាំងផ្លូវលេខ១៦៣ ដល់ផ្លូវលេខ ១៦៧ ដាក់លូទំហំ ៦00មម ប្រវែង ៤៧៤ម លទ្ធផលសម្រេចបាន ១00% ។

៣-សង្កាត់ទួលទំពូងទី១

+ច្រកផ្លូវ១២៣ ទីតាំងផ្លូវលេខ៤៦៨ ដល់ផ្លូវលេខ ៤៧៨ ចាក់បេតុង១៩១ម x ៧ម លទ្ធផលសម្រេចបាន ១00% ។

៤-សង្កាត់បឹងត្របែក

+ច្រកផ្លូវ៤៤0 ទីតាំងផ្លូវលេខ១០១ ដល់ផ្លូវទាល់ អ៊ុតកៅស៊ូ ១៣៨មx ៧,២ម លទ្ធផលសម្រេចបាន ១00%

+ច្រកផ្លូវ៤២៨ ទីតាំងផ្លូវលេខ១០៥ ដល់ផ្លូវលេខ ៩៥ អ៊ុតកៅស៊ូ ១៥៣មx ៦,២ម លទ្ធផលសម្រេចបាន ១00%

៥-សង្កាត់ផ្សារដើមថ្កូវ

+ច្រកផ្លូវ៤៣0 និង ១0៣ ភូមិ១ ភូមិ២ និងភូមិ៤ ដាក់លូទំហំ ៥00មម ប្រវែង៩៤៧ លទ្ធផលសម្រេចបាន ១00%

៤.៣.**ការងារឧស្សាហកម្ម និងសិប្បកម្ម**

- រោងចក្រសរុបចំនួន ០៣មូលដ្ឋាន ពលករសរុបៈ ២៤៥នាក់។
- សិប្បកម្មសរុបចំនួន ៣៨០មូលដ្ឋាន ពលករសរុបៈ ២,២៩១នាក់ ។
- ចុះបញ្ជីនៅការិយាល័យច្រកចេញ-ចូលតែមួយសរុបៈ ០២មូលដ្ឋាន។
- ចុះបញ្ជីនៅមន្ទីរសរុបៈ ០៥មូលដ្ឋាន ថ្មីៈ ០១មូលដ្ឋាន បន្តៈ ០៤មូលដ្ឋាន។
- ចុះបញ្ជីនៅក្រសួងសរុបៈ ០១មូលដ្ឋាន ថ្មីៈ ០០មូលដ្ឋាន បន្តៈ ០១មូលដ្ឋាន។
- យកផលិតផលពិនិត្យគុណភាពៈ ០៩មូលដ្ឋាន ស្មើៈ ១១មុខផលិតផល
- ស្រង់ស្ថិតិសិប្បកម្មចំនួនៈ ៤១មូលដ្ឋាន គ្មានច្បាប់អនុញ្ញាត។
- ចែកលិខិតជូនដំណឹងដល់ម្ចាស់សិប្បកម្មចំនួន ០២ ទីតាំង (ធ្វើអធិការកិច្ចថ្នាក់មន្ទីរ)
- ចុះណែនាំម្ចាស់សិប្បកម្មផលិតផលទឹកពិសារដបបោះពុម្ពខុសអក្ខរាវិរុទ្ធ ចំនួន ០១មូលដ្ឋាន

- ចុះណែនាំម្ចាស់សិប្បកម្មផលិតស្រាបៀរស្រស់អោយមកសុំចុះបញ្ជីចំនួន ០១ មូលដ្ឋាន
- សហការជាមួយមន្ទីរឧស្សាហកម្ម និងសិប្បកម្ម ចុះធ្វើអធិការកិច្ចសិប្បកម្មផលិតទឹកសុទ្ធ ០១លើក
- សហការជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ចុះធ្វើអធិការកិច្ចរោងចក្រ ០១លើក។
- ចុះយកផលិតផលទំនិញវេចខ្ចប់ ចំនួន ០៨ទីតាំង ស្មើ ១៣ មុខផលិតផល
- ចុះពិនិត្យ និងផ្ទៀងទាត់ង្វាស់ង្វាល់ ទីតាំងស្ថានីយ៍ប្រេងឥន្ទៈ ចំនួន ០១ស្ថានីយ៍ ស្មើ ០២ទូ ស្មើ ០៤ ដៃបាញ់ប្រេង។

### ៤.៤. **ការងារពាណិជ្ជកម្ម**

- បានចុះជម្រុញទីតាំងអាជីវកម្ម-សេវាកម្មបើកថ្មី និងបន្តសុពលភាពនៅមន្ទីរពាណិជ្ជកម្មក្នុងឆ្នាំ២០១៩ សរុបបាន ចំនួន ៣១៤ទីតាំង ក្នុងនោះមាន ៖

  -ថ្មីបានចំនួន ៧៥ទីតាំង

  -បន្តចំនួន ២៣៩ទីតាំង
- ការផ្តល់សេវាប្រកបអាជីវកម្ម-សេវាកម្មក្នុងការិយាល័យច្រកចេញចូលតែមួយតាមផ្សារ ចំនួន ៦០២តូប។
- បានសហការជាមួយមន្ត្រីកាំកុងត្រូលចុះត្រួតពិនិត្យសុវត្ថិភាពចំណីអាហារជាប្រចាំ។
- ចេញលិខិតអនុញ្ញាតតូបផ្សារចំនួន ៦០២តូប។

### ៤.៥.**ការងារទេសចរណ៍**

ក. <u>ការងារពង្រឹងការអនុវត្តច្បាប់ស្តីពីទេសចរណ៍ និងលិខិតបទដ្ឋានគតិយុត្តិនានា៖</u>

- បានប្រជុំផ្សព្វផ្សាយបញ្ហាគ្រឿងញៀនបានសរុប ០១លើក នៅសាលាខណ្ឌចំការមន មានអ្នកចូលរួមសរុបចំនួន ៧៨នាក់ ស្រី ១១នាក់។
- បានសហការដោះស្រាយបញ្ហាបង្កសម្លេងរំខាន ពីសំណាក់ទីតាំងអាជីវកម្ម ភោជនីយដ្ឋាន ខារ៉ាអូខេ និងក្លឹបឌីស្កូតែក ជាប្រចាំ។
- បានសហការផ្សព្វផ្សាយ និងចលនាម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន ចូលរួមប្រឡងប្រណាំងភោជនីយដ្ឋានស្អាត។
- បានសហការជាមួយសង្កាត់ទាំង៥ ក្នុងការចុះស្រង់ស្ថិតិធ្វើបច្ចុប្បន្នភាពសម្រាប់ឆ្នាំ២០១៩។

ខ. <u>ការងារគ្រប់គ្រងមូលដ្ឋានអាជីវកម្ម៖</u>

- ការចេញអាជ្ញាប័ណ្ណដោយរដ្ឋបាលខណ្ឌចំការមន (ការិយាល័យច្រកចេញចូលតែមួយ) បានសរុប ចំនួន ៨៧ទីតាំង ក្នុងនោះរួមមាន ៖

| | | |
|---|---|---|
| - ស្នើសុំអាជ្ញាប័ណ្ណថ្មី | ចំនួន | ៣៣ទីតាំង |
| - ស្នើសុំបន្តអាជ្ញាប័ណ្ណ | ចំនួន | ៥២ទីតាំង |
| - ស្នើសុំបិទអាជីវកម្ម | ចំនួន | ០២ទីតាំង |

គ. <u>ការងារពង្រឹងការកត់ត្រាភ្ញៀវស្នាក់នៅ តាមសណ្ឋាគារ ផ្ទះសំណាក់៖</u>

- ចុះត្រួតពិនិត្យការកត់ត្រា អត្តសញ្ញាណភ្ញៀវស្នាក់នៅតាម សណ្ឋាគារ ផ្ទះសំណាក់។
- ចូលរួមវេទិកាសាធារណៈតាមសង្កាត់ទាំង៥ អំពីភូមិ-សង្កាត់ មានសុវត្ថិភាពបានចំនួន ១២លើក។

ឃ. <u>ការងារទីក្រុងស្អាត រមណីយដ្ឋានសេវាល្អ៖</u>

- ចូលរួមប្រជុំផ្សព្វផ្សាយ និងជូនដំណឹងបឋមដល់សង្កាត់ទាំង៥ អំពីគោលការណ៍ថ្មីរបស់សាលារាជធានីភ្នំពេញ អំពីការប្រឡងប្រណាំងខណ្ឌស្អាត សង្កាត់ស្អាត កិច្ចការនេះសាលារាជធានីភ្នំពេញ បានកំពុងបង្កើតយន្តការដើម្បីប្រឡងប្រណាំង។
- សហការផ្សព្វផ្សាយ និងចូលរួមយុទ្ធនាការ បរិស្ថាន អនាម័យ សណ្តាប់ធ្នាប់ទីក្រុងសរុប ១២លើក។

- សហការជាមួយសង្កាត់ទាំង៥ ចុះណែនាំ និងយុទ្ធនាការដល់ម្ចាស់ភោជនីយដ្ឋាន អាហារដ្ឋាន អំពីគ្មានសំរាមក្រដាស។
- ចុះជម្រុញមូលដ្ឋានអាជីវកម្ម សណ្ឋាគារ ឲ្យចូលរួមប្រឡងប្រណាំងធុរកិច្ចបៃតងចំនួន ០៦ទីតាំង។
- សហការជាមួយមន្ទីរ ចុះត្រួតពិនិត្យ និងណែនាំម្ចាស់គ្រប់គ្រងអាជីវកម្ម អំពីការដាក់តាំងស្លាកយីហោអាជីវកម្មឲ្យបានត្រឹមត្រូវអនុលោមតាមសារាចរណ៍ណែនាំលេខ ០០៤ របស់ក្រសួងទេសចរណ៍បានចំនួន ០២កន្លែង។
- ចូលរួមកម្មវិធីរើសសំរាមតាមកន្លែងសាធារណៈនានាចំនួន ០៦គោលដៅ ក្រោយថ្ងៃព្រះរាជពិធីបុណ្យអុំទូក រៀបចំដោយរដ្ឋបាលរាជធានីភ្នំពេញ ក្រោមអធិបតីភាព **ឯកឧត្តម ហួត ហៃ** អភិបាលរងនៃគណៈអភិបាលរាជធានីភ្នំពេញ តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ឃួង ស្រេង** អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញ។

## ៤.៦-ការងារសង្គមកិច្ច

- ធ្វើបញ្ជីបើកប្រាក់ឧបត្ថម្ភគោលនយោបាយជូនជនចូលនិវត្តន៍ស៊ីវិលនិងអតីតយុទ្ធជន៖

| | | |
|---|---|---|
| ក- <u>ចំនួនជនចូលនិវត្តន៍ស៊ីវិល</u> | : ៣,១១៧ | នាក់ |
| -ចំនួនជនបាត់បង់សម្បទាវិជ្ជាជីវៈ | : ១៤៩ | នាក់ |
| -ចំនួនកូននៅក្នុងបន្ទុកសពមន្ត្រីរាជការស៊ីវិល | : ៣៤ | នាក់ |
| ខ- <u>អតីតយុទ្ធជន</u> | | |
| - យោធាពិការ | : ៩២ | នាក់ |
| - និវត្តន៍យោធា | : ២០១ | នាក់ |
| - និវត្តន៍នគរបាល | : ៤២២ | នាក់ |
| - គ្រួសារពលី | : ១១០ | នាក់ |
| - គ្រួសារមរណៈ | : ១១១ | នាក់ |
| - ជនបាត់បង់សមត្ថភាពការងារ | : ០៨ | នាក់ |

- ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយមន្ទីរសអយ និងអជ្ញាធរមូលដ្ឋានប្រមូលជនអនាថាតាមដងផ្លូវសាធារណៈ និងស្តុបនៅក្នុងខណ្ឌចំការមន សរុបទាំងអស់បានចំនួន ៣៤នាក់ ស្រី ១៤នាក់ បញ្ជូនទៅមន្ទីរអប់រំណែនាំ។
- នៅថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានអញ្ជើញសមាគមអតីត ចូលរួមអបអរសាទរខួបលើកទី១២ ទិវាអតីតយុទ្ធជនកម្ពុជា ២១ មិថុនា ចំនួន ១៣នាក់ នៅសាលារាជធានីភ្នំពេញ ក្នុងមួយនាក់ទទួលបានថវិកា ចំនួន ៥០,០០០រៀល (ប្រាំម៉ឺនរៀលគត់)។
- នៅថ្ងៃទី២១ ខែតុលា ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌចំការមនបានអញ្ជើញមនុស្សចាស់តាមសង្កាត់និមួយៗក្នុងមួយសង្កាត់ ០៣នាក់ សរុប ១៥នាក់ អោយចូលរួមអបអរសាទរទិវាមនុស្សចាស់អន្តរជាតិលើកទី២១ ក្រោមប្រធានបទ "គាំទ្រសុខុមាលភាពមនុស្សចាស់ គឺជាកត្តាសំខាន់ក្នុងការអនុវត្តប្រព័ន្ធគាំពារសុខុមាលភាពមនុស្សវ័យ ចាស់គ្រប់វិស័យក្នុងសង្គមជាតិនៅកម្ពុជា" ក្រោមគណៈអធិបតីភាពឯកឧត្តម ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ ក្នុងនោះមនុស្សចាស់ចូលរួមទទួលបានថវិកាក្នុងមួយនាក់ ៥០,០០០រៀល (ប្រាំម៉ឺនរៀលគត់)។
- នៅថ្ងៃទី០៣-០៦ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរងខណ្ឌចំការមន បានចូលរួមសកម្មភាពដឹកជញ្ជូនសមាជិកសមាគមអតីតយុទ្ធជនកម្ពុជារាជធានីភ្នំពេញ ទៅទទួលយក ផ្ទះ-ដី សប្បុទានសង្គមកិច្ចនៅភូមិបាក់វែក ឃុំចុងកាល់ ស្រុកចុងកាល់ ខេត្តឧត្តរមានជ័យ ចំនួន ៨៩នាក់ ក្នុងនោះ ខណ្ឌចំការមនចំនួន ០៥នាក់ សរុបគ្រួសារទាំងអស់គ្នាដែលត្រូវទៅនោះចំនួន ២៦៥គ្រួសារ។
- នៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរង

ខណ្ឌចំការមន បានអញ្ជើញគ្រួសារអតីតយុទ្ធជនចំនួន ០៨នាក់ចូលរួមសំណេះសំណាលជាមួយ ឯកឧត្តមនាយឧត្តមសេនីយ៍ គង់ គីម ទេសរដ្ឋមន្ត្រី និងជាអនុប្រធានសមាគមអតីតយុទ្ធជនកម្ពុជា នៅវិមានឈ្នះៈឈ្នះ គ្រួសារអតីតយុទ្ធជនអាស៊ាន ក្នុងមួយនាក់ទទួលបានអង្ករ ២០គីឡូក្រាម, ទឹកត្រី ០១យួរ, ទឹកស៊ីអ៊ីវ ០១យួរ, ប៊ីចេង ០១កញ្ចប់, ស្ករស ០១កញ្ចប់, ត្រីខ ១០កំប៉ុង, មុង ០១, ភួយ ០១ និងថវិកា ២០ ម៉ឺនរៀល (ម្ភៃម៉ឺនរៀលគត់)។

- នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរងខណ្ឌចំការមន និងលោក សុខ ច័ន្ទវណ្ណៈ ប្រធានភូមិភាគពិសេសខណ្ឌចំការមន បានចូលរួមបើកប្រាក់ជានារ៉ាប់រងសង្គម១២ខែ ដល់គ្រួសារសពអតីតយុទ្ធជនចំនួន ០៥គ្រួសារ រួមមានៈ

១-សំ គុន
២-ឌីម សាវីន
៣-អ៊ុក ណែត
៤-ស្រី សំអេង
៥-អ៊ុច ស៊ន

-នៅផ្ទះលេខ១២៩ ផ្លូវសុជារស ភូមិ៨ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

- នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៩ ការិយាល័យសអយខណ្ឌបានសហការណ៍ជាមួយលោកស្រី គ្រួច ស៊ីថូ អធិការរងខណ្ឌយោធាខណ្ឌ កងរាជអាវុធហត្ថខណ្ឌចំការមន ក្រុមប្រឹក្សាសង្កាត់ទួលទំពូងទី២ នាយរងប៉ុស្តិ៍ និងប្រធានភូមិ បាននាំយកថវិកាមរណៈសង្គ្រោះចំនួន ៤,០០០,០០០រៀល (បួនលានរៀលគត់) ទៅប្រគល់ជូនគ្រួសារសពលោកស្រី អ៊ុច ស៊ន នៅផ្ទះលេខ ១អា ផ្លូវលេខ ១៦៧ ភូមិ៤ សង្កាត់ទួលទំពូងទី២ ខណ្ឌចំការមន រាជធានីភ្នំពេញ។

### ៤.៧- <u>**ការងារបណ្តុះបណ្តាល និង វិជ្ជាជីវៈ**</u>

- មន្ទីរការងារ ចុះធ្វើអធិការកិច្ចការងារនៅតាមសហគ្រាស គ្រឹះស្ថាន ក្នុងខណ្ឌចំការមន បានចំនួន ៥៨ទីតាំង
- បានចូលរួមប្រជុំប្រចាំខែនៅមន្ទីរការងារបានចំនួន ១២លើក
- បានចូលរួមសិក្ខាសាលាស្តីពីសន្តិសុខ និងហានិភ័យការងារនៅមន្ទីរការងារបានចំនួន ០២ថ្ងៃ
- បានចូលរួមសិក្ខាសាលាស្តីពីទម្រង់ធ្ងន់ធ្ងរបំផុត នៃពលកម្មករ នៅមន្ទីរការងារបានចំនួន ០២ថ្ងៃ
- បានចូលរួមរៀនវគ្គបំប៉ន ច្បាប់ស្តីពីការងារបានចំនួន ០៧ថ្ងៃ នៅក្រសួងការងារ
- បានចូលរួមប្រជុំក្រុមប្រឹក្សាខណ្ឌបានចំនួន ១២លើក
- បានចូលរួប្រជុំគណៈបញ្ជាការឯកភាពខណ្ឌ ១២លើក
- បានចូលរួមប្រជុំ គ.ក.ស.ក បានចំនួន ១២លើក
- បានចូលរួមវេទិការសាធារណៈរបស់ក្រុមប្រឹក្សាខណ្ឌ ០១លើក។

### ៤.៨- <u>**ការងារសុខាភិបាល**</u>

| | | |
|---|---|---|
| • ការពិនិត្យផ្ទៃពោះសរុប | ចំនួន | ៥,៧៥៣នាក់ |
| • ការសំរាលកូនសរុប | ចំនួន | ១០៣នាក់ |
| • ការផ្តល់ជាតិដែក៩០គ្រាប់មុនសំរាល | ចំនួន | ២,៤៤៩នាក់ |
| • ចំនួនកុមារចាក់ថ្នាំបង្ការគ្រប់មុខ | ចំនួន | ២,២៨៦នាក់ |
| • ស្ត្រីមានផ្ទៃពោះចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង | ចំនួន | ១,០៣៤នាក់ |
| • ស្រីអាយុ១៥-៤៤ឆ្នាំចាក់ថ្នាំបង្ការតេតាណុសលើសពី២ដង | ចំនួន | ២,២៩១នាក់ |
| • តាមដានជាប្រចាំករណីមាតាស្លាប់និងទារកស្លាប់ក្រោម២៨ថ្ងៃ | ចំនួន | ០០លើក |
| • តាមកដានជាប្រចាំករណីជម្ងឺផ្សេងៗ | ចំនួន | ០០លើក |
| • ប្រជុំពង្រឹងការងារគាំពារមាតានិងទារក-កុមារ | ចំនួន | ២៤ដង |

- ផ្តល់ថ្នាំមេបង់ដាហ្សុលដល់សិស្សានុសិស្ស ចំនួន ៣៨,៩៦៦គ្រាប់

## ៤.៨- ការងារកិច្ចការនារី

- ចុះស្រង់ទិន្នន័យការងារសេវាសង្គមតាមសង្កាត់ទាំង៥ ក្នុងខណ្ឌចំការមនបានចំនួន ១២លើក
- ចូលរួមប្រជុំរបស់ គ.ក.ន.ក តាមសង្កាត់ទាំង៥ បានចំនួន ១២លើក
- រៀបចំការប្រជុំរបស់ គ.ក.ស.ក បានចំនួន ១២លើក
- ឧបសម្ព័ន្ធ វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាព និងថវិកា ផអ៣ ១២លើក
- នារីខណ្ឌចូលរួមផ្សព្វផ្សាយ និងសហការណ៍ជាមួយ គ.ក.ន.ក និងអង្គការជួយស្ត្រី-កុមារក្រីក្រគ្មានគោលដៅនៅតាមសង្កាត់ ឬ សហគមន៍ នានាដូចជា៖

  +ស្រង់ការធ្វើបច្ចុប្បន្នភាពស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិក្នុងខណ្ឌ សង្កាត់ ក្រុមប្រឹក្សា ប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិ ជូនទៅមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ។

  +កិច្ចការនារីខណ្ឌចំការមន ចូលរួមកម្មវិធីសិក្ខាសាលាសមាហរណកម្ម កម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២០-២០២២) របស់សង្កាត់-ខណ្ឌ ឆ្នាំ២០១៩ នៅវិទ្យាល័យ ហ៊ុន សែន ប៊ុន រ៉ានី ផ្សារដើមថ្កូវ។

  +គ.ក.ន.ក សង្កាត់ ធ្វើសំបុត្រកំណើតឲ្យគ្រួសារក្រីក្រចំនួន ០៣គ្រួសារ

  +គ.ក.ន.កសង្កាត់ និងអង្គការរ៉ាក់ចុះស្រាវជ្រាវរកជម្ងឺរបេង ក្នុងសហគមន៍បានចំនួន ០៩នាក់ ស្រី ០៣នាក់

  +គ.ក.ន.កសង្កាត់ និងអង្គការមិត្តសំឡាញ់ ការប្រើប្រាស់គ្រឿងញៀន អំពើហិង្សាទាក់ទង និងយេនឌ័រ នៅសហគមន៍ផ្សារដើមថ្កូវ បានចំនួន ១៤៧នាក់ ស្រី ៧៣នាក់។

  +ផ្សព្វផ្សាយដល់ស្ត្រីមានផ្ទៃពោះ ឲ្យទៅពិនិត្យពោះយ៉ាងតិចអោយបាន ០២ដង មុនសម្រាលចំនួន ២៤នាក់

  +អង្គការ S.H.C.C ផ្សព្វផ្សាយដល់គ្រួសារក្រីក្រស្លាប់ ក្នុងសពមួយស្មើ ៤០ដុល្លាស្មើចំនួន ០៣នាក់ លេខទំនាក់ទំនងរបស់អង្គការ S.H.C.C : ០១២ ២៧០ ១៧១ ។

  +កិច្ចការនារីខណ្ឌ ស្រង់ទិន្នន័យការធ្វើបច្ចុប្បន្នភាព ស្ត្រីជាថ្នាក់ដឹកនាំនៅថ្នាក់ក្រោមជាតិ មានក្រុមប្រឹក្សាខណ្ឌ មន្ត្រីថ្នាក់ខណ្ឌ ក្រុមប្រឹក្សាសង្កាត់ ប្រធានភូមិ អនុប្រធានភូមិ និងជំនួយការភូមិជូន ទៅមន្ទីរកិច្ចការនាទីរាជធានីភ្នំពេញ។

  +កិច្ចការនារីខណ្ឌ សហការណ៍ជាមួយ គ.ក.ន.ក សង្កាត់ទាំង០៥ ស្រង់ទិន្នន័យអំពើហិង្សា ការរំលោភសេពសន្ថវ នៅក្នុងខណ្ឌចំការមន បានចំនួន ០៥ករណី ជូនទៅមន្ទីរកិច្ចការនារីរាជធានីភ្នំពេញ។

  +គ.ក.ន.ក សង្កាត់ទន្លេបាសាក់ សហការណ៍ជាមួយអ្នកស្ម័គ្រចិត្តភូមិ ចូលរួមជាមួយមន្ទីរសុខាភិបាលផ្សព្វផ្សាយស្តីពីការដាក់កងក្នុងស្បូនដោយឥតគិតថ្លៃ។

  +គ.ក.ន.ក សង្កាត់ចូលរួមសិក្ខាសាលាជាមួយ អង្គការអាក់សិនអេកកម្ពុជា នៅសណ្ឋាគារភ្នំពេញ រយៈពេល ០២ថ្ងៃ។

## ៤.៩- ការងារអប់រំ យុវជន និងកីឡា

១- គ្រឹះស្ថានសិក្សាសាធារណៈ

ក-សាលាមត្តេយ្យដាច់ចំនួន ០២សាលា (មិនដំណើរការចំនួន ០១) មានសិស្សសរុបចំនួន ១២៥នាក់ ស្រី ៧០នាក់

-ថ្នាក់មត្តេយ្យក្នុងបឋមសិក្សាមាន ០៨ថ្នាក់ មានសិស្សសរុប ២៩០ ស្រី១២៧នាក់

ខ-សាលាបឋមសិក្សាមានចំនួន ០៥សាលា មានសិស្សសរុប ចំនួន៤,៧០៧នាក់ ស្រីចំនួន ២,២៧០នាក់

សិស្សជាប់មធ្យមភាគសរុបចំនួន ៤,៣៦៦នាក់ ស្រីចំនួន ២,១២៤នាក់ ត្រូវជា ៩២.៧៦%

សិស្សឆ្លងភូមិសិក្សាមានចំនួន ៧៣៧នាក់ ស្រីចំនួន ៣៥៨នាក់ ត្រូវជា ៩៧.៤៩%

គ-អនុវិទ្យាល័យដាច់មាន ០១សាលា មានសិស្សសរុប ២០៥នាក់ ស្រី ១១៣នាក់ ជាប់មធ្យមភាគ ១៧៩នាក់ ស្រី ១០៣នាក់ ត្រូវជា ៩៣.៦៥% សិស្សបានប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមមានចំនួន ៤៨នាក់ ត្រូវជា ៩៧.៩៥%

ឃ-វិទ្យាល័យមាន ០៣សាលា មានសិស្សសរុបចំនួន ៦,២១៨នាក់ ស្រី ៣,០៦២នាក់ ជាប់មធ្យមភាគ ៥,៨២៧ ត្រូវជា ៩៣.៧១%

-សិស្សដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាបឋមភូមិចំនួន ៩០៤នាក់ ស្រី ៤៤៦នាក់ ត្រូវជា ៩៦.៩៥%

-សិស្សប្រឡងជាប់សញ្ញាបត្រទុតិយភូមិ មានចំនួន ៥១៧នាក់ ស្រី ២៨៦នាក់ ត្រូវជា ៥១.៨០%

-សិស្សដែលទទួលបាននិទ្ទេស A ចំនួន ១៤នាក់ ស្រី ០៨នាក់ ។

ការជួយពីសប្បុរសជន៖

-សប្បុរសជន ជួយឧបត្ថម្ភសម្ភារៈសិក្សាដល់សិស្សក្រីក្រ គិតជាប្រាក់ ១,៨៥០,០០០៛

-អង្គការផ្ទះបាយជួយកុមារក្រីក្រនៅសាលាបឋមសិក្សាហ៊ុននាង បឹងត្របែកខាងត្បូង ចំនួន ៧៥នាក់ រយៈពេល ០៦ខែ គិតជាប្រាក់ ៤៨,៤២០,០០០៛

-សប្បុរសជនជួយអភិវឌ្ឍន៍បរិស្ថានសាលារៀនបឋមសិក្សា គិតជាប្រាក់ ៩,៥១៤,០០០៛ និង ១៤,៥៧៥ដុល្លា

២- គ្រឹះស្ថានសិក្សាចំណេះទូទៅឯកជន៖

ក-សាលាមត្តេយ្យឯកជនដាច់មានចំនួន ០៥សាលា មានសិស្សសរុប ២២៧នាក់ ស្រី ១០៧នាក់

ខ-ថ្នាក់មត្តេយ្យក្នុងបឋមសិក្សាមានចំនួន ១៣សាលា មានសិស្សសរុប ៣៧៦នាក់ ស្រី ២១៣នាក់

គ-សាលាចំណេះទូទៅបឋមសិក្សាមាន ២១សាលា មានសិស្សសរុប ៣,៣៩៩នាក់ ស្រី ១,៧១៦នាក់

សិស្សជាប់មធ្យមភាគសរុបចំនួន ៣,៣៩៩នាក់ ស្រីចំនួន ១,៧១៦ នាក់ ត្រូវជា ១០០%

សិស្សឆ្លងភូមិសិក្សាមានចំនួន ៤១៦នាក់ ស្រី ២៤២នាក់ ត្រូវជា ១០០%

ឃ-សាលាមធ្យមសិក្សាចំណេះទូទៅឯកជនមាន ០៨សាលា មានសិស្សសរុបចំនួន ២,៦៦១នាក់ ស្រី ១,២៣៥នាក់។

## ៤.១០- ការងារវប្បធម៌និងវិចិត្រសិល្បៈ

- សហការរួមជាមួយមន្ត្រីបេតិកភ័ណ្ឌ និងមន្ត្រីសង្កាត់ ចុះស្រង់ទិន្នន័យ និងជំរុញទីតាំងចម្លាក់ឈើជាក្បាច់រចនាបទខ្មែរឲ្យមកធ្វើច្បាប់អាជីវកម្ម។
- រួមសហការជាមួយមន្ត្រីសង្កាត់ចុះស្រង់ទិន្នន័យតាមសង្កាត់។
- បានចេញលិខិតអនុញ្ញាតដោយមន្ទីរវប្បធម៌និងវិចិត្រសិល្បៈបានចំនួន៖
  - -ថ្មីចំនួន ០៤ទីតាំង
  - -បន្តចំនួន ១៤ ទីតាំង
- បានចេញលិខិតអនុញ្ញាតដោយការិយាល័យច្រកចេញចូលតែមួយបានចំនួន៖
  - -ថ្មីចំនួន ០៤ទីតាំង
  - -បន្តចំនួន ០៦ទីតាំង

## ៤.១១- ការិយាល័យព័ត៌មាន

- ជម្រុញម្ចាស់អាជីវកម្មរោងពុម្ពអោយធ្វើច្បាប់បន្តអាជីវកម្មដែលហួសសុពលភាពបានចំនួន ៧មូលដ្ឋាន, បោះពុម្ពដៃ និងហ្វូតូកូពីបានចំនួន ៥០ទីតាំង។
- ជម្រុញម្ចាស់តូបកាសែតអោយបន្តច្បាប់អាជីវកម្មដែលហួសសុពលភាពបានចំនួន ៤១តូប។
- បិទរូបថតសកម្មភាពការងារថ្នាក់ដឹកនាំនៅបញ្ជារព័ត៌មានសាលាខណ្ឌចំការមនបានចំនួន ៧២សន្លឹក។
- ចុះណែនាំជាប្រចាំចំពោះម្ចាស់តូបលក់កាសែតអោយដាក់តាំងលក់សៀវភៅកាសែតសមស្របតាមគោលការណ៍ច្បាប់ និងតាំងលក់ដូរមានសណ្តាប់ធ្នាប់តាមការណែនាំរបស់អាជ្ញាធរនិងអោយបន្ត សុពលភាពច្បាប់ប្រចាំឆ្នាំបានចំនួន ៤៣តូប។
- ចុះជម្រុញដល់ម្ចាស់រោងពុម្ពអោយសុំបន្តច្បាប់អាជីវកម្មដែលហួសសុពលភាពបន្តទៀតបានចំនួន៤មូលដ្ឋាន។

## ៤.១២- ការងារបរិស្ថាន

ក-ការងារចុះពិនិត្យមើលសំរាមៈ

- បានចុះពិនិត្យមើលការប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ិន ទ្រី តាមដងផ្លូវសំខាន់ៗ និងផ្លូវក្នុង ចំនួន ២៤៩លើក ឃើញថាមានគ្មានសំរាមកកស្ទះទេ រថយន្តក្រុមហ៊ន ស៊ិនទ្រី បានមកប្រមូលទាន់ពេលវេលា។
- មានសំរាមកកស្ទះមួយរយៈ ដោយសារស្ទះនៅទីលាន និងកម្មករធ្វើពលកម្ម និងថ្ងៃបុណ្យភ្ជុំបិណ្ឌ ចូលឆ្នាំខ្មែរ ដោយកម្មករទៅលេងស្រុកកំណើត។

ខ-ការងារត្រួតពិនិត្យការបំពុលៈ

- បានចុះសហការណ៍ជាមួយមន្ត្រីជំនាញរបស់មន្ទីរបរិស្ថាន ចុះដោះស្រាយបណ្ដឹង របស់ប្រជាពលរដ្ឋដែលប៉ះពាល់សម្លេង និងក្លឹបបាន ០១ករណី ៖
  -ភោជនីយដ្ឋានភូមិគ្រឹះ ហ៊ា ផ្លូវលេខ ៤១០ សង្កាត់បឹងត្របែក
- បានចុះសហការណ៍ជាមួយមន្ត្រីជំនាញរបស់មន្ទីរបរិស្ថាន ចុះត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លិខិត បញ្ជាកែប្រែបាន ០១ទីតាំង ៖
  -ទីតាំងក្លឹបភ្នំពេញស្ក័រ ផ្លូវលេខ ២៧១ សង្កាត់ទួលទំពូងទី២ ទីតាំងនេះបានកែប្រែទៅតាម លិខិតរបស់មន្ទីរបរិស្ថាន
- បានចុះសហការណ៍ជាមួយរដ្ឋបាលរាជធានីភ្នំពេញ ចុះវាស់សម្លេងបាន ០១ករណី
- បានចុះសហការណ៍ជាមួយរដ្ឋបាលខណ្ឌចំការមន ចុះផ្អាកក្លឹប ម៉ែ អាម៉ី ដែលបង្កផលប៉ះពាល់ ដល់អ្នកជិតខាង
- បានចុះសហការណ៍ជាមួយក្រុមការងាររបស់មន្ទីរបរិស្ថានរាជធានីភ្នំពេញចែកលិខិតណាត់ជួបដើម្បីត្រួតពិនិត្យគុណភាពបរិស្ថាន និងច្បាប់បានចំនួន ១៩២ ទីតាំងៈ
  -ចុះបានចំនួន ១៥៨ទីតាំង ក្នុងនោះ ១៦ទីតាំង បានយលព្រមធ្វើកិច្ចសន្យាការពារបរិស្ថាន។

គ-ការងារអប់រំ

- បានសហការណ៍ជាមួយមន្ទីរបរិស្ថានរាជធានីភ្នំពេញ ចុះអប់រំ និងដើររើសសំរាមនៅវិមាន ឈ្នះ ឈ្នះ ០២ថ្ងៃ
- បានសហការណ៍ជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់បានដាក់ប៉ាន់ណូ ០២ផ្ទាក និងចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋការទុកដាក់ និងវិចខ្ចប់សំរាមបាន ០២លើក បានចំនួន ៣២២ខ្នងផ្ទះ
- ចុះអប់រំផ្សព្វផ្សាយតាមសាលាបឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ បានចំនួន ២០លើក មានលោកគ្រូ អ្នកគ្រូ សិស្ស ចូលរួមចំនួន ៦,៦៧២ នាក់
- ចុះអប់រំតាមប្រលាយបានចំនួន ០៦លើក មានអ្នកចូលរួម ២៩៦នាក់
- ទិវាបរិស្ថាន អន្តរជាតិបានសហការណ៍ជាមួយសង្កាត់ធ្វើយុទ្ធនាការ សម្អាតតាមផ្លូវក្នុងសង្កាត់ទន្លេបាសាក់ មានមន្ត្រីចូលរួមចំនួន ២៦២នាក់។

ឃ-ការងារអភិរក្ស

- បានចុះពិនិត្យទីតាំងលក់វត្ថុអនុស្សាវរីយ៍ ដែលធ្វើពីសត្វព្រៃ ចំនួន ១៣ទីតាំង ក្នុងនោះ ០៦ទីតាំង នៅក្នុងផ្សារទួលទំពូង មានលក់ ភ្លុក ធ្មេញ ស្នែងសត្វព្រៃ។

## ៤.១៣- ការងារធម្មការនិងសាសនា

- បានសហការជាមួយសាលាអនុគណខណ្ឌ បានធ្វើស្ថិតិព្រះសង្ឃអាចារ្យ គណៈកម្មការ សិស្សនិស្សិត នៅតាមបណ្ដាលវត្តដូចខាងក្រោម៖
  - វត្តមណីរតនារាមទួលទំពូង ព្រះសង្ឃសរុប ៩៤អង្គ អាចារ្យ គណៈកម្មការ ០៨នាក់ តាជីយាយជី ០៤នាក់ សិស្សនិស្សិត ៧៥នាក់
  - វត្តនួនមណីរាម ថាន់ ព្រះសង្ឃសរុប ៣៨០អង្គ អាចារ្យ គណៈកម្មការ ០៨នាក់ តាជីយាយជី ១៩នាក់ សិស្សនិស្សិត ១៣២នាក់

- វត្តប្រយូរវង្ស ព្រះសង្ឃសរុប ១៤អង្គ អាចារ្យ គណៈកម្មការ ០៦នាក់ តាជីយាយជី ០៥នាក់ សិស្សនិស្សិត ០៤នាក់
- វត្តស្វាយពពែ ព្រះសង្ឃសរុប ៣៤អង្គ អាចារ្យ គណៈកម្មការ ១០នាក់ តាជីយាយជី ១០នាក់ សិស្សនិស្សិត ៥៣នាក់
- ក្នុងនោះមានគោរម្យងារជាសម្តេច ០៤ព្រះអង្គ ព្រះរាជគណៈចំនួន ០៥អង្គ ព្រះគ្រូ ០១អង្គ ចៅអធិការវត្តចំនួន ០៤អង្គ

• បានសហការជាមួយសាលាអនុគណខណ្ឌចំការមន ព្រះចៅអធិការ អាចារ្យ គណៈកម្មការវត្ត ទួលទំពូងត្រៀមរៀបចំការប្រឡងធម្មវិន័យមណ្ឌលរាជធានីភ្នំពេញនៅសាលាបឋមសិក្សាវត្តទួលទំពូង នាថ្ងៃទី ០៦ ខែមករា ឆ្នាំ២០១៩ បេក្ខសមណសិស្សដែលបានដាក់ពាក្យប្រឡងសរុបចំនួន ១,២២៦អង្គ/នាក់ ចែកចេញជា ៣០បន្ទប់ក្នុងនោះមាន៖

- ថ្នាក់ត្រី មានចំនួនសរុប ៦៤៣ អង្គ/នាក់
- ថ្នាក់ទោ មានចំនួន សរុប ៣៥៦ អង្គ/នាក់
- ថ្នាក់ឯក មានចំនួន សរុប ២២៧ អង្គ/នាក់
- គណៈកម្មការប្រឡងចំនួន ៨៨អង្គ/នាក់
- កម្លាំងសន្តិសុខការពារមណ្ឌលប្រឡងចំនួន ១១នាក់។

- ចូលរួមពិធីអបអរសាទរខួបលើកទី៤០ ទិវាជ័យជំនះ ៧មករា ១៩៧៩-២០១៩ នៅពហុកីឡដ្ឋានជាតិអូឡាំពិករាជធានីភ្នំពេញ ។
- ចូលរួមប្រជុំនៅសាលាគណៈនៅរាជធានីភ្នំពេញ ក្រោមអធិបតីភាពសម្តេច ព្រះពុទ្ធជ័យមុនី ឃឹម សន ព្រះមេគណៈរាជធានីភ្នំពេញ និងប្រធានមន្ទីរធម្មការ និងសាសនា។
- ចូលរួមពិធីប្រកាសប្រធានមន្ទីរធម្មការ និងសាសនារាជធានីភ្នំពេញ។
- ចូលរួមពិធីរៀបចំវេរទៀនវស្សាដល់វត្តទាំងបួន ក្នុងខណ្ឌចំការមន ដឹកនាំដោយលោក ថេង សុថុល អភិបាលខណ្ឌចំការមន និងក្រុមគ្រួសារ ព្រមទាំងមន្ត្រីរាជការសាលាខណ្ឌចំការមន សង្កាត់ទាំង៥ និងផ្សារទាំង២ ។ ក្នុងនោះវត្តនីមួយៗទទួលបានទេយ្យទានមាន៖ សាដក០២, ទៀន ០១គូ, ស្ករស ២៥គីឡូក្រាម, អង្ករ ០២បាវ, មី ០១កេសធំ, ទឹកសុទ្ធ ១០កេស, ត្រីខ ០១កេសធំ, បច្ច័យ ៦០ម៉ឺនរៀល ដោយឡែកវត្តទួលទំពូង បច្ច័យសរុប ៧៥៥,០០០៛ និង ១០០ ដុល្លា (មួយរយដុល្លាអាមេរិក)។
- សាសនាគ្រឹស្ទមានវិហារចំនួន ០៨ប្រធាន និងគណៈកម្មការគ្រប់គ្រងវិហារចំនួន ៤០នាក់ បរិស័ទចំនួន ១,៥០០នាក់។
- ព្រះវិន័យវង្សា ស៊ា ប៊ុនណាត ព្រះចៅអធិការវត្តមណិរតនារាម (ទួលទំពូង) ព្រះសង្ឃ អាចារ្យ គណៈកម្មការ សហការជាមួយការិយាល័យធម្មការ សាសនាខណ្ឌបានរៀបចំទេយ្យទានជូនដល់កាកបាទក្រហមកម្ពុជា និងអនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌចំការមន ក្នុងនោះបានជួយថវិកាចំនួន៦,០០០,០០០រៀល និងគ្រឿងឧបភោគបរិភោគសរុបគិតជាថវិកាចំនួន១៩,៤៩៥,០០០រៀល (សម្រាប់ទីស្នាក់ការកណ្តាល) និងថវិកា៣,០០០,០០០រៀល និងគ្រឿងឧបភោគបរិភោគសរុបគិតជាថវិកា ១០,០០០,០០០រៀល (សម្រាប់អនុសាខាកាកបាទក្រហមកម្ពុជាខណ្ឌ)។
- ចូលរួមប្រជុំជាមួយសាលាអនុគណខណ្ឌចំការមនផ្នែកគណៈធម្មយុត្តិកនិកាយនៃព្រះរាជណាចក្រកម្ពុជា និងសម្តេចមង្គលទេព្វាចារ្យព្រះចៅអធិការអចិន្ត្រៃយ៍វត្តស្វាយពពែ ត្រៀមរៀបចំពិធីសម្ពោធអន្តេវាសិកដ្ឋាន(កុដិ) ។
- ថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៩ ពីធីសម្ពោធអន្តេវាសិកដ្ឋាន(កុដិ)វត្តស្វាយពពែ ក្រោមព្រះរាជាអធិបតីភាពសម្តេចព្រះកិត្តិឧទ្ទេសបណ្ឌិត បួរ គ្រី សម្តេចព្រះសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយនៃព្រះរាជណាចក្រកម្ពុជា និងលោកជំទាវ ញ៉េប រ៉ានី អ៊ិត សំហេង បានចូលរួមបច្ច័យក្នុងកម្មវិធីបុណ្យចំនួន១,៥០០ដុល្លារ និងលោក ថេង សុថុល អភិបាល នៃគណៈអភិបាលខណ្ឌចំការមន បានប្រគេនបច្ច័យចំនួន ១,០០០,០០០រៀល ។

- បានសហការជាមួយសាលាអនុគណខណ្ឌចំការមន នាំទេយ្យទានគ្រឿងឧបភោគបរិភោគ និងថវិកា ប្រគេនដល់សាលាគណរាជធានីភ្នំពេញ មានដូចជា អង្ករ ៥បាវ, មី១០កេស, ទឹកក្រូច ៥កេស, ទឹកសុទ្ធ ៥កេស, តែ ស្ករស ទឹកដោះគោមួយចំនួន និងថវិកាចំនួន ៧០០,០០០ រៀល ។
- បានសហការជាមួយសាលាអនុគណខណ្ឌចំការមន នាំទេយ្យទានគ្រឿងឧបភោគបរិភោគ និងថវិកាយកទៅឧបត្ថម្ភដល់កងទ័ពនៅបញ្ជាការដ្ឋានបញ្ជូនសារកំបូល ដូចជា អង្ករ០៥បាវ, មី១០កេស, ទឹកសុទ្ធ០៥កេស, ទឹកក្រូច ០៥កេស, ត្រីខ តែ ស្ករស ទឹកដោះគោ មួយចំនួន និងថវិកាចំនួន៥០០,០០០ រៀល ។
- ចូលរួមប្រជុំត្រៀមបដិសណ្ឋារកិច្ច ឯកឧត្តម ប្រធានាធិបតី និងសម្តេចព្រះសង្ឃរាជប្រទេសស្រីលង្កា នៅសាលាអនុគណខណ្ឌចំការមន។
- ចូលរួមពិធីប្រកាសតែងតាំងមន្ត្រីសង្ឃសាលាគណរាជធានីភ្នំពេញ នៅសាលសន្និសិទ្ទិចតុមុខ។
- ការិយាលយ័ធម្មការ និងសាសនាខណ្ឌបានចូលរួមប្រជុំប្រចាំខែរបស់ក្រុមការងារពង្រឹងសាសនារាជធានីភ្នំពេញ ក្រោមអធិបតិយភាព លោកជំទាវ ទូច សារ៉ុម ប្រធានក្រុមការងារ។
- ការិយាល័យធម្មការ និងសាសនាខណ្ឌបានចូលរួមផ្សព្វផ្សាយច្បាប់ស្តីពីការគ្រប់គ្រងគ្រីស្ទសាសនាទូទាំងរាជធានីភ្នំពេញ ក្រោមអធិបតិយភាព ឯកឧត្តម សៀ សុភក្រ្ត រដ្ឋលេខាធិការក្រសួងធម្មការ និងសាសនានៅវិហារគ្រីស្ទ សែនសុខ។
- ការិយាល័យធម្មការ និងសាសនាសហការជាមួយសាលាអនុគណខណ្ឌចំការមន និងសាលាអនុគណខណ្ឌបឹងកេងកង បានទទួលរៀបចំធ្វើអនុសំវច្ឆរមហាសន្និបាតមន្ត្រីសង្ឃទូទាំងរាជធានីភ្នំពេញ ក្រោមព្រះអធិបតីភាព សម្តេចព្រះពុទ្ធជ័យមុន្នី ឃឹម សន ព្រះមេគណរាជធានីភ្នំពេញ សម្តេចព្រះមហាអរិយវង្ស បណ្ឌិត សៅរ៍ ចន្ទថុល្ល សម្តេចព្រះឧត្តមចរិយា បណ្ឌិត ឈឹង ប៊ុនឈា សម្តេចព្រះសក្យមុន្នី វត្ន័ សារឿន និងលោកជំទាវ ទូច សារ៉ុម លោកប្រធានមន្ទីរធម្មការ និងសាសនា ក្នុងនោះ លោក ថេង សុថុល អភិបាល នៃគណៈអភិបាល ខណ្ឌចំការមន ក៏បានអញ្ជើញចូលរួមជាកិត្តិយសបានប្រគេនបច្ច័យចំនួនមួយលានរៀល នៅវត្តលង្កា។
- ការិយាល័យធម្មការ និងសាសនាសហការជាមួយសាលាអនុគណខណ្ឌចំការមន ព្រះចៅអធិការ អាចារ្យគណៈកម្មការ ប្រារព្ធពិធីបង្សុកូលថ្វាយព្រះវិញ្ញាណខន្ធព្រះសពសម្តេចព្រះធម្មលិខិត លាស់ ឡាយ នៅវត្តសន្សំកុសល។

## ៤.១៤-<u>**ការងាររៀបចំដែនដីនគរូបនីយកម្ម ភូមិបាល និងសំណង់**</u>

-<u>**ការងាររៀបចំដែនដីនគរូបនីយកម្ម ភូមិបាល និងសំណង់**</u>

១- <u>ការងារសុរិយោដីនិងភូមិបាលៈ</u>

| | | | | | |
|---|---|---|---|---|---|
| • ចេញប័ណ្ណកម្មសិទ្ធិផ្ទះ | ចំនួន | ០៤ប័ណ្ណ | • លក់ផ្តាច់កម្មសិទ្ធិចំនួន | ចំនួន | ០៤ច្បាប់ |
| • ចេញប័ណ្ណដី | ចំនួន | ៦៦ប័ណ្ណ | • លក់ផ្តាច់ប័ណ្ណដីចំនួន | ចំនួន | ៣២៣ច្បាប់ |
| • ចេញប័ណ្ណសហកម្មសិទ្ធិ | ចំនួន | ០០ប័ណ្ណ | • លក់ផ្តាច់សហកម្មសិទ្ធ | ចំនួន | ១,៩៥៧ច្បាប់ |
| • អំណោយផ្តាច់កម្មសិទ្ធផ្ទះ | ចំនួន | ០៤ច្បាប់ | • កាន់កាប់និងសាងសង់ | ចំនួន | ៣៩ច្បាប់ |
| • អំណោយផ្តាច់ប័ណ្ណដី | ចំនួន | ៧៥ច្បាប់ | • ទុត្តិយាតាដី-ផ្ទះ | ចំនួន | ០៣ច្បាប់ |
| • អំណោយផ្តាច់សហកម្មសិទ្ធ | ចំនួន | ០០ច្បាប់ | • ទំនាស់ដី-ផ្ទះ | ចំនួន | ០០ច្បាប់ |

- ការងារសាងសង់តាមការិយាល័យច្រក១នៅរដ្ឋបាលខណ្ឌ ចំនួន ៤៨ច្បាប់
- ការងារជួសជុលតាមការិយាល័យច្រក១នៅរដ្ឋបាលខណ្ឌ ចំនួន ២២ច្បាប់

២- ការងារសំណង់

- សំណង់ថ្មីមានច្បាប់ ចំនួន ៣៩ច្បាប់
- សំណង់ថ្មីគ្មានច្បាប់ ចំនួន ០០ច្បាប់
- សំណង់ថ្មីខុសប្លង់ ចំនួន ០០ច្បាប់
- ស្នើសុំជួសជុលទៅមន្ទីរ ចំនួន ០០ច្បាប់
- សំណង់ជួសជុលមានច្បាប់ ចំនួន ០០ច្បាប់
- សំណង់ជួសជុលគ្មានច្បាប់ ចំនួន ០០ច្បាប់
- សំណង់ជួសជុលខុសច្បាប់ ចំនួន ០០ច្បាប់

❖ **ចំនុចខ្លាំង បញ្ហាប្រឈម**

➢ **ចំនុចខ្លាំង**

➢ **បញ្ហាប្រឈម**

**១.រដ្ឋបាលខណ្ឌ**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១). ការងាររដ្ឋបាល | | |
| នៅខ្វះខាតតុ ម៉ាស៊ីនកុំព្យូទ័រ ម៉ាស៊ីនព្រីន សម្រាប់មន្ត្រីបុគ្គលិក | | សុំទិញតុ ៥ ម៉ាស៊ីនកុំព្យូទ័រ៥គ្រឿង ម៉ាស៊ីនព្រីន៥គ្រឿង សម្រាប់មន្ត្រីបុគ្គលិក |
| ២).ការងារអន្តរវិស័យ | | |
| គ្មាន | | គ្មាន |
| ៣).ការងារច្រកចេញចូលតែមួយ | | |
| គ្មាន | | គ្មាន |
| ៤).ការងារផែនការនិងគាំទ្រ សង្កាត់ | | |
| - | បញ្ហាសំរាមនៅមានការពាយប៉ាយ។ | -បន្តការផ្សព្វផ្សាយ |
| - | ការងារប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ិនទ្រី នៅមិន ទាន់ពេលវេលា។ | -ជម្រុញបន្ថែម។ |
| ៥).ការងារលទ្ធកម្ម | | |
| គ្មាន | | គ្មាន |

**២.ការិយាល័យ អន្តរាពជំនាញ៖**

| ល.រ | បញ្ហាប្រឈមសំខាន់ៗ | សំណើដំណោះស្រាយ |
|---|---|---|
| ១). ការិយាល័យទេសចរណ៍ | | |
| - | បានចុះណែនាំនិងជម្រុញដល់ម្ចាស់អាជីវ | -សូមសហការជាមួយរដ្ឋបាលខណ្ឌ និងសង្កាត់ទាំង៥ |

| | | |
|---|---|---|
| | កម្មមកធ្វើច្បាប់អាជ្ញាប័ណ្ណទេសចរណ៍ (ម្ចាស់អាជីវកម្មមួយចំនួនតូចមិនព្រមធ្វើ) | |
| ២). ការិយាល័យឧស្សាហកម្មនិងសិប្បកម្ម | | |
| - | សិប្បកម្មមួយចំនួនបានបើកនិងដំណើរការហើយមិនបានមកចុះបញ្ជីនៅការិយាល័យច្រកចេញចូលតែមួយមន្ទីរ ឬក្រសួង។ | -សុំសហការណ៍ជាមួយសាលាខណ្ឌ និងសង្កាត់ទាំង៥។<br>-បន្តជម្រុញមូលដ្ឋានមិនបានមកចុះបញ្ជី អោយមកចុះបញ្ជីនៅ ការិយាល័យច្រកចេញចូលតែមួយ មន្ទីរ រឺក្រសួង។ |
| - | សិប្បកម្មចំណីអាហារមួយចំនួនមិនបានយកផលិតផល ទៅពិនិត្យគុណភាពទៀងទាត់។ | -បន្តចុះណែនាំសិប្បកម្មផលិតស្បៀងអាហារ និងភេសជ្ជៈ ឲ្យអនុវត្តផលិតកម្មល្អ(GMP)និងអនាម័យល្អ(GHP) |
| ៣). ការិយាល័យអប់រំយុវជននិងកីឡាខណ្ឌ | | |
| - | គ្រូចូលនិវត្តន៍ និងផ្លាស់ចេញច្រើននាំឲ្យខ្វះគ្រូ សាលាបឋមសិក្សាបឹងត្របែក)<br>។ (កើត | -សូមអាជ្ញាធរសង្កាត់ផ្សារដើមថ្កូវ ជួយអប់រំប្រជាពលរដ្ឋដែលរស់នៅក្បែរសាលាបឋមសិក្សាបឹងត្របែកខាងត្បូង ឈប់យកសំរាមមកចោលតាមរបងសាលា ។ |
| - | ប្រជាពលរដ្ឋយកសម្រាមមកដាក់នៅតាមរបសាលាបឹងត្របែកខាងត្បូង។ | |
| ៤). ការិយាល័យផែនការស្ថិតិ | | |
| គ្មាន | | គ្មាន |
| ៥). ការិយាល័យការងារបណ្តុះបណ្តាលវិជ្ជាជីវៈខណ្ឌ | | |
| - | សហគ្រាស គ្រឹះស្ថាន មួយចំនួនតូចមិនគោរពច្បាប់<br>ស្តីពីការងារ។ | -ស្នើអធិការកិច្ចក្រសួង ឬ អធិការកិច្ចមន្ទីរការងារចុះផ្សព្វផ្សាយច្បាប់ស្តីពីការងារថែមទៀត ដល់សហគ្រាសទាំងនោះ។ |
| ៦). ការិយាល័យកិច្ចការនារី | | |
| | គ្មាន | គ្មាន |
| ៧). ការិយាល័យសុខាភិបាល | | |
| - | ការយល់ដឹងរបស់ប្រជាពលរដ្ឋបញ្ហាសុខភាពនិងអនាម័យនៅមានកម្រិត។ | -លើកស្ទួយសុខភាពស្ត្រី និងកុមារតម្រូវឲ្យមានការចូលរួមគ្រប់ ផ្នែកយ៉ាងសកម្ម។<br>-សូមសាលារៀនជួយចូលរួមផ្សព្វផ្សាយដល់សិស្សានុសិស្ស ស្តីពី អនាម័យស្អាត អនាម័យលំនៅដ្ឋាន។ |
| - | ការទំនាក់ទំនងនៅកន្លែងខ្លះនៅមានកម្រិត (មូលដ្ឋាន, សាលារៀន) | -សូមមូលដ្ឋានជួយចូលរួមអប់រំ ផ្សព្វផ្សាយឲ្យប្រជាជនមកទទួលសេវានៅសេវារដ្ឋ ។<br>(សេវារដ្ឋមានតម្លៃថោកដើម្បីកាត់បន្ថយភាពក្រីក្រ) |
| - | ពុំមានដៃគូជួយគាំទ្រ | |
| ៨). ការិយាល័យវប្បធម៌និងវិចិត្រសិល្បៈ | | |
| - | អាជីវករមិនទាន់យល់ពីលិខិតអនុញ្ញាត | -សហការជាមួយសង្កាត់ទាំង៥ ជម្រុញអោយម្ចាស់អាជីវ |

| | | |
|---|---|---|
| | និងអាជីវករខ្លះលោកមិនចង់សហការ។ | កម្មសុំច្បាប់អនុញ្ញាតប្រកបអាជីវកម្ម។ |
| ៩). ការិយាល័យសង្គមកិច្ច | | |
| | គ្មាន | គ្មាន |
| ១០). ការិយាល័យបរិស្ថាន | | |
| | គ្មាន | គ្មាន |
| ១១).ការិយាល័យសាធារៈការ | | |
| | គ្មាន | គ្មាន |
| ១១).មណ្ឌលសេវាកម្មយុត្តិធម៌ | | |
| | គ្មាន | គ្មាន |
| ១២).ការិយាល័យពាណិជ្ជកម្ម | | |
| | គ្មាន | គ្មាន |
| ១៣).ការិយាល័យធម្មការ និងសាសនា | | |
| | គ្មាន | គ្មាន |
| ១៤).ការិយាល័យកសិកម្ម | | |
| | គ្មាន | គ្មាន |
| ១៥).ការិយាល័យព័ត៌មាន | | |
| | គ្មាន | គ្មាន |

- **ទិសដៅអនុវត្តឆ្នាំបន្ទាប់**

| ល.រ | សកម្មភាពអាទិភាព | ត្រីមាស | | | |
|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ |
| **១. ការងារក្រុមប្រឹក្សាខណ្ឌ និងគណៈកម្មាធិការនានា** | | | | | |
| ១.១ | រៀបចំកិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌចំការមនអាណត្តិទី៣ | X | X | X | X |
| ១.២ | រៀបចំកិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សាខណ្ឌចំការមនអាណត្តិទី៣ ក្នុងករណីមានការងារចាំបាច់ បន្ទាន់ | X | X | X | X |
| ១.៣ | គ្រោងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការនានា | X | X | X | X |
| ១.៤ | រៀបចំវេទិកាផ្សព្វផ្សាយនិងពិគោះយោបល់របស់ក្រុមប្រឹក្សាខណ្ឌ | | X | | |
| ១.៥ | សហការរៀបចំវេទិកាផ្សព្វផ្សាយនិងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានីភ្នំពេញ | | | | X |
| ១.៦ | សហការរៀបចំវគ្គបណ្តុះបណ្តាលបង្កើនសមត្ថភាពដល់ក្រុមប្រឹក្សាខណ្ឌ និងពាក់ព័ន្ធ | X | X | X | X |
| **២-ការងារគណៈអភិបាលខណ្ឌ** | | | | | |
| ២.១ | ប្រជុំអឌ្ឍមាសរបស់គណៈអភិបាល | X | X | X | X |
| ២.២ | ប្រជុំប្រចាំខែរបស់គណៈអភិបាល | X | X | X | X |
| ២.៣ | រៀបចំវេទិកាសាធារណៈអនុវត្តគោលនយោបាយភូមិ.សង្កាត់មានសុវត្ថិភាព | X | X | X | X |
| ២.៤ | រៀបចំសណ្តាប់ធ្នាប់តាមទីសាធារណៈ និងផ្លូវសំខាន់ៗអោយបានល្អ | X | X | X | X |
| ២.៥ | អនុវត្តការងារការិយាល័យច្រកចេញចូលតែមួយ និងការិយាល័យប្រជាពលរដ្ឋ | X | X | X | X |

| | | | | | |
|---|---|---|---|---|---|
| ២.៦ | បន្តតាមដានព្រឹត្តការណ៍សំខាន់ៗ និងធ្វើរបាយការណ៍ជូនសាលារាជធានីភ្នំពេញ | X | X | X | X |
| ២.៧ | ចុះពិនិត្យការដ្ឋានសំណង់ ទប់ស្កាត់សំណង់គ្មានច្បាប់អនុញ្ញាត និងសំណង់ខុសប្លង់ | X | X | X | X |
| ២.៨ | ទប់ស្កាត់ការរំលោភទន្រ្ទានកាន់កាប់ផ្ទៃបឹងធម្មជាតិបឹងត្របែក | X | X | X | X |
| ២.៩ | បន្តសហការការងារបុកសៀផាយប្រឡាយ១០៥ សង្កាត់ផ្សារដើមថ្កូវ | X | X | X | X |
| **-ការងារសិប្បកម្ម និងឧស្សាហកម្ម** | | | | | |
| ២.១០ | ផ្សព្វផ្សាយច្បាប់ពីការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម | X | X | X | X |
| ២.១១ | ពង្រឹង និងតាមដានត្រួតពិនិត្យជាប្រចាំលើផលិតផលឧស្សាហកម្ម និងសិប្បកម្ម ដើម្បីធានាគុណភាព និងបរិមាណ | X | X | X | X |
| ២.១២ | ជម្រុញឲ្យម្ចាស់ស្ថានីយ៍លកប្រេងឥន្ធនៈមកអោយមកចុះបញ្ជីដំណើរការនៅមជ្ឈមណ្ឌលមាត្រាសាសជាតិ (ជ.ម.ជ) | X | X | X | X |
| ២.១៣ | ជម្រុញឲ្យម្ចាស់សិប្បកម្មមកចុះបញ្ជីដំណើរការ និងបន្តច្បាប់ | X | X | X | X |
| ២.១៤ | ចុះត្រួតពិនិត្យអាជីវកម្មហ្គាស អុកស៊ីហ្សែន ដោយជម្រុញអោយសុំច្បាប់អនុញ្ញាតនិងណែនាំអោយរៀបចំទុកដាក់ប្រកបដោយសុវត្ថិភាពត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស | X | X | X | X |
| **ការងារទេសចរណ៍** | | | | | |
| ២.១៥ | សហការជាមួយមន្ទីរទេសចរណ៍រាជធានីភ្នំពេញ បើកវគ្គអប់រំផ្សព្វផ្សាយច្បាប់ ស្តីពីទេសចរណ៍ និងលិខិតបទ ដ្ឋានគតិយុត្តិផ្សេងៗ ដើម្បីជម្រុញការអនុវត្តច្បាប់ ស្តីពីទេសចរណ៍ក្នុងការពង្រឹង គ្រប់គ្រងមូលដ្ឋានអាជីវកម្មទេសចរណ៍ | X | X | X | X |
| ២.១៦ | ចុះពិនិត្យ និងជម្រុញម្ចាស់អាជីវកម្មដ្ឋានទេសចរណ៍ដែលអស់សុពលភាព និងកើតថ្មីឲ្យចូលមកបំពេញបែបបទ ដើម្បីសុំអាជ្ញាប័ណ្ណទេសចរណ៍ប្រកបអាជីវកម្មអោយបានត្រឹមត្រូវ | X | X | X | X |
| ២.១៧ | ជម្រុញនិងណែនាំម្ចាស់សណ្ឋាគារ ផ្ទះសំណាក់ អោយកត់ត្រាអត្តសញ្ញាណភ្ញៀវ ស្នាក់នៅប្រចាំថ្ងៃ ពង្រឹងការគ្រប់គ្រងស្ថិតិភ្ញៀវអោយបានច្បាស់លាស់ និងការពារសន្តិសុខ សុវត្ថិភាពភ្ញៀវទេចរណ៍ជាតិ និងអន្តរជាតិ ជៀសវាងមានការសេពគ្រឿងញៀនក្នុងសណ្ឋាគារ ផ្ទះសំណាក់ | X | X | X | X |
| **ការងារសុខាភិបាល** | | | | | |
| ២.១៨ | សហការជាមួយមន្ទីរសុខាភិបាលចុះពិនិត្យឱសថ ឱសថស្ថានរង ដើម្បីកែលម្អចំណុចខុសឆ្គង លុបបំបាត់ ឱសថខុសច្បាប់ដែលដាក់លក់ | X | X | X | X |
| ២.១៩ | ជម្រុញអ្នកបើកសេវាសុខាភិបាលឯកជនថ្មី អោយមកសុំច្បាប់អនុញ្ញាត | X | X | X | X |
| ២.២០ | សហការជាមួយមន្ទីរសុខាភិបាលរាជធានីភ្នំពេញ ចុះអប់រំអំពីជម្ងឺអេដស៍ដល់ស្រ្តីបម្រើការងារក្នុងសេវាកំសាន្តនានា | X | X | X | X |
| ២.២១ | កាត់បន្ថយជនអនាថាតាមចិញ្ចើមផ្លូវ និងទីសាធារណៈ | X | X | X | X |
| **ការងារកិច្ចការនារី** | | | | | |
| ២.២២ | ផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ស្តីពីសីលធម៌សង្គម តម្លៃស្រ្តី និងគ្រួសារខ្មែរ | X | X | X | X |
| ២.២៣ | គ.ក.ស.ក សង្កាត់-ខណ្ឌ សហការជាមួយការិយាល័យ ដែលមានការពាក់ព័ន្ធដើម្បីចុះអនុវត្តន៍ | X | X | X | X |
| ២.២៤ | ផ្សព្វផ្សាយពីសុខភាពស្រ្តី កុមារថែទាំ អនាម័យ (ស្រ្តីមុនសម្រាល នឹងក្រោយសម្រាល) | X | X | X | X |
| ២.២៥ | ការចុះសំបុត្រកំណើតទារក មានរយៈពេលយ៉ាងតិច ក្រោម៣០ថ្ងៃ | X | X | X | X |

| | | | | | |
|---|---|---|---|---|---|
| ២.២៦ | គ.ក.ស.ក សង្កាត់-ខណ្ឌ សហការជាមួយ អង្គការដៃគូរមានការពាក់ព័ន្ធ ចុះធ្វើសកម្មភាពដល់មូលដ្ឋាន | X | X | X | X |
| **ការងារសាសនា** | | | | | |
| ២.២៧ | យកចិត្តទុកដាក់គ្រប់គ្រងតាមវត្តអារាម និងត្រួតពិនិត្យសកម្មភាពពាហិរសាសនា | X | X | X | X |
| **ការរងារបរិស្ថាន** | | | | | |
| ២.២៨ | ផាកពិន័យអ្នកបោះសំរាមគ្មានសណ្តាប់ធ្នាប់ | X | X | X | X |
| ២.២៩ | សហការជាមួយមន្ទីរបរិស្ថានរាជធានីភ្នំពេញ ត្រួតពិនិត្យការបំពុលបរិស្ថាន | X | X | X | X |
| ២.៣០ | ពិនិត្យមើលការប្រមូលសំរាមរបស់ក្រុមហ៊ុន ស៊ិន ទ្រី | X | X | X | X |
| ២.៣១ | ចុះដោះស្រាយ និងវាស់សម្លេងបណ្តឹងរបស់ប្រជាពលរដ្ឋ | X | X | X | X |
| ២.៣២ | ចុសហការជាមួយក្រុមការងារត្រួតពិនិត្យច្បាប់ និងគុណភាពបរិស្ថាននៅឆ្នាំ២០២០ ចំនួន២៤០ទីតាំង | X | X | X | X |
| ២.៣៣ | សហការជាមួយការងារដាក់ប៉ានណូចោលសំរាមចំនួន ១០ប៉ាន់ណូនៅតាមបណ្តោយផ្លូវលូ ទឹកស្អុយ និងតាមសង្កាត់មួយចំនួន | X | X | X | X |
| **ការរងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ** | | | | | |
| ២.៣៤ | ចុះផ្សព្វផ្សាយ ច្បាប់ស្តីពីការងារ ដល់សហគ្រាស គ្រឹះស្ថាន ក្នុងមូលដ្ឋានខណ្ឌចំការមន | X | X | X | X |
| ២.៣៥ | ចុះអធិការកិច្ច និងជម្រុញដល់គ្រិះស្ថានណាដែលមានប្រើប្រាស់ជនបរទេសអោយទៅធ្វើប័ណ្ណការងារ | X | X | X | X |
| ២.៣៦ | ចុះអធិការកិច្ច និងជម្រុញដល់គ្រឹះស្ថានណាដែលមានប្រើប្រាស់បុគ្គលិក ចាប់ពី ៦០ នាក់ឡើងទៅបំពេញកាតព្វកិច្ច រីកវ៉ីន កូនជាង | X | X | X | X |
| **ការងារផែនការ** | | | | | |
| ២.៣៧ | រៀបចំសិក្ខាសាលាសមាហរណកម្មផែនការសង្កាត់នៅថ្នាក់ខណ្ឌនិងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ខណ្ឌ | | | | X |
| ២.៣៨ | ចុះសិក្សាគម្រោងនិធិសង្កាត់ឆ្នាំ២០២០ | X | | | |
| ២.៣៩ | សម្របសម្រួលការដេញថ្លៃគម្រោងមូលនិធិសង្កាត់ឆ្នាំ២០២០ | | X | | |
| ២.៤០ | សម្របសម្រួលសង្កាត់រៀបចំផែនការកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០២១ | | | X | |
| ២.៤១ | រៀបចំផែនការកម្មវិធីវិនិយោគបីឆ្នាំរំកិល (២០២១-២០២៣) របស់រដ្ឋបាលខណ្ឌ | | | X | |
| ២.៤២ | សម្របសម្រួលសិក្ខាសាលាសមាហរណកម្មវិនិយោគ សង្កាត់ ខណ្ឌ ឆ្នាំ(២០២១-២០២៣) នៅថ្នាក់ខណ្ឌ | | | | X |
| ២.៤៣ | រៀបចំសៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិល (២០២១-២០២៣) របស់រដ្ឋបាលខណ្ឌ | | | | X |
| ២.៤៤ | សម្របសម្រួលសង្កាត់រៀបចំសៀវភៅកម្មវិធីវិនិយោគសម្រាប់ឆ្នាំ២០២១ | | | | X |
| ២.៤៥ | សម្របសម្រួលវគ្គបណ្តុះបណ្តាលការស្រង់ព័ត៌មានទិន្នន័យភូមិ សង្កាត់ ខណ្ឌ ឆ្នាំ ២០២០ | | | | X |
| ២.៤៦ | រៀបចំប្រជុំដេញថ្លៃគម្រោងមូលនិធិសង្កាត់ឆ្នាំ២០២០ | | X | | |
| **ការងាររដ្ឋបាលខណ្ឌ** | | | | | |
| ២.៤៧ | ចងសម្ព័ន្ធមេត្រីភាពជាមួយកងវរៈសេនាតូចលេខ ៣៩២ | X | X | X | X |
| ២.៤៨ | ពង្រឹងការគ្រប់គ្រងអាជីវកម្មមណ្ឌលកម្សាន្តមនុស្សពេញវ័យ | X | X | X | X |

| | | | | | |
|---|---|---|---|---|---|
| ២.៤៩ | ចូលរួមឆ្នាំសកល | X | | | |
| ២.៥០ | ចូលរួមទិវាជ័យជំនះលើរបបប្រល័យពូជសាសន៍ | X | | | |
| ២.៥១ | ចូលរួមបុណ្យមាឃបូជា | X | | | |
| ២.៥២ | ចូលរួមទិវានារីអន្តរជាតិ ៨មីនា | X | | | |
| ២.៥៣ | ចូលរួមនិងរៀបចំផែនការការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ | | X | | |
| ២.៥៤ | ចូលរួមទិវាពលកម្មអន្តរជាតិ ១ឧសភា | | X | | |
| ២.៥៥ | ចូលរួមបុណ្យពិសាខបូជា | | X | | |
| ២.៥៦ | ចូលរួមនិងរៀបចំផែនការការពារព្រះរាជពិធីបុណ្យចម្រើនព្រះជន្មព្រះករុណានៃព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី | | X | | |
| ២.៥៧ | ចូលរួមព្រះរាជពិធីច្រត់ព្រះនង្គ័ល | | X | | |
| ២.៥៨ | ចូលរួមទិវាកុមារអន្តរជាតិ ១មិថុនា | | X | | |
| ២.៥៩ | រៀបចំផែនការការពារសន្តិសុខ សណ្តាប់ធ្នាប់ក្នុងឱកាសព្រះរាជពិធីបុណ្យចម្រើនព្រះជន្មសម្តេចមហាក្សត្រី ព្រះវររាជមាតា នរោត្តម មុនីនាថ សីហនុ | | X | | |
| ២.៦០ | ចូលរួមទិវាប្រកាសប្រើរដ្ឋធម្មនុញ្ញ | | | X | |
| ២.៦១ | រៀបចំផែនការការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ | | | X | |
| ២.៦២ | ចូលរួមទិវាប្រារព្ធពិធីគោរពព្រះវិញ្ញាណក្ខន្ធ "ព្រះបរមរតនកោដ្ឋ" ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាព ទឹកដីនិងឯកភាពជាតិខ្មែរ (ព្រះបរមរតនកោដ្ឋ) | | | | X |
| ២.៦៣ | ចូលរួមទិវារំលឹកខួបនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងបារីស | | | | X |
| ២.៦៤ | ចូលរួមព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា | | | | X |
| ២.៦៥ | ចូលរួមទិវាបុណ្យឯករាជ្យជាតិ ០៩ វិច្ឆិកា | | | | X |
| ២.៦៦ | រៀបចំផែនការការពារសន្តិសុខ សណ្តាប់ធ្នាប់ ក្នុងឱកាសព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប សំពះព្រះខែ និងអកអំបុក | | | | X |
| ២.៦៧ | ចូលរួមទិវាសិទ្ធិមនុស្ស | | | | X |

- **សេចក្តីសន្និដ្ឋាន**

ក្នុងឆ្នាំ២០១៩កន្លងមកនេះ ក្រោមការដឹកនាំរបស់ក្រសួងមហាផ្ទៃ និងរដ្ឋបាលរាជធានីភ្នំពេញ ខណ្ឌចំការមនបានបន្តខិតខំជម្នះ ពុះពាររាល់ការលំបាកស្មុគស្មាញ និងអនុវត្តគ្រប់វិធានការ សេសការងារចាត់តាំងគោលនយោបាយភូមិ.សង្កាត់ មានសុវត្ថិភាពបានកាន់តែល្អ ទ្រោលបានសភាពការណ៍ សន្តិសុខនៅក្នុងខណ្ឌ ក្នុងនោះគួរអោយកត់សំគាល់សកម្មភាពបង្កចលាចលនយោបាយ និងអំពើភេរវកម្ម ត្រូវបានទប់ស្កាត់មិនអោយកើតមានអំពើប្លន់ប្រដាប់អាវុធ អំពើអានាចារ្យ អំពើអបាយមុខបង្កដោយក្រុមក្មេងទំនើង ល្បែងស៊ីសង និងគ្រឿងញៀន ត្រូវបានកាត់បន្ថយ ផ្តល់នូវភាពកក់ក្តៅដល់ប្រជាពលរដ្ឋ វិនិយោគិន និងភ្ញៀវបរទេស។ ម្យ៉ាងទៀតការពង្រឹងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោកជូនប្រជាពលរដ្ឋ និងរួមចំណែកធ្វើអោយករណីគ្រោះថ្នាក់ និងករណីកកស្ទះចរាចរណ៍ ត្រូវបានកាត់បន្ថយ ។ បានខិតខំរៀបចំផែនការសកម្មភាពលម្អិត សន្ទស្សន៍ និងប្រតិទិនការងារតាមសង្កាត់នីមួយៗ ដើម្បីជម្រុញ

ការផ្តល់អត្តសញ្ញាណប័ណ្ណសញ្ញាតិខ្មែរជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងរៀបចំផែនការស្តីពីកិច្ចការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈសម្រាប់ដំណើរការចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ២០១៩, សភាពការណ៍ខាងលើនេះបានផ្តល់នូវកាលានុវត្តភាពដល់ការអនុវត្តគោលនយោបាយវិមជ្ឈការ វិសហមជ្ឈការ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលអោយទទួលបានជោគជ័យ ពិសេសគឺការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ សំណង់អគារខ្ពស់ៗ ធ្វើឲ្យខណ្ឌចំការមន កាន់តែមានសោភ័ណភាពស្រស់បំព្រងឡើងថែមទៀត និងបានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការកាត់បន្ថយភាពក្រីក្រ និងលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋ។

ទន្ទឹមនឹងលទ្ធផល ដែលសម្រេចបានជាវិជ្ជមានខាងលើ ក៏នៅមានបញ្ហាប្រឈមមួយចំនួន ដែលត្រូវប្រមូលផ្តុំ ដោះស្រាយអោយបានល្អនាពេលខាងមុខជាអាទិ៍៖

- បញ្ហាសន្តិសុខ សណ្តាប់ធ្នាប់សង្គម ក្មេងទំនើង គ្រឿងញៀន នៅតែជាចំណុចក្តៅរបស់ខណ្ឌចំការមន។
- បញ្ហាចរាចរណ៍ សណ្តាប់ធ្នាប់តាមដងផ្លូវនៅតែចោទជាបញ្ហា អាស្រ័យដោយកំណើនយ៉ាងឆាប់រហ័សនៃមធ្យោបាយយានយន្ត និងប្រជាជន។
- បញ្ហាគ្រោះអគ្គិភ័យនៅតែជាកង្វល់ដ៏ធំរបស់អាជ្ញាធរខណ្ឌ និងប្រជាជន។
- បញ្ហាដីធ្លី លំនៅដ្ឋាន បរិស្ថានក៏នៅតែប្រឈម។
- បញ្ហាសំរាមនៅតែ ធ្វើអោយប្រជាពលរដ្ឋថ្នាំងថ្នាក់ចំពោះក្រុមហ៊ុនស៊ីនទ្រី។

ថ្ងៃ..............................ខែ............ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី...............ខែ .............. ឆ្នាំ២០១៩

**អភិបាលនៃគណៈអភិបាលខណ្ឌចំការមន**

# រចនាសម្ព័ន្ធរដ្ឋបាលខណ្ឌចំការមន



# ខណ្ឌចំការមន


ខណ្ឌដូនពេញ
ខណ្ឌបឹងកេងកង
ទន្លេបាសាក់
ទួលទំពូងទី២
បឹងត្របែក
ទួលទំពូងទី១
ខណ្ឌច្បារអំពៅ
ផ្សារដើមថ្កូវ
ជើង
ខណ្ឌមានជ័យ

តារាងខាងក្រោមនេះគឺជាការឆ្លុះបញ្ចាំងរវាងការអនុវត្តសកម្មភាពរបស់រដ្ឋបាលខណ្ឌចាស់(ឆ្នាំ ២០១៨) និងសមត្ថភាពនៃដំណើរការគ្រប់គ្រងរបស់រដ្ឋបាលខណ្ឌថ្មី(២០១៩)។

| **វិស័យ** | **លក្ខណៈគម្រោង** | **ឆ្នាំ២០១៨** | **ឆ្នាំ២០០១៩(ត្រីមាសទីបី)** |
|---|---|---|---|
| សេដ្ឋកិច្ច | ចំនួនគម្រោង | ២ | ២ |
| | តម្លៃគម្រោង(គិតជាលានរៀល) | ១,១៣៤.៦៦០ | ១,៤៨៣.៦៤៥ |
| | ស្ថានភាពនៃការអនុវត្ត | ០១មិនទាន់អនុវត្ត | ០១កំពុង/០១មិនទាន់ |
| សង្គមកិច្ច | ចំនួនគម្រោង | ០ | ១ |
| | តម្លៃគម្រោង(គិតជាលានរៀល) | ០ | ១. |
| | ស្ថានភាពនៃការអនុវត្ត | ០ | ០១កំពុង |
| គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថានការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | ចំនួនគម្រោង | ២ | ៣ |
| | តម្លៃគម្រោង(គិតជាលានរៀល) | ២,៧៣០.៧០០ | ៥១៨.៩៦០ |
| | ស្ថានភាពនៃការអនុវត្ត | ១កំពុង/១បញ្ចប់ | ២មិនទាន់/១កំពុង |
| រដ្ឋបាល សន្តិសុខសណ្តាប់ធ្នាប់សាធារណៈ | ចំនួនគម្រោង | ៨ | ១៣ |
| | តម្លៃគម្រោង(គិតជាលានរៀល) | ១២.០០០ | ១៨.០០០ |
| | ស្ថានភាពនៃការអនុវត្ត | ២កំពុង/៦បញ្ចប់ | 13កំពុង |
| **សរុបតម្លៃគម្រោង** | | ៣,៨៧៧.៣៦០ | ២,០២១.៦០៥ |